Decalssified to Public
06 September 2012



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ

# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"

## សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩**

**សវនាការលើកទី៧៣**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CATWRIGHT)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក លឹម ស៊ុយហុង

កញ្ញា ណាតាសា វីស៊ែល រីសឺ

*(Ms. Natacha WEXELS-RISER)*

លោក ម៉ាតេអូ គ្រីស្ពារ *(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក វីលៀម ស្មីត *(Mr.William SMITH)*

*ជនជាប់ចោទ៖*

*លោក កាំង ហ្កេកអ៊ាវ*

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

លោក ចាន់ រ៉ាវុធ

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

កញ្ញា ទី ស្រ៊ីនណា

លោក គង់ ពិសី

កញ្ញា ម៉ុច សុវណ្ណារី

លោក ហុង គីមសួន

លោក ការីម ខាន (Mr. Karim KHAN)

លោកស្រី ស៊ីលឃិ ស្ទូតហ្ស៊ីនស្គី

*(Ms. Silke STUDZINSKY)*

លោកស្រី ម៉ាទីន ហ្សាកកាំង

*(Ms. Martine JACQUIN)*

លោក ហ្វីលីព កាណុន

*(Mr. Philippe CANNONE)*

លោក ព្យែរ អូលីវីយេ ស្សួរ

*(Mr.Pierre- Olivier SUR)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក ហ្វីលីព កាណុន | បារាំង |
| លោក ហុង គីមសួន | ខ្មែរ |
| លោកស្រី ម៉ាទីន ហ្សាកកាំង | បារាំង |
| លោក ការីម ខាន | អង់គ្លេស |
| លោក គង់ ពិសី | ខ្មែរ |
| កញ្ញា ម៉ុច សុវណ្ណារី | ខ្មែរ |
| លោកស្រី ស៊ីលយិ ស្ទួតហ្សីនស្គី | អង់គ្លេស |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោក ព្យែរ អូលីវីយេ ស្សួរ | បារាំង |
| កញ្ញា ទី ស្រ៊ីនណា | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលមកកាន់បន្ទប់សវនាការ)*

[០៩:០២:០៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងចាប់ផ្ដើមដំណើរការសវនាការ អញ្ជើញលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគីដែលត្រូវអញ្ជើញចូលរួមនៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន, ខ្ញុំបានត្រួតពិនិត្យវត្តមាន អវត្តមាន និងអត្តសញ្ញាណរបស់ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅក្នុងថ្ងៃនេះរួចរាល់ហើយ។ ភាគីទាំងអស់មានវត្តមានគ្រប់ចំនួន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបរំឭកជូនដល់ភាគី និងសាធារណជនទាំងអស់បានជ្រាបថា នៅក្នុងសប្ដាហ៍នេះ គឺចាប់ពីថ្ងៃនេះទៅរហូតដល់ថ្ងៃទី១៦ ឬក៏អាចឈានដល់ថ្ងៃទី២៦ ឬក៏ថ្ងៃ២៧ អង្គជំនុំជម្រះនឹងដំណើរការសវនាការដើម្បីស្ដាប់នូវសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគីដោយអនុលោមតាមវិធាន៩៤នៃវិធានផ្ទៃក្នុងនៃអ.វ.ត.ក និងដីកាកំណត់កាលវិភាគសម្រាប់ធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគីដែលអង្គជំនុំជម្រះសាលាដំបូងបានចេញកាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩។

ដើម្បីឲ្យដំណើរការនៃការធ្វើសេចក្ដីថ្លែងការណ៍សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគីប្រព្រឹត្តទៅបានត្រឹមត្រូវ ច្បាស់លាស់ ដោយសារនេះជាដំណាក់កាលចុងក្រោយ ហើយមានសារសំខាន់នោះ អង្គជំនុំជម្រះសូមរំឭកដល់ភាគីថា ដំណើរការសវនាការពិភាក្សាដេញដោលសំណុំរឿងលេខ០០១នេះ គឺឈានដល់ដំណាក់កាលចុងក្រោយហើយ គឺការឡើងធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគី។

ដើម្បីឲ្យដំណើរការដ៏មានសារសំខាន់នេះប្រព្រឹត្តទៅបានត្រឹមត្រូវ ច្បាស់លាស់ល្អ ភាគីគប្បីចង ចាំនិងអនុវត្តឲ្យបានល្អតាមសំណើរសុំរបស់អ្នកបកប្រែភាសា ដើម្បីជាការធានាដល់ការធ្វើប្រតិចារឹកនៃ កិច្ចដំណើរការនីតិវិធីដូចខាងក្រោមនេះ៖

១) ភាគីត្រូវចងចាំថា អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាតុលាការមួយដែលប្រើប្រាស់បីភាសា និងមានពហុវប្បធម៌ ដូច្នេះគប្បីភាគីឡើងធ្វើសេចក្តីសន្និដ្ឋាន និយាយឲ្យបានយឺតៗហើយច្បាស់។

២) គប្បីអាននូវតួរលេខយឺតៗ ហើយច្បាស់ប្រសិនអាចធ្វើបានសុំអានបញ្ជាក់ឡើងវិញម្តង ទៀត។

៣) ភាគីគប្បីប្រកបឈ្មោះទាំងឡាយណាដែលមានអក្ខរាវិរុទ្ធច្រើន ឬនិងពិបាកសរសេរ។ ភាគី ត្រូវបើកកុងតាក់*មីក្រូហ្វូន*ជាមុនសិន មុននឹងចាប់ផ្តើមនិយាយ ហើយនិយាយឲ្យចំក្បាល*មីក្រូហ្វូន*។ ករណីភាគីចាប់ផ្តើមនិយាយហើយបានដឹងខ្លួនថាមិនបានបើកកុងតាក *មីក្រូហ្វូន* សុំបើកកុងតាក់ *មីក្រូហ្វូន* ហើយសុំឲ្យចាប់ផ្តើមនិយាយសាជាថ្មីឡើងវិញម្តងទៀតនូវចំណុចទាំងឡាយណាដែលខ្លួនបាននិយាយ ដោយមិនបានចុកកុងតាក់បើក *មីក្រូហ្វូន* ពីព្រោះអ្នកបកប្រែភាសាមិនអាចចាប់ផ្តើមបកប្រែភាសាពាក់ កណ្តាលប្រយោគបានទេ។ ប្រសិនបើមានការនិយាយឆ្លើយឆ្លងគ្នារវាងភាគីដែលនិយាយជាភាសាតែ មួយ ភាគីម្ខាងត្រូវរង់ចាំភាគីម្ខាងទៀតបញ្ចប់នូវការឡើងនិយាយរបស់ខ្លួនជាមុនសិន មុនពេលខ្លួនចាប់ ផ្តើមនិយាយដើម្បីទុកលទ្ធភាពឲ្យអ្នកបកប្រែភាសាអាចបកប្រែភាសាចប់ចុងចប់ដើម។

អង្គជំនុំជម្រះសង្ឃឹមថានៅក្នុងកិច្ចដំណើរការសប្តាហ៍នេះ គឺភាគីទាំងអស់ដែលមានភារកិច្ចក្នុង ការឡើងធ្វើសេចក្តីថ្លែងបញ្ចប់កិច្ចពិភាក្សាដេញដោលនៅក្នុងអំឡុងពេលនេះ និងអនុវត្តទៅបានល្អដើម្បី ឲ្យលទ្ធផលនៃដំណើរការនីតិវិធីធ្វើសេចក្តីថ្លែងការណ៍ សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលនូវ សំណុំរឿងលេខ០០១នេះ ប្រព្រឹត្តទៅបានល្អ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់ឈើរាងរង់ក្រចកសេះនៅទីនោះ ដែលអង្គជំនុំជម្រះ បានរៀបចំទុកសម្រាប់ជនជាប់ចោទ។

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមអញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយឡើងធ្វើ សេចក្តីសន្និដ្ឋានមុន។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយមានរយៈពេលមួយម៉ោង និងដប់

ប្រាំនាទីក្នុងការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។

សូមអញ្ជើញ!

[០៩:០៨:៥៧]

**កញ្ញា ទី ស្រ៊ីនណា៖**

ជាបឋមនាងខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ នាងខ្ញុំឈ្មោះ ទី ស្រ៊ីនណា ជាមេធាវីជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ សូមធ្វើការណែនាំខ្លួន និងសុំធ្វើការណែនាំសហមេធាវីអន្តរជាតិរបស់នាងខ្ញុំឈ្មោះលោក ការីម ខាន ដែលគាត់នឹងធ្វើការឡើងមកធ្វើសេចក្តីសន្និដ្ឋានជាមុន ហើយចំណែកនាងខ្ញុំនឹងធ្វើសេចក្តីសន្និដ្ឋានបន្តពីគាត់។

ជាកិច្ចបន្តនេះ នាងខ្ញុំសុំអញ្ជើញប្រគល់វេទិការនេះជូនដល់លោក ការីម ខាន ដែលជាសហមេធាវីអន្តរជាតិនាងខ្ញុំក្នុងការធ្វើសេចក្តីសន្និដ្ឋាន។

**លោក ការីម ខាន៖**

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព, មេធាវីការពារក្តី និងសហព្រះរាជអាជ្ញាជាទីគោរព ហើយនិងសហសេវីករបស់ខ្ញុំ និងភាគីទាំងអស់នៅក្នុងនេះ។

លោក លោកស្រីចៅក្រម វាប្រាំបួនខែរួចមកហើយ ដែលយើងបានដំណើរការតាំងពីពេលសវនាបឋម ហើយបញ្ហានេះត្រូវបានបើកសវនាការ ហើយនៅចុងបញ្ចប់នេះ ចុងបញ្ចប់នៃការជំនុំជម្រះនេះលោក លោកស្រីចៅក្រម បានចេញនូវសេចក្តីសម្រេច និងជាយុត្តិសាស្ត្រមួយដែលវានឹងចេញពីតុលាការនេះ ដែលនៅក្នុងយុត្តិសាស្ត្រនឹងលើកឡើងអំពីការទទួលខុសត្រូវតាមផ្លូវច្បាប់នៅក្នុងតុលាការមួយនេះ ដែលយុត្តិសាស្ត្រ និងការទទួលខុសត្រូវខាងផ្លូវច្បាប់នេះវាកើតចេញពីរយៈពេលដែលឧក្រិដ្ឋកម្មកើតឡើង កាលពីសាមសិបឆ្នាំទៅមុន។

លោក លោកស្រីចៅក្រម, យើងខ្ញុំមានបុព្វសិទ្ធិណាស់ ដែលមកមានវត្តមាននៅទីនេះ តំណាងឲ្យក្រុមទីមួយ ហើយដាក់ជូននូវសេចក្តីសន្និដ្ឋានបិទការដេញដោលនៅទីនេះ។

លោក លោកស្រីចៅក្រមជាទីគោរព និងភាគីទាំងឡាយ គឺមានរាល់ឯកសារជាលាយលក្ខណ៍អក្សរដែលបានដាក់ជាមុនរួចហើយតាំងនាមឲ្យក្រុមទីមួយ។ ដូច្នេះ វាមិនមែនជាបំណងរបស់យើងក្នុងការអាននូវទឡ្ហីករណ៍ទាំងនោះទេ។ យើងខ្ញុំគោរពនិងដឹងថាលោក លោកស្រីចៅក្រម និងភាគីបានពិចារណាយ៉ាងហ្មត់ចត់ ហើយពិនិត្យមើលទៅលើសេចក្តីសន្និដ្ឋានទាំងអស់នោះដែលបានដាក់ជូន ក្នុង

នាមដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីមួយ ដែលយើងខ្ញុំជាមេធាវីតំណាង។

លោក លោកស្រីចៅក្រម, នេះជារឿងក្តីទីមួយ ហើយនៅទីនេះគឺជាសវនាការរឿងក្តីទីមួយ ដែលបានបញ្ចប់។ ហើយមិនត្រឹមតែតុលាការនេះទេ គឺសវនាការទីមួយលើកនេះ គឺមានតួនាទីសកម្ម របស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយជាការពិត ផ្លូវដែលយើងដើរវាមិនមានលក្ខណៈងាយស្រួលនោះទេ ហើយយើងមានមេរៀន និងបទពិសោធន៍ដែលយើងសិក្សាពីចំណុចទាំងអស់នេះ ហើយយើងសង្ឃឹមថា អ្វីៗដែលយើងសិក្សាវាមានភាពជាក់ស្តែង នេះជាការលើកឡើងរបស់ខ្ញុំ។

នៅពេលដែលមានចំណុចខ្វះខាត ឬក៏វិការៈណាមួយនោះ ការតំណាងទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី គឺនឹងព្យាយាមបំពេញទៅតាមហ្នឹង ហើយធ្វើការតំណាងឲ្យក្រុមរបស់ខ្លួន។ ហើយយើងខ្ញុំជាដើមបណ្តឹងរដ្ឋប្បវេណីធ្វើឡើងដោយសុចរិត ហើយមានបំណងក្នុងការធ្វើឲ្យប្រព័ន្ធដំណើរការនេះ ដំណើរការទៅដោយល្អ ដែលតួនាទីនិងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានគ្រោងទៅតាមវិធានច្បាប់ រៀបចំឡើងដោយអង្គការសហប្រជាជាតិនិងកម្ពុជា។

លោក លោកស្រីចៅក្រម, នៅពេលដែលយើងពិនិត្យទៅលើសក្ខីកម្មដែលយើងបានបើកសវនាការរួចមកហើយនោះ។ លោក លោកស្រីចៅក្រម គឺនឹងធ្វើការពិចារណាទៅលើទឡ្ហីករណ៍ទាំងអស់នោះ និងភាពជាក់ស្តែង ហើយពេលខ្លះទៅ យើងត្រូវតែពិចារណាទៅចំណុចទាំងអស់នេះ។ យើងឃើញថា មានការចោទប្រកាន់បានធ្វើឡើងចំពោះដើមបណ្តឹងរដ្ឋប្បវេណីនៅទីនេះ ហើយនិងជនរងគ្រោះដែលដើមបណ្តឹងរដ្ឋប្បវេណីតំណាង។ ដូច្នេះ យើងខ្ញុំសូមលើកឡើងថា យើងនឹងធ្វើការបញ្ជាក់ទៅលើចំណុចនេះ ដូចដែលមេធាវីបានលើកឡើង ហើយយើងនៅទីនេះ នៅមុខតុលាការជំនុំជម្រះ មិនមែននៅទីផ្សារនោះទេ ដែលមិនមានការចោទប្រកាន់គ្នាទៅវិញទៅមកនោះទេ។ ហើយជនជាប់ចោទ លោក លោកស្រីចៅក្រម នឹងធ្វើការសម្រេចទៅលើ ដោយផ្អែកទៅលើវិសាលភាពដែលដើមបណ្តឹងរដ្ឋប្បវេណីបានចូលរួមនៅក្នុងទីនេះ មិនថាទទួលបានជោគជ័យ ឬក៏យ៉ាងណានោះទេ។

ខ្ញុំសូមគោរពនិងចងចាំទៅលើយោបល់របស់ខ្ញុំកាលពីខែកុម្ភៈ ដែលខ្ញុំបានព្យាយាមបញ្ជាក់យ៉ាងច្បាស់នៅក្នុងប្រតិចារឹកថា ដើមបណ្តឹងរដ្ឋប្បវេណីដែលយើងខ្ញុំតំណាងគឺក្រុមទីមួយ ហើយខ្ញុំជឿថា ប្រតិចារឹក គឺបានលើកឡើងបញ្ជាក់យ៉ាងច្បាស់ជាសំឡេងយើងខ្ញុំនៅក្នុងនុំង ហើយយើងខ្ញុំជាដើមបណ្តឹងរដ្ឋប្បវេណីទទួលរងទៅលើការឈឺចាប់និងទុក្ខសោកជាច្រើនឆ្នាំ ហើយដើមបណ្តឹងរដ្ឋប្បវេណីគឺមិនមានការមកទីនេះដើម្បីសងសឹកនោះទេ។ ប៉ុន្តែពួកគាត់មានបំណងក្នុងការដាក់ខ្លួនពួកគេនៅចំពោះ

មុខកិច្ចដំណើរការនីតិវិធីដែលយើងអនុវត្តនេះដើម្បីឲ្យពួកគេមានលទ្ធភាពក្នុងការសម្តែងចេញនិងជួយទៅដល់អង្គជំនុំជម្រះក្នុងការស្វែងរកការពិត។

[០៩:១៥:៣៧]

លោក លោកស្រីចៅក្រមជាទីគោរព, លោក លោកស្រីចៅក្រមនឹងពិនិត្យទៅលើចំណុចទាំង-ឡាយ និងការលើកឡើងដែលយើងបានដាក់ជូន ហើយយើងខ្ញុំមិនមែនមានតួនាទីលើសពីអយ្យការ ឬក៏សហព្រះរាជអាជ្ញានោះទេ។ វិធាន២៣នៃវិធានផ្ទៃក្នុង បានចែងអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយលោក លោកស្រីចៅក្រមជ្រាបហើយ យើងខ្ញុំបានចូលរួមនៅទីនេះដើម្បីគាំទ្រទៅលើការចោទប្រកាន់ យើងនៅទីនេះមិនមែនជាការជួយទៅដល់សហព្រះរាជអាជ្ញា ក្នុងលក្ខណៈណាមួយលើសពីនេះនោះទេ។ ខ្ញុំគ្រាន់តែជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។ ដូច្នេះ ខ្ញុំចាំទៅសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងការព្យាយាមដែលលើកឡើងដោយសហព្រះរាជអាជ្ញា ដែលបានលើកឡើងអំពីលទ្ធិនៃសហកម្ម ឧក្រិដ្ឋកម្មរួម ហើយខ្ញុំបានលើកនូវការសង្កេតរបស់ខ្ញុំផងដែរនៅខែកុម្ភៈនោះ ហើយមេធាវី រូ ហើយនិងក្រុមការពារក្តីរបស់ជនជាប់គឺបានលើកឡើងទៅលើចំណុចនេះ ទាក់ទងទៅនឹងលទ្ធិសហកម្ម ឧក្រិដ្ឋកម្មរួម។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ មិនបានដាក់ឯកសារយោងគាំទ្រទៅលើការឡើងនូវលទ្ធិនោះទេ។

លោក លោកស្រីចៅក្រម, នៅក្នុងដំណើរការក្តីនេះ នៅពេលដែលយើងពិនិត្យទៅលើភ័ស្តុតាង លោក លោកស្រីចៅក្រមនឹងមើលទៅលើការលើកឡើងជាច្រើនដែលថាដើម្បីបណ្តឹងរដ្ឋប្បវេណីគឺមានចំនួន មានសិទ្ធិដូចជនជាប់ចោទ។ ដូច្នេះ ខ្ញុំសូមឲ្យលោក លោកស្រីចៅក្រមពិចារណា ហើយធ្វើការសម្រេចថាតើដើម្បីបណ្តឹងរដ្ឋប្បវេណីគាត់មានបំណងចូលរួមក្នុងទីនេះ ឬយ៉ាងម៉េច?

លោក លោកស្រីចៅក្រមជាទីគោរព, នេះគឺជាការប្រឈមមួយដែលលោក លោកស្រីចៅក្រមមានវិជ្ជាជីវបានជួបប្រទះ ហើយមានបទពិសោធន៍ការងារស្វែងការពិតនៅទីនេះ ហើយយុត្តាធិការរបស់តុលាការនេះ គឺវាមិនមានលក្ខណៈសាមញ្ញនោះទេ ក្នុងការបង្ហាញអំពីពិរុទ្ធភាព ឬក៏ក្នុងការបង្ហាញអំពីភាពស្លូតត្រង់របស់ជនជាប់ចោទដែលនៅចំពោះមុខលោក លោកស្រីចៅក្រម។ ខ្ញុំទទួលការកែតម្រូវប្រសិនបើ ខ្ញុំលើកកំហុសណាមួយនោះ ហើយខ្ញុំសូមដាក់ជូនថា បំណងនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទាមទារសំណង ដូចដែលមានចែងនៅក្នុងវិធាន២៣ នេះ គឺដើមបណ្តឹងរដ្ឋប្បវេណី គឺដើម្បីឲ្យជនរងគ្រោះចូលរួមនៅទីនេះ ហើយដូចដែលយើងមានឯកសារហើយ ដែលថាដើមបណ្តឹងរដ្ឋ

ប្បវេណីចូលរួមនៅទីនេះ។ ខ្ញុំសូមផ្តល់ការយល់ឃើញទៅដល់អង្គជំនុំជម្រះ ទាក់ទងទៅនឹងឥទ្ធិពលដែលឧក្រិដ្ឋកម្មទាំងអស់នោះមានឥទ្ធិពលទៅលើជីវិតរបស់ពួកគេនិងជនរងគ្រោះ និងអ្នកជាទីស្រឡាញ់របស់ពួកគេ ហើយយើងខ្ញុំនៅទីនេះក្នុងការលើកអំពីទិដ្ឋភាព និងទស្សនៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី ធ្វើយ៉ាងណាពួកយើងអាចមានលទ្ធភាពផ្តល់ជូននិងសម្តែងចេញជូនអង្គជំនុំជម្រះសាលាដំបូងដើម្បីស្វែងរកការពិត។

[០៩:១៩:០៨]

លោក លោកស្រីចៅក្រម, នៅក្នុងថ្ងៃនេះ សេចក្តីសន្និដ្ឋានរបស់យើង គឺនឹងធ្វើការរៀបរាប់ទៅលើសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ហើយដូចដែលសហមេធាវីរបស់ខ្ញុំ ទី ស្រ៊ីនណា នឹងធ្វើការរៀបរាប់ជូនអង្គជំនុំជម្រះសាលាដំបូងក្នុងលក្ខណៈពិស្តារអំពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងបទដ្ឋានផ្លូវច្បាប់ ហើយនិងធ្វើយ៉ាងណាឲ្យលោក លោកស្រីចៅក្រមអាចផ្អែកសេចក្តីសម្រេចដែលពិចារណាទៅលើអង្គហេតុតាមរយៈការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

លោក លោកស្រីចៅក្រម, ខ្ញុំមានបំណងក្នុងការដាក់ជូននូវសេចក្តីសន្និដ្ឋាននៅទីនេះ ដែលយើងជាដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១បានបំណងចង់លើកឡើងថា វាទាក់ទងទៅនឹងពិរុទ្ធភាពរបស់ជនជាប់ ហើយខ្ញុំក៏សូមលើកឡើងទាក់ទងទៅនឹងបញ្ហានៃការទាមទារសំណង និងចំណុចផ្សេងៗទៀតដែលអាចលេចចេញ។

លោក លោកស្រីចៅក្រម, នៅពេលដែលយើងពិចារណាទៅលើសេចក្តីសន្និដ្ឋានទាំងឡាយ ហើយនិងពិចារណាទៅលើវិសាលភាពនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសូមស្នើសុំថា នៅពេលដែលយើងបញ្ចប់នីតិវិធីនេះនៅក្នុងការសម្រេចរបស់លោក លោកស្រីចៅក្រម, លោក លោកស្រីត្រូវពិចារណាទៅលើការលើកឡើងរបស់មេធាវីការពារក្តីផងដែរ ដែលពេលខ្លះទៅវាទាក់ទងទៅនឹងការលើកឡើងអំពីសមភាពរវាងគូភាគី។ យើងឃើញនៅខាងណោះមានមេធាវីការពារក្តីដែលគាត់មិនប្រឈម តែសហព្រះរាជអាជ្ញាមួយរូបប៉ុណ្ណោះទេ គឺប្រាំរូបនៅទីនេះ។ ហើយដើមបណ្តឹងរដ្ឋប្បវេណីមិនមែនជាសហព្រះរាជអាជ្ញានោះទេ ប៉ុន្តែទាក់ទងទៅនឹងបញ្ហាសមភាពរវាងគូភាគីយើងត្រូវពិចារណាថា នៅពេលដែលយើងពិចារណាទៅភ័ស្តុតាង ជោគជ័យនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីយើងត្រូវចាំទៅលើចំណុចនេះ ហើយយើងត្រូវចាំទៅលើចំណុចនេះដែលមេធាវីការពារក្តីគាត់និយាយផ្ទុយពីហ្នឹង។ ហើយសហព្រះរាជអាជ្ញាដែលគាត់អង្គុយនៅខាងឆ្វេងនៅទីនេះ គាត់មិនបានទទួលនូវការ

ផ្តល់ជាជំនួយ ថវិកាណាមួយចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ ទាំងនេះគឺជាសេចក្តីសន្និដ្ឋានរបស់ខ្ញុំដែលសុំដាក់ជូន។ ហើយនេះគឺជាគោលការណ៍នៃច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលខ្ញុំលើកឡើងទាក់ទងនឹងចំណុចនេះផងដែរ។ សិទ្ធិទាំងឡាយត្រូវតែធ្វើយ៉ាងណាឲ្យមានប្រសិទ្ធភាពនិងជាក់ស្តែង មិនមែនបង្ហាញ ឬគោរពតាមតែទ្រឹស្តីនោះទេ។

[០៩:២១:៥៨]

លោក លោកស្រីចៅក្រម, ខ្ញុំទទួលយកនូវការព្យាយាមរបស់លោកស្រីចៅក្រមក្នុងការអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ប៉ុន្តែយើងមិនមានធនធានផ្តល់ជូនយើងខ្ញុំដូចដែលបានផ្តល់ជូនទៅខាងមេធាវីការពារក្តី។ លោក លោកស្រីចៅក្រម, ទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ នៅពេលដែលខ្ញុំមកទីនេះកាលពីឆ្នាំមុន មកតំណាងដើមបណ្តឹងរដ្ឋប្បវេណី៣៧រូបដែលមាននៅក្នុងក្រុមរបស់យើងខ្ញុំ។ ជាការពិត វាគឺជាការលើកឡើងមួយជាក់ស្តែងរបស់ខ្ញុំនៅពេលនោះ ហើយដែលមិនមែនតែខ្ញុំលើកឡើងអំពីបញ្ហាធនធាននោះទេ។ នៅពេលដែលខ្ញុំជួបប្រទះទៅលើបញ្ហាទាំងឡាយ មិនថាតែយើងមានបំណងផ្តល់ជាជំនួយឬយ៉ាងណានោះទេ ហើយវាអាចជួបប្រទះបញ្ហាមួយចំនួន។ ដូច្នេះ វាអាចនាំឲ្យប៉ះពាល់ទៅដល់ក្រុមទី១ ដែលគាត់មិនអាចមានមេធាវីតំណាង។

លោក លោកស្រីចៅក្រមជាទីគោរព, ខ្ញុំមិនបានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីនៅនេះច្រើនលើកនោះទេ។ ខ្ញុំសូមអភ័យទោសដែលខ្ញុំអវត្តមាននៅក្នុងកិច្ចដំណើរការនីតិវិធីមួយចំនួននោះ។ មូល-ហេតុដែលខ្ញុំលើកទៅលើចំណុចនេះដោយសារតែខ្ញុំ មិនមានបំណងណាមួយដែលមិនមកចូលរួមនោះទេ ប៉ុន្តែការដែលមិនមកចូលរួមនោះមិនមែនវាថាប៉ះពាល់ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ហើយវាមិនមែនថាជាការគោរពទៅក្រុមប្រឹក្សាជំនុំជម្រះនោះទេ។ ប៉ុន្តែ អ្វីដែលសំខាន់នៅក្នុងសវនាការនេះក្រុមមេធាវីទីមួយ គឺយើងមានមេធាវីតំណាងដែលមានមេធាវីតំណាងជាតិដែលអង្គុយជិតខ្ញុំ រួមទាំងមានមេធាវីតំណាងអន្តរជាតិផងដែរ។ ហើយត្រង់ចំណុចនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះត្រង់ទៅដល់សេវិករបស់ខ្ញុំ មេធាវី អាឡាំង វ៉ែនណឺ ដែលគាត់មានវត្តមាននៅគ្រប់ដំណាក់កាលនីតិវិធីនៅទីនេះ។

លោក លោកស្រីចៅក្រម, ខ្ញុំសង្ឃឹមថា នៅពេលដែលលោក លោកស្រីចៅក្រមធ្វើការវិភាគទៅលើភ័ស្តុតាងដែលយើងបានដាក់ជូន ឬក៏ភ័ស្តុតាងទាំងឡាយ សំណួរផ្សេងៗដែលបានដាក់ជូន និងសេចក្តីសន្និដ្ឋានរបស់ក្រុមទី១នោះ លោក លោកស្រីចៅក្រមនឹងអាចឈានទៅដល់ការធ្វើសេចក្តីសម្រេចនិងសន្និដ្ឋានថា នៅក្នុងនេះវាបានផ្តល់ទៅជាពន្លឺមួយទៅលើរឿងក្តីនេះ។

លោក លោកស្រីចៅក្រម ជាចៅក្រមឯករាជ្យ ហើយលោក លោកស្រីចៅក្រមមិនធ្វើការទទួលយកការរិះគន់ណាមួយដែលបានលើកឡើងពីខាងសហព្រះរាជអាជ្ញា ឬក៏មេធាវីការពារក្តីនោះទេចំពោះបញ្ហាទាំងឡាយ ឬក៏ លោក លោកស្រីចៅក្រមត្រូវពិចារណាទៅលើសេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តី។ ប៉ុន្តែ លោក លោកស្រីចៅក្រមត្រូវធ្វើការថ្លឹងថ្លែង វាយតម្លៃឡើងវិញទៅលើភ័ស្តុតាងដែលលោក លោកស្រីចៅក្រមទទួលបាននោះ។ ហើយតាមរយៈភ័ស្តុតាងទាំងអស់នេះទើបឲ្យលោក លោកស្រីចៅក្រមអាចស្វែងរកការពិតបាន។

[០៩:២៥:៥៤]

ចំណុចចុងក្រោយ មុនពេលខ្ញុំបង្វែរវេទិកានេះជូនសហមេធាវីដែលជាសហសេវិករបស់ខ្ញុំនៅទីនេះ គឺយើងឃើញថា ជនជាប់ចោទគាត់បានទទួលស្គាល់នូវចំណុចមួយចំនួន ហើយដែលលោក លោកស្រីចៅក្រមត្រូវបង្ហាញទៅលើករណីទាំងអស់នោះ។ ដូច្នេះ លោក លោកស្រីចៅក្រមត្រូវតែពិចារណាទៅលើអ្វីដែលបានយល់ស្របដោយជនជាប់ចោទផងដែរ។ លោក លោកស្រីចៅក្រមត្រូវតែពិចារណាជាក់ស្តែងទៅលើភ័ស្តុតាងដើម្បីសម្រេចថាតើ អ្វីដែលទទួលស្គាល់ដោយជនជាប់ចោទនោះវាជាការលាតត្រដាងការពិតទាំងស្រុងដែរឬទេ? មូលហេតុដែលខ្ញុំលើកឡើង ហើយបន្ទាប់មកមេធាវី ទី ស៊្រីនណា គាត់នឹងលើកឡើង។ យើងឃើញថា ភ័ស្តុតាងដែលលាតត្រដាងនេះគឺបង្ហាញជាការសន្និដ្ឋានតែមួយនូវអ្វីដែលលើកឡើងរបស់ជនជាប់ចោទ ហើយយើងឃើញថា វាមានភ័ស្តុតាងនិងសម្ភារៈជាច្រើនដែលបានដាក់ជូន។ ហើយនៅក្នុងថ្ងៃនេះ ជនជាប់ចោទគាត់ព្យាយាមធ្វើការបង្រួម ឬក៏ចៀសចេញពីការជាក់ស្តែងដែលវាទាក់ទងទៅនឹងមន្ទីរស-២១ និងរបបដែលគ្រប់គ្រងនៅសម័យនោះ។ ជោគវាសនានិងការឈឺចាប់វាធ្លាក់ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយដែលខ្ញុំតំណាង។

ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូងផ្តល់វេទិកានេះជូនទៅដល់សហសេវិករបស់ខ្ញុំ គឺមេធាវី ទី ស៊្រីនណា។ សូមអរគុណច្រើនលោក លោកស្រីចៅក្រម។

**កញ្ញា ទី ស៊្រីនណា៖**

ជាកិច្ចបន្តនេះ នាងខ្ញុំសូមធ្វើសេចក្តីសន្និដ្ឋានបន្ទាប់ពីសហមេធាវីអន្តរជាតិនៅក្នុងក្រុមរបស់នាងខ្ញុំដូចតទៅ៖

តាងនាមនាងខ្ញុំជាដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ

និងជាតំណាងឲ្យប្រយោជន៍ស្របច្បាប់របស់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៣៧នាក់ ដែលបងប្អូនរបស់

គាត់ ក៏ដូចជាជនរងគ្រោះដទៃទៀតបានទទួលរងទុក្ខវេទនា ដោយសារអំពើទារុណកម្មយ៉ាងព្រៃផ្សៃ និងបានបាត់បង់ជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសនៅមន្ទីរស-២១ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច។ សុំធ្វើសេចក្តីសន្និដ្ឋានដោយលើកយកនូវតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងបទដ្ឋានច្បាប់ សម្រាប់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងលើកយកនូវឯកសារជាភ័ស្តុតាងមួយចំនួន ដែលបញ្ជាក់អំពីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមនាងខ្ញុំ។

ជាដំបូង នាងខ្ញុំសុំលើកបញ្ហាតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី បើយើងយោងទៅលើវិធានផ្ទៃក្នុង វិធាន២៣ នៃអ.វ.ត.ក ក៏ជាមាត្រាមួយចំនួននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ដែលនៅជាធរមាន ដែលយើងបានសរសេរលម្អិតនៅក្នុង--ទាក់ទងទៅនឹងបញ្ហាច្បាប់នេះ ក្រុមនាងខ្ញុំបានសរសេរយ៉ាងលម្អិតនៅក្នុងឯកសារសន្និដ្ឋានជាផ្លូវការដែលបានដាក់ជូនអង្គជំនុំជម្រះរួចហើយ ព្រមទាំង-- ក្នុងនោះដែរក៏មានការអនុវត្តនៅក្នុងតុលាការអន្តរជាតិនានា ក៏បានលើកឡើងអំពីតួនាទីដ៏សំខាន់របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមនៅក្នុងដំណើរនីតិវិធីព្រហ្មទណ្ឌនៃ អ.វ.ត.ក យើងនេះ ដែលផ្តោតជាចម្បងទៅលើសិទ្ធិក្នុងការចូលរួមដំណើរការនីតិវិធីប្រឆាំងនឹងជនទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មក្រោមយុត្តាធិការអង្គជំនុំជម្រះវិសាមញ្ញដោយគាំទ្ររបស់អយ្យការ។

[០៩:៣១:១៤]

ក្នុងន័យនេះ ដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះដោយផ្ទាល់ ក៏ដូចជាជនរងគ្រោះដោយប្រយោលបានដើរតួនាទីក្នុងការបំភ្លឺអំពីព្រឹត្តការណ៍ដ៏សាហាវព្រៃផ្សៃកាលពីសាមសិបឆ្នាំមុន នៅក្នុងមន្ទីរស-២១ ក៏ដូចជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ដែលបានកើតឡើងចំពោះពួកគាត់ផ្ទាល់ ឬចំពោះសាច់ញាតិរបស់ពួកគាត់ ដែលបណ្តាលឲ្យពួកគាត់ឈឺចាប់ទាំងផ្លូវកាយនិងផ្លូវចិត្ត រហូតមិនអាចបំភ្លេចបានអស់មួយជីវិត។ និងគាត់អាចបំភ្លឺនូវ-- ចូលរួមបំភ្លឺនៃការខូចខាតរបស់ពួកគាត់តាមរយៈការដាក់ពាក្យបណ្តឹង និងការឆ្លើយបំភ្លឺនៅចំពោះ អ.វ.ត.ក យើងនេះ។

នៅក្នុងដំណាក់កាលនៃការសួរដេញដោលនៅចំពោះមុខអង្គជំនុំជម្រះរបស់ដើមបណ្តឹងរដ្ឋប្បវេ-ណីកន្លងមក នាងខ្ញុំយល់ឃើញថា ប្រសិនបើគ្មានវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងនីតិវិធី អ.វ.ត.ក យើងនេះទេ នោះអង្គជំនុំជម្រះក៏ពុំអាចវាស់ស្ទង់នូវទំហំនៃការឈឺចាប់របស់ជនរងគ្រោះទាំងអស់នៅមន្ទីរស-២១ ក៏ដូចជាព្យសនកម្មដ៏ធ្ងន់ធ្ងរដែលបានកើតឡើងចំពោះពួកគាត់ឡើយ។

ចំពោះវត្តមានដើមបណ្តឹងរដ្ឋប្បវេណីក៏អាចជួយដល់អង្គជំនុំជម្រះក្នុងការជួយថ្លឹងថ្លែងការអះអាង

របស់ជនជាប់ចោទទាក់ទងទៅនឹងស្ថានភាពនៅមន្ទីរស-២១ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់ថា តើមានលក្ខណៈត្រឹមត្រូវត្រឹមកម្រិតណា?

[០៩:៣៣:៥០]

ម៉្យាងទៀត ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងនីតិវិធី អ.វ.ត.ក នេះក្នុងគោលបំណងជាចម្បងគឺ ដើម្បីស្វែងរកយុត្តិធម៌សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីខ្លួនគាត់ផ្ទាល់ ឬក៏សម្រាប់សាច់ញាតិរបស់ពួកគាត់ផងដែរ ដែលបានទទួលរងនូវអំពើទារុណកម្មយ៉ាងសាហាវឃោរឃៅ ដោយអយុត្តិធម៌ជាទីបំផុត។

ដូចអង្គសវនាការបានជ្រាបហើយថា ជនរងគ្រោះនៅមន្ទីរស-២១ ទាំងអស់ ពុំមានឱកាសដឹងឮអំពីទោសកំហុសរបស់ខ្លួនឡើងនៅពេលដែលពួកគាត់ជាប់នៅក្នុងមន្ទីរស-២១។ បន្ថែម-- ហេតុនេះហើយពួកគាត់បានព្យាយាមចង់ដឹង ចង់ឮ ចង់ឃើញ និងចង់ចូលរួមចំណែកក្នុងការកាត់ទោសឧក្រិដ្ឋជន ក៏ដូចជាជនដែលពាក់ព័ន្ធទាំងឡាយ ដែលបានប្រព្រឹត្តមកលើពួកគាត់ ឬក៏សាច់ញាតិរបស់ពួកគាត់។ បន្ថែមលើនេះទៀត អង្គសវនាការនៃ អ.វ.ត.ក នេះបានជួយឲ្យដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់អាចរំសាយនូវកំហឹង និងការឈឺចាប់ដែលបានកប់ក្នុងចិត្តអស់រយៈកាលជាងសាមសិបឆ្នាំមកហើយឲ្យបានធូរស្បើយឡើងវិញ។

ជាក់ស្ដែងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ នេត ផល្លី បានបំភ្លឺនៅចំពោះមុខអង្គជំនុំជម្រះកាលពីដំណាក់កាលនៃការដេញដោល បង្ហាញអំពីឆន្ទៈរបស់គាត់ក្នុងការស្វែងរកយុត្តិធម៌ជូនបងប្រុសរបស់គាត់ដែលបានទទួលទារុណកម្ម និងបានបាត់បង់ជីវិតនៅមន្ទីរស-២១ ដោយធ្វើការឧទ្ទិសសុំឲ្យវិញ្ញាណក្ខន្ធបងប្រុសរបស់គាត់ទៅកាន់សុគតិភព ដោយសារតែឥឡូវនេះបងប្រុសគាត់នឹងទទួលបានយុត្តិធម៌ ដោយសារមានអង្គជំនុំជម្រះវិសាមញ្ញនៅពេលនេះធ្វើការកាត់ក្ដីទៅលើជនជាប់ចោទ ដែលបានសម្លាប់គាត់ដោយគ្មានមូលហេតុ។

សរុបសេចក្ដីមកតួនាទីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងនីតិវិធីរបស់របស់ អ.វ.ត.ក យើងនេះ ពិតជាមានសារសំខាន់ណាស់ក្នុងការជួយដល់អង្គជំនុំជម្រះ ដើម្បីជាមធ្យោបាយក្នុងការស្វែងរកការពិត និងឈានទៅរកការកាត់ក្ដីប្រកបដោយភាពយុត្តិធម៌ជូនជនរងគ្រោះទាំងអស់ក៏ដូចជាជូនជនរួមជាតិ និងមាតុភូមិកម្ពុជានៅក្នុងលក្ខណៈនៃការផ្សះផ្សាជាតិទាំងមូល។

ជាកិច្ចបន្តនេះនាងខ្ញុំ-- ដោយផ្អែកទៅលើសារសំខាន់នេះហើយ ទើបមានបណ្ដឹងរដ្ឋប្បវេណី

ចំនួន៩៩នាក់ ដែលបានដាក់ពាក្យបណ្ដឹងនៅក្នុងសំណុំរឿង០០១ នោះ។ នៅក្នុងចំណោម៩៩នាក់ ក៏មានដើមបណ្ដឹងរដ្ឋប្បវេណីរបស់ក្រុមនាងខ្ញុំដែលមានចំនួន៣៧នាក់។ នៅក្នុងដើមបណ្ដឹងរដ្ឋប្បវេណី ៣៧នាក់ នេះគឺមានម្នាក់បានបដិសេធដោយអង្គជំនុំជម្រះ ដោយសារការដាក់ពាក្យបណ្ដឹងយឺតយ៉ាវខុសទៅតាមទៅតាមនីតិវិធី។

[០៩:៣៧:៥០]

នៅក្នុងនោះដែរ នាងខ្ញុំក៏សូមលើកអំពីដើមបណ្ដឹងរដ្ឋប្បវេណីមួយនៅក្នុងក្រុមរបស់នាងខ្ញុំដើម្បីបញ្ជាក់ជូនអង្គជំនុំជម្រះក្នុងការពិនិត្យ និងពិចារណាដើម្បីទទួលយកគាត់ជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវច្បាប់។ ទីមួយ ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ លី ហ៊ា ដែលមានលេខសម្គាល់ E2/61 គាត់គឺជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវជាជនរងគ្រោះដោយផ្ទាល់នៃស-២១ និងត្រូវបានបញ្ជាក់ដោយភ័ស្តុតាងជាឯកសារដែលជនជាប់ និងសាក្សី ម៉ម ណៃ បានបញ្ជាក់បន្ថែមកាលពីថ្ងៃទី២៨ កក្កដា ឆ្នាំ២០០៩ ដែលមានលេខឯកសារ លេខ E137 ហើយសក្ខីកម្មរបស់គាត់ផ្ទាល់ក៏បានបញ្ជាក់អំពីការឃុំខ្លួនរបស់គាត់នៅមន្ទីរស-២១ ដែរ។ លី ហ៊ា បានទទួលព្យសនកម្មទាំងផ្លូវកាយនិងផ្លូវចិត្តដែលមិនអាចជួសជុលបានឡើយ ដោយសារតែការឃុំខ្លួននៅមន្ទីរស-២១ ប៉ុន្តែនៅពេលដែលគាត់ឡើងមកធ្វើសក្ខីកម្ម គាត់បានបញ្ជាក់ហើយថា ពីភាពនៃការប្រែប្រួលនៃឈ្មោះរបស់គាត់គឺ ឈ្មោះ លី ហ៊ា គឺគាត់បានផ្លាស់ប្ដូរពីឈ្មោះ អៀ ហ៊ា ដែលជាចំណុចនេះហើយ ដែលធ្វើឱ្យជនជាប់ចោទបានបដិសេធគាត់មិនទទួលស្គាល់ជាជនដើមបណ្ដឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះដោយផ្ទាល់។

ដូចអង្គសវនាការបានជ្រាបហើយថា នៅក្នុងសង្គមខ្មែរយើង យើងឃើញថា ពាក់ព័ន្ធជាមួយនឹងប្រជាពលរដ្ឋដែលនៅសេសសល់ពីរបបកម្ពុជាប្រជាធិបតេយ្យ គឺគាត់ពុំមានលទ្ធភាពនៅក្នុងការយល់ដឹងអំពីបញ្ហាផ្លូវច្បាប់នៅក្នុងការផ្លាស់ប្ដូរ ឬក៏កែប្រែឈ្មោះឡើយ។ ដូច្នេះហើយទើបគាត់ធ្វើការកែប្រែឈ្មោះដោយខ្លួនឯង។

ចំណុចពីរ ទាក់ទងទៅនឹងជនរងគ្រោះ ហារី ហាមីល គាត់ជាប្អូនប្រុសរបស់ដើមបណ្ដឹងរដ្ឋប្បវេណី រ៉ូប៊ីត ហាមីល ដែលមានលេខសម្គាល់ ERN E2/87 រ៉ូប៊ីត ហាមីល ជាជនបរទេសម្នាក់ (សូមទោស) នាងខ្ញុំមានការភាន់ច្រឡំបន្តិច គឺ ឃែរី ហាមីល ជាជនបរទេសម្នាក់ឃុំខ្លួន និងសម្លាប់នៅមន្ទីរស-២១ ហើយចម្លើយសារភាពរបស់គាត់ពីមន្ទីរស-២១ បានបញ្ជាក់បន្ថែមលើសក្ខីកម្មនេះ។ ការស្លាប់របស់ ឃែរី ហាមីល មានផលប៉ះពាល់យ៉ាងធំធេង និងមិនអាចយល់បានទៅលើ រ៉ូប៊ីត ហាមីល

និងក្រុមគ្រួសារទាំងមូលរបស់គាត់។ ជីវិតជាក្រុមគ្រួសាររបស់គាត់ត្រូវបានបាក់បែកបន្ទាប់ពីការស្លាប់របស់ ឃែរី បងប្រុសរបស់គាត់ម្នាក់ទៀត ក៏បានធ្វើអត្តឃាតនៅពេលដែលគាត់បានដឹងដំណឹងថា ឃែរី ត្រូវបានស្លាប់នៅមន្ទីរស-២១។ ឪពុកម្តាយរបស់គាត់ក៏បានបាត់បង់សមត្ថភាព ធ្វើជាឪពុកម្តាយអស់រយៈពេលជាយូរ ដោយសារតែទុក្ខព្រួយធ្ងន់ធ្ងរពេក ហើយគាត់ខ្លួនឯងក៏ងាកមកផឹកស្រាដែលបានធ្វើឲ្យប៉ះពាល់ដល់ការរៀនសូត្ររបស់គាត់។

[០៩:៤២:១៥]

ទីបី ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ហាវ សោភា ដែលមានលេខសម្គាល់ ERN D25/4 ត្រូវជាកូនរបស់ជនរងគ្រោះឈ្មោះ ចិន សៀ ហៅ ហាន ដែលបានជាប់ឃុំឃាំងនៅមន្ទីរស-២១ និងឈ្មោះៗរបស់-- ចំពោះឈ្មោះ ចិន សៀ និងឈ្មោះរបស់គាត់នៅក្នុងបញ្ជីអ្នកទោសរួមត្រូវបានបញ្ជាក់បន្ថែមកាន់តែច្បាស់ដោយជនជាប់ចោទបានទទួកស្គាល់ថា ចិន សៀ ជាជនរងគ្រោះម្នាក់នៅមន្ទីរស-២១។ ព្យសនកម្មរបស់ដើមបណ្តឹង ហាវ សោភា ពីការបាត់បង់ឪពុក គឺមានយ៉ាងជាក់លាក់ ទាំងថវិកា និងរូបរាងកាយ និងផ្នែកស្មារតី ក្រុមគ្រួសាររបស់គាត់ស្ថិតនៅក្នុងស្ថានភាពដ៏លំបាក។ ម្តាយរបស់គាត់ត្រូវទទួលរងនូវការឈឺចាប់កប់នៅក្នុងចិត្តដោយពុំអាចថ្លែងបាន។ គាត់ពុំប៊ានប្រឈមមុខនៅក្នុងការមកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ ដោយគាត់សុខចិត្តឲ្យកូនស្រីរបស់គាត់ជាអ្នកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីទាមទាររកយុត្តិធម៌ជូនឪពុករបស់គាត់។

ទាក់ទងនឹងចំណុចហ្នឹងដែរ ជនជាប់ចោទក៏បានទទួលស្គាល់ ចិន សៀ ដែលជាឪពុកថា ពិតជាបានស្លាប់នៅមន្ទីរស-២១ ក៏ប៉ុន្តែគាត់បែរជាលើកឡើងថា “ ហាវ សោភា មិនដឹងជាកូនស្រីរបស់ មិនដឹងៗ មិនត្រូវជាកូនស្រីរបស់ ចិន សៀ ហ្នឹងពិតប្រាកដ ឬក៏យ៉ាងណា?” គាត់ក៏ទាមទារធ្វើឲ្យមានស្នើសុំបំភ្លឺបន្ថែមពីទំនាក់ទំនង។ ទាក់ទងទៅនឹងចំណុចនេះដែរ នាងខ្ញុំសូមជម្រាបអង្គសវនាការថា ជនជាប់ចោទកន្លងមកតែងតែធ្វើការអះអាង និងស្នើសុំទទួលស្គាល់នូវទោសកំហុសទាំងអស់ដែលគាត់បានប្រព្រឹត្តនៅមន្ទីរស-២១ និងស្នើសុំអភ័យទោសដល់ជនរងគ្រោះទាំងអស់ដែលទទួលរងទុក្ខវេទនានៅមន្ទីរស-២១ ប៉ុន្តែជាក់ស្តែងគាត់បែរទៅបែរជាមិនព្រមទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវជាកូនចៅរងជនរងគ្រោះទៅវិញ។ នាងខ្ញុំសូមទាញចំណាប់អារម្មណ៍ដល់អង្គសវនាការក្នុងការពិនិត្យ និងពិចារណាត្រង់ចំណុចនេះ។

ជាបន្តទៀត គឺជនរងគ្រោះដែលមានឈ្មោះ នេត ប៊ុនធី ជាបងប្រុសរបស់ដើមបណ្តឹងរដ្ឋប្ប-

វេណី នេត ផល្លី ដែលមានលេខសម្គាល់ E2/50។ ប្រវត្តិទាក់ទងទៅនឹងដើមបណ្ដឹងរូបនេះ គឺគាត់មានប្រវត្តិរូបអ្នកទោសស-២១ របស់ នេត ប៊ុនធី នៅក្នុងសំណុំរឿងដែលត្រូវបានបញ្ជាក់បន្ថែម ដោយជនជាប់ចោទ ទទួលស្គាល់ថា នេត ប៊ុនធី ជាជនរងគ្រោះនៅមន្ទីរស-២១។ នេត ផល្លី និងក្រុមគ្រួសាររបស់គាត់មានទុក្ខសោកយ៉ាងខ្លាំងនៅពេលដឹងអំពីការសម្លាប់បងប្រុសរបស់គាត់នៅមន្ទីរស-២១។

ថ្ងៃមួយនៅពេលដែលគាត់មានទុក្ខព្រួយខ្លាំងពេក មិនបានចាប់អារម្មណ៍មែកឈើក៏បានបាក់ធ្វើឲ្យគាត់បាត់បង់ដៃអស់មួយចំហៀង ដោយសារតែភ្លឹកក្នុងការនឹកគិតដល់បងប្រុសរបស់គាត់។

ជនរងគ្រោះ ឈ្មោះ ចស្សហ្វ រ៉ស់ឆាលដ៏ និង ដេហ្វ្រីយ៍ ចេមស៍ ត្រូវជាកូនរបស់--ត្រូវជាក្មួយរបស់ ចេមស៍ វីល្លៀម ខ្លាក ដែលដើមបណ្ដឹងរដ្ឋប្បវេណីនេះ មានឯកសារពាក់ព័ន្ធនៅក្នុងមន្ទីរស-២១ និងចម្លើយសារភាពពីមន្ទីរស-២១របស់គាត់ បញ្ជាក់ថា គាត់ត្រូវបានឃុំខ្លួននិងសម្លាប់នៅមន្ទីរស-២១។ ដើមបណ្ដឹងរដ្ឋប្បវេណី ចេមស៍ រ៉ស់ឆាលដ៏ និងដេហ្វ្រីយ៍ ចេមស៍ មានជំងឺដេកមិនលក់ យល់សប្តិអាក្រក់ និងថប់អារម្មណ៍ចាប់ពីទទួលដំណឹង អំពីការស្លាប់របស់ឪពុកមាររបស់គាត់។

ជនរងគ្រោះផ្ទាល់ឈ្មោះ ម៉ាន ស៊ីម ជាកូនរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ាន ស៊ត D25/18 ម៉ាន ស៊ីម ហៅ រៀម ចូលមន្ទីរស-២១ នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៧៦ និងត្រូវបានសម្លាប់ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧។ ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ាន ស៊ត កំពុងស្ថិតក្នុងភាពជឿចាប់សព្វថ្ងៃនេះ ដោយសារតែការស្លាប់យ៉ាងវេទនារបស់កូនប្រុសគាត់នៅមន្ទីរស-២១ ដូចជាការសោកសង្វេគ នឹករឭកកូន និងនាំឲ្យមាន កើតមានជំងឺក្រពះជាប្រចាំ។

ជនរងគ្រោះដោយផ្ទាល់ ស្អាន ស្លេះ ជាបងប្រុសរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ស្អាន ណុប E2/44 និង ស្អាន់ សរ E2/45។

ជនរងគ្រោះផ្ទាល់ឈ្មោះ ស្អាន សាម៉ាត ជាក្មួយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ស្អាន ណុប និងជាកូនប្រុសរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ស្អាន់ សរ។ ស្អាន ស្លេះ ហៅ ឡេង សុខា ត្រូវឃុំឃាំងខ្លួននិងសម្លាប់នៅមន្ទីរស-២១ ដូចដែលមានឃើញនៅក្នុងបញ្ជីអ្នកទោសស-២១រួម និងប្រវត្តិរូបអ្នកទោសស-២១របស់គាត់។ សាម៉ាត ហៅ សារឿន ត្រូវឃុំខ្លួននិងសម្លាប់នៅមន្ទីរស-២១ដែរ ដូចដែលបានឃើញនៅក្នុងបញ្ជីអ្នកទោសស-២១រួម និងប្រវត្តិរូបអ្នកទោសរបស់គាត់។

ជនរងគ្រោះផ្ទាល់ តាឡុស ម៉ាត ហៅ ម៉ាន, ម៉ាន ម៉ាត និងហៅ ម៉ាន ម៉ា ជាកូនប្រុសរបស់

ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ម៉ះ E2/51 ហៅ ម៉ាន ម៉ាលីម៉ះ។ ឈ្មោះរបស់គាត់នៅក្នុងបញ្ជីអ្នកទោស ស-២១ បញ្ជាក់ថាគាត់ពិតជាត្រូវឃុំឃាំង និងសម្លាប់នៅមន្ទីរស-២១។

ជនរងគ្រោះផ្ទាល់ឈ្មោះ ធ្លក លួន ហៅ យ៉ន ជាឪពុករបស់ដើមបណ្តឹងរដ្ឋប្បវេណី យឹម ឡេង D25/23 គាត់មានប្រវត្តិរូបអ្នកទោសស-២១ របស់ ធ្លក លួន និងឈ្មោះនៅលើបញ្ជីអ្នកទោសរួម បញ្ជាក់ថា គាត់ពិតជាត្រូវឃុំខ្លួន និងសម្លាប់នៅមន្ទីរស-២១។

ជនរងគ្រោះផ្ទាល់ សួស សុវណ្ណ ត្រូវជាបងស្រីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ សួស សារិន D25/24 ដែល សួស សារិន គាត់បានទទួលមរណភាព គាត់ក៏បានផ្ទេរសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណីទៅឲ្យប្តីរបស់គាត់ ដែលតុលាការក៏បានប្រកាសទទួលស្គាល់តាមផ្លូវច្បាប់រួចហើយ។ ទាក់ទងទៅនឹងជនរងគ្រោះរូបនេះ គាត់មានប្រវត្តិរូបរបស់អ្នកទោស សុវណ្ណ និងរូបថតពីមន្ទីរស-២១ និងឈ្មោះនៅលើបញ្ជីអ្នករួម បញ្ជាក់ថា គាត់ពិតជាត្រូវឃុំឃាំ និងសម្លាប់នៅមន្ទីរស-២១។

ចំពោះជនរងគ្រោះផ្ទាល់ឈ្មោះ កែ កេងស៊ី ហៅ ដន ត្រូវជាបងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ កែ ខុន D25/25 និង កែ សាម៉ូត E2/46 គាត់មានប្រវត្តិរូបអ្នកទោសទួលស្លែងរបស់កែ កេងស៊ី និងឈ្មោះនៅលើបញ្ជីអ្នកទោសរួម។ បញ្ជាក់ថា គាត់ពិតជាត្រូវឃុំខ្លួន និងសម្លាប់នៅមន្ទីរស-២១។

ចំពោះជនរងគ្រោះផ្ទាល់ឈ្មោះ ផែ ហេង ត្រូវជាបងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី ផែ ប៉ាប D25/10 គាត់មានប្រវត្តិរូបអ្នកទោស ស-២១ របស់ ផែ ហេង មានភ្ជាប់ជាមួយនូវរូបថត បញ្ជាក់ថា គាត់ពិតជាត្រូវឃុំខ្លួននិងសម្លាប់នៅមន្ទីរស-២១។ ចំពោះជនរងគ្រោះផ្ទាល់ឈ្មោះ ម៉ៃឃើល ឌីដស៍ ត្រូវជាប្អូនប្រុសរបស់ ធីម៉ូស៊ី ឌីដស៍ ដែលជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានលេខសម្គាល់ D25/22 គាត់មានចម្លើយសារភាពរបស់ ម៉ៃឃើល ឌីដស៍ ពីមន្ទីរស-២១ បញ្ជាក់ថា គាត់ត្រូវបានឃុំខ្លួន និងសម្លាប់នៅមន្ទីរស-២១។

ជនរងគ្រោះផ្ទាល់ឈ្មោះ រ៉ូន ម៉ាត ហៅ រ៉ូន សារី ជាបងប្អូនប្រុសបង្កើតរបស់ដើមបណ្តឹង រ៉ូន ស្រីណុប E2/42។ រ៉ូន ម៉ាត ហៅ សារី មានឈ្មោះនៅលើបញ្ជីអ្នកទោសរួម និងចម្លើយសារភាព និងប្រវត្តិរូបបញ្ជាក់ថា គាត់ត្រូវឃុំខ្លួន និងសម្លាប់នៅមន្ទីរស-២១។

ជនរងគ្រោះផ្ទាល់ឈ្មោះ អ៊ីស្មាអែល អាម៉ាត ហៅ សុខ ជាបងប្រុសដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ អែម លីម៉ះ E2/43 គាត់មានប្រវត្តិរូបអ្នកទោសស-២១ របស់ អ៊ីស្មាអែល អាម៉ាត និងឈ្មោះ

នៅក្នុងបញ្ជីអ្នកទោសរួម បញ្ជាក់ថា គាត់ត្រូវឃុំខ្លួន និងសម្លាប់នៅមន្ទីរស-២១។ ទាក់ទងទៅនឹង អ៊ីស្មាអែល អាម៉ាត គឺជាបុគ្គល ជាបង្គោលគ្រួសារ ដែលក្រុមគ្រួសាររបស់គាត់តែងតែចាត់ទុកគាត់ថា ជាមនុស្សសំខាន់របស់គ្រួសារ ពីព្រោះថា គាត់គឺជានិស្សិតជនជាតិអ៊ីស្លាម ដែលបានទទួលអាហារូបករណ៍ ទៅរៀននៅប្រទេសបារាំង ក្រោយមកត្រូវបានគេហៅ ដើម្បីមកសម្លាប់នៅមន្ទីរស-២១។

ជនរងគ្រោះផ្ទាល់ឈ្មោះ មិន កាន ត្រូវជាកូនប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ែន ឡាយ E2/47។ មិន កាន មានឈ្មោះនៅលើបញ្ជីអ្នកទោសរួម ចូលក្នុងមន្ទីរស-២១ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៥ និងក្រោយមកត្រូវសម្លាប់នៅឆ្នាំ១៩៧៥។

ជនរងគ្រោះដោយផ្ទាល់ឈ្មោះ ញ៉ែម ចុល ហៅ វ៉ា ជាបងស្រីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ែម សុផាត E2/48។ ញ៉ែម ចុល ហៅ វ៉ា មានឈ្មោះហៅលើបញ្ជីអ្នកទោសរួម ហើយនេះបញ្ជាក់ថា គាត់ត្រូវឃុំខ្លួន និងសម្លាប់នៅមន្ទីរស-២១។

ជនរងគ្រោះផ្ទាល់ ស្រី យ៉េង ជាប្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ កុំ ម៉ែន ហៅ គុម ម៉ែន E2/52 គាត់មានប្រវត្តិរូបអ្នកទោស ស-២១ មានរូបថតរបស់ ស្រី យ៉េង និងឈ្មោះនៅលើបញ្ជីអ្នកទោសរួម បញ្ជាក់ថាគាត់ត្រូវឃុំខ្លួន និងសម្លាប់នៅមន្ទីរស-២១។

ជនរងគ្រោះផ្ទាល់ឈ្មោះ ខឿង មុយស័រ ហៅ ខឿង បួយស័រ ជាបងប្អូនប្រុសបង្កើតរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ទ្រី ង៉ិចលាង E2/53។ មុយស័រ មានឈ្មោះនៅលើបញ្ជីឈ្មោះជនរងគ្រោះសម្លាប់នៅមន្ទីរស-២១ ក្នុងឆ្នាំ១៩៧៦ ហើយបញ្ជីអ្នកទោសរួមបានបញ្ជាក់ថាគាត់ចូលមន្ទីរស-២១ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៧ និងត្រូវសម្លាប់នៅថ្ងៃទី២០ កក្កដា ឆ្នាំ១៩៧៧។

ជនរងគ្រោះផ្ទាល់ឈ្មោះ សុខ ហេង ជាឪពុករបស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ង៉ិចហុង E2/54 គាត់មានប្រវត្តិរូបអ្នកទោសស-២១ របស់ សុខ ហេង ដែលមានរូបថត និងឈ្មោះនៅក្នុងបញ្ជីអ្នកទោសរួម បញ្ជាក់ថាគាត់ត្រូវឃុំខ្លួន និងសម្លាប់នៅមន្ទីរស-២១។

ជនរងគ្រោះផ្ទាល់ឈ្មោះ ប៉េង ពុំ ជាបងប្អូនប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉េង ចាន់ថន E2/55 ប្រវត្តិរូបអ្នកទោសរបស់ ប៉េង ពុំ និងឈ្មោះលើបញ្ជីអ្នកទោសរួម បញ្ជាក់ថាគាត់ត្រូវឃុំខ្លួន និងសម្លាប់នៅមន្ទីរស-២១។

ជនរងគ្រោះផ្ទាល់ យុន លឿន ជាក្មួយរបស់ដើមបណ្តឹងរដ្ឋប្បវេណី យុន ឈឿន E2/56 គាត់មានប្រវត្តិរូបអ្នកទោស ស-២១ របស់ យុន លឿន បញ្ជាក់ថាគាត់ត្រូវឃុំឃាំងខ្លួន និងសម្លាប់នៅមន្ទីរ

ស-២១។

ជនរងគ្រោះផ្ទាល់ឈ្មោះ អួយ រ៉ែន ឬហៅ អួយ រ៉ែន ហៅ ម៉ៅ ជាប្អូនស្រីរបស់ដើមបណ្តឹងរដ្ឋប្បវេណី លី ឃៀក E2/57 គាត់មានឈ្មោះនៅក្នុង-- ឈ្មោះរបស់ អួយ រ៉ែន ត្រូវបានរកឃើញនៅលើបញ្ជីគ្រប់គ្រងអ្នកទោសស-២១ ប្រចាំថ្ងៃនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៧៧ ដែលនេះបញ្ជាក់អំពីការឃុំខ្លួន និងការសម្លាប់នៅមន្ទីរស-២១។

ជនរងគ្រោះផ្ទាល់ ពូល តឿន ហៅ ចាំង ត្រូវជាឪពុករបស់ដើមបណ្តឹងរដ្ឋប្បវេណី ពូល ពន្លក E2/58។ គាត់មានចម្លើយសារភាពពីមន្ទីរស-២១ របស់ ពូល តឿន និងឈ្មោះនៅលើបញ្ជីអ្នកទោសរួម បញ្ជាក់ថា គាត់ត្រូវឃុំឃាំង និងសម្លាប់នៅមន្ទីរស-២១។

[១០:00:30]

ជនរងគ្រោះផ្ទាល់ ចាន់ ស៊ីនួន ជាបងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចាន់ ក្រូច E2/59 គាត់មានប្រវត្តិរូបពីមន្ទីរស-២១ របស់ ចាន់ ស៊ីនួន ឈ្មោះនៅលើបញ្ជីអ្នកទោស និងអ្នកសួរចម្លើយនៅក្នុងក្រុម៨ របស់សមមិត្ត ស្លួន និងឈ្មោះនៅលើបញ្ជីអ្នកទោសរួម បញ្ជាក់ថាគាត់ឃុំឃាំង និងសម្លាប់មន្ទីរស-២១។ ជនរងគ្រោះផ្ទាល់ នង គីមវ៉េត ជាបងស្រីបង្កើតរបស់ដើមបណ្តឹងរដ្ឋប្បវេណី នង គីមលៀង E2/60 គាត់មានប្រវត្តិរូបអ្នកទោសស-២១ របស់ នង វ៉េត បញ្ជាក់ថាគាត់ត្រូវបានឃុំខ្លួន និងសម្លាប់នៅមន្ទីរស-២១។ ជនរងគ្រោះផ្ទាល់ សាំង គីមឡេង ជាបងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី E2/62 ដោយគាត់មានរូបថតអ្នកទោសស-២១ របស់ សាំង គីមឡេង បញ្ជាក់ថាគាត់បានឃុំខ្លួន និងសម្លាប់នៅមន្ទីរស-២១។ ជនរងគ្រោះផ្ទាល់ ប៉ែន អ៊ុម ហៅ រិត ជាបងប្អូនជីដូនមួយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្លួន សៀង D25/15 គាត់មានប្រវត្តិរូបរបស់អ្នកទោស ប៉ែន អ៊ុម ហ្នឹង។ ឈ្មោះនៅក្នុងបញ្ជីអ្នកទោសកម្ទេចនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៧៧ បញ្ជាក់ថា គាត់ត្រូវឃុំខ្លួន និងសម្លាប់នៅមន្ទីរស-២១។ ជនរងគ្រោះផ្ទាល់ឈ្មោះ ណុប ង៉ាន ហៅ សរ ហៅ ចារើន ជាបងប្រុសបង្កើតរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ង៉ែត សុខ D25/20 គាត់មានប្រវត្តិរូបអ្នកទោសស-២១ របស់ ណុប ង៉ាន បញ្ជាក់ថា គាត់ត្រូវឃុំខ្លួន និងសម្លាប់នៅមន្ទីរស-២១។ ជនរងគ្រោះផ្ទាល់ ភាច គីម ត្រូវជាជីដូនមួយបង្កើតរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ិន ស៊ីណែត។

នាងខ្ញុំសូមធ្វើការកែប្រែត្រង់ចំណុចនេះ ភាច គីម ត្រូវជាជីតារបស់ ស៊ិន ស៊ីណែត E2/41 រូបថតពីមន្ទីរស-២១។ មានបញ្ហាបច្ចេកទេសបន្តិចបន្តួច នាងខ្ញុំសូមពិភាក្សាជាមួយក្រុមសិន។

[១០:០៣:២៧]

ដោយសារតែពេលវេលារបស់នាងខ្ញុំកាន់តែកៀកហើយ ដូច្នេះនាងខ្ញុំសូមធ្វើការអានតែឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ជនរងគ្រោះផ្ទាល់ ម៉ាយិត ជាបងប្រុសបង្កើតរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ លឹម យ៉ុន E2/69។ ជនរងគ្រោះផ្ទាល់ ហេង ពុន ឬ ជន ហៅជន ជាស្វាមីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប E2/75។ ជនរងគ្រោះផ្ទាល់ ប្រាក់ ប៉ាត ជាស្វាមីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត អ៊ុយ E2/73។ ទាក់ទងទៅនឹង--។

ជាសរុបមក នាងខ្ញុំសូមធ្វើសេចក្តីសន្និដ្ឋានដោយសរុបថា ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងនាងខ្ញុំមួយចំនួន គឺគាត់មានឯកសារគ្រប់គ្រាន់ ដែលគាត់អាចក្លាយទៅជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវច្បាប់បាន។ ជាអកុសល មានដើមបណ្តឹងរដ្ឋប្បវេណីនៅក្រុមរបស់នាងខ្ញុំចំនួន៧រូបដែលគាត់ពុំមានឯកសារគ្រប់គ្រាន់នៅក្នុងការបង្ហាញអំពីទំនាក់ទំនងជាដើមបណ្តឹងរដ្ឋប្បវេណី ជាមួយនឹងសាច់ញាតិរបស់គាត់ដែលបានទទួលរងនូវទារុណកម្មនៅមន្ទីរស-២១ រួមមាន៖ E2/41, E2/62, D25/15, E2/67 និង E2/73, E2/74 និង E2/75។

[១០:០៥:៣៥]

ពាក់ព័ន្ធជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីក្រុមយើងខ្ញុំ ដែលគាត់ខ្វះនូវឯកសារ ខ្វះនូវឯកសារដើម្បីបញ្ជាក់នេះ នាងខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះថា មូលហេតុនិងកត្តាដែលនាំឲ្យយើងពុំអាចស្វែងរកឯកសាររបស់ពួកគាត់បានគ្រប់គ្រាន់ គឺដោយសារតែស្ថានភាពដែលបានកើតឡើងកាលពីអំឡុងសាមសិបឆ្នាំមុន គឺបានបំផ្លាញនូវឯកសារជាច្រើននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យក៏ដូចជានៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ យើងឃើញថាឯកសារក៏ត្រូវបានបំផ្លិចបំផ្លាញជាច្រើន។

ជាកិច្ចបន្ត នាងខ្ញុំសូមបង្វែរវេទិកានេះជូនទៅសហមេធាវីអន្តរជាតិរបស់នាងខ្ញុំ ដោយសារតែពេលវេលាមានការកាន់តែខើចហើយ អ៊ីចឹងនាងខ្ញុំសូមប្រគល់វេទិកានេះជូនគាត់។

**លោក ការីម ខាន៖**

លោកប្រធានជាទីគោរព, សូមអរគុណយ៉ាងច្រើនចំពោះសារណាដែលបានដាក់ជូនដោយសហមេធាវីជាតិរបស់ខ្ញុំ។ ប្រហែលជាខ្ញុំសូមឲ្យមន្ត្រីតុលាការ សុំសួរបន្តិច តើយើងមានពេលរយៈពេលប៉ុន្មានទៀតសម្រាប់ដើមបណ្តឹង-- មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ? តើនៅសល់ពេល១០នាទីទៀត ឬក៏១៥នាទី? បាទ, ១៥នាទី។ សូមអរគុណ បាទ។

លោកប្រធានជាទីគោរព, ខ្ញុំព្យាយាមបញ្ចប់ឲ្យបានទាន់ពេលវេលានូវសារណារបស់យើងខ្ញុំនៅក្នុងរយៈពេល១៥នាទី។ វាជាការពិតណាស់ ដែលថាមានមូលហេតុជាច្រើនដែលយើងត្រូវលើកឡើង។ ប្រហែលជាលោកប្រធានក៏បានជ្រាបហើយគឺថា យើងត្រូវមានបញ្ហាច្រើនដែលត្រូវលើកឡើង ហើយខ្ញុំដឹងថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមផ្សេងទៀតនឹងចំណាយពេលវេលាច្រើន ទាក់ទងទៅនឹងការទាមទារសំណងជំងឺចិត្ត។ ជំហររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ គឺថានឹងសូមដាក់ជូនឲ្យបានលម្អិតទាក់ទងទៅនឹងសារណាស្តីអំពីសំណើសុំរួមគ្នា ដែលបានដាក់ជូនអង្គជំនុំជម្រះរួចមកហើយនោះ។ តាមការព្រួយបារម្ភ ជាការគួរឲ្យចាប់អារម្មណ៍ ហើយដូចដែលបានដឹងច្បាស់ហើយ សារណារបស់ក្រុមយើងខ្ញុំ គឺបានបែកចែកទៅជាបួនចំណុចសំខាន់ៗ ដែលជនជាប់ចោទមានអំណាចស្វ័យភាពនៅមន្ទីរស-២១។

លោកប្រធានជាទីគោរព, ជនជាប់ចោទបាននិយាយរួចមកហើយថា នៅពេលដែលមានរឿងរ៉ាវមិនល្អកើតឡើងនៅមន្ទីរស-២១ គឺគាត់មិនអាចធ្វើអ្វីឲ្យបានច្រើនលើសពីអ្វីដែលគាត់ធ្វើបាន ដើម្បីសម្រួលទៅដល់ការឈឺចាប់ទាំងអស់នេះ គឺថាគាត់អាចធ្វើក្នុងនាមជាប្រធានស-២១។ ទិដ្ឋភាពទីពីរ នៃសារណាចុងបញ្ចប់នេះ គឺជាសេចក្តីសន្និដ្ឋានមួយដែលជនជាប់ចោទបានប្រើស្វ័យភាពរបស់គាត់ គឺមិនបានសម្រាលនូវការឈឺចាប់នោះទេ ហើយគឺជាការមួយដែលកើតឡើងជាញឹកញាប់។ ជាឧទាហរណ៍ គាត់បានបញ្ជាក់ថា ដោយថាមិនមានមនុស្សណាម្នាក់ដែលគាត់បានជួយសង្គ្រោះទេ ប៉ុន្តែការងារនោះ គឺបានបញ្ជាក់ដោយភ័ស្តុតាង ដែលបានបញ្ជាក់ថាមិនមានការសម្រាលការឈឺចាប់នោះទេ។ មិនមានបុគ្គលណាម្នាក់ដែលស្វែងរកឱកាសដើម្បីកាត់បន្ថយការឈឺចាប់ ប៉ុន្តែផ្ទុយទៅវិញគាត់បានបន្ត ហើយបន្តទៀត គាត់បានលះបង់ចំពោះការងាររបស់គាត់។

[១០:១០:៤៣]

លោក លោកស្រីចៅក្រម, នេះគឺជាអំពើ ជាតួនាទីរបស់គាត់ ដែលគាត់បានអនុវត្ត មិនមែនថាជាស្ថានភាពកម្រិតត្រឹមតែស-២១នោះទេ មិនមែនថាជាអំពើទារុណកម្ម ការសម្លាប់នៅទីនោះដោយផ្អែកលើមូលដ្ឋាននៅក្នុងលក្ខណៈតាមការបញ្ជា។ យុទ្ធនាការនៃទារុណកម្ម ហើយនិងអំពើភ័យខ្លាចដែលជនជាប់ចោទបានដឹកនាំនៅស-២១នោះ ហើយគាត់បានគ្រប់គ្រងនៅទីនោះ ហើយមានផលប៉ះពាល់មូលដ្ឋានមួយ ដែលថាគាត់បង្កើតនូវភាពភ័យខ្លាចនៅក្នុងបក្ស ជាពិសេសនៅក្នុងថ្នាក់លើរបស់បក្សគាត់នោះឯង ដែលច្រានឲ្យមានវដ្តមួយ នាំឲ្យមានមនុស្សកាន់តែច្រើនទទួលការចាប់ខ្លួន មនុស្ស

កាន់តែច្រើនទទួលរងទារុណកម្មដ៏អាក្រក់ ហើយគឺជាលទ្ធផលគឺបានចម្លើយសារភាពជាច្រើន ដែលជាចម្លើយសារភាពមិនពិតនោះទេ។

ដូចដែលអង្គជំនុំជម្រះបានជ្រាបហើយ ជនជាប់ចោទបានបញ្ជាក់ជាមួយនឹងរបាយការណ៍ចិត្តសាស្ត្រ។ គាត់បានបញ្ជាក់ថាមិនមែនថា ផ្អែកទៅលើមនោគមវិជ្ជារបស់ខ្មែរក្រហមនៅពេលនោះទេ ប៉ុន្តែគាត់មានចេតនាស្ថិតនៅក្នុងក្រុមមួយដែលមានអំណាចនៅក្នុងរបបនោះផងដែរ។ ហើយជាពិសេសធ្វើឲ្យជីវិតរបស់គាត់មានភាពស្រុកស្រួលនៅក្នុងពេលនោះផងដែរ។

លោក លោកស្រីចៅក្រម, បើយើងនិយាយអំពីស្វ័យភាពរបស់គាត់ ផ្ទុយទៅនឹងអ្វីដែលការអះអាងរបស់ជនជាប់ចោទ គាត់ថាគាត់គ្មានអំណាចនោះ ប៉ុន្តែភស្តុតាងបានបង្ហាញថា គឺជាការអះអាងមិនពិតនោះទេ គឺជាការអះអាងកុហក។ ភស្តុតាងនោះដែលបានដេញដោលចំពោះអង្គជំនុំជម្រះរួចហើយនៅថ្ងៃទី២០, ២២ នៃខែមិថុនា ឆ្នាំនេះ ជនជាប់ចោទបាននិយាយថា គាត់ស្ទើតែភ្លេចទៅហើយថាគាត់គាត់បានធ្វើការជួបជាមួយនឹងពេទ្យធ្មេញ ហើយបន្ទាប់មកជននោះបានស្លាប់ ហើយគាត់ក៏បាននិយាយថានៅទំព័រ២៩ទៅដល់៣០ ថាមានមនុស្សបីនាក់ទៀតបានទុករស់ឲ្យរានមានជីវិត។ ពិតហើយ គឺជាអំពើ ជាឧបាយកលមួយដែលថា នៅក្នុងឯកសារដាក់ជូនចំពោះអង្គជំនុំជ្រះ ហើយប៉ុន្តែគាត់បានគេចកែដែលថាក្រុមនោះ ជនជាប់ចោទមានឱកាសក្នុងបរិបទ ដែលងងឹតងងល់ ហើយពិបាកនោះ គាត់ក៏អាចមានលទ្ធភាព ប៉ុន្តែមិនបានបង្ហាញភាពអាណិតអាសូរ ហើយគាត់បានបញ្ជាក់ពីមូលហេតុដែលថាគាត់ត្រូវតែកម្ទេចអ្នកទាំងនោះនៅពេលនោះ គឺថាក្នុងពេលដែលជិតដែលពួកកងទ័ពវៀតណាមចូលមកដល់ហើយនោះ នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ១៤ ជាឧទាហរណ៍មួយទៀត គឺជាក្រុមមួយដែលគាត់បានសម្រេច គាត់មានស្វ័យភាពទាំងស្រុង។ ដើម្បីនឹងស្វែងរកការជួយ ប៉ុន្តែគាត់បានជួយតែមនុស្សមួយក្រុម ដូចជាជាងគំនូរ ហើយនិងពួកវិចិត្រករដែលគាត់យកមកប្រើនោះ។

[១០:១៥:៣០]

លោក លោកស្រីចៅក្រម នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ គាត់បានឲ្យឧទាហរណ៍មួយទៀតដែរ អំពីស្វ័យភាព អំពីអំណាចរបស់គាត់ដែលថា គាត់អះអាងផ្ទុយថាគាត់គ្មានអំណាចនោះ គាត់បាននិយាយថា នៅក្នុងពេលនោះ ឲ្យច្បាស់នោះ ក្នុងការផ្តួចផ្តើមរបស់គាត់ គាត់បានស្នើប្តូរមន្ទីរឃុំឃាំងទៅកាន់ពញាយ៉ាតហៃស្គូល។ គឺប្តូរទៅពញាយ៉ាតហៃស្គូល វិទ្យាល័យពញាយ៉ាត ហើយគាត់បានជាអ្នកផ្តល់គំនិត ហើយគាត់ទទួលការឯការភាពពីថ្នាក់លើផងដែរ។

លោក លោកស្រីចៅក្រម ក្នុងពេលជាមួយគ្នាគាត់បានសម្រេចនូវវាលពិឃាដថ្មីមួយ ដើម្បីនឹងបើកឡើងគឺជា "ជើងឯក"។ ហើយគាត់បាននិយាយដែរថា គាត់មិនបានស្នើសុំឲ្យមានការឯកភាពជាមុននោះទេ។ គាត់មិនបានត្រូវការមានការពិគ្រោះយោបល់ ឲ្យមានការសម្រេចជាទូទៅទេ ប៉ុនគាត់បានធ្វើខ្លួនឯងដោយចេតនារបស់គាត់ ហើយគាត់យល់យ៉ាងច្បាស់អំពីអំណាចរបស់គាត់ បន្ទាប់ពីគាត់ធ្វើការសម្រេច ហើយគាត់មានការសេចក្ដីទុកចិត្តក្នុងការរាយការណ៍ទៅថ្នាក់លើរបស់គាត់ ដែលអ្នកទាំងនោះគ្រាន់តែផ្ដល់ការឯកភាពជាទម្រង់បែបបទប៉ុណ្ណោះ ហើយមិនមានទទួលផលវិបាកអ្វីពីការធ្វើបែបនេះនោះទេ។ ទាក់ទងទៅមន្ទីរឃុំខ្លួនដែលបែងចែកទៅជាតូចៗ គាត់មិនបានរាយការណ៍ដោយមិនសុំការឯកភាពពីមុនទេ ប៉ុន្តែគាត់មិនទាំងរាយការណ៍ទៅថ្នាក់លើនោះផង ដែលនិយាយអំពីការបង្កើតបន្ទប់ឃុំខ្លួនតូចៗជាដើមនោះ។

ដូចដែលលោក លោកស្រីចៅក្រមពិនិត្យឃើញ ហើយអាចនឹងឆ្លល់ថា នៅពេលដែលយើងពិចារណាទៅលើភ័ស្តុតាងទាំងឡាយនោះ ថាតើអ្វីកើតឡើងចំពោះស្វ័យភាព ចំពោះអំណាចរបស់គាត់នោះតើវាដំណើរការដូចម្ដេចនៅពេលដែលយើងឈានទៅដល់ចំណុចមួយទាក់ទងទៅនឹងការសួរចម្លើយការធ្វើទារុណកម្ម ហើយនិងការសម្លាប់នោះ គឺការសម្លាប់មនុស្សជាច្រើន។ លោក លោកស្រីចៅក្រមយើងមិនមានភ័ស្តុតាងអ្វីទេ ដែលបង្ហាញដោយមេធាវីការពារ ដែលគេអាចនិយាយបញ្ជាក់ប៉ុន្តែអះអាងថា គាត់មិនមានអំណាចនោះ។ ប៉ុន្តែយើងមានរឿងក្ដីមួយដែលថា គាត់បានព្យាយាមបំព្រួញ ឬក៏និយាយឲ្យកាន់តែតិចអំពីតំណែង តួនាទីរបស់ជនជាប់ចោទ ទាក់ទងទៅដែលថាគាត់ជាអ្នកផ្ដល់ការណែនាំអប់រំអំពីការទារុណកម្ម អំពីការសួរចម្លើយ ហើយគាត់បានផ្ដល់ការណែនាំឲ្យច្បាស់។ គាត់មិនបានប៉ុនប៉ងស្វែងរក ដើម្បីឲ្យបានចម្លើយអំពីអ្នកដែលត្រូវបានឃុំខ្លួន ហើយគាត់ក៏បានចង់បានឲ្យមានការឆ្លើយដាក់ទៅអ្នកផ្សេងទៀត។ អញ្ចឹងគឺជាគំនិតមួយដែលជាការប្រព្រឹត្តិទៅដើម្បីពង្រីកនូវអំណាច។ ការដែលអះអាងថា ជនជាប់ចោទ មិនមានចេទនានោះ គឺមិនត្រឹមត្រូវទេ។ តាមពិតគាត់ស្រលាញ់ការងារហ្នឹង គឺគាត់ទទួលភារកិច្ចការងារហ្នឹង គាត់ពេញចិត្តនឹងធ្វើបែបនោះដោយចេតនា ប៉ុន្តែភ័ស្តុតាងដែលលើកឡើងនោះ គឺខុសពីអ្វីដែលគាត់អះអាង។ អ្វីទាំងអស់ដែលគាត់អះអាង គឺមិនពិត គឺធ្វើឲ្យមានការច្រឡំមួយចំនួននៅក្នុងនោះ គឺអាចបំភ័ន្តអំពីខណៈនៃការពិត គឺវាឋិតនៅក្នុងលាក់កំបាំងនៅក្នុងការបដិសេធមួយដែលគាត់ចង់ប្ដូរការស្ដីបន្ទោស ហើយនិងការទទួលខុសត្រូវឲ្យផុតពីខ្លួនគាត់ទៅកន្លែងផ្សេង ដោយសារថាគាត់ជាប្រធានស-២១។

[១០:១៨:២៧]

ពេលដែលលោក លោកស្រីពិចារណាលើភស្តុតាង ខ្ញុំសូមស្នើឲ្យអង្គជំនុំជម្រះពិនិត្យមើលថាតើភស្តុតាងណាមួយដែលជាកត្តាជំរុញនោះ? ហើយខ្ញុំនឹងពិនិត្យមើលប្រតិចារឹក នៅក្នុងឧទាហរណ៍មួយចំនួនដែលបង្ហាញឲ្យយើងឃើញច្បាស់ថា កាលណាយើងមានសំណួរដែលដឹកមុខនោះ ដែលលើកឡើងដោយមេធាវីការពារក្នុងពេលសវនាការ ជនជាប់ចោទបានផ្តល់នូវភស្តុតាង ហើយគាត់បានផ្តល់ភស្តុតាងតិចតួចណាស់ ហើយមិនមានតម្លៃជាភស្តុតាងគ្រប់គ្រាន់នោះទេ គឺថាគឺវាមានទម្ងន់តិចតួច ដោយមិនមានផ្តល់ភស្តុតាងដោយឯករាជ្យ ឬក៏ចេញពីខ្លួនផ្ទាល់ ពីមាត់ផ្ទាល់របស់ជនជាប់ចោទនោះទេ នេះជាឧទាហរណ៍មួយ គឺចាត់ការសួរដេញដោលថ្ងៃទី១៦ ខែកញ្ញា ទំព័រ៥១ មេធាវីការពារនោះគឺលោក រូ បានសួរសំណួរនេះទៅជនជាប់ចោទ ហើយខ្ញុំនឹងអានសំណួរនេះទាំងស្រុង គាត់សួរថា “ឌុច តើលោកបានបញ្ជាខ្ញុំឲ្យប្រាប់ជនរងគ្រោះថា ប្រសិនបើគេចង់ គេអាចមកជួបលោកបាននៅក្នុងកន្លែងឃុំឃាំង តើលោកបើទ្វារទទួលគេដែរឬទេ? ហើយនិងទ្វារចិត្តរបស់អ្នកដើម្បីទទួលពួកគេទេ? តើលោកអនុញ្ញាតឲ្យខ្ញុំប្រាប់ពួកគេដែរឬទេ? តើលោកចង់ឲ្យខ្ញុំប្រាប់ថា ផ្លូវគឺមិនបញ្ចប់នៅថ្ងៃនេះនោះទេ ផ្លូវអាចនឹងភ្ជាប់ពីអ្នកឯងនិងពួកគេនៅតែត ប្រសិនបើពួកគេចង់ធ្វើដូច្នោះ”។ លោក លោកស្រីចៅក្រម អាចនឹងអានឃើញហើយនៅក្នុងចម្លើយនោះគឺថា ខ្ញុំសូមលើកឡើងថា នេះគឺជាចំណុចមួយដែលជាសំណួរដឹកមុខដែលនាំជនជាប់ចោទ ហើយនិងជនជាប់ចោទខ្លួនឯង ត្រូវឆ្លើយចម្លើយទៅសំណួរបែបនេះ គឺថាត្រូវតែមានការពិចារណាដោយអង្គជំនុំជម្រះ។ ហើយនិងចាត់ទុកថា មិនមានតម្លៃជាភស្តុតាងអ្វីនោះទេ ហើយនិងពិចារណាលំអិតទៅលើខ្លឹមសារ ដោយប្រុងប្រយ័ត្ននោះផងដែរ។

លោក លោកស្រីចៅក្រម គឺថាដោយសារគាត់មានអំណាចស្វ័យភាពទាំងស្រុងចំពោះ ឌុច ដែលថាគាត់ប្រើវិធីសាស្ត្រទារុណកម្មដែលបានទទួលស្គាល់នោះ គឺថានៅក្នុងបណ្តុំសារមួយចំនួនយើងមិនទទួលបាន មិនមានកត្តាណាដែលបង្គាប់ឲ្យគាត់ត្រូវប្រើវិធីសាស្ត្រទារុណកម្មណាមួយទេ ប៉ុន្តែគាត់មានស្វ័យភាពក្នុងការសម្រេចដូចដែលយើងបានឃើញ។ ហើយគាត់បានធ្វើការសម្រេចនៅក្នុងប្រព័ន្ធមួយទាំងស្រុង។ គាត់បានយកពីអ្វីដែលគាត់បានចេះដឹងពីម-១៣ ហើយនិងប្រើឲ្យមានប្រសិទ្ធភាពនៅក្នុងកម្រិតមួយឲ្យធំធេង ដើម្បីឲ្យបានប្រសិទ្ធការងារធំធេងចំពោះស-២១។

[១០:២១:៣៦]

លោក លោកស្រីចៅក្រម, ភស្តុតាងនៅក្នុងម-១៣ គឺថាវាមិនទាក់ទងទៅនឹងរឿងក្តីមែន ក៏ប៉ុន្តែ

វាបានផ្តល់នូវគំនិតមួយជ្រាលជ្រៅដែលថា អ្វីដែលឆ្លងមកឲ្យគាត់មានការងារនៅស-២១ បានមានប្រសិទ្ធភាពបែបនេះនោះ។ អ៊ីចឹងហើយភ័ស្តុតាងដែលជនជាប់ចោទ បានបង្ហាញនោះនៅម-១៣ នៅពេលដែលគេដាក់មនុស្សនៅក្នុងរណ្តៅ ហើយមានអ្នកខ្លះត្រូវបានលង់ទឹកស្លាប់ផងពេលមានទឹកជំនន់។ ហើយនៅក្នុងគំនិតមួយដែលថា ឃោរឃៅដែលថា ដាក់ឃុំឃាំងដោយមិនមានការការការពារ។ ហើយបានគាត់ថា ការពារអ្នកទោសអំពីការទម្លាក់គ្រាប់បែករបស់អាមេរិកាំង ប៉ុន្តែលោក លោកស្រីចៅក្រមបានជ្រាបហើយនៅពេលនោះ ការទម្លាប់គ្រាប់បែកនោះ គឺបានបញ្ចប់ទៅហើយ ការទម្លាប់គ្រាប់បែកដោយសហរដ្ឋអាមេរិកនោះ។ នេះជាឧទាហរណ៍មួយដែលថា ជនជាប់ចោទ មិនបានទទួលស្គាល់ការពិតដែលគាត់បានធ្វើ ហើយគាត់បានកាត់បន្ថយតួនាទីរបស់គាត់ ហើយគាត់ក៏បានបញ្ជាក់ថា គាត់បានធ្វើអ្វីដោយមានការអាណិតអាសូរទៅដល់ជនរងគ្រោះនោះដែរ។ នេះគឺជាការបង្ហាញចង់បានការស្ពានសម្រាលនៅក្នុងដំណើរ គឺគាត់មិនបានក្តាប់ឲ្យបានការពិតនៅក្នុងអំពើរបស់គាត់ទេ ប៉ុន្តែគាត់មិនបានច្រានចោលនូវអង្គហេតុមួយចំនួនទាក់ទងទៅនឹងការបង្រៀន ឬក៏ទ្រឹស្តីនៃការធ្វើទារុណកម្ម។ ហើយគាត់បានទទួលគាត់បានបង្រៀន ការទទួលខុសត្រូវរបស់គាត់ នេះគឺមិនមែនជាការងារមិនច្បាស់ទេ គឺខ្មៅនិងសឲ្យច្បាស់ ហើយយើងឃើញវិភាគច្បាស់នៅក្នុងភ័ស្តុតាង យើងនឹងធ្វើការវិភាគ ដោយពិនិត្យពិច័យដើម្បីស្វែងរកការពិត នៅពេលយើងពិនិត្យលើភ័ស្តុតាង គឺថាយើងច្បាស់ហើយថា ជាឧទាហរណ៍ភ័ស្តុតាងនៅថ្ងៃទី២២ ខែមិថុនា គាត់បានបដិសេធថាមិនបានផ្តល់អំណោយ ថាឲ្យដកក្រចកអ្នកទោសទេ នៅពេលគាត់បានដឹង គាត់ថាឲ្យឈប់ទៅ ពីព្រោះថា អាក្រក់ណាស់ ដែលមានការដកបែបនេះ។ ប៉ុន្តែតើមានការភ័ស្តុតាងអំពីការដាក់ទោសទៅលើចារី ដែលបានដកក្រចកគេនោះដែរទេ? តើនេះគឺជាការបដិសេធ ឬគាត់បានបញ្ជាឲ្យគេធ្វើ ហើយក្រោយមកគាត់ធ្វើបែបនោះ? ហើយគឺថា គេបានបង្ហាញក្នុងភ័ស្តុតាងប៉ុន្តែថា បង្ខំឲ្យអ្នកទោសបរិភោគសត្វល្អិត ឬក៏អ្វីផ្សេងៗទៀតនោះ។ ហើយគាត់បានអះអាងទៅនឹងដើម្បីបន្ថយតួនាទីរបស់គាត់ ដើម្បីបានស្ពានសម្រាលបើសិនជាមាន ភ័ស្តុតាងបង្ហាញថាគាត់មិនបានធ្វើទារុណកម្ម ឬដាក់ទោសទៅលើអ្នកដែលប្រព្រឹត្តខុសរបស់គាត់ទេ ប៉ុន្តែយើងពិនិត្យមើលនៅថ្ងៃទី២១ ជាចម្លើយមួយគាត់ថា គាត់បានទទួលការបង្រៀនពីមេរបស់គាត់ គឺគាត់បានបង្រៀនពីវិធីយកម្ជុលទៅចាក់ក្រចក គឺថាគឺធ្វើឲ្យមានការឈឺចាប់ ហើយដើម្បីឲ្យទទួលបាននូវចម្លើយសារភាព។

[១០:២៤:៥៥]

នៅក្នុងសាក្សីដែលនោះ គឺថាបញ្ជាក់នៅពេលក្រោយទៀតថា ការធ្វើបែបនេះគឺធ្វើដើម្បីបំបាក់

ឬក៏បំបាត់មនុស្សធម៌ពីមនុស្សទាំងអស់នេះ។ ហើយគាត់បានប្រាប់ទៅអ្នកយាមរបស់គាត់ថា ពួកគេត្រូវធ្វើយ៉ាងណាឲ្យអ្នកទោសបរិភោគលាមកខ្លួនឯង។ តើអាចទៅរួចដែរទេ ដែលឲ្យគេអាចបរិភោគលាមករបស់គេនោះ? ចម្លើយពីសាក្សីនោះ គេឆ្លើយថា នៅក្នុងករណីពិសេសមួយនេះ គាត់បានប្រាប់ឲ្យអ្នកសួរចម្លើយឲ្យធ្វើបែបនោះ គឺឲ្យបង្គាប់ទៅអ្នកទោសឲ្យបញ្ជាអ្នកទោស ដូចជា គាត់បង្គាប់ឲ្យគេគូររូបឆ្កែ ហើយអ្នកទោសថ្វាយបង្គំ។ ដូច្នេះជាអំពើអាក្រក់ណាស់ បើនិយាយពីរប្បធម៌របស់កម្ពុជានៅពេលនោះ នោះ ថាតើគាត់មានលទ្ធភាពនឹងរក្សាទុកជីវិតរបស់គេបានដែរទេ ទៅតាមជោគវាសនាដែលថាគាត់អាចជាម្ចាស់នោះ? ប៉ុន្តែអ្វីដែលគាត់និយាយ គឺគ្មានន័យ គឺជាការប្រឌិតឡើងតែប៉ុណ្ណោះ។ ដូច្នេះគឺជាការជំទាស់ការតវ៉ាជាច្រើនមួយចំនួននៅក្នុងការសារភាព ឬក៏ការសម្ដែងវិប្បដិសារីរបស់គាត់។ ប៉ុន្តែពាក្យមួយៗដែលគាត់ប្រើនោះគឺមិនស្មោះត្រង់នោះទេ គឺអង្គជំនុំជម្រះអាចនឹងពិនិត្យឃើញបាន ហើយតើមានភាពស្មោះត្រង់សុទ្ធចិត្តដែរឬទេនោះ។ ប៉ុន្តែ យើងពិនិត្យតាមគោលការណ៍ច្បាប់ កាលណាយើងធ្វើការប្រៀបធៀបនីតិវិធីនៅទីនេះ ទាក់ទងទៅនឹងគំរូនៃគណៈកម្មការស្វែងរកការពិតនិងសន្តិភាពនោះយើងបានយោងទៅរកគំរូរបស់អាហ្វ្រិកខាងត្បូង កាលណាមាននីតិវិធីមួយដែលថា ផ្ដល់នូវការលើកលែងទោស ការបន្ធូរបន្ថយនោះកាលណាគេបានផ្ដល់ការសារភាពដែលស្មោះត្រង់ គ្មានការលាក់លៀម។

ដូច្នេះ អង្គជំនុំជម្រះកាលណាត្រូវពិចារណា លើស្ថានទម្ងន់នៃអំពើរបស់គាត់ គឺត្រូវផ្អែកលើចម្លើយរបស់គាត់ ការសារភាពរបស់គាត់ អ្វីដែលមាននោះគឺត្រូវតែច្បាស់ អ្វីដែលគាត់និយាយទំនងជាជាឧទាហរណ៍ច្បាស់លាស់ដែលថា ជនជាប់ចោទបានបដិសេធយ៉ាងច្បាស់ទៅលើអ្វីគេផ្ដល់ភ័ស្តុតាងនោះថ្ងៃទី២០ មិថុនា ២២ មិថុនា ឆ្នាំ២០០៩ នោះ គេបានបញ្ជាក់ភ័ស្តុតាងមួយ ជនជាប់ចោទ។ ហើយដែលជនជាប់ចោទ បានប្រាប់*កាំម្ចរ៉ាត* ប៉ុន គឺមិត្តប៉ុន ឲ្យប្រើវិធីក្ដីដើម្បីទទួលយកចម្លើយសារភាពអ្នកដែលជាប់ឃុំ ប្រើវិធីណាក៏ដោយ ទោះបីជាស្លាប់ក៏មិនបញ្ហាដែរ។ ដូច្នេះ ជាផ្នែកមួយនៃបណ្ដុំសារដែលយើងទទួលបានពីសំណុំឯកសារ នេះគឺជាចំណុចមួយដែលគាត់ទទួលស្គាល់ហើយ គឺជាបញ្ហាអ្វីដែលគាត់បញ្ជាក់នៅពេលនោះ តើនេះគឺជាវិធីមួយដើម្បីបំបាក់ទៅអ្នកទោសដែរឬទេ? បើយើងពិនិត្យមើលចំណុចនេះ គឺថាវាមានជាគំរូបែបនេះ គឺមិនមែនជាវិធីសាស្ត្រដើម្បីបំភ័យ ដើម្បីកំហើញទេ គឺជាវិធីសាស្ត្រដែលជនជាប់ចោទ ប្រើដើម្បីកំហើញ ឬក៏បំភ័ន្តតុលាការនេះវិញទេ។

[១០:២៨:៣៥]

**ប្រធានអង្គជំនុំ៖**

ក្រុមមួយ ដូចជាបានចំណាយពេលវេលាលើសម៉ោងកំណត់ហើយ។ តើលោកត្រូវការពេលប៉ុន្មានទៀតដើម្បីបញ្ចប់ ពីព្រោះព្រឹកនេះយើងធ្វើពីរក្រុម ក្រុមមួយនិងក្រុមពីរ។ ពេលវេលាត្រូវចែកច្បាស់លាស់ ហើយត្រឹមត្រូវគឺកាលដល់ម៉ោង១២ គឺត្រូវចប់ក្រុមទីពីរ។

**លោក ការីម ខាន៖**

លោកប្រធាន, ខ្ញុំដឹងទៅលើចំណុចនេះ ហើយខ្ញុំសុំអភ័យទោសដែលថា ពេលវេលារបស់យើងបានបញ្ចប់ ប៉ុន្តែយើងមានចំណុចច្រើន ខ្ញុំសូមអនុគ្រោះពីអង្គជំនុំជម្រះរយៈពេលតែ៥ ឬក៏១០នាទីបន្ថែមទៀត ដើម្បីឱ្យខ្ញុំបញ្ចប់ទៅលើចំណុចទាំងឡាយដែលបានលើកឡើងនៅក្នុងចំណុចនេះ។

ដូច្នេះហើយ គឺខ្ញុំសូមអនុគ្រោះពីអង្គជំនុំជម្រះ ប៉ុន្តែជាការសម្រេចរបស់អង្គជំនុំជម្រះទៅលើករណីនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះ ដោយលោកបន្តបីនាទីទៀត ដោយហេតុថា កាលពីដើមឡើយគឺការចាប់ផ្តើមវាវែងពេក ដោយមិនស៊ីជម្រៅទៅលើការវិភាគអង្គហេតុ។ អ៊ីចឹងហើយបានជាមកវិភាគចុងក្រោយទើបមានបញ្ហា។ អ៊ីចឹងគឺអនុញ្ញាតឱ្យតែបីនាទីទៀតតែប៉ុណ្ណោះ។

**លោក ការីម ខាន៖**

ខ្ញុំសូមអរគុណលោកប្រធាន។ ភ័ស្តុតាងនៅចំពោះមុខ លោក លោកស្រីចៅក្រម គឺមាននៅក្នុងសារណារបស់យើងខ្ញុំ ហើយវាបានបង្ហាញអំពីករណីជនជាប់ចោទ ដែលគាត់ព្យាយាមចៀសវាងគេចចេញពីភាពសាហាវឃោរឃៅនៅស-២១ ហើយគាត់បានលើកឡើងថា គាត់មិនដឹងទៅលើករណីទាំងអស់នេះ។

លោក លោកស្រីចៅក្រម, ជនរូបនេះបានព្យាយាមធ្វើការផ្លាស់ប្តូរ ឬក៏គេចចេញពីការងាររបស់គាត់ ហើយវាជាឧទាហរណ៍មួយដែលថា គាត់មានសិទ្ធពេញលេញនៅពេលនោះ។ ហើយយើងមានឧទាហរណ៍ជាច្រើន ដែលថាមនុស្សជាច្រើនត្រូវបានគេចាត់ទុកដូចសត្វ ហើយអ្នកទាំងអស់នោះត្រូវបានបបរ ហូបបបរ ហើយមានការឈឺចាប់ ដូច្នេះហើយវាមានចំណុចជាច្រើនកើតឡើង។

[១០:៣០:៥៥]

គាត់មានសិទ្ធច្រើននៅក្នុងនោះ ប៉ុន្តែគាត់ធ្វើអ្វីខ្លះគាត់មិនបានដឹង គាត់បានធ្វើ។ ដូច្នេះ លោក

លោកស្រីចៅក្រម បានដឹងហើយនូវអ្វីដែលគាត់បានប្រព្រឹត្ត ហើយនិងការដែលគាត់ទាក់ទងជាមួយនឹងមេរបស់គាត់ ហើយគាត់បានលើកឡើងថា គាត់ចង់លើកកិត្តិយសនៃមន្ទីរស-២១។ លោក លោកស្រីចៅក្រម, ការភ័យខ្លាចនឹងចំណុចនេះ គឺវាបានលើកឡើងយ៉ាងពិស្តារ តាមរយៈភ័ស្តុតាងដែលមាននៅចំពោះមុខអស់លោក លោកស្រីចៅក្រម។ ហើយខ្ញុំលើកអំពីសក្ខីកម្មរបស់លោកបណ្ឌិត អេតធេសាន់ និងរបស់លោកបណ្ឌិត ដេវីត ឆេនដ៍ល័រ ផងដែរ យើងឃើញថា គាត់បានមានទំនាក់ទំនងរវាងសកម្មភាពរបស់ ឌុច ហើយនិងការឈឺចាប់ និងសកម្មភាពដែលកើតឡើងនៅស-២១។ លោកចៅក្រម ឯកសារលេខ E88.3 .4 និង .2 នោះជាឯកសារដែលសហព្រះរាជអាជ្ញាបានលើកឡើងទាក់ទងទៅនឹងមនុស្សទាំងឡាយត្រូវបានជាប់ឃុំនិងត្រូវបានគេសម្លាប់។ ហើយអំឡុងពេលនោះ គឺជនជាប់ចោទ គឺមានភាពសកម្មនៅក្នុងការងាររបស់ខ្លួន ហើយយើងឃើញមានមនុស្សជាច្រើនត្រូវបានជាប់ចោទ ហើយនិងសម្លាប់ ហើយខ្ញុំសូមលើកឡើងប្រតិចារឹកដែលមានលើកឡើងនៅក្នុងឯកសាររបស់យើង ហើយគឺយើងឃើញមានសេចក្តីសម្រេចដែល ឌុច គាត់បានទទួល ហើយគាត់បានអនុវត្តការងារធ្វើទារុណកម្មក្នុងលក្ខណៈវិជ្ជាជីវៈ។

លោក លោកស្រីចៅក្រម, ខ្ញុំសូមឲ្យអស់លោក លោកស្រីចៅក្រមពិចារណាទៅលើភ័ស្តុតាងទាំងឡាយដែលមានដើម្បីឈានទៅដល់ការស្វែងរកការពិត។ ហើយទាក់ទងទៅនឹងសំណង គឺការសម្រេចចិតនៅក្នុងការពិចារណារបស់លោក លោកស្រីចៅក្រម ហើយវាមិនទាមទារពីរាជរដ្ឋាភិបាលនោះទេ ប៉ុន្តែយើងចង់ឲ្យបង្ហាញការពិត។ ដូច្នេះហើយវាអាស្រ័យទៅលើលោក លោកស្រីចៅក្រមពិចារណាទៅលើភ័ស្តុតាងថាតើការពិតនោះវាមានតម្លៃចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលយើងតំណាងដែរឬទេ?

លោក លោកស្រីចៅក្រម, ភ័ស្តុតាងជាច្រើន គឺយើងគួរតែចងចាំ ហើយខ្ញុំចង់លើកឡើងទៅលើចំណុចចំនួនបី។ នៅពេលដែលយើងពិចារណាទៅលើ រ៉ូប៊ីតហាមីល ករណីរបស់គាត់ យើងឃើញថា វាគឺជាករណីដែលគ្រួសារត្រូវបានបែកបាក់ ដោយសារតែអំពើរបស់ឌុច។ ហើយយើងអាចមើលឃើញថាតើគ្រួសារទាំងអស់នោះ ត្រូវបានគេកាប់សម្លាប់ និងបំផ្លិចបំផ្លាញយ៉ាងម៉េច? យើងឃើញមានការលោតចុះពីលើជ្រោះថ្ម ហើយឪពុកម្តាយ គាត់បាត់បង់សមត្ថភាព។ ហើយយើងឃើញថាមិត្តស្រីរបស់សមាជិកនៃគ្រួសារនោះ គឺមិនមានការរៀបការដោយសារតែមានការបាត់បង់ទៅលើសមាជិក។

[១០:៣៣:៥៦]

ដូច្នេះ ការឈឺចាប់ទាំងអស់នោះ គឺវាមិនបញ្ចប់ត្រឹមតែស-២១ ប៉ុណ្ណោះនោះទេ ហើយវាមិនបានបញ្ចប់នៃការស្លាប់របស់បុគ្គលតែម្នាក់នៅក្នុងនោះទេ វាបានបន្តទៅដល់អ្នកដែលគេស្រលាញ់ទៅលើជនរងគ្រោះរហូតដល់សព្វថ្ងៃ។ លោក លោកស្រីបានពិនិត្យមើលទៅលើភ័ស្តុតាងទាំងអស់រួចមកហើយ ហើយសាក្សីទីពីរ សោភា ថាតើគាត់ដែលគាត់នោះកើតក្រោយ២១ ថ្ងៃតែប៉ុណ្ណោះដែលឪពុករបស់គាត់ត្រូវបានគេសម្លាប់។ ដូច្នេះហើយ យើងឃើញថាវាបញ្ហានេះ វាបណ្តាលឲ្យមានការឈឺចាប់បន្តមកទៀត ដោយឈរទៅលើមូលហេតុជាច្រើន។ ដូច្នេះហើយ អង្គសវនាការមានអំណាចក្នុងការស្វែងរកយុត្តិធម៌ហើយពិចារណាទៅលើចំណុចនេះ។

ខ្ញុំសូមអរគុណអង្គជំនុំជម្រះ ដែលអនុញ្ញាតឲ្យខ្ញុំដាក់ជូននូវសេចក្តីសន្និដ្ឋាននៅពេលនេះ ហើយសូមឲ្យលោកចៅក្រមពិចារណាទៅលើការលើកឡើងរបស់មេធាវីការពារក្តី សហព្រះរាជអាជ្ញា រួមទាំងអ្វីដែលបានលើកឡើងដោយជនជាប់ចោទ។ ខ្ញុំសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំនាទី រហូតដល់ម៉ោងដប់មួយ ខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីកិច្ចដំណើរការនីតិវិធីសវនាការរបស់យើង។

*(សវនាការសម្រាកពីម៉ោង ១០:៣៥នាទី ដល់ម៉ោង ១០:៥៣នាទី)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាកិច្ចបន្តនេះសូមអញ្ជើញមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ឡើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល។ អង្គជំនុំជម្រះសូមជម្រាបថា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏មានពេលវេលាដូចគ្នានឹងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយដែរ គឺមួយម៉ោងដប់ប្រាំនាទី។

សូមអញ្ជើញ!

**លោក គង់ ពិសី៖**

អរុណសួស្តី ហើយខ្ញុំបាទសូមអរគុណលោកប្រធាន ដែលផ្តល់វេទិកានេះឲ្យមេធាវីក្រុមពីររបស់យើងខ្ញុំបាទសូមគោរព លោក លោកស្រីចៅក្រមជាតិ និងអន្តរជាតិទាំងអស់ ហើយនិងសូមគោរពអង្គ

សវនាការ។ ជាកិច្ចចាប់ផ្តើមនេះ គឺថាខ្ញុំបាទសូមផ្តល់វេទិកានេះជូនទៅដល់សហសេវិករបស់ខ្ញុំបាទ ដែលជាមេធាវីអន្តរជាតិ ស៊ីលឃី ស្ទូតហ្សីនស្គី នឹងចាប់ផ្តើមមុន ហើយខ្ញុំនឹងបន្តធ្វើកិច្ចសន្និដ្ឋានបញ្ចប់ការសួរដេញដោលនេះជាចុងក្រោយបាទ។ សូមអរគុណ។

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម លោក លោកស្រីទាំងអស់ដែលបានចូលរួមនៅក្នុងសវនាការ ដែលមានសារសំខាន់នៅក្នុងថ្ងៃនេះ។ ខ្ញុំសូមលើកឡើងនូវចំណុចពីរជាដំបូង ទីមួយ គឺខ្ញុំសូមដាក់ជូននូវសុន្ទរកថាទាក់ទងទៅនឹងសារណាបិទពិភាក្សាដេញដោល និងទីពីរ នឹងសូមអាននូវសារណាបន្តទៅទៀត។

ក្នុងនាមជាជនជាតិអាល្លឺម៉ង់ ដែលសព្វថ្ងៃកំពុងរស់នៅជាមួយនឹងការយល់ដឹងអំពីអំពើឃោរឃៅ ដែលបានប្រព្រឹត្តឡើងអំពីអតីតកាលនៅក្នុងប្រទេសខ្ញុំ ហើយក្នុងនាមជាមេធាវីនៅ អ.វ.ត.ក ខ្ញុំសូមចាប់ផ្តើមដកស្រង់សម្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់រដ្ឋអាជ្ញានាំមុខ ជាជនជាតិអង់គ្លេសឈ្មោះ ហាង់រី សនខូស ដែលលើកឡើងថា ច្បាប់ត្រូវតែមានជ័យជម្នះលើពួកបិសាច ដើម្បីដំណើរការនីតិវិធី មិនមែនធ្វើឡើងសម្រាប់មូលហេតុនៃការសងសឹកនោះទេ។ ប៉ុន្តែដើម្បីសេចក្តីសម្រេចតឹងរ៉ឹងមួយដែលថាឧក្រិដ្ឋកម្មសាហាវឃោឃៅយង់ឃ្នងបែបនេះត្រូវតែមិនត្រូវមានម្តងទៀតឡើយ។

ការជំនុំជម្រះនៅសាលាជម្រះក្តី គឺជារឿងមួយថ្មីសន្លាងនៅក្នុងប្រវត្តិសាស្ត្រនៃអរិយធម៌ និងជាគ្រឹះនៃសាលាជំនុំជម្រះក្តីអន្តរជាតិ និងសាលាក្តីដែលមានលក្ខណៈអន្តរជាតិ ដែលកំពុងកាប់សម្លាប់យ៉ាងសាហាវយង់ឃ្នង។ សេចក្តីសង្ឃឹមនៅក្រោមភាពតក់ស្លុតនៃសង្គ្រាមលោកទីពីរ នៅតែមាននៅឡើយ ដែលបានធ្វើឲ្យមានការរួញរា ដោយសារប្រវត្តិសាស្ត្របានបញ្ជាក់អះអាងថា សង្គ្រាមគឺជាការវាយប្រយុទ្ធគ្នា រួមទាំងរបបកម្ពុជាប្រជាធិបតេយ្យបន្ទាប់ពីរយៈពេលសាមសិបឆ្នាំនៃសង្គ្រាមលោកលើកទីពីរ ដែលបានប្រល័យជីវិតមនុស្សអស់រាប់រយលាននាក់។ នេះបង្ហាញឲ្យឃើញថា តុលាការអន្តរជាតិនានាដែលកំពុងតែកាត់សេចក្តីជនដែលទទួលខុសត្រូវជាន់ខ្ពស់ គឺជាអ្នកសម្របសម្រួលឲ្យមានការកាប់សម្លាប់ដ៏ធំធេង និងឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នងផ្សេងៗទៀត មិនបានធានាចំពោះការមិនឲ្យកើតមានឡើងវិញនោះឡើយ។

ប៉ុន្តែ ការចោទប្រកាន់ឧក្រិដ្ឋជនសង្គ្រាមកំពុងតែមានកើនឡើងនៅក្នុងទសវត្សរ៍ចុងក្រោយនេះ

ចម្លង

រួមទាំងការបង្កើត អ.វ.ត.ក ក៏ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ ដែលជាមធ្យោបាយចុងក្រោយបំផុតដែលជាការចូលរួមចំណែកដល់ការតស៊ូដ៏ធំធេងនៅក្នុងពិភពលោកប្រឆាំងនឹងនិទ្ទណ្ឌភាព។ ទោះជាមានរយៈពេលសាមសិបឆ្នាំក្រោយការប្រព្រឹត្តបទល្មើសទាំងនោះរួចទៅហើយក្ដី ក៏ការបង្កើត អ.វ.ត.ក ជាមួយសវនាការជាលើកដំបូងចំពោះសាលាក្ដី គឺលុបបំបាត់នូវចន្លោះប្រហោងនិទ្ទណ្ឌភាព។ តាមរយៈការជំនុំជម្រះនេះ អ.វ.ត.ក នឹងនាំឲ្យមានភាពលេចធ្លោឡើង ដែលជាការរួមចំណែកដល់ការផ្សះផ្សាជាតិរបស់ប្រជាជនកម្ពុជាទាំងនៅទីនេះ នៅឯក្រៅប្រទេស។ ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងរបបកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីការជំនុំជម្រះអស់រយៈពេលចិតសិបបីថ្ងៃរួចមក យើងទាំងអស់គ្នាពិពណ៌នាអំពីទស្សនៈរបស់កូនក្ដីយើងខ្ញុំ ដែលសព្វថ្ងៃមានចំនួនដប់ប្រាំពីរ ចូលរួមនៅក្នុងដំណើរជំហានទីពីរ។ យើងនឹងបំភ្លឺអំពីដំណើរការរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលមិនបានផ្ដល់សក្ខីជូនតុលាការ។

[១០:៥៧:៣៩]

ទីបី យើងនឹងវិភាគល្អិតល្អន់ទៅលើចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ណាំ ម៉ុន និងទីបួន វាយតម្លៃភស្ដុតាងប្រកបទៅដោយហេតុផលទាក់ទងទៅនឹងឧក្រិដ្ឋផ្លូវភេទ។ ចុងក្រោយយើងនឹងពិនិត្យទៅលើយុត្តិសាស្ត្ររបស់មេធាវីការពារក្ដី និងសង្កត់ធ្ងន់ទៅលើសំណង។

ឥឡូវនេះខ្ញុំសូមលើកឡើងអំពីសេចក្ដីសង្ឃឹមរបស់កូនក្ដីយើងខ្ញុំ និងសូមដាក់ការកត់សម្គាល់របស់ពួកគាត់នៅក្នុងអំឡុងដំណើរការនីតិវិធីទាក់ទងទៅនឹងផលប៉ះពាល់ជាវិជ្ជមាននិងអវិជ្ជមានមកពួកគាត់។ ដោយសារតុលាការជាតុលាការទីមួយ ដែលបានអនុញ្ញាតឲ្យជនរងគ្រោះក្លាយជាភាគីមួយ និងដើរតួស្មើគ្នានឹងព្រះរាជអាជ្ញា និងសហមេធាវី ទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្ស និងហើយដែលជាសវនាការលើកទីមួយ ដែលលោក កាំង ហ្គេកអ៊ាវ ដែលនឹងជាឧទាហរណ៍ និងជាការណែនាំទៅដល់មនុស្សជំនាន់ក្រោយ។

[១០:៥៦:២៧]

ឥឡូវនេះ គឺថាដល់ពេលវេលាដែលយើងត្រូវធ្វើឲ្យមានការរីកចំរើននៅក្នុង ដើម្បីធានាឲ្យមានចូលរួមទៅដល់ការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា។ យោងតាមឯកសារដែលមាននៅស-២១ ដែលមានជនរងគ្រោះចំនួនដប់ពីរ ជាងដប់ពីរពាន់នាក់ ដែលឈ្មោះអ្នកទាំងអស់នោះ គឺថាអាចត្រូវបានរកឃើញនៅស-២១ ប៉ុន្តែកុមារៗមិនមានគេចុះឈ្មោះនៅទីនោះទេ ហើយដោយសារតែឯកសារដែលបានបាត់បង់ចំនួនពិតប្រាកដគិតថានឹងអាចមានចំនួនច្រើនជាងនេះ។ ក៏ប៉ុន្តែមានតែជនរងគ្រោះ៩៤ ប៉ុណ្ណោះ --

ភាគីដើមបណ្ដឹងរដ្ឋប្បវេណី-- ជនរងគ្រោះ៩៤ ដែលចូលរួមក្នុងដំណើរការនេះ ដែលវាមានទៅតិចជាង ០.៨ ភាគរយនៅក្នុងចំនួនអ្នកទោសទាំងអស់នៅស-២១។ ហេតុអីក៏ចំនួនទាំងអស់នេះក៏តិចម្ល៉េះ បើប្រៀបធៀបទៅនឹងអ្នកទោសទាំងអស់? តើអស់លោក លោកស្រីអាចរំពឹងទេថា គួរតែមានដើមបណ្ដឹងរដ្ឋប្បវេណីមួយតំណាងឲ្យជនរងគ្រោះម្នាក់ដែរទេ? ជនរងគ្រោះ ហើយនិងសាក្សីដ៏សំខាន់ៗ នៅតែមានការភ័យខ្លាចចំពោះការធ្វើទុក្ខបុកម្នេញនៃសមាជិកខ្មែរក្រហម ហើយដែលគាត់នៅជឿជាក់ថា អ្នកទាំងអាចនឹងវិលត្រឡប់មកកាន់អំណាច ហើយអ្នកខ្លះក៏ស្ថិតនៅក្នុងរដ្ឋាភិបាលនៅឡើយ។

ហេតុដូច្នេះ សំណើរសូមមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី សូមឲ្យមានវិធានការពាររបស់គាត់ដោយមិនឲ្យបញ្ជាក់អត្តសញ្ញាណរបស់គាត់។ កូនក្ដីរបស់យើងខ្ញុំនៅក្នុងបន្ទប់នេះ សូមឲ្យចាត់វិធានការជាបន្តបន្ទាប់ពាក់ព័ន្ធទៅនឹងសន្តិសុខរបស់ពួកគាត់។ ប៉ុន្តែ ក្រោយពីគាត់បានជួបគ្នាជាមួយនឹងដើមបណ្ដឹង រដ្ឋប្បវេណីផ្សេងទៀត គាត់មានភាពកក់ក្ដៅទាក់ទងទៅនឹងសន្តិសុខនេះ។ ឥឡូវនេះគាត់គិតថា គាត់ម្នាក់ៗមិនមែនមានតែម្នាក់ឯង ហើយដោយសារ-- នេះដោយសារតែបទពិសោធន៍នៃការចូលរួមសាមគ្គីរបស់ពួកគាត់ទាំងអស់គ្នា។

ការចូលខ្លួនមកអង្គសវនាការនៅចំពោះមុខសាធារណជន គឺថាវាទាមទារឲ្យមានភាពក្លាហាន ខ្ញុំសូមថ្លែងអំណរគុណចំពោះភាពអង់អាចក្លាហាន ការចូលរួមមកក្នុងសវនាការ ហើយចំពោះការលុបបំបាត់ចោលនូវភាពភ័យខ្លាចរបស់ពួកគាត់ទាំងអស់នេះ។ ដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើន គឺថាគិតថាដួងវិញ្ញាណរបស់ព្រាយបិសាចនៅតែចង់លងកម្ពាចយាយីគាត់នៅឡើយ ហើយគាត់ចង់យកជ័យជម្នះទៅលើបញ្ហាទាំងអស់នេះ។

[១១:០០:៥៥]

កូនក្ដីរបស់យើងខ្ញុំបី ពីរនាក់ដែលរស់រានមានជីវិតពីស-២១ គឺដែលត្រូវបានដាក់ឃុំឃាំងនៅស-២១ និងសម្លាប់។ ស្ថានភាពនៅទីនោះ គឺមានលក្ខណៈខុសគ្នាៗ រវាងអ្នករស់រានមានជីវិតទាំងអស់នោះ។ អ្នករស់រានមានជីវិត គឺថាមានការយល់ដឹងយ៉ាងច្រើនទៅនឹងវិសាលភាពនៅក្នុងស-២១ គាត់រស់នៅក្នុងភាពរន្ធត់ ញាប់ញ័រ ពីមួយថ្ងៃទៅមួយថ្ងៃ ទាំងថ្ងៃទាំងយប់។ ហើយអ្នករស់រានមានជីវិតនៅក្នុងមន្ទីរឃុំឃាំង ខ្ញុំសូមលើកសម្ដីគាត់ឡើងថា "អ្នកណាក៏ដោយដែលត្រូវបានទទួលការធ្វើទារុណកម្មនៅតែរងការធ្វើទារុណកម្ម អ្នកដែលទទួលនូវការឈឺចាប់ គឺមិនអាចនឹងលុបបំបាត់ទៅវិញបានទេ នៅក្នុងពិភពលោកយើងនេះ"។ ការធ្វើកាយវិកលកម្មទៅលើមនុស្សណាម្នាក់ គឺជារឿងមួយធ្ងន់ធ្ងរ។ តាម

ការពិតនោះ គឺថាការទះកំផ្លៀងមនុស្សម្នាក់ គឺវាជាការពិតមួយរួចទៅហើយ លើសពីការធ្វើកាយវិលកម្មផ្សេងទៀត។

ឥឡូវនេះ ទាក់ទងទៅនឹងជំងឺប្រចាំកាយរបស់កូនក្ដីរបស់យើង គឺកូនក្ដីឈ្មោះ ប៊ូ ម៉េង។ ខ្ញុំសូមរៀបរាប់ដូចខាងក្រោម៖

គាត់នឹងមិនអាចក្លាយទៅជាមនុស្សមានសុខភាពល្អវិញបានទេ ទាក់ទងទៅនឹងទារុណកម្មដែលគាត់បានទទួលរងពីស-២១។ ស្លាកស្នាមដែលមាននៅលើរាងកាយរបស់ខ្លួនគាត់នៅតែមាននៅលើខ្លួនគាត់ ហើយនិងវានឹងបន្តមានជារៀងរហូត។ ខ្ញុំសូមដកស្រង់សម្ដី “អ្នករស់រានមានជីវិត គឺរស់នៅជាមួយនឹងការចងចាំជាប្រចាំថ្ងៃ ហើយសង្ឃឹមថា តុលាការនឹងទទួលស្គាល់ថា ជនរងគ្រោះជាដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីដាក់ជូនដំណើររឿងរបស់គាត់ ជូនតុលាការ ដែលនៅស-២១ គឺថាបានដកហូតសេរីភាពជាមនុស្ស លុបបំបាត់ភាពជាមនុស្សរបស់គាត់។ ហេតុអីក៏គាត់-- គាត់ចោទសួរថា ហេតុអីក៏គាត់ត្រូវបានគេចាប់យកដាក់ពន្ធនាគារដោយមិនបានប្រព្រឹត្តអំពើអីខុស ដោយមិនមានមូលហេតុអីសោះអីចឹង។ ខ្ញុំមិនមានទោសកំហុសអ្វីទាំងអស់”។

កាលៈទេសៈរបស់សាច់ជាតិរបស់គាត់ គឺជារឿងពិសេសមួយ គេចង់ដឹងថា តើមានអ្វីកើតឡើងទៅនឹងជនរងគ្រោះទាំងអស់នោះ? តើគេប្រើប្រាស់វិធីសាស្ត្រធ្វើទារុណកម្មអ្វីខ្លះ? តើគេមានធ្វើការវាយសួរចម្លើយទេ? អ្នកណាជាវាយសួរចម្លើយ? ហើយរយៈពេលប៉ុន្មានដែលគេស្ថិតនៅក្នុងស-២១? តើគេមានលាក់បំបាំងព័ត៌មានណាពីយើងទេ? តើអ្នកទាំងអស់នោះបានស្រែកដង្ហើយហៅឲ្យយើងជួយទេ នៅពេលគេធ្វើទារុណកម្ម? តើគេសម្លាប់អ្នកទាំងអស់នោះដោយរបៀបណា? ហើយសម្លាប់នៅត្រង់ណា? ហេតុអីក៏ជ្រើសរើសអ្នកទាំងអស់នេះមកប្រព្រឹត្តអំពើអមនុស្សធម៌បែបនេះ?

[១១:០៣:៥០]

ការដែលសួរសំណួរបែបទាំងអស់នេះ គឺដោយសារការធ្វើទារុណកម្មមិនអាចធ្វើឲ្យយុត្តិកម្មបានទេ។ រឿងក្ដីនេះមិនអាចឆ្លើយតបទៅនឹងសំណួរនេះទេ ដូច្នេះការឈឺចាប់ គឺថាមិនអាចនឹងព្យាបាលជាសះស្បើយទាំងស្រុងបានទេ។ នៅក្នុងអ្នកដែលទទួលរងគ្រោះដោយផ្ទាល់ពីស-២១ សម្រាប់ឯអ្នកមិនផ្ទាល់ សម្រាប់អ្នកទាំងអស់នេះ គឺថាការស្វែងរកការពិត ការទទួលបានចម្លើយ គឺថាចង់បានចម្លើយទាំងអស់នោះ វានៅតែចោទ ជាៗការលងទៅដល់គាត់ទាំងអស់គ្នាជារៀងរាល់ថ្ងៃ ហើយធ្វើឲ្យគាត់គឺថាមានពិបាកក្នុងការសម្រាកប្រចាំថ្ងៃផងនោះ។

ការដកសិទ្ធិសេរីភាពរបស់គាត់ជាប្រចាំថ្ងៃនេះ គឺថាដើមបណ្តឹងរដ្ឋប្បវេណី សូមឲ្យបង្ហាញនូវការពិតទាក់ទងទៅនឹងសាច់ញាតិរបស់គាត់ ដែលបានស្លាប់បាត់បង់ជីវិតទៅហើយ តាមព័ត៌មាន ដែលតាមអាចធ្វើទទួលទៅបាន។ ដើម្បីបង្កើតឡើងវិញនូវសេចក្តីនូវសាច់ញាតិរបស់គាត់ ដើម្បីឲ្យការរស់នៅរបស់គាត់ គឺថារស់នៅដោយមិនមានភ័យខ្លាច។

កូនក្តីរបស់យើងខ្ញុំទាំងអស់មិនបានផ្តល់សក្ខីកម្មទាំងអស់គ្នាជូនតុលាការទេ។ ប៉ុន្តែរឿងរ៉ាវរបស់គាត់ គឺថាមិនបានបង្ហាញជូនដល់សាធារណជនក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់គ្នាទេ។ ហេតុដូច្នេះយើងខ្ញុំ សូមជម្រាបជូនអំពីកូនក្តីរបស់យើងខ្ញុំដូចតទៅនេះ។

លោក ហាត ឡូន កើតនៅឆ្នាំ១៩០០ គឺថាគាត់មានអាយុបីឆ្នាំនៅពេលដែលឪពុករបស់គាត់ចូលរួមជាកងទ័ពខ្មែរក្រហម។ នៅក្នុងឆ្នាំ២០០៦ គាត់ដឹងថាឪពុករបស់គាត់ត្រូវបានគេសម្លាប់នៅស-២១ ហើយគាត់មិនបានដឹងព័ត៌មានបន្ថែមទៀតក្រៅពីនោះទេ។ ហើយគាត់ចង់ស្វែងរករូបថតរបស់ឪពុកគាត់ ហើយពេលដែលគាត់ឃើញ គឺថាគាត់មានការរន្ធត់យ៉ាងខ្លាំង។ គាត់ចង់ចូលរួមជា ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីទទួលបានព័ត៌មានច្រើនអំពីឪពុករបស់គាត់ដែលគេសម្លាប់នៅស-២១។ ជនរងគ្រោះម្នាក់ទៀត ក៏ត្រូវចាប់នៅឆ្នាំ១៩៧៦ គឺថ្ងៃដែលគេបានចាប់និងសម្លាប់ខ្លួន ដោយការរស់នៅមិនមានឪពុកជួយឧបត្ថម្ភគាំទ្រជីវិតគាត់កំពុងតែជួបប្រទះការលំបាកយ៉ាងខ្លាំង ជាពិសេសនៅក្នុងប្រទេសកម្ពុជា។ ទោះបីជាគាត់ចូលរួមក្នុងសវនាការជាច្រើន ដឹងអំពីដំណើរការ ប្រតិបត្តិការនៅស-២១ គាត់ចង់ដឹងសេចក្តីស្មោះត្រង់របស់ឪពុកគាត់ ហើយគាត់មិនចង់ឲ្យការឈឺចាប់ទាំងអស់នេះកើត មានជាប្រចាំថ្ងៃមកលើគាត់ទេ។

ជនរងគ្រោះម្នាក់ទៀត គឺគាត់បានវាយជាមួយនិងកងទ័ព លន់ នល់ ហើយគាត់ត្រូវបានចាប់ខ្លួននៅក្នុងខែមីនា-- ឆ្នាំ១៩៧៧ កងទ័ព កងពល៧០៣ គឺថាត្រូវបានគេចាប់ខ្លួនជាច្រើន។ គាត់មានការភ័យខ្លាចយ៉ាងខ្លាំងដែលថា គាត់ថ្ងៃណាមួយនឹងត្រូវគេចាប់ខ្លួនហើយនិងសម្លាប់។ ហើយលោក ស៊ឹម អឿនដែលនិងត្រូវជាក្មួយប្រុសរបស់លោក គង់ ផល្លា ដែលអ្នកទាំងពីរនេះគឺថាបានវាយប្រយុទ្ធរួមគ្នា ត្រូវបានគេចាប់មកស-២១ និងសម្លាប់នៅស-២១ ដោយមិនដឹងថាហេតុអីបានជាគាត់អាចរស់រានមានជីវិតបាន ដែលយុទ្ធជនមកពីកងទ័ព កងពល៧០៣ នេះគឺថាបានស្លាប់យ៉ាងច្រើន។ គាត់កំពុងតែស្វែងរកយុត្តិធម៌សម្រាប់ខ្លួនគាត់នេះ។

លោកស្រី ហឿង សែ រៀបការជាមួយនិង អេង ម៉ាត នាងមានកូនបី។ កូនប្រុសមួយ និងកូនស្រីពីរ។ ប្តីរបស់គាត់ គឺត្រូវជាអនុប្រធានពាណិជ្ជកម្ម ហើយត្រូវបានគេយកទៅមន្ទីរអប់រំកែប្រែ។ គាត់មិនបានជួបប្តីគាត់ម្តងទៀតទេ ពេលដែលគេចាប់ខ្លួនទៅគឺចាប់នៅថ្ងៃទី១៣ ខែតុលា ១៩៧៦ នៅក្នុងអគារ(ខ) បន្ទប់តូចលេខ៥ ហើយគាត់មានលេខអ្នកទោសហ្នឹងលេខ២៤។ លោកស្រី សែ គាត់ដឹងថា គាត់អានទស្សនាវដ្តីស្វែងរកការពិត ទើបបានដឹងថាប្តីរបស់គាត់ស្លាប់នៅស-២១។ សម្រាប់រយៈដប់ប្រាំឆ្នាំដែលគាត់រស់នៅ គឺថាថ្ងៃណាមួយគាត់នឹងបានដឹងរឿងហ្នឹងនូវចំពោះការស្លាប់របស់ប្តីគាត់នៅស-២១។ ហើយគាត់ចង់ដឹង ប៉ុន្តែការប្រព្រឹត្តមកលើប្តីគាត់នោះ គឺគាត់មិនបានដឹងទេ លោកស្រីរស់នៅជាស្ត្រីមេម៉ាយអស់រយៈពេលយ៉ាងយូរក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនគាត់។ តាំងពីគាត់បាត់បង់ប្តីគាត់ទៅ គាត់មានជំងឺជាប្រចាំកាយ ហើយមិនអាចជាសះស្បើយវិញបានឡើយ។ គាត់មានការឈឺចាប់ គាត់ខំប្រឹងប្រែងតស៊ូដើម្បីជីវិតរបស់គាត់។

ខ្ញុំចង់លើកឡើងអំពីលោកស្រី អ៊ាម សយ គាត់បាត់បង់ប្អូនប្រុសរបស់គាត់នៅស-២១ ដែលប្អូនប្រុសចូលរួមជាមួយខ្មែរក្រហមឆ្នាំ៧៣ ជាកងទ័ព នៅកងពល៣១០ នៅ-- ហើយអ្នកទាំងពីរនេះគឺអាចរស់រានមានជីវិតរហូតដល់៤ មករា។ នៅពេល ឈ្មោះគាត់បាន ត្រូវបានគេរកឃើញនូវ-- គេសួរចម្លើយនៅ ស-២១។ គាត់មានលេខ *(អ្នកបកប្រែ៖ សូមលោកប្រធាន មេត្តាជួយសម្រួលលឿនពេក)*។

**ប្រធានអង្គជំនុំ៖**

លឿន១ពេក សុំសម្រួលនិយាយឲ្យបានយឺតជាងនេះ ដើម្បីអាចបកប្រែទាន់ ដែលអ្នកបកប្រែឃើញថាលឿនណាស់ន៎ែ។ លោកមេធាវី ខ្ញុំសូមសម្រួលឲ្យយឺតជាងនេះ ដើម្បីអាចបកប្រែបាន ហើយសូមបកសារឡើងវិញលើចំណុចបីឃ្លា ឬបួនឃ្លាមុនដែល--មុននេះ។

**លោកស្រី ស៊ីលឃី ស្ទួតហ្ស៊ីនស្គី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចាប់ផ្តើមជាមួយនិងអ្នកស្រី អ៊ាម សយ គាត់បាត់បង់ប្អូនប្រុសរបស់គាត់នៅស-២១។ ប្អូនប្រុសគាត់ចូលរួមជាមួយខ្មែរក្រហមនៅឆ្នាំ៧៣ ហើយចូលធ្វើជាកងទ័ពខ្មែរក្រហមនៅកងពល៣១០ គាត់ចាប់ខ្លួននៅខែមករា ឆ្នាំ-- ហើយរស់រានមានជីវិតរហូតដល់ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅពេលឈ្មោះគាត់ត្រូវបានរកឃើញនៅស-២១។ គាត់មានលេខអ្នកទោស លេខរៀងទី៧ នៅបន្ទប់តូចលេខ២។ លោកស្រី អ៊ាម សយ គាត់បានដឹងថាប្អូនប្រុសរបស់គាត់ គឺត្រូវបានគេ

ដាក់នៅស-២១ ត្រូវគេសួរចម្លើយ និងសម្លាប់នៅទីនោះ។ គាត់មានការរន្ធត់ខ្លាំងណាស់ ប៉ុន្តែគាត់មិនបានទទួលព័ត៌មានអ្វីក្រៅពីនេះ ឲ្យលើសពីនេះទៀតទេ។ អ្នកស្រីមាន ការនឹកអាឡោះអាល័យដល់ប្អូនស្រី នឹកអាណិតអាសូរយ៉ាងខ្លាំង។ ហើយក្នុងនាមជាបងស្រី អ្នកស្រីបានជួយចិញ្ចឹមគាត់ឲ្យក្លាយទៅជាបុរសម្នាក់ដែលសុភាពរាបសា តាំងពីការបាត់ខ្លួនរបស់ប្អូន ប្រុសគាត់ ក្រុមគ្រួសាររបស់គាត់ គឺថាគាត់មានការអស់សង្ឃឹម ហាក់បីដូចជាខ្លួនមនុស្សដែលត្រូវបាត់ បង់អវៈយវៈ មានតែដងខ្លួនអ៊ីចឹង។ គាត់ក៏បានចោទសួរថាហេតុអីក៏គាត់ស្រឡាញ់ប្អូនប្រុសគាត់ដែលត្រូវគេសម្លាប់ម្ល៉េះ បើទោះបីណាគាត់ដឹងថា ត្រូវបានគេសម្លាប់យ៉ាងខុសច្បាប់យ៉ាងនេះ ហើយដោយវាមានជាប់ទាក់ទងអ្វីទៅនឹងការពិតអ្វីទាល់តែសោះ។

[១១:១១:២០]

ឥឡូវនេះ ខ្ញុំសូមចូលមកដល់លោកស្រី ស៊ឹម លៀងស៊ា ដែលគាត់បានស្វែងរកយុត្តិធម៌ដើម្បីបងប្រុសរបស់គាត់ឈ្មោះ សិទ្ធិ ជុំលីម។ ប្ដីរបស់គាត់បានចូលរួមជាមួយនិងបដិវត្តន៍នៅឆ្នាំ១៩៧០ ក្នុងនាមជាអនុប្រធានពាណិជ្ជកម្ម។ ប្តីគាត់បានបាត់ខ្លួននៅខែមិថុនា ឆ្នាំ១៩៧៧ ហើយត្រូវបានគេចាប់ខ្លួននៅថ្ងៃទី២២ សីហា ឆ្នាំ៧៧។ ប្អូនស្រីរបស់គាត់ឈ្មោះ ស៊ឹម ជុំលីម ក៏ត្រូវបានចាប់ខ្លួនមកស-២១ ប្រាំឆ្នាំក្រោយមក ប្អូនស្រីរបស់គាត់រស់នៅជាមួយគាត់ រស់នៅជាមួយប្តីគាត់ទាំងអស់គ្នា អ្នកទាំងពីរគឺថាហាក់បីដូច ដើរតួហាក់បីដូចជាឪពុកម្តាយដោយផ្តល់ការអប់រំ ផ្តល់ដំបូន្មាន និងផ្តល់សេចក្តីស្រឡាញ់ទៅដល់ប្អូនស្រីរបស់គាត់។

នៅពេលដែលអ្នកទាំងអស់នោះបានបាត់ខ្លួន អ្នកស្រីបានរស់នៅតែឯកោ តែឯង គាត់នឹកទៅដល់ប្អូនស្រីរបស់គាត់ នឹកប្អូនសាច់ថ្លៃ គាត់ក៏បានសួរថាហេតុអីក៏គាត់នឹកអាឡោះអាល័យទៅដល់សាច់ញាតិរបស់គាត់ទាំងអស់នេះខ្លាំងម្ល៉េះ។ គាត់ចង់ផ្តល់កិត្តិយសទៅដល់សាច់ញាតិរបស់គាត់។ ប៉ុន្តែ គាត់នៅតែចង់ស្វែងរកអំពីជោគវាសនារបស់អ្នកទាំងអស់នោះនៅស-២១។

ឥឡូវនេះ ខ្ញុំសូមចូលដល់លោកស្រី ហុង សាវ៉ាត។ គាត់គឺជាគ្រូ ហើយដែលត្រូវបានគេទទួលស្គាល់យ៉ាងច្រើន ទទួលស្គាល់នៅក្នុងភូមិ។ អ្នកស្រីចំណាយពេលវេលាយ៉ាងច្រើនជាមួយ នៅក្នុងផ្ទះរបស់ឪពុកមាររបស់គាត់។ នៅពេលឪពុកមាររបស់គាត់បាត់ខ្លួន គាត់មានការនឹកទៅដល់បុរសគួរជាទីស្រឡាញ់ និងប្រកបទៅដោយភាពវៃឆ្លាតណាស់។ នៅក្នុងឆ្នាំ២០០៨ នៅពេលដែលគាត់បានឃើញ

រូបថតនៅទួលស្លែង គាត់បានស្រែកយំ ហើយមានការធុញថប់អារម្មណ៍យ៉ាងខ្លាំង ដោយគាត់គិតថាគាត់ទទួលរងការធ្វើទារុណកម្មយ៉ាងណាទៅវិញដែរ។

[១១:១៣:៣២]

អ្នកស្រីមិនអាចគិតថាតើ គាត់មានប្រព្រឹត្តអ្វីខុសទេ។ សំណួរនេះ គឺថាវាតាមលងគាត់ម្តងហើយម្តងទៀត ដែលមិនអាចឲ្យគាត់គិតទៅបានថាហេតុអ្វីបានជាគាត់ចាប់គាត់ ហើយចាត់ទុកគាត់ថាជាខ្មាំង ហើយយកគាត់មកធ្វើជា-- មកធ្វើការសួរចម្លើយ ធ្វើទារុណកម្មដោយខុសច្បាប់បែបនេះ។

ឥឡូវនេះ សុំចូលទៅដល់អ្នកស្រី ប៉ែន សុខែន គាត់បាត់ប្អូនស្រីរបស់គាត់ដែលមានអាយុក្មេងជាងគាត់បីឆ្នាំនៅស-២១។ នៅពេលមានអាយុ២២ ប្អូនស្រីរបស់នាងគឺត្រូវបានរៀបការ ហើយក្រោយមកគេចាប់មកស-២១។ គាត់បានទទួលព័ត៌មានរឿងប្អូនស្រីរបស់គាត់នៅឆ្នាំ១៩៩០ តាមរយៈរូបថតដែលគាត់បានឃើញនៅស-២១។ ហើយស-២១ នេះគឺត្រូវបានគេ រូបថតនោះគេឮរផ្កាប់ក្បាលចុះមកក្រោម។ លោកស្រី ប៉ែន សុខែន គាត់-- រូបថតនេះគឺថាបានតាមលងគាត់ជារៀងរហូត។ គាត់គិតថាគាត់មានការឈឺចាប់យ៉ាងខ្លាំងនៅពេលគាត់គិតថា តើប្អូនស្រីរបស់គាត់ទទួលរងការឈឺចាប់ធ្ងន់ប៉ុនណាទៅទាក់ទងទៅនឹងការឈឺចាប់ និងភាពគួរឲ្យរន្ធត់ដែលប្អូនស្រីរបស់គាត់ទទួលរងការធ្វើទារុណកម្មនេះ។

អ្នកស្រី ប៉ែន សុខែន គាត់ថាមិនបានទទួលព័ត៌មានអ្វីក្រៅពីនេះក្រៅពីនេះ ថាតើប្អូនស្រីរបស់គាត់ត្រូវបានគេធ្វើទារុណកម្មសម្លាប់ដោយរបៀបណា? ទោះបីជាគាត់បានចូលរួមនៅក្នុងដំណើរការនីតិវិធីជាច្រើនលើកច្រើនសាមកហើយក៏ដោយ។ ហើយជាពិសេសគាត់ចង់ដឹងថាតើប្អូនស្រីរបស់គាត់ហ្នឹងត្រូវបានគេសម្លាប់នៅថ្ងៃណា? ហើយលើសពីនេះគាត់មានទុក្ខសោកយ៉ាងខ្លាំង ដែលគាត់មិនបានរៀបចំពិធីបូជាសពដើម្បីឲ្យមានភាពស្និទ្ធស្នាលទាក់ទងទៅជាមួយនឹងបុព្វការីជន តាមបែបព្រះពុទ្ធសាសនា។

ឥឡូវនេះ ខ្ញុំសូមចូលមកដល់អ្នកស្រី ញិប គឹមស្រ៊ា ដែលកើតនៅឆ្នាំ១៩៧៨ ហើយគាត់បាត់បង់ឪពុកមាររបស់គាត់ឈ្មោះ ជៀប បារ៉ូ ហើយនិងភរិយារបស់គាត់ ព្រមទាំងកូនប្រាំនាក់នៅស-២១។ គាត់ជាយុទ្ធជននៅកងពលលេខ៤៥០។ គាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៩ កុម្ភៈ ៧៧។ បើទោះបីជា អ្នកស្រីមិនបានដឹងថាតើឪពុកមា ហើយនិងក្រុមគ្រួសាររបស់គាត់ ក៏អ្នកស្រីក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីបានដឹងពីឪពុកម្តាយ អំពីជោគវាសនារបស់ក្រុមគ្រួសាររបស់ឪពុកមាគាត់ ហើយជាពិសេសការ

ឈឺចាប់ដែលឪពុកម្តាយរបស់គាត់បានទទួលរងនេះ។ ការបាត់បង់សមាជិកគ្រួសារដ៏ច្រើន ហើយនិងភាពគួរឲ្យរន្ធត់ដែលកើតមាននៅស-២១ គឺថាគាត់ធំធាត់ឡើងដោយតែម្នាក់ឯង រស់នៅជាមួយនិងម្តាយមីង។

[១១:១៦:៣៧]

ខ្ញុំសូមលើកឡើងអំពីលោកស្រី លាង ខន គាត់បាត់បង់ក្តីប្រុសរបស់គាត់លោក នាម ឆឹយ ដែលជាប់ឃុំ និងសម្លាប់ចោលនៅមន្ទីរស-២១។ រហូតដល់ឆ្នាំ១៩៧៥ គាត់រស់នៅជាមួយនឹងគ្រួសាររបស់គាត់ រួមទាំងក្តីប្រុសរបស់គាត់នៅភូមិអង្គរជ័យ ហើយរស់នៅធំធាត់ជាមួយនិងគាត់។ គាត់ដូចជាបងប្រុសរបស់លោកស្រីដូច្នេះដែរ ហើយគាត់មានទំនាក់ទំនងល្អជាមួយនឹងគាត់ ហើយគាត់ស្រឡាញ់លោកនោះខ្លាំងណាស់។ ក្រោយមកអ្នកទាំងពីរត្រូវបានគេបំបែក ហើយក្តីប្រុសរបស់គាត់ត្រូវបានគេចាប់ចូលទ័ពខ្មែរក្រហម តែពួកគេព្យាយាមជួបដោយសម្ងាត់ ហើយគាត់នៅចាំយ៉ាងល្អអំពីពេលដែលគេចាប់-- ពេលដែលលោកស្រីជួបគាត់ និងគាត់បានជម្រាបលោកស្រីអំពីផែនការរបស់ខ្មែរក្រហម។

លោកស្រី លាង ខន មានការភ្ញាក់ផ្អើល និងតក់ស្លុតនៅពេលដែលគាត់ឃើញរូបថតនៅទួលស្លែងនៅក្នុងឆ្នាំ២០០៨ ដែលនៅក្នុងនោះគាត់ឃើញមានពាក់ស្លាកលេខ៥៦៧។ លោកស្រីមានការតក់ស្លុត ហើយព្រួយបារម្ភរបស់គាត់នៅស-២១។ គាត់មិនបានទទួលព័ត៌មានអំពីជនរងគ្រោះនោះទេនៅក្នុងកិច្ចដំណើរការនីតិវិធី។ ដោយសារតែកង្វះព័ត៌មាន គាត់នៅតែរស់នៅដោយគ្មានភាពប្រាកដប្រជា។ រូបភាពក្តីប្រុសរបស់គាត់ គាត់គួរតែមិនបានឃើញនៅក្នុងសំលៀកបំពាក់ នូវសម្លៀកបំពាក់ដែលមានលេខ៥៦៧ នៅមន្ទីរស-២១។

ទាំងអស់នេះ គឺជារឿងរ៉ាវរបស់កូនក្តីរបស់ខ្ញុំដែលគាត់មិនមានឱកាសក្នុងការជម្រាបទៅដល់តុលាការ។ ប៉ុន្តែ ពួកគាត់គួរតែធ្វើការសម្តែងជាសាធារណៈដើម្បីរំឭកវិញ្ញាណក្ខន្ធ និងលើកកិត្តិយសអ្នកដែលជាទីស្រឡាញ់របស់ពួកគេ ដែលទទួលរងទារុណកម្ម ដែលត្រូវបានប្រព្រឹត្តធ្វើបាប ហើយចុងក្រោយត្រូវបានសម្លាប់នៅមន្ទីរស-២១។

ឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តដោយជនជាប់ចោទធ្វើឲ្យគ្រួសារទាំងអស់នោះមានភាពបាក់បែក។ ហើយពួកគេនៅតែមានភាពភ័យខ្លាចជារៀងរាល់ថ្ងៃ។ យើងខ្ញុំមិនលើកឡើងអំពីរឿងលោក ប៊ូ ម៉េង និង ជុំ ម៉ី ទេ ប៉ុន្តែខ្ញុំនឹងរៀបរាប់បន្ថែមទៅលើសាក្សី ណាំ ម៉ុន។ អ្នកដែលរស់រានមានជីវិតទាំងអស់ នេះ

បានចូលរួមផ្តល់ជាភស្តុតាង ហើយផ្តល់ជាពន្លឺអំពីកិច្ចការងារនៅមន្ទីរស-២១។

សាក្សី ជនរងគ្រោះមិនផ្ទាល់ ដែលបានបាត់បង់គ្រួសារផងដែរនៅមន្ទីរ ស-២១ ដូចជាលោកស្រី ឈិម ណារី លោក ជុំ ស៊ីវ៉ាត់ លោកស្រី ភីង ហ្គុតស៊ុនថារី និងម្តាយរបស់គាត់ អ៊ឹម សុធី និងលោក ស៊ាង វ៉ាន់ឌី បានចូលរួមលើកឡើងអំពីផលវិបាកដែលឧក្រិដ្ឋប្រព្រឹត្តដោយជនជាប់ចោទ វាបានមាន និង មានឥទ្ធិពលទៅលើពួកគាត់ ហើយវាជាគំរូមួយសម្រាប់សង្គមកម្ពុជា។

សក្ខីកម្មទាំងអស់នេះមាន ពោរពេញទៅដោយអារម្មណ៍ ហើយមានការតក់ស្លុត។ ពួកគេបាន បង្ហាញអំពីការឈឺចាប់ដែលនៅបន្តមាននៅលើពួកគេអស់រយៈពេលជាងសាមសិបឆ្នាំ ក្រោយពីឧក្រិដ្ឋ-កម្មកើតឡើង។ ពួកគេកំពុងតែស្វែងរកយុត្តិធម៌តាមរយៈចង់ឲ្យមានការលាតត្រដាងការពិតចំពោះអ្នក ដែលជាទីស្រឡាញ់របស់ពួកគេ ហើយធ្វើការស្វែងរកការពិតអំពីរបៀបគ្រប់គ្រងនៃរបបខ្មែរក្រហម ហើយជាពិសេសអំពីប្រព័ន្ធនៃសន្តិសុខនិងការឃុំខ្លួន។

[១១:២០:០៧]

ដើមបណ្តឹងរដ្ឋប្បវេណីបានបំពេញសិទ្ធិចូលរួមរបស់ខ្លួន ដើម្បីទទួលបានគោលបំណងដ៏សំខាន់ នេះ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សក្ខីកម្មមានការពេញចិត្តដែលសាលាដំបូងបានផ្តល់សិទ្ធិឲ្យ ពួកគេសម្តែងអំពីបទពិសោធន៍របស់ពួកគេ។ ប៉ុន្តែពួកគេមានការភ័យខ្លាច។ ដូច្នេះ ធ្វើឲ្យពួកគេចាំតិច តួចទៅលើព្រឹត្តការណ៍ជាក់ស្តែង។ ប៉ុន្តែ អ្នកមួយចំនួនមិនមានការទទួលស្វាគមន៍ដោយអង្គជំនុំជម្រះ សាលាដំបូង ហើយខ្ញុំនឹងពន្យល់ចំណុចនេះ។

ពួកគេយល់ឃើញថា សាលាដំបូង គឺមិនបានទទួលយកការឈឺចាប់របស់ពួកគេ។ ដើមបណ្តឹង រដ្ឋប្បវេណីបានផ្តល់សក្ខីកម្មនៅក្នុងខែសីហា មិនទទួលបានការអរគុណទាល់តែសោះចំពោះការចូលខ្លួន របស់ពួកគេ ទោះបីចំណុចនេះមានការថ្លែងអំណរគុណទៅដល់សាក្សីនានា អ្នកជំនាញនិងដើមបណ្តឹង រដ្ឋប្បវេណីដែលផ្តល់សក្ខីកម្មក្នុងខែកក្កដា។

ពាក្យថា "អរគុណ" គឺជាពាក្យតែពីរម៉ាត់ប៉ុណ្ណោះ ប៉ុន្តែវាមានន័យយ៉ាងច្រើន ពួកគេត្រូវបាន ចាត់ទុកជាសាក្សីបម្រុង ហើយបានកោះហៅមកផ្តល់សក្ខីកម្មចំពោះរឿងក្តីមួយចំនួន ដូចលោកស្រី ភីង ស៊ុនថារី ម្តាយរបស់គាត់ អ៊ឹម សុធី ដែលបានមកទីនេះ ដោយទទួលបានការជូនដំណឹងតិចតួចតែ ប៉ុណ្ណោះ មិនមានការរៀបចំត្រឹមត្រូវ ហើយមិនមានការចាប់អារម្មណ៍ពីសាលាដំបូង។ ហើយអ្នក ទាំងពីរមិនមានការគេងឲ្យបានគ្រប់គ្រាន់ទេ ពេលដែលពួកគេមកទីនេះ។ ហើយពួកគេមិនបានរៀបចំ

បានត្រឹមត្រូវដោយសារតែករណីទាំងអស់នេះ ហើយនិងករណីនេះ គឺដោយសារពួកគេមានការភ័យខ្លាច ប៉ុន្តែយ៉ាងណាក៏ដោយពួកគេព្យាយាមដើម្បីកុំឲ្យបាត់បង់ឱកាសនៅទីនេះ នៅពេលដែលពួកគេមកផ្តល់សក្ខីកម្ម។ ហើយមិនមានអ្នកជំនាញទាំងឡាយ ត្រូវបានទទួលការរាក់ទាក់-- មិនមានអ្នកជំនាញទាំងឡាយទទួលការប្រព្រឹត្តដូចដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

ដើមបណ្តឹងរដ្ឋប្បវេណីផ្តល់ចម្លើយនៅក្នុងខែសីហា បានកត់សម្គាល់ឃើញអំពីសំណួរទាំងឡាយដែលអង្គជំនុំជម្រះសួរ។ ប៉ុន្តែយ៉ាងណាក៏ដោយមានរយៈពេលមួយភាគបីប៉ុណ្ណោះ ដើម្បីធ្វើការសួរសំណួរទៅដល់ភាគី។ ប៉ុន្តែយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានបង្គាប់ឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីធ្វើការទប់អារម្មណ៍យំខ្សឹបខ្សួលរបស់ខ្លួននៅពេលផ្តល់សក្ខីកម្ម។ ហើយពួកគេបានធ្វើការគ្រប់គ្រងទៅលើអារម្មណ៍របស់ពួកគេ បើសិនមិនដូច្នេះទេ ពួកគេនឹងគ្មានឱកាសផ្តល់ឡើយ។

[១១:២២:៥៦]

អង្គជំនុំជម្រះសាលាដំបូងដែលធ្វើការកម្រិតទៅលើអារម្មណ៍របស់ពួកគេនេះ គឺមិនបានជួយទៅដល់ការរៀបរាប់របស់ពួកគេទេ តែវាធ្វើឲ្យពួកគេកាន់តែបាក់ស្បាត។ ការបង្ហាញចំណុចទាំងអស់នេះគឺវាកើតចេញពីលទ្ធផលនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយជនជាប់ចោទ ដូច្នេះហើយវាជាការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការដាក់ទោសឲ្យបានសមស្រប។

ហើយលោក ប៊ូ ម៉េង ត្រូវបានអង្គជំនុំជម្រះ គឺលោកប្រធានឲ្យបង្ហាញស្លាកស្នាមនៅលើខ្នងរបស់គាត់ជាសាធារណៈ ដោយមិនគោរពទៅលើសេចក្តីថ្លៃថ្នូរ និងភាពឯកជនរបស់គាត់។ ប៉ុន្តែ គាត់មិនមានការប៉ាននក្នុងការបដិសេធទេ ដែលគាត់ត្រូវគោរពទៅលើចៅក្រមនៅក្នុងអង្គជំនុំជម្រះនេះ។ ដើមបណ្តឹងរដ្ឋប្បវេណីចង់ដឹងការពិត ពួកគេចង់ធ្វើការសាកសួរទៅលើសាក្សី និងជនជាប់ចោទថា តើហេតុអ្វីបានជាជនជាប់ចោទបានប្រព្រឹត្ត និងមិនលាតត្រដាងទៅលើអ្វី ដែលវាជាលក្ខខណ្ឌនៃការឃុំខ្លួននៅពេលនោះ។

បន្ថែមទៅលើចំណុចនេះ ដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា តុលាការមិនអនុវត្តភារកិច្ចយកចិត្តទុកដាក់ចំពោះពួកគេនោះទេ ពួកគេមិនមានអារម្មណ៍ទទួលការការពារនៅពេលមេធាវីជាតិ ការពារជាតិ ការពារក្តីជាតិបានស្រែកគំហកដល់ពួកគេ ហើយឲ្យពួកគេផ្លាស់ប្តូរ-- ហើយគាត់មិនបានផ្លាស់ប្តូរនូវអត្តចរិតរបស់គាត់នៅពេលដែលគាត់ពន្យល់ថា វាជាបញ្ហា ឬក៏អាប្បកិរិយាធម្មតារបស់គាត់។ ហើយពួកគេមិនមានការយកចិត្តទុកដាក់ពីលោកប្រធាន នៅពេលដែលជនជាប់ចោទធ្វើការម៉ាក់ងាយ

ទៅលើពួកគេ។ ប៉ុន្តែ ចំណុចម៉ាក់ងាយនេះមិនត្រូវបានបកប្រែជាភាសាអង់គ្លេស ឬបារាំងនោះទេ។

ដើមបណ្តឹងរដ្ឋប្បវេណីមិនមានអារម្មណ៍ថា ទទួលបានការការពារនៅពេលដែលពួកគេផ្តល់សក្ខីកម្ម ដូច្នេះហើយពួកគេយល់ឃើញថា មិនទទួលបានការគោរពសមស្រប ឬក៏ស្មើគ្នាទៅនឹងសាក្សីដទៃ សាក្សីអ្នកជំនាញ និងជនជាប់។ ថាតើការឈឺចាប់របស់ពួកគេមានការលំបាកក្នុងការទ្រាំដែរឬទេ?

នៅចុងក្រោយ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានដកចេញមិនឱ្យសួរសំណួរទៅកាន់សាក្សីទៅលើអត្តចរិត រួមទាំងអ្នកជំនាញចិត្តសាស្ត្រ និងផ្លូវចិត្ត ហើយក៏មិនអនុញ្ញាតឱ្យធ្វើការសាកសួរ និងលើកយោបល់ទាក់ទងទៅនឹងការដាក់ទោសសមស្របផងដែរ ដែលនេះជាចំណុចល្អមួយក្នុងការស្វែងរកយុត្តិធម៌។

[១១:២៥:៤០]

ដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា ពួកគេបានដកសិទ្ធិចូលរួមដែលវិធានផ្ទៃក្នុងនិងច្បាប់មិនបានកម្រិតសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីក្នុងការសាកសួរសាក្សី អ្នកជំនាញ ឬក៏ដាក់សេចក្តីសន្និដ្ឋានទៅលើការដាក់ទោសនោះទេ។ បន្ទាប់ពីការបានទទួលហេតុផលនៃសេចក្តីសម្រេចទាំងអស់នេះ ពួកគេមិនឃើញថាមានមូលដ្ឋានត្រឹមត្រូវអនុលោមតាមវិធានផ្ទៃក្នុងនិងច្បាប់នោះទេ។ ផ្ទុយទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលមិនទទួលបានការគោរព អ្នកផ្សេងទៀតគាត់បានអះអាងថា លោកប្រធាន ឬក៏ចៅក្រមគួរតែអរគុណពួកគេ ហើយការពារពួកគេ។ មោទនភាពចំពោះខ្លួនឯងនេះ គឺធ្វើឱ្យពួកគេទទួលបានក្នុងកម្រិតទាប ដែលធ្វើឱ្យពួកគេមិនមានភាពក្លាហាន ជឿជាក់ ហើយពួកគេគួរតែទទួលបាននូវចំណុចទាំងអស់នេះ។

ទោះបីជាមានចន្លោះប្រហោង ដែលយើងបានលើកឡើងនេះក៏ដោយ ដើមបណ្តឹងរដ្ឋប្បវេណីថ្លែងអំណរគុណចំពោះឱកាស ដែលផ្តល់ឱ្យពួកគេក្នុងការរៀបរាប់រឿងរ៉ាវនៅចំពោះមុខតុលាការនេះ ហើយមានការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គសវនាការ។

នៅទីនេះ ខ្ញុំសូមលើកចម្លើយរបស់លោកស្រី ណាំ ម៉ុន ចម្លើយរបស់គាត់គួរតែចាប់អារម្មណ៍ឱ្យបានច្រើន ហើយត្រូវតែវិភាគអំពីភាពជឿជាក់នៃចម្លើយរបស់គាត់។ ជាលើកដំបូង គាត់បានលាតត្រដាងនៅចំពោះអង្គជំនុំជម្រះសាលាដំបូងនៅរឿងរ៉ាវរបស់គាត់។ គាត់ជម្នះរាល់ឧបសគ្គទាំងឡាយ ហើយគាត់ព្យាយាមពង្រឹងកម្លាំងពលំរបស់គាត់មិននៅស្ងៀមទៀតទេ ក្រោយពីសាមសិបឆ្នាំដែលគាត់បានធ្វើការងារជាពេទ្យនៅមន្ទីរស-២១ ក្នុងវ័យអាយុ១៥ឆ្នាំ ហើយដែលនៅពេលនោះបងប្រុសរបស់

គាត់ពីររូបជាអ្នកយាមនៅមន្ទីរគុក។

បន្ថែមទៅលើនេះ គាត់រៀបរាប់អំពីពូរបស់គាត់ អឿន ដែលជាមេកងពល៣១០ និងពូកេត ដែលគាត់នៅខាងក្រោមន្ទីរស-២១។ ដែលលោកស្រីបានពិនិត្យឃើញទៅលើព្រឹត្តការណ៍ទាំងអស់នេះ ពីអគារ “ខ”។ ក្រោយមក លោកស្រីត្រូវបានគេចាប់ខ្លួនសួរចម្លើយ ធ្វើទារុណកម្ម ហើយរំលោភមុន ពេលបញ្ជូនទៅស-២៤។ ឪពុកម្ដាយនិងប្អូនប្រុសរបស់គាត់ត្រូវបានគេសម្លាប់នៅស-២១។ ហើយគាត់ បានឮផងដែរថា បងរបស់គាត់ឈ្មោះ រឿន ត្រូវបានគេបង្គាប់បញ្ជាឲ្យវាយឪពុករបស់គាត់រហូត ដល់ស្លាប់។ តើរឿងរ៉ាវនេះគួរឲ្យជឿជាក់ដែរឬទេ? ថាតើលោកស្រីបានរៀបរាប់អំពីការពិតដែរឬទេ? ដើម្បីធ្វើការវិភាគទៅលើសក្ខីកម្មរបស់លោកស្រី យើងនឹងប្រើប្រាស់ឧបករណ៍ក្នុងការវាយតម្លៃភាព ជឿជាក់ទៅលើសក្ខីកម្មរបស់លោកស្រី។ ឧបករណ៍ ឬក៏យន្តការទីមួយ គឺយើងត្រូវពិចារណាអំពីភាព ជឿជាក់ តើយើងត្រូវមើលអំពីដើមហេតុ ឬក៏ប្រភពនៃរឿងរ៉ាវរបស់លោកស្រី។

ទាក់ទងទៅនឹងប្រភពនៃសក្ខីកម្មរបស់លោកស្រី និងការពន្យល់របស់លោកស្រី លោកស្រីបាន លើកឡើងថា គាត់ប្រាប់រឿងរ៉ាវនេះដោយមិនមានការភ័យខ្លាចឡើយ ដោយសារសមាជិកគ្រួសាររបស់ គាត់ធ្វើការនៅស-២១។ បន្ទាប់ពីបានចូលរួមនៅក្នុងសវនាការ គាត់បានទទួលការគាំទ្រ និងការជំរុញ ទឹកចិត្ត ដោយដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនទៀត ដែលធ្វើឲ្យគាត់និយាយដោយបើកចំហ ហើយលាត ត្រដាងអំពីអតីតកាល។ ដូច្នេះ ការពន្យល់ទាំងអស់នេះគឺជាចំណុចដែលយើងជឿជាក់។

ទីពីរ គឺជារបៀបនៃការរៀបរាប់នៃរឿងរ៉ាវរបស់លោកស្រី។ រឿងរ៉ាវរបស់លោកស្រី គឺរួមមក ជាមួយ ឬក៏ចងភ្ជាប់ជាមួយនូវអារម្មណ៍ និងអារម្មណ៍ដ៏លើសលប់ និងរំជើបរំជួល។ លោកស្រី បានលាតត្រដាងអំពីសេចក្ដីពិស្ដារ ដែលគាត់ឃើញផ្ទាល់ភ្នែក។ ការស្លាប់របស់ពូ លោកស្រី អឿន ដែលជាប្រធានកងពល៣១០ ហើយនិង ពូកេត នៅក្នុងកងពលដូចគ្នានេះ គឺជាចម្លើយមួយដែលគួរឲ្យ ជឿជាក់។

ទីបី សាក្សីអ្នកជំនាញខាងចិត្តសាស្ត្រ យើងគួរពិនិត្យពិចារណាទៅលើចំណុចទាំងអស់នេះ ដែល វាពិតជាមានហេតុផលនៅពីក្រោយ។ ហើយយើងឃើញថា លោកស្រីមិនមានចេតនាណាមួយក្នុងការ ប្រឌិតរឿងរ៉ាវទាំងអស់នេះទេ ហើយលោកស្រីក៏មិនទទួលបានអ្វីដែរ ប្រសិនបើលោកស្រីដាក់បន្ទុកទៅ លើជនជាប់ចោទនៅក្នុងដំណាក់កាលចុងក្រោយនេះ។ លោកស្រីបានដាក់ជូននូវឯកសារជាច្រើនដែល គាំទ្រលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណី ដូច្នេះហើយវាមិនផ្ដល់ជាប្រយោជន៍អ្វីចំពោះឋានៈលោកស្រី

ជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

បន្ថែមទៅលើចំណុចនេះ លោកស្រីមិនមែនបង្កើតរឿងរ៉ាវរបស់គាត់ ដោយសារការស្អប់ខ្ពើម ឬការខឹងសម្បានោះទេ។ គាត់និយាយក្នុងលក្ខណៈវិជ្ជមានទៅលើជនជាប់ចោទ ហើយរៀបរាប់គាត់ផងដែរថា ជាបុរសសង្ហាមួយរូបនៅពេលនោះ។ ចាតើលោកស្រី គាត់ធ្វើការដាក់បន្ទុកចុងចោទទៅលើចំណុចនេះឬយ៉ាងនេះ។

[១១:៣០:៥៦]

ចំណុចទីបួន លោកស្រីបានបន្ទុកខ្លួនឯង នៅពេលលោកស្រីបានរៀបរាប់ជូនតុលាការអំពីស្ថាប័នស្វយ័តនៅស-២១ ដែលលោកស្រីជាសមាជិក ហើយចូលរួមចំណែកធ្វើបាបអ្នកទោស។ ដែលនៅពេលនោះលោកស្រីនៅក្មេង។ ហេតុអ្វីបានជាលោកស្រីចាំបាច់ធ្វើការប្រថុយប្រថានក្នុងការទម្លាក់កំហុសមកលើខ្លួនឯង ប្រសិនបើវាមិនមែនជារឿងពិតទេនោះ។ ហើយប្រសិនបើលោកស្រីត្រូវបានគេចោទប្រកាន់ ការដែលលោកស្រីលាតត្រដាងទៅលើរឿងរ៉ាវរបស់លោកស្រីនេះ វាអាចធ្វើឱ្យខូចកិត្តិយសរបស់លោកស្រីនៅក្នុងភូមិរបស់លោកស្រី ហើយអាចមានការគេបណ្តេញចេញ លោកស្រីចេញពីភូមិទៀតផង។ ដូច្នេះហើយយើងគិតថាចម្លើយទាំងអស់នេះ គឺជាការពិត។

ទីប្រាំ ទាក់ទងទៅនឹងខ្លឹមសារនៃរឿងរ៉ាវរបស់លោកស្រី យើងមានភាពជឿជាក់ទៅលើចម្លើយទាំងអស់នេះ។ លោកស្រីបានផ្តោតទៅលើសមាជិកជាចម្បងនៅក្នុងគ្រួសាររបស់លោកស្រី ហើយលោកស្រីបានរៀបរាប់អំពីស្ថានភាពដ៏គួរឱ្យតក់ស្លុតនៅពេលដែលលោកស្រីនៅក្មេង។ ដូច្នេះ លោកស្រីមិនអាចទប់អារម្មណ៍ទាំងអស់នេះនោះទេ។ នៅពេលដែលលោកស្រីមិនអាចធ្វើការស្គាល់រូបថតរបស់ជនជាប់ចោទ ដែលថតនៅរបបខ្មែរក្រហមនោះ គឺវាមិនមែនអ្វីដែលយើងគួរសង្ស័យនោះទេ។ ទីមួយទាក់ទងទៅនឹងគុណភាពរូបថតនោះ ដែលវាមិនមានលក្ខណៈល្អ។ ទីពីរ គឺវាទាក់ទងទៅនឹងលទ្ធភាពរបស់បុគ្គលម្នាក់ចងចាំនូវរូបថតដែលបានថតសាមសិបឆ្នាំរួចមកហើយ។

ដូច្នេះ ហេតុផល សេចក្តីសន្និដ្ឋានដ៏សមហេតុផលគឺទាក់ទងទៅនឹងខ្លឹមសាររឿងរ៉ាវ របៀបដែលលោកស្រីរៀបរាប់ ហើយនិងព័ត៌មានពិស្តារទាំងអស់នេះ គឺវាមិនមែននាំឱ្យយើងយល់ថា ចម្លើយទាំងអស់នេះវាខុសនោះទេ។ វាជាចម្លើយជាក់ស្តែង ហើយវាជាចម្លើយមួយដែលមានភាពជឿជាក់ និងអាចទុកចិត្តបាន ហើយវាមានហេតុផលត្រឹមត្រូវ។

បន្ថែមទៅលើចំណុចនេះ នៅពេលដែលជនជាប់ចោទមិនធ្វើការឆ្លើយតបដោយផ្ទាល់មាត់ វាជា

ឥរិយាបថមួយដែលចម្លែក។ ផ្ទុយពីហ្នឹង ប្រតិកម្មរបស់គាត់ទៅលើសាក្សីផ្សេងៗ និងដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងៗ នៅពេលដែលលោកស្រី ណាំ ម៉ុន បានរៀបរាប់អំពីការចូលរួមដោយផ្ទាល់របស់ជនជាប់ចោទនៅក្នុងការសម្លាប់មិត្តភក្តិរបស់លោកស្រី និងកម្មាភិបាល អឿន និង កេត។ គាត់ ជនជាប់ចោទរូបនេះ គាត់បានមើលទៅលើពិដាន ហើយធ្វើដូចជាមិនចាប់អារម្មណ៍។ នៅក្នុងគុកក្នុងករណីទាំងអស់ ជនជាប់ចោទបានពិចារណា និងយកចិត្តទុកដាក់ចំពោះចម្លើយរបស់អ្នកផ្សេង។

[១១:៣៣:៤០]

បន្ថែមទៅលើចំណុចនេះ នៅពេលដែលលោកស្រីសួរថា តើលោកជនជាប់ចោទធ្វើការបដិសេធទៅលើរឿងរ៉ាវរបស់លោកស្រីឬយ៉ាងម៉េច? គាត់មិនបានឆ្លើយតបនោះទេ ហើយគាត់បានផ្ដល់ជាចម្លើយទូទៅលើតួនាទីរបស់គាត់ទៅលើឧក្រិដ្ឋកម្ម។ ដូច្នេះ គឺយើងឃើញថា ជនជាប់ចោទបានបដិសេធដោយដោយដាច់អហង្ការទៅលើការលើកឡើងទាំងអស់នេះ។ ហើយគាត់បានបដិសេធ ទោះបីជាគាត់មិនបានបដិសេធចំពោះការចូលរួមរបស់គាត់ទាំងស្រុងក៏ដោយ។ ដូច្នេះ យើងឃើញថាលោកស្រី ណាំ ម៉ុន គាត់បានលើកឡើងទៅលើចំណុចទាំងអស់នេះ ហើយគាត់បានពន្យល់ថា គាត់បានចូលទៅមន្ទីរស-២១ នេះ មុនពេលដែលបង្កើតមន្ទីរនេះទៅទៀត ដែលគាត់នៅពេលនោះ គឺគាត់ស្លៀកពាក់ដូចបុរសអីចឹង នៅពេលដែលទីតាំងនោះមិនទាន់បានបង្កើតឡើងដោយជនជាប់ចោទ។

ទាក់ទងទៅនឹងរូបថត នៃការស្លាប់របស់សមាជិករបស់របស់លោកស្រី លោកស្រីបានលើកឡើងជាច្រើនទៅលើចំណុចមួយចំនួន ហើយនិងរូបថតដែល រូបថតទាំងអស់នោះ វាស៊ីសង្វាក់ទៅនឹងភ័ស្តុតាងទាំងឡាយ។

[១១:៣៥:០០]

បន្ទាប់មកយើងឃើញថា ជនជាប់ចោទបានបន្តមិនឲ្យចាប់អារម្មណ៍លោកស្រី ណាំ ម៉ុន ក្នុងខណៈដែលសាលាដំបូងធ្វើការរំឭកគាត់ជាច្រើនដងឲ្យធ្វើការផ្ដល់យោបល់ទៅលើដើមបណ្ដឹងរដ្ឋប្បវេ-ណីនេះ មិនឲ្យធ្វើយោបល់ទៅលើដើមបណ្ដឹងរដ្ឋប្បវេណីផ្សេង។

សរុបមក ប្រតិកម្មនិងខ្លឹមសាររបស់ជនជាប់ចោទទៅលើចំណុច និងសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ គឺវាហាក់ដូចជាគាត់មិនប៊ានធ្វើការតវ៉ានៅពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីនេះនៅប្រឈមចំពោះមុខ។ ដូច្នេះចម្លើយទាំងឡាយគឺវាជាចម្លើយការពិត។ ការសម្លាប់ប្ដូរបស់គាត់ក្នុងចំណោមមនុស្ស១២.២៧៣ នាក់ គឺជាបទចោទមួយដាក់បន្ទុកទៅលើជនជាប់ចោទ ដែលជនរងនេះត្រូវទទួល

ខុសត្រូវព្រហ្មទណ្ឌចំពោះការស្លាប់ទាំងអស់នោះ។ ចំពោះទម្រង់នៃការទទួលខុសត្រូវយោងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលគាត់បញ្ជាទៅលើការសម្លាប់ទាំងអស់នេះ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការវិភាគទៅលើទម្រង់នៃការទទួលការខុសត្រូវ យោងតាមអង្គហេតុដែលដាក់ចំពោះខ្លួន។

កាលដែលយើងជំនួសការទទួលខុសត្រូវរបស់ថ្នាក់លើតាមរយៈការប្រព្រឹត្តិដោយផ្ទាល់នោះ វាមិនប៉ះពាល់ទៅដល់សិទ្ធិរបស់ជនជាប់ចោទនោះទេ ហើយគឺវាមានទម្ងន់ដូចគ្នា និងស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ដែលត្រូវធ្វើការកំណត់ទៅលើទម្រង់នៃការទទួលខុសត្រូវនៅចុងក្រោយ។ ក្នុងអំឡុងពេលសវនាការ លោកស្រី ណាំ ម៉ុន ក៏បានលាតត្រដាងជូនមេធាវីរបស់ខ្លួនបន្ទាប់ពីគាត់បានប្រកាសនៅក្នុងតុលាការ ហើយបន្ទាប់ពីគាត់បានឃើញអ្នកយាម ឈុន ផល មកផ្តល់សក្ខីកម្ម ហើយជនរូបនេះបានរំលោភលោកស្រី។ ក្រោយមក យើងបានស្នើសុំដាក់ព័ត៌មានបន្ថែមដល់អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះទទួលយកសំណើនេះ ប៉ុន្តែពន្យារពេលដាក់ព័ត៌មាន ហើយអ្វីដែលគួរឲ្យភ្ញាក់ផ្អើលអង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលព័ត៌មានបន្ថែមទាំងអស់ទាក់ទងទៅនឹងការរំលោភផ្លូវភេទ ដោយលើកឡើងថា វាមិនពាក់ព័ន្ធទៅនឹងអង្គ ហើយខ្លួនមិនអាចរកហេតុផលគ្រប់គ្រាន់នៅក្នុងពេលសមស្រប។ សេចក្តីសម្រេចនេះ គឺចេញនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៩។ សេចក្តីសម្រេចនេះមានកំហុសចំនួនពីរ៖

[១១:៣៧:៤៩]

ទីមួយ គឺយើងប្រកាសភ្លាមៗបន្ទាប់ពីយើងបានទទួលព័ត៌មាន ហើយយើងស្នើសុំអង្គជំនុំជម្រះសាលាដំបូងក្នុងការអនុញ្ញាតឲ្យយើងខ្ញុំដាក់ព័ត៌មានទាំងអស់នេះ។

ទីពីរ សេចក្តីសម្រេចនេះ វាហាក់ដូចជាទាត់ចោលភាពលំបាកលំបិនរបស់ជនរងគ្រោះនៃអំពើរំលោភផ្លូវភេទ ក្នុងការចូលខ្លួនរៀបរាប់អំពីរឿងរ៉ាវទាំងអស់នេះ បន្ថែមពីលើនេះសេចក្តីសម្រេចនេះ គឺមិនបានពិចារណាទៅលើផលប៉ះពាល់នៃការលាតត្រដាងនៃអំពើរំលោភផ្លូវភេទ លើកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ស្ត្រីភេទនៅក្នុងប្រទេសកម្ពុជានោះឡើយ។ លោកស្រីអាចត្រូវបានគេចាត់ទុកនៅក្នុងសហគមន៍របស់គាត់ ជាល្បែងលែងសើចប្រសិនបើលោកស្រីបានរៀបរាប់ទៅលើអំពើទាំងអស់នេះ។ ដូច្នេះ វាមានការលំបាកសម្រាប់លោកស្រី ហេតុដូច្នេះលោកស្រីមិនអាចរៀបរាប់អំពីអង្គហេតុទាំងអស់នេះ ក្នុងរយៈពេលជាងសាមសិបឆ្នាំរួចមកហើយនោះ។ នៅពេលដែលលោកស្រីឃើញចារីតែប៉ុណ្ណោះ ដែលលោកស្រីព្យាយាម ហើយចាប់ផ្តើមនិយាយដោយមានការក្តាហាន។

បន្ថែមទៅលើចំណុចនេះ ជនជាប់ចោទគាត់បានទទួលស្គាល់ទៅលើអំពើឃោរឃៅមួយចំនួន ដែលនៅដំបូង គាត់បដិសេធ។ ដូច្នេះភាពជឿជាក់ទៅលើជនចាប់រូបនេះ គឺជាចំណុចមួយគួរឲ្យសង្ស័យ ដោយសារតែយើងពិនិត្យឃើញគាត់ធ្វើការឲ្យព័ត៌មានខុសទៅដល់តុលាការលើចំណុចមួយចំនួន ហើយ បន្តធ្វើការដកចេញនៅព័ត៌មានមួយចំនួន ទោះបីជាគាត់ដឹងថាវាការពិតក៏ដោយ។ ឧទាហរណ៍ដែល គួរព្រឺសម្បុរមួយនោះ គឺវាទាក់ទងទៅនឹងការបូមឈាម និងការធ្វើការវះកាត់ និងការពិសោធទៅលើខ្លួន មនុស្ស។ ហើយដូច្នេះហើយយើងគិតថា វាជាចំណុចមួយដែលគួរឲ្យមានការតក់ស្លុត ហើយវាជា ចំណុចទាំងឡាយ ដែលលោកស្រីមិនអាចភ្លេចបាននោះទេ។ ដូច្នេះ នៅពេលនេះ ខ្ញុំសូមវេទិកាទៅដល់ សហសេវិករបស់ខ្ញុំ ដើម្បីឲ្យគាត់រៀបរាប់ទៅលើអង្គហេតុមួយចំនួនរបស់គាត់។ សូមអរគុណ។

[១១:៣៩:៥៨]

**លោក គង់ ពិសី៖**

បាទសូមអរគុណ លោកប្រធាន ហើយសូមគោរពលោក លោកស្រីចៅក្រមជាតិ និងអន្តរជាតិ ព្រមទាំង អង្គសវនាការសាជាថ្មីម្តងទៀត។ ខ្ញុំជាមេធាវីជាតិ សូមបន្តធ្វើការ ធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ ការសួរដេញដោលពីមេធាវីអន្តរជាតិដូចតទៅ៖

នៅក្នុងចំណុចនេះ ខ្ញុំបាទធ្វើសេចក្តីសន្និដ្ឋានបន្តនេះ គឺមានបីចំណុច។ ទីមួយ បទល្មើស និងអ្នក ស្នួរចម្លើយជាស្ត្រី។ ទីពីរ យុទ្ធសាស្ត្រការពារខ្លួនរបស់ជនត្រូវចោទ។ ទីបី សំណាង ហើយលើកចុង ក្រោយនឹងធ្វើសំណូមពរ។ អ៊ីចឹងខ្ញុំបាទសូមធ្វើសេចក្តីសន្និដ្ឋានដូចតទៅ បន្តដូចតទៅ៖

នៅពេលដែលយើងខ្ញុំបានទទួលសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលរបស់ព្រះរាជអាជ្ញា យើងខ្ញុំមានការភ្ញាក់ផ្អើលដោយសារតែមានការលើកឡើង ដោយមិនមានការលើកឡើងសោះថា ការ រំលោភផ្លូវភេទនេះ ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ទោះបីជាអំពើរំលោភផ្លូវភេទមានការចែងនៅ ក្នុងដីកាបញ្ជូនរឿងឲ្យទៅជំនុំជម្រះក៏ដោយ និងទោះបីជាជនត្រូវចោទបានទទួលស្គាល់ថា យ៉ាងហោច ណាស់អំពើនេះបានកើតឡើងម្តងពិតមែន។ ការមិនបញ្ចូលអំពើរំលោភផ្លូវភេទដែលបានប្រព្រឹត្តនៅមន្ទីរ ស-២១ បង្កើតជាគំរូអាក្រក់មួយសម្រាប់ប្រទេសកម្ពុជា ដែលជាប្រទេសមួយត្រូវបានមន្ត្រីនគរបាល និងមន្ត្រីតុលាការនាពេលថ្មីៗនេះមិនចាត់ទុកជាអំពើរំលោភផ្លូវភេទលើស្ត្រី ដែលអស់ភាពបរិសុទ្ធ ដែល ជាអំពើរំលោភផ្លូវភេទនេះឡើយ។ នេះជាសេចក្តីដកស្រង់ចេញពី ខេមស័បូឌា ដេលី។ ទោះបីជាការ រំលោភផ្លូវភេទគ្រប់ទម្រង់ជាឧក្រិដ្ឋកម្មគួរឲ្យស្អប់ខ្ពើមបំផុត ដែលភាគីច្រើនប្រព្រឹត្តលើស្ត្រីភេទក៏ដោយ

អ្វីដែលគួរឲ្យសោកស្តាយ គឺឧក្រិដ្ឋកម្មមិនត្រូវបានគេយកមកជំនុំជម្រះ ហើយនិទ្ទណ្ឌភាពនៅមានភាពធំធេង។

សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត មិនបានធ្វើការស៊ើបអង្កេតលើអំពើហិង្សាផ្លូវភេទឲ្យបានសមស្រប ហើយព្រងើយកន្តើយនឹងភស្តុតាងទាំងឡាយដែលមាន។ ហេតុដូច្នេះយើងខ្ញុំសូមអនុញ្ញាតធ្វើការសង្ខេបនូវការយល់ឃើញរបស់ខ្ញុំដូចតទៅ៖

[១១:៤២:២៦]

ករណីទីមួយ គឺពាក់ព័ន្ធនឹងអ្នកសួរចម្លើយម្នាក់ដែលគេមិនស្គាល់ឈ្មោះ បានរំលោភអតីតគ្រូបង្រៀនជនត្រូវចោទ ដោយធ្វើការយកឈើរុកចូលយោនីរបស់គ្រូរូបនេះនៅពេលសួរចម្លើយ។ យោងតាមសម្តីជនត្រូវចោទ អ្នកសួរចម្លើយរូបនេះមិនត្រូវបានដាក់ទណ្ឌកម្មឡើយ ដោយសារមានការយល់ព្រមពី សុន សេន។ ជនត្រូវចោទ បានលើកឧទាហរណ៍ដូចតទៅ "បើសិនជាខ្ញុំយល់ដឹងច្បាប់ត្រឹមត្រូវនោះ ថាអំពើនោះជាអំពើរំលោភផ្លូវភេទ ខ្ញុំនឹងមិនអត់អោនឲ្យឡើយ ខ្ញុំនឹងសុំសំណើពីមេរបស់ខ្ញុំ។ នៅពេលនោះ ខ្ញុំមិនបានយល់ដឹងច្បាប់អំពីច្បាប់ ខ្ញុំមិនបានរៀបច្បាប់ព្រហ្មទណ្ឌកម្ពុជា។ ដូច្នេះ ខ្ញុំមិនយល់ដឹងអំពីករណីនេះឡើយ សូម្បីតែមេរបស់ខ្ញុំក៏ប្រហែលជាមិនដឹងដែរ"។ នៅពេលសួរថា តើជនរូបនេះបានដឹងថា ការប្រព្រឹត្តិអំពើរំលោភផ្លូវភេទជាអំពើល្មើសនៅពេលនោះ និងនៅពេលបច្ចុប្បន្នដែរឬទេ? ជនរូបនេះរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ ដូច្នេះ យើងមិនចាំបាច់សិក្សាច្បាប់ព្រហ្មទណ្ឌកម្ពុជាដើម្បីឲ្យដឹងថា អំពើរំលោភផ្លូវភេទ គឺជាការបៀតបៀនផ្លូវភេទ ជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរឡើយ។ ការប៉ុនប៉ងរបស់ជនត្រូវចោទដើម្បីគេចចេញពីការទទួលខុសត្រូវតាមរយៈការយកច្បាប់ព្រហ្មទណ្ឌមកទ្រាប់ខ្នងនោះ គឺជាការទះកំផ្លៀងជនរងគ្រោះយ៉ាងធ្ងន់ធ្ងរ។

ជនជាប់ចោទមិនចាំបាច់សិក្សាច្បាប់ព្រហ្មទណ្ឌដើម្បីដឹងថា ការរុកឈើចូលក្នុងយោនីនោះ ជាឧក្រិដ្ឋកម្មមួយធ្ងន់ធ្ងរឡើយ។ ជាថ្មីម្តងទៀត នេះជាឧទាហរណ៍មួយអំពីរបៀបដែលជនត្រូវចោទព្យាយាមកិច្ចចេញពីការទទួលខុសត្រូវរបស់ខ្លួនយ៉ាងឆ្អតវៃ នៅពេលដែលមានកាលៈទេសៈសមរម្យសម្រាប់រូបខ្លួន។ វាបង្ហាញយ៉ាងច្បាស់ថា ក្នុងនាមជាមេបញ្ជាការនៃស-២១ ខ្លួនមិនដែលចាប់អារម្មណ៍រវល់នឹងរបៀបនៃការប្រព្រឹត្តិអំពើលើអ្នកទោស ក្នុងរយៈពេលដែលអ្នកទោសទាំងនោះចូលមកមន្ទីរនេះ ហើយត្រូវបានកំណត់ទុកសម្រាប់ប្រហារជីវិត។

[១១:៤៤:៤២]

ដោយសារមូលហេតុទាំងនេះ ស្ត្រីជាច្រើនបានធ្លាក់ទៅជាចំណីនៃការរំលោភផ្លូវភេទ នៅក្រោមការគ្រប់គ្រងបញ្ជារបស់ជនត្រូវចោទរូបនេះ។ ដូចគ្នានេះដែរ អ្នកទោសទាំងនេះមិនទទួលបានការការពារពីរបៀបធ្វើទារុណកម្ម និងការធ្វើបាបទាំងឡាយ ដែលបានកើតឡើងលើរូបពួកគេទាំងអស់ទាំងយប់ទាំងថ្ងៃឡើយ។ ទោះបីជាជនត្រូវចោទជឿថាករណីរំលោភមួយនេះបានកើតឡើងតែម្តងនៅមន្ទីរស-២១ក៏ដោយ ជនត្រូវចោទរូបនេះមិនបានផ្តល់នៅហេតុផលណាមួយពីការសន្និដ្ឋានរបស់ខ្លួនបែបនេះឡើយ។ ភ័ស្តុតាងមួយនេះ បានច្រានចោលនៅការលើកឡើងរបស់ជនត្រូវចោទរូបនេះ ដែលខ្លួនចង់ឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកការលើកឡើងរបស់ខ្លួន ថាជាការពិតវិញ។

ករណីទីពីរ បានរៀបរាប់តាមរយៈលោកសាក្សី ប្រាក់ ខន និងលោក ឡាច មាន លើករណីអ្នកសួរចម្លើយឈ្មោះ តូច។ អ្នកសួរចម្លើយរូបនេះ បានរំលោភអ្នកទោសស្ត្រីម្នាក់នៅក្នុងពេលបាយថ្ងៃត្រង់ អ្នកយាមទាំងអស់នៅមន្ទីរស-២១ បានឡោមព័ទ្ធជនរូបនេះ ដើម្បីកុំឲ្យរត់គេចខ្លួន។ ជនរូបនេះត្រូវបានចាប់ខ្លួន។ ទោះបីជាហេតុការណ៍នេះ ធ្វើឲ្យអ្នកយាមទាំងអស់ចាប់អារម្មណ៍ក៏ដោយ ជនជាប់ចោទធ្វើជាមិនបានដឹងថាមានករណីនេះកើតឡើង ដោយថាមិនស្គាល់អ្នកសួរចម្លើយឈ្មោះ តូច។

ជាថ្មីម្តងទៀតទៀត ចំណុចនេះធ្វើឲ្យមានការបាត់បង់លើការជឿជាក់លើជនត្រូវចោទរូបនេះ ប្រសិនបើបុគ្គលិកនៅមន្ទីរស-២១ បានដឹងរឿងនេះទាំងអស់គ្នានោះហើយ ជនត្រូវចោទត្រូវតែដឹងលើរឿងនេះដែរ។ អ្វីដែលកើតឡើងនៅមន្ទីរស-២១ មិនមែនថា ជនត្រូវចោទមិនបានដឹងឡើយ។

[១១:៤៦:៣២]

ករណីទីបី អំពីការរំលោភផ្លូវភេទត្រូវបានដឹងតាមរយៈការរៀបរាប់របស់សាក្សី ឈុន ផល ដែលមេរបស់គាត់បានប្រាប់អំពីករណីអ្នកយាមម្នាក់នៅយាមជិតគាត់បានប្រព្រឹត្តអំពើរំលោភផ្លូវភេទ ហើយបានឃើញជនរងគ្រោះនៃអំពើរំលោភផ្លូវភេទ។ ជនត្រូវចោទបានអះអាងថា ខ្លួនបានទប់ស្កាត់ហេតុការណ៍នៃអំពើរំលោភផ្លូវភេទនេះ ដោយចាត់តាំងឲ្យមានក្រុមអ្នកសួរចម្លើយស្ត្រី។ ប៉ុន្តែ យើងមិនបានឃើញភ័ស្តុតាងស៊ីសង្វាក់គ្នាទៅនឹងការអះអាងនេះឡើយ។ ម្យ៉ាងវិញទៀត ទោះបីមានអ្នកសួរចម្លើយស្ត្រីក៏ដោយ វាមិនប្រាកដថាអ្នកសួរចម្លើយស្ត្រីនោះ អាចការពារស្ត្រីរាប់រយនាក់នៅក្នុងមន្ទីរស-២១ឡើយ ដែលស្ត្រីទាំងនោះភាគច្រើនជាអ្នកយាមបុរសតាមដានជារៀងរាល់ថ្ងៃ។ បន្ថែមលើនេះទៀត ជនត្រូវចោទខ្លួនឯង បានអះអាងថា អ្នកសួរចម្លើយស្ត្រីទាំងនោះត្រូវបានគេកម្ទេចចោល។ ដូច្នេះ តើនរណាជាអ្នកការពារស្ត្រីរងគ្រោះទាំងអស់នោះ ក្រោយពេលដែលអ្នកសួរចម្លើយស្ត្រីទាំងនោះត្រូវបាន

គេយកទៅកម្ទេចចោលនោះ ?

ដោយពិចារណាទៅលើស្ថានភាពនៃអ្នកយាមជាបុរសនៅមន្ទីរស-២១ ជនត្រូវចោទមានហេតុផលគ្រប់គ្រាន់ បានដឹងថា អ្នកសួរចម្លើយ និងអ្នកយាមជាបុរស ដែលត្រូវបានគេផ្តល់សិទ្ធិខាងផ្លូវភេទ និងទំនងជាធ្វើការកេងប្រវ័ញ្ចលើស្ថានភាពរបស់អ្នកទោសស្រីៗដែលគ្មានទីពឹង។ ស្ត្រីទាំងនោះដែលត្រូវបានគេកំណត់ក្នុងគុកសម្រាប់ប្រហារជីវិត ដែលនឹងទទួលរងការមើលងាយអមនុស្សធម៌ និងតិចជាងសត្វធាតុទៀត ងាយស្រួលក្លាយជាចំណីតណ្ហាផ្លូវភេទ ដែលបានប្រព្រឹត្តដោយអ្នកយាមទាំងនោះមកលើពួកគេ។ បន្ថែមលើចំណុចនេះ ជនត្រូវចោទបានខកខាន មិនបានចាត់វិធានការចាំបាច់ និងសមហេតុផលក្នុងការរារាំងឧក្រិដ្ឋកម្មទាំងនេះ ឬក៏បានដាក់ទោសចារីទាំងនោះឡើយ។ ហេតុដូច្នេះ ជនត្រូវចោទមានការទទួលខុសត្រូវព្រហ្មទណ្ឌយ៉ាងហោចណាស់លើករណីរំលោភផ្លូវភេទចំនួនបីករណី ដែលបានប្រព្រឹត្តនៅមន្ទីរស-២១។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានដាក់បញ្ចូលនៅអង្គហេតុនានា ហើយបានបង្ហាញយ៉ាងច្បាស់គ្រប់គ្រាន់ក្នុងការចោទប្រកាន់ជនរូបនេះ យ៉ាងហោចណាស់លើករណីរំលោភផ្លូវភេទមួយករណី។

ករណីទីបួន ការរំលោភផ្លូវភេទដែលមានអ្នកយាមឈ្មោះ ឈុន ផល ជាចារីប្រព្រឹត្តលើដើមបណ្តឹងរដ្ឋប្បវេណី ណាំ ម៉ុន ត្រូវបានអង្គជំនុំជម្រះសាលាដំបូងដកចេញពីភ័ស្តុតាងយ៉ាងគួរឲ្យសោកស្តាយ ដែលធ្វើឲ្យករណីនេះនៅតែមិនទទួលបានការជំនុំជម្រះ។ ម្យ៉ាងវិញទៀត លោកសាក្សីឈ្មោះ វ៉ាន់ ណាត និងដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ម៉េង បានរៀបរាប់ថា វាគឺក្រិត្យក្រមអនុវត្តសាមញ្ញទៅហើយ ដែលអ្នកទោសបុរសនៅក្នុងបន្ទប់ធំៗ បន្ទប់ឃុំឃាំងធំៗត្រូវតែស្រាតខោអាវចេញដោយខ្លួនឯង នៅពេលដែលអ្នកយាមបាញ់ទឹកមុជឲ្យពួកគេ ហើយជាញឹកញយអ្នកយាមទាំងនេះយកពេលនេះ ធ្វើការឌឺឌង ប្រដាប់ភេទរបស់អ្នកទោស ហើយនិយាយមើលងាយយ៉ាងអាសអាភាស។ តាមផ្លូវច្បាប់ករណីនេះជាការប្រមាថផ្លូវភេទ ហើយបានចាត់បញ្ចូលជាអំពើអមនុស្សធម៌មួយបែបទៀតចំពោះអ្នកទោសទាំងឡាយ។

[១១:៥០:១១]

ចំណុចទីពីរដែលខ្ញុំចង់លើកឡើង គឺយុទ្ធសាស្ត្រការពារខ្លួនរបស់ជនត្រូវចោទ។ យុទ្ធសាស្ត្ររបស់មេធាវីការពារជនត្រូវចោទ ផ្អែកជាចម្បងលើចំណុចចំនួនបួនដូចតទៅ៖

១) ជនត្រូវចោទ ក្នុងនាមជាជនរងគ្រោះមួយរូបនៃរបបកម្ពុជាប្រជាធិបតេយ្យមិនអាចរត់គេច

ខ្លួន ហើយគ្រាន់តែស្តាប់តាមបញ្ជាដោយគ្មានសេរីភាពក្នុងការសម្រេចសេចក្តីណាមួយនោះទេ។ ជនត្រូវចោទបានធ្វើការងារក្នុងឋានៈជាប្រធានម-១៣ និងស-២១ ដោយស្ទាក់ស្ទើរ។

២) ប្រកែកដាច់ខាតចំពោះការពាក់ព័ន្ធផ្ទាល់ខ្លួនណាមួយនៅក្នុងការធ្វើទារុណកម្ម ការសម្លាប់ និងការចាប់ខ្លួន។

៣) ធ្វើពុតជាសហការណ៍ពេញលេញ និងធ្វើពុតជាសារភាពទៀងត្រង់។

៤) ស្នើសុំឲ្យអត់ឱនទោស សុំទោស និងបង្ហាញអំពីវិប្បដិសារី។

យើងមិនចង់លើកឡើងសាជាថ្មីនូវទឡ្ហីករណ៍របស់សហមេធាវី សហការីរបស់យើងនឹងចូលរួមទាំងស្រុងជាមួយនឹងសហការីយើងទាក់ទងទៅនឹងចំណុចទីមួយនៃការការពារខ្លួនរបស់ជនត្រូវចោទក្នុងនាមជាជនរងគ្រោះមួយរូប និងជាចំណាប់ថ្នូរមួយរូបរបស់របបកម្ពុជាប្រជាធិបតេយ្យ ដែលជនត្រូវចោទត្រូវតែគោរពបញ្ជានោះ។ ហេតុដូច្នេះ ជនត្រូវចោទមិនអាចរត់គេចខ្លួនបានទេ។

ដើមបណ្តឹងរដ្ឋប្បវេណីលើកទឡ្ហីករណ៍ថា ការធ្វើពុតជាជនរងគ្រោះម្នាក់ គឺជាប្រមាថដល់ពួកគាត់ និងរងគ្រោះទាំងឡាយនៅក្នុងប្រទេសកម្ពុជាទាំងមូល។

ដូចគ្នានេះដែរ ជនត្រូវចោទមិនមែនជាអ្នកត្រូវទទួលថ្នបាក់ទេ តាមរយៈការលើកឡើងជាថ្មីថាឥឡូវខ្លួនគឺជាជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះជាច្រើនដែលលាក់បាំងនូវការស្អប់ខ្ពើម ដែលបានដកស្រង់ចេញពីអត្ថបទនៅក្នុងការសែតបារាំងឈ្មោះ ឡឺម៉ុងដ៍ ដែលស្រង់សម្តីរបស់លោក រូ។ ជនជាប់ចោទ និងមេធាវីការពារក្តីខ្លួនហាក់ដូចជាយល់ច្រឡំទាំងស្រុងអំពីការពិតថា តើអ្នកណាជាជនរងគ្រោះនិងអ្នកណាចារី? នៅក្នុងយុទ្ធនាការសារព័ត៌មានដែលសន្និដ្ឋានអំពីរឿងក្តីខាងក្រៅសាលតុលាការ។ ភ័ស្តុតាងដែលលើកឡើងនៅក្នុងតុលាការផ្ទុយទៅនឹងទឡ្ហីករណ៍ការពារក្តីរបស់ជនជាប់ចោទ។

[១១:៥២:៤០]

យើងសន្និដ្ឋានថា ជនត្រូវចោទគឺជាអ្នកចូលរួមដោយស្ម័គ្រចិត្ត ដោយពេញចិត្ត និងដោយល្អិតល្អន់ និងដោយមានសេរីភាពក្នុងការសម្រេចយ៉ាងទូលំទូលាយ រួមមានការឲ្យរួចជីវិត និងការធ្វើឲ្យប្រសើរនូវស្ថានភាពគុកសម្រាប់-- ឧទាហរណ៍ដូច វ័ន្ន គត់ និង ចៅ សេង ដែលជាជនត្រូវចោទហៅពួកគេថា ពាក់កណ្តាលអ្នកទោស និងផ្តល់ឲ្យអ្នកនោះនូវទីកន្លែងស្នាក់នៅ និងម្ហូបអាហារសមគួរ។

ជនត្រូវចោទមិនត្រឹមតែពេញចិត្តនឹងការងារនិងជឿជាក់លើមាគ៌ាបក្សក្នុងការកំណត់អត្តសញ្ញាណខ្មាំង និងកម្ទេចពួកគេដោយគ្មានអារម្មណ៍ថា ខុសឆ្គងប៉ុណ្ណោះទេ ប៉ុន្តែខ្លួនថែមទាំងចូលចិត្តអំណាចក្នុង

នាមជាបុរសឃ្លានអំណាច និងបានអនុវត្តការងាររបស់ខ្លួនលើសពីមួយរយភាគរយដោយគ្មានអាណិតអាសូរដល់ជនរងគ្រោះរបស់ខ្លួនឡើយ។

ជនត្រូវចោទមានគោលបំណងរក្សាអំណាចក្នុងមុខតំណាងដែលទទួលស្គាល់យ៉ាងខ្ពស់តាមរយៈការទាក់ទងប្រចាំថ្ងៃដោយផ្ទាល់ជាមួយនឹងថ្នាក់លើខ្ពស់បំផុត។

ជនត្រូវចោទចូលចិត្តផ្គាប់ចិត្តថ្នាក់លើរបស់ខ្លួន និងធ្វើឲ្យថ្នាក់លើពេញចិត្ត។ ឧទាហរណ៍ជនត្រូវចោទបានបញ្ជាឲ្យជាងគំនូរគូរ-ក របស់ ប៉ុល ពត ឲ្យស្អាត។

ជនត្រូវចោទបានរស់នៅក្នុងផ្ទះវីឡានៅទីក្រុងភ្នំពេញ និងចូលចិត្តកម្រិតជីវភាពរស់នៅខ្ពស់ ក្នុងកាលៈទេសៈនេះជនត្រូវចោទបានបាត់បង់អ្វីភ្លាមៗ ប្រសិនបើខ្លួនលាលែងពីតំណែង។

ហេតុដូច្នេះហើយ ទើបក្រោយមកជនត្រូវចោទដើរតាមការស្រេកឃ្លានរបស់ខ្លួន ចង់ស្ថិតក្នុងពិភពមួយដែលមានអំណាច ហើយជនត្រូវចោទបានផ្លាស់ប្តូរមកជាកាន់សាសនាគ្រិស្ត ដើម្បីស្ថិតក្នុងពិភពនៃគ្រិស្តសាសនាដ៏ត្រឹមត្រូវមានអំណាចបំផុតនាពេលបច្ចុប្បន្ន។ ដូចដែលខ្លួនបានចាត់ថ្នាក់វាដូចនឹងអ្វីដែលបានលើកឡើង ដោយអ្នកជំនាញចិត្តវិទ្យា និងអ្នកជំនាញវិកលចរិត។ បើជនត្រូវចោទនៅតែបន្តកាន់ព្រះពុទ្ធសាសនាឧក្រិដ្ឋកម្មរបស់ខ្លួននឹងធ្វើឲ្យខ្លួនគាត់ធ្លាក់ទៅក្នុងនរកជប់ប្រាំបីជាន់ ដែលជាកន្លែងដែលមិនអាចចាប់កំណើតជាមនុស្សវិញបានឡើយ។ ហេតុដូច្នេះ ការនិយាយដោយខ្លួនឯងថា ជាអ្នកទទួលបញ្ជាដែលត្រូវឲ្យគេគោរពតាម ការនិយាយបែបនេះត្រូវតែបដិសេធចោល។

នៅចំណុចនេះ យើងនឹងដកស្រង់ចេញពីសៀវភៅរបស់ *ហាណា ហារិនដ៍ (Hannah Arendt) អែស្មិន អ៊ីន ជេរូសាឡឹម(Eichman in Jerusalem) ដ៏បាណាលីធី អុហ្វ ឌី អ៊ីវិល (The Banality of the Evil)* ដែលអ្នកនិពន្ធបានស្នើសុំថា តុលាការគួរប្រាប់ជនជាប់ចោទឈ្មោះ អែស្មិន ដែលបានអះអាងខ្លួនថា ធ្វើអ្វីៗគឺជាការគោរពបញ្ជា ដែលចំណុចនេះ ខ្ញុំចង់ប្រាប់ជនជាប់ចោទដូចតទៅថា៖ វានៅតែជាការពិតដដែល លោកបានអនុវត្ត ហើយបានគាំទ្រយ៉ាងសកម្មនូវគោលនយោបាយសម្លាប់រង្គាល។ នយោបាយមិនដូចនឹងការមើលថែកុមារទេ។ នៅក្នុងរឿងនយោបាយការស្តាប់បង្គាប់ និងការគាំទ្រគឺវាដូចគ្នា។

[១១:៥៦:១០]

ចំណុចទីពីរនៃការការពារខ្លួន ជំទាស់ទៅនឹងការពាក់ព័ន្ធផ្ទាល់ខ្លួនណាមួយនៅក្នុងការធ្វើទារុណកម្ម ការសម្លាប់ និងការចាប់ខ្លួន។ ហេតុអ្វីបានជាសំខាន់ណាស់សម្រាប់ជនត្រូវចោទក្នុងការបដិសេធ

ដាច់ខាតក្នុងការពាក់ព័ន្ធជាបុគ្គល ដោយផ្ទាល់ណាមួយជាមួយនឹងឧក្រិដ្ឋកម្ម ទោះបីជាខ្លួនបានសារភាពថា ខ្លួនបញ្ជាពួកគេឲ្យធ្វើក៏ដោយ។ ខ្ញុំព្យាយាមឆ្លើយនឹងសំណួរនេះ រហូតមកទល់ពេលជនត្រូវចោទត្រូវបានឃុំខ្លួននៅ អ.វ.ត.ក ខ្លួនបានយល់ឃើញថា អ្នកទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌគឺជាអ្នកប្រព្រឹត្តអំពើនេះដោយដៃផ្ទាល់ ហើយអ្នកដែលសម្របសម្រួលអំពើមនុស្សឃាតពីក្រោយក្នុងនាមជាឃាតកប្រយោល។ អ្នកសម្របសម្រួលនេះមិនមានកំហុស ឬមានកំហុសព្រហ្មទណ្ឌបន្តិចបន្តួចតែប៉ុណ្ណោះ។ លើសពីនេះទៅទៀត ជនត្រូវចោទ ចោទរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យថាជាអ្នកទទួលខុសត្រូវរឿងនេះ។ តាមរយៈនៃការផ្តល់យោបល់របស់មេធាវីការពារក្តីរបស់ខ្លួន ខ្ញុំសូមដកស្រង់សម្តីជនត្រូវចោទដូចនេះថា “មេធាវីការពារក្តីរបស់ខ្ញុំប្រាប់ខ្ញុំថា ខ្ញុំត្រូវតែសារភាព និងទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្ញុំ ហើយខ្ញុំមិនត្រូវបន្ទោសរដ្ឋាភិបាលដូចដែលខ្ញុំបានធ្វើកាលពីអតីតកាលទេ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩”។ ចំណុចនេះ បង្ហាញយ៉ាងច្បាស់ថា ជនត្រូវចោទខ្វះមនសិការអំពីកំហុសនូវពេលខ្លួនបានប្រព្រឹត្តកម្ម ដោយសារការជឿជាក់លើមាគ៌ានយោបាយរបស់បក្សឲ្យកម្ទេចខ្មាំង។

យើងកត់សម្គាល់ថា ជនត្រូវចោទបានធ្វើតាមដំបូន្មានមេធាវីរបស់ខ្លួន ហើយឥឡូវនេះជនត្រូវចោទបានទទួលស្គាល់កំហុស និងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ខ្លួនចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅស-២១ជាទូទៅ។ ប៉ុន្តែ យុត្តិសាស្ត្រការពារខ្លួនរបស់មេធាវីការពារជនត្រូវចោទក្នុងការបដិសេធការពាក់ព័ន្ធផ្ទាល់ខ្លួនទៅនឹងការធ្វើទារុណកម្ម ការសម្លាប់ និងការចាប់ខ្លួន គឺជាយុត្តិសាស្ត្រមិនជោគជ័យនោះទេ។ ភ័ស្តុតាងដែលលើកឡើងនៅក្នុងតុលាការផ្ទុយទៅនឹងការការពារខ្លួន ការពារក្តីរបស់ខ្លួន។

[១១:៥៨:៣៥]

ចម្លើយរបស់លោក ប្រាក់ ខន, លោក សោម ម៉េត, លោក វ៉ាន់ ណាត និង លោកស្រី ណាំ ម៉ុនបានផ្តល់ភ័ស្តុតាងថា ពេលខ្លះជនត្រូវចោទបានធ្វើបាប និងធ្វើទារុណកម្មដោយផ្ទាល់ តាមរយៈការវាយដំបង ការឆក់ខ្សែភ្លើង និងការទាត់ធាក់។ បន្ថែមពីលើនេះទៀត ចំណារលើចម្លើយសារភាព សក្ខីកម្មរបស់ ខៀវ ចេស ដែលគាត់បាន ដែលគាត់ជាជនម្នាក់ក្នុងក្រុមចាប់ចង ដែលជាជនបានចាប់ខ្លួនមនុស្សពាសពេញផ្ទៃប្រទេសទាំងអស់ និងការឆ្លើយឆ្លងឯងសារផ្ទាល់ជាមួយនឹងប្រធានកងពលធំ ស៊ូ ម៉េត អំពីការកំណត់អត្តសញ្ញាណខ្មាំង និងការដឹកជញ្ជូនមនុស្សទៅស-២១ ដែលរួមមានការចាប់ខ្លួនពួកគេដែលត្រូវបានរៀបចំនៅក្នុងផ្ទះរបស់ខ្លួន។ អំពើទាំងនេះបង្ហាញអំពីការពាក់ព័ន្ធដោយផ្ទាល់របស់ជនត្រូវចោទ

ក្នុងការចាប់ខ្លួន ប៉ុន្តែជនត្រូវចោទក៏បានបន្តការអនុវត្តម-១៣ ដោយពេលខ្លះជនត្រូវចោទបានសម្លាប់ដោយផ្ទាល់ដូចដែលលោកស្រី ណាំ ម៉ុន បានរៀបរាប់អំពីរបៀបដែលជនត្រូវចោទបានវាយដល់ស្លាប់ដោយប្រើដំបងដែកទៅលើឪពុកមារបស់អ្នកស្រីឈ្មោះ អឿន និងឈ្មោះ កេត ដែលពួកគាត់ទាំងពីរជាសមមិត្តជិតស្និតរបស់ខ្លួន និងជាអ្នកបដិវត្តន៍។

ចំណុចទីបីនៃការការពារខ្លួនរបស់ជនត្រូវចោទ គឺជាការសហការណ៍ពេញលេញជាមួយតុលាការតាមរយៈការទទួលសារភាពទោស និងការឆ្លើយតបដោយស្មោះត្រង់ជូនទៅលើដើមបណ្តឹងរដ្ឋប្បវេណី។ ការសហការបែបនេះមិនមានភាពស្មោះត្រង់និងត្រឹមត្រូវនោះទេ។ ការសហការជាមួយតុលាការ និងការធ្វើពុតជាសារភាព គឺគ្រាន់តែជាការស្ទាក់ស្ទើរប៉ុណ្ណោះ។ ជនត្រូវចោទមិនបានឆ្លើយតបទៅនឹងសំណួរជាច្រើនរបស់ភាគីទាំងអស់ និងសំណួររបស់ចៅក្រម ឬជនត្រូវចោទឆ្លើយមិនចំនឹងសំណួរ ឆ្លើយដោយមានះ និងយ៉ាងប៉ិនប្រសប់។ ការសារភាពរបស់ខ្លួនមានត្រឹមតែហុកសិបប្រាំបីភាគរយនៃអង្គហេតុរបស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងមិនអាចជាតម្លៃនៃចម្លើយសារភាពនោះទេ។ វាគ្រាន់តែជាផ្នែកមួយនៃចម្លើយសារភាព ដែលមិនច្រើន និងបន្តិចប៉ុណ្ណោះ។ ជនត្រូវចោទខកខានក្នុងការអនុវត្តតាមការសន្យារបស់ខ្លួនចំពោះដើមបណ្តឹងរដ្ឋប្បវេណី នៅពេលដែលខ្លួនបានធានាចំពោះដើមបណ្តឹងរដ្ឋប្បវេណីតាំងពីដើមដំបូងនៃសវនាការថា ខ្លួននឹងប្រើប្រាស់អស់ពីកម្លាំងកាយចិត្តដើម្បីលើកឡើងនូវការពិត និងឆ្លើយបតដោយស្មោះត្រង់នូវគ្រប់សំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់។

[១២:០១:២០]

ជនត្រូវចោទមិនបានធ្វើតាមការសន្យានេះបីបួនដង។ ដំបូងជនត្រូវចោទឆ្លើយមិនគួរឲ្យជឿនៅពេលខ្លួនលើកឡើងថា ខ្លួនមិនបានដឹងអំពីសាស្ត្រាចារ្យ ភឹង តុន ដែលសាស្ត្រាចារ្យនេះត្រូវបានគេគោរពយ៉ាងខ្លាំងនៅប្រទេសកម្ពុជា។ ដូចនេះ វត្តមានរបស់គាត់នៅក្នុងមន្ទីរឃុំឃាំងមិនអាចត្រូវបានជនត្រូវចោទមើលរំលងនោះទេ ដើម្បីលាក់បាំងការទទួលខុសត្រូវរបស់ខ្លួន ជនត្រូវចោទបានតវ៉ាថា ឯកសារស្តីពីការបរិច្ឆេទចូលរបស់សាស្ត្រាចារ្យ ភឹង តុន ប្រាកដជាខុស ហើយខ្លួនលើកឡើងទៀតថា សាស្ត្រាចារ្យ រូបនេះប្រហែលជាត្រូវចាប់ខ្លួននៅមន្ទីរស-២១ តាំងពីពេលដែលលោក ណាត ធ្វើជាប្រធាន។ តាមការឆ្លើយនេះ មានន័យថាសាស្ត្រាចារ្យ ភឹង តុន ស្ថិតក្នុងស-២១ ជាងម្ភៃខែ បើយោងតាមចម្លើយរបស់ជនត្រូវចោទថា ដោយគ្មានការធ្វើទារុណកម្ម។ វាច្បាស់ណាស់ថា ជនត្រូវចោទបានកុហក។ ដូចគ្នានេះដែរ ជនត្រូវចោទបានឆ្លើយថា ខ្លួនមិនដឹងពីការដាក់ឃុំឃាំងចំពោះមិត្តជិតស្និទ្ធរបស់

ខ្លួន ជុំ ស៊ីណារ៉េត និង ជុំ ណារិទ្ធ ដែលចម្លើយបែបនេះមិនគួរឲ្យជឿបានទាល់តែសោះ។ ខ្ញុំយល់ថា វត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាប់ពាក់ព័ន្ធ ដែលភ្នែកអ្នកទាំងអស់សម្លឹងដោយផ្ទាល់ទៅលើជនត្រូវចោទ បានហាមឃាត់ជនត្រូវចោទមិនឲ្យទទួលយកនូវការទទួលខុសត្រូវក្នុងអង្គហេតុដែលថា ខ្លួនគឺជាភាគីមួយនៅក្នុង

មួយទៅនឹងឃាតក ដែលគាត់សរសើរ និងឃាតកដែលជាមិត្តជិតស្និតរបស់ខ្លួនផង។

បន្ថែមពីលើនេះ ការពន្យារក្នុងការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី ទៅមើលជនត្រូវចោទនៅក្នុងមន្ទីរឃុំឃាំងបានក្លាយទៅជាការមិនគប្បី បន្ទាប់ពីសវនាការ៧៣ថ្ងៃ ដែលជនត្រូវចោទជាប់គាំងទៅនឹងសំណួរ។

ជាចុងក្រោយ ចំណុចសំខាន់ទីបួននៃការការពារខ្លួនរបស់ជនត្រូវចោទ គឺការស្នើសុំដដែលៗឲ្យអត់ឱនទោស សុំទោស និងការបង្ហាញនូវវិប្បដិសារីរបស់ខ្លួនចំពោះដើមបណ្តឹងរដ្ឋប្បវេណី និងគ្រួសាររបស់ពួកគេ។ ចំណុចនេះកាន់តែមិនមានន័យអ្វីទាល់តែសោះនៅក្នុងតុលាការ និងការស្នើសុំទាំងអស់ផ្ទុយទៅនឹងវិធីការពារខ្លួន ដែលបានលើកឡើងខាងលើ។ ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ការសុំទោសដដែលៗនៅក្នុងអំឡុងពេលដំណើរការនីតិវិធី គ្រាន់តែជាការបញ្ជាក់នូវកំហុសរបស់ខ្លួនចំពោះដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ។ លើសពីនេះទៅទៀត ចេតនាធ្វើពុតមានវិប្បដិសារីតាមការយំជារឿយៗកើតឡើងប្រហែលជាម៉ោងបួនល្ងាចនៅចុងបញ្ចប់នៃសវនាការ ត្រូវបានដើមបណ្តឹងរដ្ឋប្បវេណីចាត់ទុកថា ជាទឹកភ្នែកសិប្បនិមិត្ត។ ដើមបណ្តឹងរដ្ឋប្បវេណីយល់ថា វាជាការរៀបចំ និងគ្មានន័យអ្វីទាល់តែសោះ។ តាមរយៈការគេចចេញពីសំណួរ និងការបង្ហាញនូវវិប្បដិសារី ជនត្រូវចោទបានបាត់បង់ឱកាសក្នុងការធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីជឿជាក់ថា ខ្លួនពិតជាមានវិប្បដិសារី និងធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីទទួលយកការសុំទោស ឬអត់ឱនទោសចំពោះទង្វើមិនអាចអត់ឱនទោសឲ្យបាន។

[១២:០៥:៤៥]

ចំពោះសំណង យើងបានដាក់សំណើលម្អិតអំពីសំណងនៅក្នុងដីកាសន្និដ្ឋានបញ្ចប់ការសួរដេញដោល។ ដូច្នេះយើងខ្ញុំគ្រាន់តែចង់លើកជូនដោយសង្ខេបដូចតទៅ៖

យើងបានបានកត់សម្គាល់អំពីមតិយោបល់នៅក្នុងដីកាសន្និដ្ឋានបញ្ចប់ការសួរដេញដោលថា ជនត្រូវចោទគឺជាអ្នកក្រ ហើយយើងបានបញ្ចូនករណីនេះ ដូចនេះជនត្រូវចោទនឹងមិនអាចសងនូវសំណងនូវប្រភេទណាមួយបាននោះទេ យើងរំឭកជនត្រូវចោទថា អ្នកមិនអានគ្រាន់តែអង្គុយចុះ ហើយបន្ទូ

អារម្មណ៍ដោយញញើមក្នុងចិត្តនោះបានទេ ជនត្រូវចោទអាចធ្វើការងារច្រើនជាងនេះ។ យើងស្នើសុំថា ជនត្រូវចោទត្រូវទទួលបន្ទុកហិរញ្ញវត្ថុចំពោះឧក្រិដ្ឋកម្មរបស់ខ្លួន និងវិធីដែលខ្លួនអាចសងនូវសំណងបែបនេះបាន។ ជនត្រូវចោទអាចស្នើសុំធ្វើការងារដែលខ្លួនអាចធ្វើបាន ពេលនៅពន្ធនាគារ ឬសរសេរជីវប្រវត្តិដើម្បីលក់ក្នុងការប្រមូលលុយសម្រាប់សំណងដែលស្នើសុំ។ ត្រង់ចំណុចនេះ យើងគ្រាន់តែចង់គូសបញ្ជាក់សំណើជាក់ស្តែងរបស់យើងថា បញ្ជាឲ្យជនត្រូវចោទសរសេរលិខិតជាចំហចំនួនពីរច្បាប់ទៅរាជរដ្ឋាភិបាលកម្ពុជាដើម្បីសុំទោស-- កម្ពុជាដើម្បីសុំ៖

១) ការអត់ឱនទោសតាមផ្លូវរដ្ឋ និង២) ស្នើសុំមួយភាគបីនៃតម្លៃចូលសារមន្ទីរទួលស្លែង និងជើងឯក ត្រូវប្រើប្រាស់សម្រាប់សម្រេចឲ្យបាននូវសំណងដែលស្នើសុំផ្សេងៗទៀត។

នៅចុងបញ្ចប់នៃសេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោល យើងខ្ញុំសូមគោរពដាក់ជូននូវសំណើដូចខាងក្រោមជូនអង្គជំនុំជម្រះដូចតទៅនេះ៖

សំណូមពរ:

១) ប្រកាសទទួលស្គាល់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់។

២) ពិចារណាអង្គហេតុនានាដែលទាក់ទងទៅនឹងកំហុសជនត្រូវចោទ ដូចដែលបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោលសម្រាប់សាលក្រមស្ថាពរ ជាពិសេសទាក់ទងទៅនឹងការសម្លាប់ចំនួនពីរករណី និងការរំលោភសេពសន្ថវៈចំនួនបីករណី។

៣) ផ្តល់នូវសំណើសុំសំណង ដូចមាននៅក្នុងសារណាបិទកិច្ចពិភាក្សាដេញដោល។

៤) បដិសេធសេចក្តីប្រាថ្នា សេចក្តីប៉ុនប៉ងប្រាថ្នារបស់ជនត្រូវចោទក្នុងការវិលត្រឡប់ចូលក្នុងសង្គមកម្ពុជាវិញ។

សូមអរគុណ។

[១២:០៧:១៤]

**ប្រធានអង្គជំនុំ៖**

ឃើញថា សេចក្តីថ្លែងការណ៍ សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ឃើញថាដល់ទីបញ្ចប់ ហើយតាមកាលវេលាដែលបានកំណត់ ហើយឥឡូវនេះដល់ពេលត្រូវពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយនិងសាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ច

ដំណើរការនីតិវិធីសវនាការ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនជនជាប់ចោទទៅកាន់បន្ទប់សម្រាប់រង់ចាំ ដែលបានរៀបចំទុកសម្រាប់ជនជាប់ចោទ ឬក៏នាំគាត់ទៅកាន់បន្ទីរឃុំឃាំង និងឲ្យនាំគាត់មកកាន់សាលសវនាការវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះជាកំហិត។

[១២:០៨:៤៨]

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកនៅម៉ោង១២:០៨នាទីរហូតដល់ម៉ោង ១៣:៣២នាទី )*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ អង្គជំនុំជម្រះសាលាដំបូង ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹង--

អង្គជំនុំជម្រះសាលាដំបូង ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការសម្រាប់រសៀលនេះ។

មុននឹងប្រគល់វេទិកាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី អង្គជំនុំជម្រះសូមធ្វើការកត់សម្គាល់អំពីសេចក្តីថ្លែងការណ៍សន្និដ្ឋានរបស់មេធាវីការពារក្តីពីព្រឹកមិញថា មានការចេញហួសផុតពីអង្គហេតុ អង្គច្បាប់ និងភាពពាក់ព័ន្ធដែលជាប្រយោជន៍នៅក្នុងការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ដោយសារថា អង្គជំនុំជម្រះ និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលបានចេញនៅក្នុងអំឡុងពេលនៃដំណើរការសវនាការ វាពុំមែនជាកម្មវត្ថុនៃសេចក្តីសន្និដ្ឋានបញ្ចប់របស់ភាគីឡើយ។ ហេតុដូច្នេះ សូមមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីពីរក្រុមទៀត ក៏ដូចជាភាគីផ្សេងទៀតសូមមានការចាប់អារម្មណ៍។ ហើយអង្គជំនុំជម្រះមិនចង់ទេ នៅក្នុងការកាត់ផ្តាច់នូវអ្វីដែលអស់លោក លោកស្រីកំពុងតែធ្វើសេចក្តីថ្លែងការណ៍វានាំឲ្យអាក់ខាននូវអារម្មណ៍ដែលកំពុងតែផ្ចិតផ្ចង់នៅក្នុងការថ្លែងនោះ។ អ៊ីចឹងសូមរំឭកជាមុនប្រសិនបើទិដ្ឋភាពដូចព្រឹកមិញនេះ យើងនឹងរក្សាសិទ្ធនៅក្នុងការកាត់ចេញនូវអ្វីដែលឥតប្រយោជន៍ ឬក៏វាប្រាសចាកនូវគោលការណ៍ នៃសេចក្តីសន្និដ្ឋានបញ្ចប់ពាក់ព័ន្ធទៅនឹងរឿងក្តី។

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមអញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ឡើងធ្វើ

សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល។ ហើយជម្រាបថា មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបីក៏មានពេលវេលា ដូចគ្នានឹងមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ និងក្រុមពីរដែរ គឺមានពេលវេលាមួយម៉ោង និងដប់ប្រាំនាទីក្នុងការធ្វើសេចក្តីសន្និដ្ឋាននាពេលនេះ។

សូមអញ្ជើញ!

**កញ្ញា ម៉ុច សុវណ្ណារី៖**

ជាដំបូងនាងខ្ញុំសូមគោរពដល់លោកប្រធាន និងអង្គជំនុំជម្រះទាំងមូល។ នាងខ្ញុំមេធាវី ម៉ុច សុវណ្ណារី គឺជាមេធាវីជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី។ មុននឹងក្រុមរបស់នាងខ្ញុំ ចាប់ផ្តើមនៅក្នុងការធ្វើសេចក្តីបញ្ចប់នេះ នាងខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីអនុញ្ញាតឲ្យមេធាវីបរទេសរបស់នាងខ្ញុំ ទីមួយ គឺលោកមេធាវី ហ្វីលីព កាណុន ដើម្បីឲ្យគាត់ធ្វើការចាប់ផ្តើម បន្ទាប់មកទៀតលោកមេធាវី ម៉ាទីន ហ្សាកកាំង ហើយនាងខ្ញុំនឹងត្រឡប់មកដើម្បីបញ្ចប់ទាក់ទងជាមួយនឹងបញ្ហានៃសំណង។ នាងខ្ញុំសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំ។ សូមអញ្ជើញលោកមេធាវី។

**លោក ហ្វីលីព កាណុន៖**

លោកប្រធានជាទីគោរព លោក លោកស្រីចៅក្រមជាទីគោរព, ខ្ញុំឈ្មោះ ហ្វីលីព កាណុណ ហើយកញ្ញា ម៉ុច សុវណ្ណារី ទើបបានលើកឡើងអម្បាញ់មិញថា ខ្ញុំគឺជាមេធាវីឲ្យមេធាវីគ្មានព្រំដែនរបស់បារាំងតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី។

ខ្ញុំមានមោទនភាពណាស់ដែលតុលាការបានអនុញ្ញាតឲ្យយើងខ្ញុំទាំងបីនាក់ធ្វើជាតំណាង មេធាវីតំណាងឲ្យរដ្ឋប្បវេណី។ ហើយពេលវេលា ជាពិសេសដែលផ្តល់មកឲ្យខាងក្រុមយើងខ្ញុំ។ ហើយសេចក្តីថ្លែងបិទការពិភាក្សាចុងក្រោយនោះគឺ នឹងនិយាយអំពីផ្នត់គំនិតរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទឹកចិត្តរបស់គាត់ និងសេចក្តីរំពឹងទុករបស់គាត់ទាំងអស់គ្នា។ ម៉ាទីន ហ្សាកកាំង នឹងលើកឡើងជូនលោកលោកស្រីចៅក្រម អំពីអត្តចរិតរបស់ជនរបស់ជនរងគ្រោះ។ លោកស្រីនឹងប្រាប់អំពីអត្តសញ្ញាណរបស់អ្នកទាំងនេះ អំពីប្រវត្តិ និងដំណើររឿងរ៉ាវរបស់គាត់ទាំងអស់នេះ។ កញ្ញា ម៉ុច សុវណ្ណារី នឹងប្រាប់អំពីទម្រង់នៃសំណងជំងឺចិត្ត ដែលយើងបានពិចារណាទាំងអស់គ្នានៅក្នុងលក្ខណៈមួយ ដែលថាតើសំណងនោះនឹងត្រូវបានផ្តល់ដោយរបៀបណានោះ? ហើយខ្ញុំក៏សូមជូនអានជូនទៅដល់តុលាការ ក៏ដូច

ជាសាធារណជន ហើយខ្ញុំស្វាគមន៍ទៅបដិបក្ខរបស់ខ្ញុំផងដែរ នៅក្នុងពេលខ្ញុំថ្លែង សេចក្ដីថ្លែងទាំងស្រុងនេះ តំណាងឲ្យជនរងគ្រោះ។

យើងបានបំពេញកិច្ចការជាមេធាវីនេះគឺថាដោយគ្មាននឿយណាយបន្តិចណាសោះឡើយ។ វាជាកិច្ចការមួយដ៏មានសារសំខាន់ទាំងអស់ ដែលត្រូវនាំនូវជនរងគ្រោះទាំងអស់គ្នា ហើយជាពិសេសបំផុតនោះ ដើម្បីកំណត់ឲ្យច្បាស់អំពីសេចក្ដីសង្ឃឹមរបស់គាត់។ ឋានៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានផ្ដល់ជូនទៅពួកគាត់ នៅជុំវិញបរិបទនៃតុលាការព្រហ្មទណ្ឌអន្តរជាតិគឺជារឿងមួយថ្មី ហើយយើងអាចលើកឡើងជូនតុលាការនៅក្នុងចំណុចនេះ ដោយសារយើងមានអង្គការជាច្រើនបានជួយយើង។ មានអង្គការអន្តរជាតិ អាជ្ញាធរកម្ពុជា រដ្ឋាភិបាល និងថៅក្រុមផងដែរ។ ការស៊ើបអង្កេតនៅក្នុងរឿងក្ដីនេះគឺមានរយៈពេលវែង ហើយនិងមានលក្ខណៈផ្ចិតផ្ចង់។ តុលាការ នេះវាស់វែងអំពីវិសាលភាព ឬក៏ទំហំនៃព្រឹត្តិការណ៍ទាំងឡាយដែលជាកម្មវត្ថុនៃសវនាការបញ្ចប់ការពិភាក្សាដេញដោលនៅថ្ងៃនេះ។ ហើយឥឡូវនេះ គឺវាស្ថិតនៅក្នុងជំហារមួយដែលអង្គជំនុំជម្រះត្រូវធ្វើសេចក្ដីសម្រេច។

[១៣:៣៩:២២]

ដូច្នេះ ថាតើក្នុងចំណុចនេះ យើងមានតួនាទីអ្វី យើងខ្ញុំនឹងមិននិយាយអ្វីពាក់ព័ន្ធទៅនឹងបញ្ហាព្រហ្មទណ្ឌនៅក្នុងរឿងក្ដីនេះទេ។ យើងសន្យាថានឹងមិននិយាយបញ្ហានេះទេ តាមការពិត គឺយើងត្រូវបានហាមឃាត់មិនឲ្យនិយាយបញ្ហានេះទេ។ យើងនឹងនិយាយអំពីបញ្ហារដ្ឋប្បវេណី យើងនឹងពិភាក្សាអំពីការទទួលខុសត្រូវ ហើយនិងការឈឺចាប់ដែលបានទទួលរង។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា យើងអាចជួយតុលាការនេះ ដើម្បីធានានូវភាពត្រឹមត្រូវនៃដំណើរការជំនុំជម្រះក្ដី មេធាវីគឺជាមន្ត្រីរបស់តុលាការ។ មេធាវីមិនមែនជាអ្នកបង្កឧបសគ្គទៅដល់តុលាការទេ ហើយមេធាវីពិតណាស់ថា ក៏មិនមែនជាសត្រូវរបស់តុលាការដែរ។ ជំហារនិងពាក្យសម្ដីឬរបស់ជនរងគ្រោះនៅក្នុងថ្ងៃនេះ គឺជាលទ្ធផលនៃដំណើរការដ៏វែងអន្លាយដែលមានការគិតគូររយៈពេលជាយូរមកហើយ។ យើងត្រូវគិត-- គឺថាចេះបញ្ឆោតទៅដល់ខ្លួនឯង គឺទីមួយ ប្រតិកម្មរបស់មនុស្សយើងគឺថាវាមានសភាវគតិ។ ដើមបណ្ដឹងរដ្ឋប្បវេណីគាត់បានប្រាប់ខ្ញុំថា អ៊ីចេះ "ឌុច ត្រូវតែទទួលរងការឈឺចាប់ឲ្យដូចគ្នាទៅនឹងការប្រព្រឹត្តិដែលយើងបានទទួល"។ ហើយយើងត្រូវតែបញ្ចេញសម្ដែងចំពោះប្រតិកម្មទាំងអស់នេះ ហើយយើងត្រូវតែមានភាពក្លាហានដើម្បីបញ្ចេញនិងស្ដាប់នូវចម្លើយទាំងអស់នេះ។ ប៉ុន្តែ យើងត្រូវតែខំពុះពារចំពោះកិច្ចការនេះ។ នៅពេលនេះហើយទើបយុត្តិធម៌នឹងកើតមានឡើង គឺមិនមែនភាពសាហាវយង់ឃ្នងនោះទេ។

ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យើងមានបំណងចង់ឆ្លើយតបជាមួយនឹងពាក្យពេចន៍ដែលយើងនិយាយទៅកាន់មនុស្សជាតិទាំងអស់គ្នា។ លោកជាជនជាប់ចោទ ខ្ញុំបានស្តាប់រួចមកហើយ ឬក៏បានអានហើយ បានអានយ៉ាងជិតដិតបំផុតទៅក្នុងសេចក្តីថ្លែងរបស់លោក ពេលវេលារបស់ខ្ញុំខ្លីណាស់ ខ្ញុំនឹងអានដោយមិនថែមពាក្យពេចន៍អ្វីមួយម៉ាត់ទេទៅនឹងសេចក្តីថ្លែងរបស់លោក លោកបាននិយាយថា "ខ្ញុំជាមនុស្សហ្មត់ចត់ខ្ញុំអាចធ្វើកិច្ចការអ្វីបានល្អៗឥតខ្ចោះ ឬក៏ខ្ញុំអាចមិនធ្វើក៏បាន។ គោលបំណងគឺដើម្បីបណ្តុះបណ្តាលឲ្យមានភាពឃោរឃៅ យើងបានបណ្តុះបណ្តាលមនុស្សឲ្យក្លាយទៅជាសមាគមរបស់សមាគមយុវជន ដើម្បីឲ្យធ្វើអ្វីៗទាំងអស់ ដែលពួកគេទទួលបានបញ្ជាឲ្យធ្វើ។ យើងបានបណ្តុះបណ្តាលពួកគេ បង្ហាត់ពួកគេឲ្យចេះសម្លាប់មនុស្ស។ ខ្ញុំទទួលខុសត្រូវចំពោះការអប់រំ ខ្ញុំបានបណ្តុះបណ្តាលអំពីវិធីធ្វើទារុណកម្មបក្សជឿទុកចិត្តលើខ្ញុំ។ ការទទួលខុសត្រូវរបស់ខ្ញុំផ្ទាល់នោះគឺមានដូចខាងក្រោមនេះ ទទួលបានចម្លើយសារភាព រៀបចំរបាយការណ៍ទាំងឡាយដោយយោងទៅលើមូលដ្ឋាននៃការឆ្លើយសារភាព ចំពោះអ្នកដែលត្រូវបានធ្វើទារុណកម្ម ចារទៅលើចម្លើយសារភាព អប់រំ ហើយនិងសួរចម្លើយ ហើយនិងវាយប្រហារទៅលើមនុស្ស ទទួលចម្លើយសារភាព។ នេះគឺជាកាតព្វកិច្ចរបស់ខ្ញុំហើយ"។

[១៣:៤៣:១៧]

ហើយយោងទៅលើអ្នកដែល បើតាមលោកដឹងថា មិនបានចែករំលែកចំពោះមនោគមវិជ្ជាជាមួយ លោកនិយាយថា "ពួកអ្នកទាំងនោះគឺជា ដង្កូវស៊ីរូងផ្ទៃក្នុងដែលត្រូវតែដកហូតចេញ។ ហើយថ្នាក់លើទុកចិត្តខ្ញុំមិនមែនទុកចិត្តទៅលើអ្នកដទៃទេ។ មិនមានអ្នកណាម្នាក់អាចប្រព្រឹត្តកម្មឲ្យបានជាឧក្រិដ្ឋកម្មច្រើន ដូចដែលខ្ញុំបានធ្វើទេ"។ ហើយខ្ញុំសូមផ្អាកត្រឹមនេះសិន ដែលខ្ញុំបានដកស្រង់សម្តីលោក ឌុច លោកបានធ្វើការសុំទោសទៅកាន់ប្រជាជនរបស់លោកនៅថ្ងៃទី២៩ ខែមេសា ដែលលោកនិយាយថា "យុត្តិធម៌អាចនឹងផ្តល់ដល់ប្រជាជនកម្ពុជា គឺអ្នកទាំងឡាយណាដែលបានរស់រានមានជីវិតពីរបបដ៏គួរឲ្យមហាសែនរន្ធត់នេះ"។ ដូច្នេះ ខ្ញុំក៏សូមសួរខ្លួនឯងផងដែរថា ថាតើការភ្ញាក់រឭករបស់លោកហ្នឹងគឺស្មោះត្រង់ទេ? លោកបានសម្រក់ទឹកភ្នែកបង្ហូរទឹកភ្នែក នៅពេលការធ្វើត្រាប់ឡើងវិញ នៅក្នុងដំណាក់កាលដំបូង នៅដំណាក់កាលចាប់ផ្តើមដំបូង។ "សុំទោស" មានន័យថា ការយល់ដឹង និងការសន្និដ្ឋានទៅលើការទទួលខុសត្រូវ ការបញ្ចប់សវនាការ នេះគឺតំណាងឲ្យភាពក្លាហានពិតប្រាកដមែន។ ហើយខ្ញុំអាចលើកឡើងថា នៅក្នុងអំឡុងនៃដំណាក់កាលនីតិវិធី លោកបានដាក់ពាក្យសុំឲ្យមានការដោះលែង។

ដើម្បីក្រឡេកមើល ស្តាប់មើលឃើញ អ្នកដែលធ្លាប់បានទទួលការធ្វើទារុណកម្ម គឺដើម្បីបញ្ឈប់ទៅលើការគិតថា មនុស្សជាវត្ថុអ្វីមួយ ដែលមានន័យថា ជនរងគ្រោះត្រូវបានអនុញ្ញាតឲ្យទទួលបាននូវសេចក្តីថ្លៃថ្នូរបស់ខ្លួនឡើងវិញ។ ដូច្នេះ ឌុច មើលទៅលើបុរសស្ត្រីទាំងអស់នោះ ដែលអ្នកឯងគិតថានឹងកម្ទេចចោល ឬដែលគាត់ ឪពុកម្តាយរបស់គាត់ទាំងអស់ហ្នឹង ឬក៏សហព័ន្ធ ប្តីប្រពន្ធរបស់គាត់ទាំងអស់ហ្នឹង កូនចៅរបស់គាត់ទាំងអស់ហ្នឹង គឺថាអ្នកត្រូវកម្ទេចចោល។ លោកអាចកម្ទេច ឬ កម្ទេចសត្វល្អិតៗ ឬក៏កម្ទេចសត្វពាហនៈបាន ប៉ុន្តែលោកមិនអាចកម្ទេចមនុស្សទាំងអស់បានទេ ដោយសារមានថ្ងៃគេនឹងងើបក្រោឈរឡើងតាមរូបភាពណាមួយ ទោះជាតាមរយៈអ្នកស្នង ឬក៏ទាយាទរបស់គាត់ ដែលនឹងត្រូវទាមទារនូវការក្រោកឈរនេះ។

លោកមានការជឿជាក់យ៉ាងមុតមាំនៅក្នុងព្រះពុទ្ធសាសនា ហើយក៏ក្រោយមកក្លាយបានទៅជាអ្នកកាន់គ្រិស្តសាសនា។ នៅក្នុងសាសនាទាំងពីរហ្នឹង គឺថាដួងព្រលឹងមនុស្ស គឺថាមិនសំខាន់ទេ បើខ្លួនប្រាណរបស់មនុស្សមិនល្អទេនោះ។ មនុស្សយើងកើតមក គឺថាត្រូវមានភាពស្មើគ្នា មិនមានភាពស្មើដូចគាត់ទេ។ មនុស្សកើតមកត្រូវមានភាពស្មើៗគ្នា ដោយសារគេអាចគិត អាចមានអារម្មណ៍ អាចទទួលរងការឈឺចាប់ ហើយមនុស្សក៏នឹងផ្តល់នូវការអនុគ្រោះបានផងដែរ។ ហើយដោយសារតែការសម្លឹងមិនដាក់ភ្នែកនេះ ដែលមាននៅទីនេះ។ ចាប់តាំងពីដើមដំបូងមក ប្រហែលជនរងគ្រោះរបស់លោកនឹងអនុគ្រោះឲ្យលោក ក្រោយពីសវនាការនេះបានបញ្ចប់ទៅ ប្រហែលជាអាច។ ប៉ុន្តែលោកមិនអាចគិតថា តើប្រជាជនទាំងអស់នេះកំពុងតែស្រាវជ្រាវរកអ្វីទេ?

ដំបូងនិងសំខាន់បំផុត គឺថាពួកគាត់ទាំងអស់គ្នាទទួលរងការឈឺចាប់ ជាពិតណាស់ ប៉ុន្តែពួកគាត់ទាំងអស់កំពុងព្យាយាមស្វែងយល់។ ហេតុអីបានជាមនុស្ស ដែលមិនមានស្អីដែលត្រូវអាក្រក់ជាងគ្នានោះ អាចបង្កើតនូវភាពសាហាវយង់ឃ្នងព្រៃផ្សៃបែបនេះ? ហើយថាតើមនុស្សម្នាក់ ជាពិសេសមនុស្សសាមញ្ញធម្មតា ដែលក្នុងពេលជាមួយគ្នា អ្នកខ្លះអាចត្រូវគោរព ហើយអ្នកខ្លះជាមនុស្សដែលគួរឲ្យភ័យខ្លាច? ហេតុអីបានជាការបំពារបំពានភ្លាមៗចូលទៅក្នុងអាយុជីវិតរបស់អ្នកទាំងអស់នេះ តាមរយៈរបបផ្តាច់ការមួយដែលបានបង្កឲ្យមហន្តរាយទៅដល់ជីវិតរាប់រយ រាប់ពាន់ រាប់លានរហូតឈានទៅដល់សេចក្តីស្លាប់?

[១៣:៤៨:២២]

ហ្វ្រង់ស្វ័រ ប៊ីហ្សូ ដែលជាសាក្សីសំខាន់បានផ្តល់សក្ខីកម្មកាលពីខែមេសា បានបង្រៀនយើងថា

វាគឺជាកំហុសក្នុងការពិចារណាថា អ្នកមិនមែនជាឃាតកនោះ ដោយយោងទៅលើ-- ។ យើងដឹងថា នេះមិនមែនជារឿងមួយធម្មតាទេ។ មេធាវីរបស់លោកនឹងប្រាប់ឲ្យយើងទាំងអស់គ្នា ថាតើគាត់នឹងព្យាយាមអប់រំទៅដល់ការចែករំលែកការទទួលខុសត្រូវដោយរបៀបណា? ពួកគេនឹងធ្វើបញ្ហានេះប្រកបដោយមនសិការ។

ភាគីដើមបណ្តឹងរដ្ឋប្បវេណី គឺទាំងអ្នកសាមញ្ញ អ្នកដែលមានជីវភាពរស់នៅសមរម្យ អ្នកក្រីក្រ អ្នកដែលមិនបានទទួលការអប់រំអ្វីសោះ ឬក៏ផ្ទុយទៅវិញ អ្នកដែលបានទទួលការអប់រំយ៉ាងខ្ពស់ៗបំផុត អ្នកដែលដឹកនាំជីវិតរបស់គេ គឺថាយើងទាំងអស់គ្នាប្រយុទ្ធប្រឆាំងទៅនឹងអ្វីទាំងអស់គ្នានឹងអ្វីដែលត្រូវប្រយុទ្ធប្រឆាំង។ វាជាការតស៊ូក្នុងលក្ខណៈជាសាកល ដែលចែងនៅក្នុងទស្សនទាននៃច្បាប់ ដើម្បីចៀសវាងការធ្លាក់ទៅដល់ការចាត់ទុកមនុស្សថា ជាសត្វបន្ត ដែលយើងទាំងអស់គ្នាត្រូវបន្តកើតទៅជាមនុស្ស។ បន្តកើតជាមនុស្សប្រុស មនុស្សស្រី ដែលមានន័យថា អ្នកមិនបានបំផ្លិចបំផ្លាញដោយចេតនាដោយឆន្ទៈនូវសហការី ដែលជាមនុស្សល្អក្នុងនាមឲ្យសាសនាមួយ ឬក៏មនោគមវិជ្ជាមួយនោះ។ អ្នកទាំងនឹងត្រូវបានបន្ទាបបន្ថោក ត្រូវបានប្រព្រឹត្ត-- ការប្រព្រឹត្តិមកលើពួកគេដោយការប្រមាថ វាជាការបន្ទាបបន្ថោកមនុស្សរួចស្រេចទៅហើយ។

ដូចដែលខ្ញុំបានអានពីសារភាពព័ត៌មាន ដែលដើមបណ្តឹងរដ្ឋប្បវេណីថា ដើមបណ្តឹងរដ្ឋប្បវេណីគឺថាមានរប៉ាត់រប៉ាយនៅក្នុងសវនាការនេះ វាជាការពិតណាស់។ លោក ការីម ខាន បានរំឭកហើយពីព្រឹកមិញនេះថា គឺថានៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ វាបានបង្កើតនូវប្រព័ន្ធថ្មីនៅទីនេះ ហើយដូច្នេះវាមិនមែនជារឿងមួយងាយដែលក្នុងការចូលរួមទាំងអស់គ្នាទេ។ ការរិះគន់វាជាការងាយទេ។

ប៉ុន្តែ វានេះជាឱកាសមួយដ៏ត្រឹមត្រូវហើយ ដែលត្រូវរិះគន់ទៅលើអ្នកដែលមានចេតនាបង្កើតឲ្យមានសវនាការនេះឡើង។ តើនេះគឺជាសារដែលគួរតែផ្តល់ជូនទៅដល់អ្នកដែលអស់សង្ឃឹម អ្នកដែលខិតខំពុះពារគ្រប់បញ្ហាទាំងអស់ ដើម្បីទទួលនូវការស្វែងយល់ និងអ្នកដែលខិតខំប្រឹងប្រែងស្វែងរកយុត្តិធម៌?

ខ្ញុំសូមមិនអាននូវសេចក្តីថ្លែងទាំងអស់នេះនោះទេ ដែលមានចេតនាក្នុងការធ្វើឲ្យប្រព័ន្ធនេះឲ្យមានលក្ខណៈល្អប្រសើរឡើង។ វិធីទាំងឡាយណាដែលមានការពិចារណាមិនបានល្អិតល្អន់ ខ្ញុំបានឃើញការជំទាស់តវ៉ាដ៏គួរឲ្យភ្ញាក់ផ្អើលមួយ នៅពេលថ្មីៗនេះ វាជាការចាំបាច់ណាស់ ដែលថាឥឡូវនេះសម្រាប់ជនរងគ្រោះ ដែលមានសិទ្ធិផ្តល់ចម្លើយនៅក្នុងដំណាក់ជាក់លាក់មួយក្នុងដំណើរការនីតិវិធី

ហើយឥឡូវគេទាំងអស់នោះត្រូវនៅស្ងាត់ស្ងៀមទៅវិញ បែរជាត្រឡប់នៅស្ងាត់ស្ងៀម។ គេអាចក្លាយទៅជា-- គួរតែក្លាយទៅជាមិនអាចប៉ះពាល់បាន គួរតែទទួលបាននូវការគោរព ប៉ុន្តែមិនត្រូវឲ្យមានការនៅស្ងៀមស្ងាត់នោះទេ។

[១៣:៥២:៣៣]

តើយើងគួរលាក់បំបាំងពួកគេទេ? ថាតើមេធាវីការពារមានបំណងថា ចំណុចនេះនឹងមិនគួរកើតមានឡើងតាមរូបណាមួយនោះឡើយ។ ប្រសិនបើអ្នកណាម្នាក់មិនចង់ឲ្យក្លាយទៅជនរងគ្រោះនៃប្រវត្តិសាស្ត្រទេ។ នោះត្រូវតែស្វះស្វែងព្យាយាមយល់បញ្ហានេះបន្តិច។ ដើមបណ្ដឹងរដ្ឋប្បវេណី គឺបានធ្វើបែបនេះហើយ គេមានបំណងបន្តទៅទៀត គេមិនមានអារម្មណ៍ខឹងសម្បាស្អប់ខ្ពើម គេមិនមានអារម្មណ៍សងសឹក។ ពួកគាត់ទាំងអស់គ្រាន់តែចង់ឲ្យបានថាប្រវត្តិសាស្ត្រត្រូវតែមានការកសាងប្រវត្តិសាស្ត្រឡើងវិញ គ្មានអ្វីអាចកើតមានឡើងដដែលដូចគ្នានេះទេ។ ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នេះកំពុងតែក្លាយទៅជាអ្នកតាមដានមើលប្រកបដោយភាពវៃឆ្លាត។ នៅពេលណាដែលគេមានគោលបំណងធ្វើឲ្យបុរស ឬស្ត្រីណាម្នាក់នៅស្ងៀម បំបិទមាត់មនុស្សណាម្នាក់នោះ ឌុច ថ្មីនឹងងើបឡើងហើយ។ ជនរងគ្រោះបានកំណត់អត្តសញ្ញាណ បង្ហាញនូវការឈឺចាប់។ ក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី ពួកគាត់បានរៀនបានយល់ដឹងយ៉ាងច្រើន ថាតើសំណងបែបណាដែលវាអាចនឹងកើតមានទៅបាននោះ?

យើងនិយាយទាក់ទងតែទៅនឹងបញ្ហាទម្រង់នៃសំណងជំងឺចិត្ត។ ក្រុមរបស់យើងខ្ញុំនឹងនិយាយអូសបន្លាយបន្តិចទៅលើបញ្ហានេះ ខ្ញុំនឹងគោរពទៅលើគោលការណ៍ទាំងអស់ដែលបានលើកឡើង និងដែលបានដាក់ជូនតុលាការនេះ។ ខ្ញុំបានចូលរួមនៅក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីឈានទៅដល់ទីបញ្ចប់។ ប៉ុន្តែខ្ញុំមានបំណងចែករំលែកនូវអារម្មណ៍ផ្ទាល់។ សំណងដ៏មានតម្លៃបំផុត គឺប្រហែលជាវត្តមានរបស់គាត់ទាំងអស់គ្នា ដែលត្រូវមានវត្តមាននៅទីនេះ។ វាគឺជាការទទួលស្គាល់នូវសិទ្ធិរបស់ពួកគាត់ ការសាមគ្គីភាពរបស់ពួកគាត់ ការបើកឱកាសជូនឲ្យដល់ពួកគាត់។

តុលាការនេះ ដែលបណ្ដាជនទាំងឡាយណាបានចូលបរិច្ចាគ ដើម្បីបង្កើតនាំមុខនូវភាពមនុស្សធម៌ ជូនកាល-- ជាពិសេសសមាសភាពនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនឹងកំណត់នូវតុលាការកូនកាត់មួយថ្មី។ អ្វីដែលខ្ញុំចង់និយាយត្រង់ចំណុចនេះ គឺយុត្តាធិការជាតិដែលបានអានឡើង ជាអត្ថិភាព គឺជាអត្ថិភាព ក៏ប៉ុន្តែក៏ត្រូវមានសមាសភាពអន្តរជាតិផងដែរ ដូចជា ការរីកចម្រើនទាក់ទងនឹងបង្កើតនូវអង្គភាពជនរងគ្រោះ ដែលមានសារសំខាន់ដូចគ្នាទៅនឹងក្រុមមេធាវីការពារក្ដី ដែលត្រូវផ្ដល់ទាំងសម្ភារៈ

ពិតប្រាកដ ក៏ដូចជាជំនួសផ្នែកខាងចិត្តសាស្ត្រ និងសម្ភារៈពិតប្រាកដចំពោះជនរងគ្រោះ ដែលទទួលរងគ្រោះដោយសារអំពើឃោរឃៅនេះ។

[១៣:៥៦:០៥]

ហេតុដូច្នេះឯង ខ្ញុំកំពុងតែជួយតម្រែតម្រង់ចំពោះសេចក្ដីសង្ឃឹមពិតៗនេះ ហើយនៅក្នុងវត្តមានរបស់កញ្ញា សុវណ្ណារី នេះ។ កញ្ញាជាមេធាវីជនជាតិកម្ពុជា មានអាយុ២៥ឆ្នាំ កញ្ញាមានភាពអង់អាចក្លាហានចូលរួមនៅក្នុងដំណើរការនីតិវិធីនេះ កញ្ញាតំណាងឲ្យយុវជន ហើយដែលខ្ញុំធ្លាប់បានកំពុងតែជួបប្រទះការលំបាករយៈពេលបីឆ្នាំហើយ ក្នុងពេលដែលផ្ដល់ការបណ្ដុះបណ្ដាលទៅដល់តុលាការក្មេងៗ មេធាវីក្មេងនៅក្នុងប្រទេសកម្ពុជា តាំងនាមឲ្យមេធាវីគ្មានព្រំដែនរបស់បារាំង ដោយមានការយល់ព្រមពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងប្រធាននៃគណៈមេធាវីនេះ។

ប្រទេសក្រីក្រមួយនេះ លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ បានលើកឡើង នៅពេលដែលគាត់និយាយអំពីប្រទេសកម្ពុជា។ ប្រទេសដ៏សំខាន់មួយនេះ ខ្ញុំអាចនិយាយបានថាអ៊ីចឹង។ ដូចដែលខ្ញុំបានដឹងថាតើប្រជាជនទាំងអស់កំពុងតែក្រោកឈរយ៉ាងរឹងមាំនៅខាងពីក្រោយសេចក្ដីសង្ឃឹម និងពាក់ព័ន្ធទៅនឹងសេរីភាពរបស់ពួកគាត់ ហើយយើងមិនត្រូវកម្ទេចពួកគាត់ម្ដងទៀតទេ។ ការផ្សះផ្សាជាតិ គឺជាសារមួយដ៏មានសារសំខាន់ វាជាមាគ៌ាដែលយើងត្រូវប្រកាន់ខ្ជាប់ចំពោះកាតព្វដែលត្រូវធ្វើការកត់សម្គាល់។ ប៉ុន្តែ ការផ្សះផ្សាគួរតែឆ្លងកាត់តាមរយៈសវនាការនេះ វាត្រូវតែរួមមានជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណី រួមជាមួយវាសនារបស់អនាគតដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវប្រឈមនឹងកិច្ចការថ្មីៗជាច្រើន ដើម្បីចូលរួមចំណែកបន្តទៅទៀតនៅក្នុងដំណើរការនៃការផ្សះផ្សាជាតិ។

នៅដើមដំបូងៗនៃការស្តួរចម្លើយ ខ្ញុំសូមដកស្រង់សម្ដីរបស់លោកជាភាសាបារាំង ហើយខ្ញុំនឹងដកគោលជំហរនេះម្ដងទៀត។ ពាក្យថា យំសោក និងការបន់ស្រន់ គឺជាភាពកំសាក ចូរអ្នកធ្វើការងារដ៏លំបាក ហើយនិងល្អចុះ ពីព្រោះព្រេងវាសនាមិនអនុញ្ញាតឲ្យអ្នកតវ៉ាអ្វីឡើយ ទោះបីឈឺចាប់ ឬក៏ស្លាប់ក៏មិនថ្ងូរមួយម៉ាត់ដែរ។ ហើយលោកបានប្រកាន់ទៅតាមកំណាព្យនេះហើយ ការពិតហើយយើង គឺជាកំណាព្យដ៏ល្បីមួយជាភាសាបារាំង ដែលអ្នកកំណាព្យឈ្មោះ អាល់ហ្វ្រេត ដឺ វិញី ជាមរណភាពរបស់ចចក។ តើលោកដឹងដែរឬទេ លោកបានប្រកាន់យកនូវអ្វីដែលថាជាចំណុចគ្រោះថ្នាក់ណាស់នៅក្នុងកំពាព្យនេះ? អ្វីដែលវាមានការឈឺចាប់ ឬក៏ភាពជូរចត់បំផុតនៅក្នុងនោះ ដែលបង្កប់នៅក្នុងនោះ គឺមិនបានផ្ដល់ឱកាសអ្វីមួយដល់មនុស្សជាតិនោះទេ។ លោកបានដកចេញនូវអ្វីៗដែលលោកបន្តជីវិតរបស់

លោកហ្នឹងខុសពីជនដែលលោកត្រូវគ្រប់គ្រង ដែលវាខុសពីលក្ខណៈមនុស្សធម៌ ដែលថាមនុស្សលោកត្រូវតែមានគោលការណ៍មនុស្សលោកក្នុងលក្ខណៈជាបុរស។ ឥឡូវនេះនៅពេលដែលលោកស្ថិតនៅក្នុងការជំនុំជម្រះពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ហើយលោកបានយោងទៅរកកំណាព្យមួយដែលចំណុចមួយចំនួន គឺគោរពទៅតាមគោលការណ៍មនុស្សធម៌។ នេះជាចំណុចសំខាន់ណាស់ វាមានលទ្ធភាពពីរទីមួយ លោកគិតថា លោកត្រូវតែស្លាប់ដោយមិននិយាយអ្វីតែសោះ នៅពេលដែលលោកបំពេញការងារក្នុងជីវិតរបស់លោកនោះ។

[១៤:00:00]

ដូច្នេះ ខ្ញុំសួរខ្លួនឯងថា តើៗអ្វីជាវិភាគទានរបស់លោកនៅក្នុងដំណាក់កាលនេះ តាំងពីចំណុចចាប់ផ្តើមមកនោះ? លោកបានព្យាយាមដោយចំហ បាននិយាយឲ្យគេស្តាប់ទៅពីរោះ សឹងតែសម្រាន្តលក់។

ផ្អែកលើមូលដ្ឋានសេចក្តីដកស្រង់កំណាព្យនេះ ខ្ញុំក៏សួរខ្លួនឯងថា តើអ្វីជាមនុស្សធម៌របស់លោកនៅក្នុងខ្លួនលោកនោះ? នៅក្នុងករណីណាក៏ដោយ តើលោកដឹងដែរឬទេថា នៅទីនេះ គឺភាពខុសគ្នាខាងប្រវត្តិសាស្ត្រដ៏ធំ ដែលធ្វើឲ្យយើងមានការភ្ញាក់ផ្អើល។ យើងមិនមែនមកជំនុំជម្រះនេះ ដើម្បីនិយាយឲ្យពីរោះប៉ុណ្ណោះទេ។ ហើយយើងមិនពិភាក្សាអំពីអក្សរសាស្ត្រនោះទេ ខ្ញុំនិយាយចំពោះលោកអំពីលោកមនុស្សមួយម៉ឺនពីរពាន់នាក់ជាងដែលស្លាប់នៅទួលស្លែង។ អ្នកខ្លះក៏បាននិយាយថា មួយម៉ឺនប្រាំមួយពាន់ទៅទៀតនោះ។

ដូច្នេះ តើអ្វីជាមនោសញ្ចេតនាដែលបង្កប់នៅក្នុងកំណាព្យនេះនោះ? ហើយតាមដែលយើងពិនិត្យពិចារណាទៅ ហើយប្រសិនបើយើងចង់បន្តភ្ជាប់ទៅនឹងការយោងទៅនឹងនៃកំណាព្យនេះ យើងពិចារណាយើងពិចារណាថា លោកក្លាយទៅជាចចកដ៏កំសត់មួយនៅក្នុងកំណាព្យនោះ គឺជាមនុស្សបែបជាចចកប៉ុន្តែលោកមិនមែនជាមរណភាព ដូចជាស្ថិតនៅក្នុងមរណភាពដូចចចកនោះទេ។ ហើយខ្ញុំនឹងបញ្ចប់ក្នុងរយៈពេលឥឡូវនេះលោកប្រធាន។

អត្ថបទមួយផ្សេងទៀត ដែលខ្ញុំបានរកឃើញថា វាមានលក្ខណៈជាប្រលោមលោក ជាកំណាព្យគឺជា បុព្វកថានៃប្រទេសរបស់លោក ហើយមុននឹងសរសេរបុព្វកថានៃរដ្ឋធម្មនុញ្ញ គេនិយាយថា យើងប្រជាជនរាស្ត្រខ្មែរ មានធ្លាប់មានអរិយធម៌ឧត្តុង្គឧត្តម ប្រទេសជាតិស្តុកស្តម្ភ ធំទូលាយ ថ្កុំថ្កើង រុងរឿងកិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺចែងចាំង ដូចជាពេជ្រពណ្ណរាយ។ បានធ្លាក់ខ្លួនដ៏សែនរន្ធត់ក្នុងអំឡុងពីរទសវត្សរ៍

ចុងក្រោយនេះ។ ឆ្លងកាត់ទុក្ខសោកវេទនា អន្តរាយ ទ្រុឌទ្រោម និងថយ មហាសោក មហាសោក ស្តាយបានភ្ញាក់រឭកក្រោកឈរឡើង និងចងបាច់ឆន្ទៈមោះមុតប្តូរផ្តាច់ រួមគ្នាបង្រឹងឯកភាព រក្សាការពារទឹកដីកម្ពុជាអធិបតេយ្យ ថ្លៃថ្លា និងអធិបតេយ្យដ៏ខ្ពង់ខ្ពស់ នេះជាចំណុចដ៏សំខាន់គួរឲ្យចងចាំថា គឺរូបភាព ហើយដែលខ្ញុំចាំនៅក្នុងបញ្ញារបស់ខ្ញុំនោះ។ មិនមែនចំណុចមួយដែលនិយាយអំពីទារុណកម្មនោះទេ។

សូមអរគុណអង្គជំនុំជម្រះ។ សូមអរគុណលោក លោកស្រី ចៅក្រម ចំពោះការយកចិត្តទុកដាក់ស្តាប់ ហើយនិងបានផ្តល់សិទ្ធិឲ្យខ្ញុំបានក្រោកឈរនៅទីនេះ ដើម្បីនិយាយ។ ឥឡូវនេះ ខ្ញុំនឹងជូនវេទិកាទៅកញ្ញា មេធាវី ហ្សាកកាំង ហើយគាត់ត្រូវការពីរបីវិនាទី ដើម្បីរៀបចំ។

[១៤:០៣:៥៧]

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមគោរពលោកប្រធាន លោក លោកស្រី ចៅក្រម ខ្ញុំសូមអនុញ្ញាត ហើយនិងសូមសម្តែងការគោរព យើងបានឈរទីនេះ ដើម្បីជម្រាបជូនតុលាការក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី ដែលជាជនរងគ្រោះអំពើរបស់លោក ឌុច ដែលទទួលការជំនុំជម្រះថ្ងៃនេះ។ ដូច្នេះ ថ្ងៃនេះយើងមានការលំបាក ដើម្បីរំឭកពី វិញ្ញាណក្ខន្ធ អាយុ ជីវិត ការឈឺចាប់ ដែលដើមបណ្តឹងរដ្ឋប្បវេណីបានរងគ្រោះនៅស-២១ នោះ។ *ស៊ីម៉ូនវេ (Simone Veil)* គឺរដ្ឋមន្ត្រីរបស់បារាំង បានចូលទៅហ្វឹងមិនឈប់ មន្ទីរឃុំឃាំងរបស់ណាហ្ស៊ី ហើយគាត់បានត្រលប់មកវិញនៅក្នុងពិភពលោក។ វាមានការប៉ុនប៉ងដើម្បីបំបាត់យើងអំពីមនុស្សឃាត ហើយគាត់ចង់ប្រាប់យើងនូវចំណុចនេះ ហើយក៏យើងបានជួបឡើងវិញអំពីហេតុការណ៍នេះម្តងទៀត។

គឺជាច្រើនឆ្នាំក្រោយមក យើងបានឃើញមានសេចក្តីក្លាហាន ដើម្បីនិយាយបញ្ហានេះ ពីព្រោះថាពិភពលោកបានស្តាប់យើង។ នៅក្នុងមតិរបស់មេធាវីការពារ គឺជាទិដ្ឋភាពសំខាន់ដែលទាក់ទងទៅនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី គេបានប្រកាន់យកប្រទេសកម្ពុជា ដូចប្រទេសផ្សេងៗទៀតដែលទទួលរងនូវបទពិសោធន៍ស្រដៀងគ្នានេះដែរ។

ជាច្រើនទសវត្សរ៍ដែលអនុញ្ញាតឲ្យអ្នករស់រានមានជីវិតបាន ដោយហេតុថា អ្នកធ្វើទារុណកម្មក៏នៅក្នុងចំណោមនោះដែរ។ គេត្រូវតែមានការក្លាហានក្នុងចំណុចពេលមួយដែលគេអាចជួបអ្នកទាំងអស់ អ្នកទាំងឡាយដែលជាអ្នករងការចោទប្រកាន់ពីបទឧក្រិដ្ឋដ៏អាក្រក់នេះ គឺត្រូវពិនិត្យដោយយកចិត្តទុកដាក់ថា តើអ្នកទាំងនោះជាមនុស្សល្អ ឬក៏អាក្រក់?

ដើមបណ្តឹងរដ្ឋប្បវេណី គឺជាចំណុចដំបូងដែលគេតែនិយាយចេញ ថាតើគេប្រកាន់ជំហរណាមួយ? ម៉្យាទៀត គឺថាកូនស្រីរបស់លោក ម៉ាតថា *(Martyrs)* ម្តងទៀត យើងបានឃើញមនុស្សមួយចំនួនដែលជាប្រជាពរដ្ឋ ជាប្រជាពលរដ្ឋដែលចង់បំភ្លេច ឬក៏ចង់ជួយឲ្យអ្នកផ្សេងទៀតបំភ្លេចនូវអ្វីដែលគេទទួលរង។ នៅក្នុងករណីនេះ អ្វីដែលយើងត្រូវធ្វើ គឺគេត្រូវនិយាយ ឌុច លោកស្ថិតនៅក្នុងប្រភេទទីពីរ អ្នកដែលចង់ឲ្យគេបំភ្លេចថា អតីតរបស់ខ្លួនយ៉ាងដូចម្តេច?

[១៤:០៦:៣៣]

ហ្វ្រង់ស្វ័រ ប៊ីស្សូ បាននិយាយថា បានសរសេរថា “ការគោរពទៅតាមអំពើដ៏អាក្រក់ ឬក៏ឃោរឃៅក្នុងភាពស្ងប់ស្ងាត់នោះ ខ្ញុំសង្ស័យថា តើគាត់បានចាត់វិធានការទាក់ទងទៅនឹងអំណាចដ៏អាក្រក់ដែលខ្លួនមាននៅពេលនោះ? គាត់បាននិយាយអំពីលោក លោក ឌុច។ ទីមួយគាត់បាននិយាយថា វាមានមនុស្សធម៌មួយចំនួននៅក្នុងខ្លួនលោក ប៉ុន្តែលោកបានបំភ្លេចចោល ហើយលោកបានដឹងថានៅចំណុចមួយនោះ លោកបានទទួលនូវអំណាចដើម្បីសម្លាប់មនុស្ស ហើយគាត់ឆ្ងល់ថា តើលោកមានមនស្សធម៌នៅក្នុងខ្លួនដែរឬទេ កាលនោះ?

ទៅតាមបច្ចេកទេស ដើម្បីឲ្យឈានដល់ចំណុចដាច់ខាត ទៅតាមការណែនាំផ្ទាល់មកលោកនោះ តាមទស្សនៈរបស់គឺថា លទ្ធិពុទ្ធសាសនានៅក្នុងទូទាំងប្រទេស ប៉ុន្តែអង្គការបានមកជំនួស បំប្លែងថា ខ្លួនធ្វើឲ្យរុងរឿង ប៉ុន្តែប្រទេសទាំងមូលត្រូវបានគេកម្ចាត់ចោល ឲ្យស្ថិតនៅក្នុងទុរ្ភិក្ស ហើយគេអះអាងថា កុំឲ្យមានជនក្បត់នៅក្នុងប្រទេស។ នេះហើយនៅក្នុងចារីទាំងអស់នេះ ជនកំសាកទាំងអស់នេះ ពួកមនុស្សអាក្រក់ទាំងអស់ហ្នឹង គឺទុកដូចជាបីសាច ប៉ុន្តែមុននឹងគេស្លាប់ គេបានមកជួបលោកនៅទីនេះ ហើយគេបានបង្គាប់ឲ្យខ្ញុំនិយាយពេលនេះ។ នេះជាសំឡេងរបស់គេដែលខ្ញុំយកពីគេមក ដើម្បីនិយាយប្រាប់លោកតទៅ ជាសំឡេងដែលនៅសល់ ដែលបន្សល់ពីកូនប្រុស កូនស្រី ទារក និងកុមារទាំងឡាយ។

មកដល់ថ្ងៃនេះ ការជឿជាក់បាននូវពាក្យសម្តីទាំងអស់នោះ គោលបំណងនៃការជំនុំជម្រះនេះ គឺត្រូវបញ្ចប់តែម្តង ហើយឲ្យចប់ជារហូតនូវការបដិសេធនូវជីវិតពិត ឬក៏មនុស្សធម៌នៅកម្ពុជា។ ការចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី គឺជាអ្វី? ជាសំខាន់តាមទស្សនៈមួយដែលថាគេធ្លាប់រងនូវអំពើបំពានប្រសិនបើយើងនិយាយពីមនុស្សឃាត ឬក៏ទារុណកម្ម វាមិនមែនជាផ្នែកមួយនៃការពលី ឬក៏ការបូជានោះ ពីព្រោះថាវាជាកត្តាខុសផ្សេង។ ពីព្រោះថាយើងមិនអាចនិយាយថា យើងធ្វើពលិកម្មដើម្បីប្រទេសដោយសម្លាប់មនុស្សនោះទេ។ អ៊ីចឹងបើការកម្មេចគ្រប់ៗគ្នាទាំងអស់ តើអ្នកណាម្នាក់ថ្ងៃណាមួយអាច

នឹងកសាងអ្វីអ្នករស់បាននោះ? ថ្ងៃនេះគឺថា លោកអាចនឹងនិយាយថា ពួកយើងស្វែងរកការសងសឹក មិនមែនដូច្នោះទេ អ្វីដែលយើងចង់បាននោះគឺយើងចង់និយាយ។ នៅពេលដែលលោកមិនអាចអះអាងបដិសេធបាន។ នេះគឺជាស្ថានភាពដ៏លំបាកមួយដែលថាលោកមានវិបត្តិមួយដែលថាលោកស្រេចឈាម ហើយមិនមែនជាមនុស្សដែលប្រកបដោយសន្តិភាព។ លោកជាមនុស្សឃោរឃៅ ហើយលោកជាអ្នកចងក្រងបង្កើតនូវយន្តការដ៏គ្រោះថ្នាក់នោះ ប៉ុន្តែលោកនិយាយថា លោកមិនមែនស្ថិតនៅក្នុងមនុស្សនោះទេ។ តើយើងអាចកំណត់ដូចម្តេចបានថា តើសោកនាដកម្មក្នុងសតវត្សរ៍ទី២០នេះ យើងអាចបញ្ជាក់ការពិតដូចម្តេចបាន តើយុត្តិធម៌មានដូចម្តេចបាន?

[១៤:១០:១០]

អ៊ីចឹងហើយនេះគឺជាមធ្យោបាយដែលយើងត្រូវយល់អំពីការទទួលស្គាល់ទោះបីជានៅកម្ពុជាមិនមានប្រភេទណាមួយនៃប្រជាពលរដ្ឋកម្ពុជា ដែលចូលដល់ដៃមន្ទីរនោះហើយ ត្រូវបានទុកជីវិតនោះទេ។ អំណាចនៅក្នុងដៃរបស់លោក តើធ្លាប់ទុកជីវិតអ្នកណាឲ្យរស់ដែរឬទេ? នៅក្នុងតុលាការនេះ ដើម្បីជាកិត្តិយស ដូចដែលបានបញ្ជាក់នៅក្នុងអង្គហេតុដែលថា ដើម្បីផ្តល់សំឡេង ដើម្បីគោរពដល់វិញ្ញាណក្ខន្ធ ឬក៏រំឭកអ្នកដែលស្លាប់នោះ តើយើងអាចនិយាយបានដែរឬទេ តើមនុស្ស៥៤០នាក់ហ្នឹង គឺត្រូវស្លាប់ដោយសារការទម្លាប់គ្រាប់បែក? ថាតើនៅក្នុងបរិបទនេះតាំងពីឆ្នាំ១៩៧៣មក ដែលរារាំងមិនឲ្យកម្ពុជាមិនចូលរួមនៅក្នុងសង្គ្រាមនោះ។

មិនមានការដោះសារអ្វីទេ នៅក្នុងការអំពើហិង្សាដែលបណ្តាឡើងដោយបស្ចិមប្រទេសទេ គឺឬក៏និយាយថា ទស្សនវិទូដែល-- ទស្សនវិជ្ជាដែលចេញមកបស្ចិមប្រទេសនោះទេ។ ឌុច លោកជាអ្នកបានសិក្សា លោកបានធ្វើការក្នុងសម័យមួយដែលថា មិនមានសាលា មិនមានតុលាការ មិនមានសាស្ត្រាចារ្យ មិនមានសៀវភៅ មិនមានអ្វី សកម្មភាព គឺថា វាមានតែវិន័យ-- មានតែការងារដោយបង្ខំម្តៃប្អូនម៉ោងក្នុងមួយម៉ោង។ល។ អង្គការជាអ្នកសម្រេចអ្វីៗទាំងអស់ គឺវាមានអនាគតមួយដែលមាននិយាយនៅក្នុងពេលនោះគឺថា "ទុកមិនចំណេញ ដកចេញក៏មិនខាត" នេះជាពាក្យស្លោកនាកាលនោះ។

តើយើងអាចនិយាយបានទេ អ្វីៗដែលបានបញ្ជាក់នៅក្នុងតុលាការនេះមិនទាន់និយាយអស់នៅឡើយទេ នៅមានច្រើនណាស់។ ខ្ញុំមិនអាចនិយាយតែប៉ុណ្ណេះដោយចប់នោះទេ ពីព្រោះថាមិនមានករណីពីមុនៗមនទេនៅកម្ពុជានោះ។ ដូច្នេះគោលបំណងថ្ងៃនេះ គឺគោលបំណងមួយនៃអង្គជំនុំជម្រះនេះដែលដើមបណ្តឹងរដ្ឋប្បវេណីមានការព្រួយបារម្ភនោះ សាមសិបឆ្នាំក្រោយមក សំឡេងត្រូវបានផ្តល់ទៅ

ឲ្យអ្នកដែលគេបំបិទមាត់ មនុស្សដែលមិនអាចនិយាយ ឥឡូវនេះអាចនិយាយ។ ឥឡូវនេះយើងមានលទ្ធភាពឲ្យកូនប្រុស កូនស្រី របស់គេដែលទទួលរងទារុណកម្ម ហើយនិងត្រូវបានគេវះពោះសម្លាប់ ហើយតុលាការបានស្តាប់ពួកគេ នេះគឺជាទិដ្ឋភាពដ៏សំខាន់។ លោក ឌុច លោកមើលមុខយើងថ្ងៃនេះ ហើយលោកប្រាប់យើងថា លោកជាមនុស្សថ្មី។ លោកបាននិយាយថា លោករកឃើញសំឡេងមួយនៅក្នុងសាសនា ដែលទទួលបាននូវការលើកលែងទោស។ តើការលើកលែងទោសទទួលយកបានទេនៅទីនេះ? តើដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលការអះអាងរបស់លោកបានទេ ចំពោះអ្វីដែលគេទទួលរងបន្ទាប់ពីសាមសិបឆ្នាំក្រោយមកនោះ។ ឥឡូវនេះ គេទើបតែបាននិយាយ តើនេះជាសម្តីសំខាន់របស់គេមិនមែនដោយលោកជាអ្នកអនុញ្ញាតនោះទេ ឬក៏ជាច្បាប់ជាអ្នកអនុញ្ញាត គឺតុលាការអនុញ្ញាតឲ្យ ឬកម្ពុជាជាអ្នកផ្តល់នូវសម្បជញ្ញៈឲ្យគេ។

[១៤:១៣:២១]

ប៉ុន្តែជាទស្សនៈមួយដែលផ្ទុយពីមនសិការអាក្រក់ នេះជាសំខាន់ណាស់ដែលយើងត្រូវចាំ យើងមិនអាចដឹងជាការពិតច្បាស់ប៉ុនណាទេ ប៉ុន្តែពួកគេបាននិយាយ ហើយសំឡេងត្រូវបានឮទៅដល់អង្គចៅក្រម។ ខ្ញុំស្ថិតនៅក្នុងក្រុមមួយដែលមាន ២៨នាក់នៃដើមបណ្តឹងរដ្ឋប្បវេណីដែលស្ថិតនៅក្នុងចំណោមមនុស្ស ១២០០០នាក់ ឬក៏ ១០០០៦នាក់ នៅទួលស្លែង។ ខ្ញុំនឹងលើកឡើងសម្តីរបស់ដើមបណ្តឹងរដ្ឋប្បវេ-ណីជាជនរងគ្រោះមួយរូបនៅក្នុងក្រុមរបស់ខ្ញុំ គឺថាយើងបានឃើញម្នាក់ដែលថាគាត់មានសេចក្តីក្លាហាន ប៉ុន្តែគាត់មានការលំបាកគឺជនរងគ្រោះមិនរក្សារហស្សនាមជាការសម្ងាត់ទេ គឺយើងនិយាយស្ត្រី កុមារ បុរស ហើយគេមានគ្រួសារ ហើយគេមានជីវិត គេមានសិទ្ធិរស់រានមានជីវិត។ ជនរងគ្រោះត្រូវតែវត្តមាននៅក្នុងៗនៅក្នុងការសម្រេចរបស់តុលាការ គឺការវិភាគចុងក្រោយ គឺថាភាពវក់វង់របស់មនុស្សមួយ គឺថាវាអាចស្ថិតនៅក្នុងបរិបទមនោគមវិជ្ជា ប៉ុន្តែមិនគប្បីនាំឲ្យមនុស្ស បុរស ស្ត្រី រាប់មួយលានដែលបាត់បង់ជីវិតដោយសារភាពងប់ងល់របស់ខ្លួននោះទេ។ ដូច្នេះ ខ្ញុំសូម-- ខ្ញុំចង់អនុញ្ញាតបង្ហាញជនរងគ្រោះមួយចំនួន។ សូមអនុញ្ញាតលោកប្រធាន។

[១៤:១៥:០៣]

**ប្រធានអង្គជំនុំ៖**

ខាងសោតទស្សន៍សូមពិនិត្យបច្ចេកទេស ឥឡូវហ្នឹងអត់ឮសំឡេងទេ។ សូមអញ្ជើញ!

ឥឡូវនេះអង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំ ប៉ុន្តែអង្គជំនុំជម្រះរក្សាសិទ្ធិនៅក្នុងការបញ្ចប់ត្រឹម

ម៉ោងដែលអង្គជំនុំជម្រះបានអនុញ្ញាត។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមអរគុណលោកប្រធាន។ លោកប្រធានជាទីគោរព, ជាបឋម យើងមានលោក ឃាង សារិន គាត់ចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី ចំពោះការឃុំខ្លួនពូរបស់គាត់ ឃិន សារ៉ុត ដែលគាត់ធ្វើការទូតនៅប្រទេសជប៉ុន។ គាត់ត្រឡប់មកប្រទេសកម្ពុជាវិញ តាមរយៈសំណើរបស់រដ្ឋាភិបាលកម្ពុជា គេឃុំខ្លួនគាត់ ហើយគេសម្លាប់គាត់នៅស-២១។ លោកស្រី មាស កេត, លោកស្រី ជូឡុង អង់តូនីញ៉ា, ជូឡុង នេវ៉ា គាត់ចូលរួមជាប្អូនស្រីផងដែរ គាត់ជាអ្នកធ្វើការនៅប្រទេសកម្ពុជា គាត់ធ្វើការនៅប៉ុស្តិ៍វិទ្យុ។ គាត់ត្រូវបានចាប់ខ្លួន ដោយចោទថាជាសេ.អ៊ី.អា សម្លាប់នៅស-២១ ហើយគាត់បានបាត់បង់ជីវិត។ អង់តូនីញ៉ា នេវ៉ា មិនដែលភ្លេចប្អូនស្រីរបស់គាត់នោះទេ ហើយនេះជាកូនដែលយើងមើលឃើញនៅក្នុងរូបភាពនេះផងដែរ។ លោក គីម៉ារី គឺជាប្តីរបស់ រាំងស៊ី ជូឡុង គាត់ស្លាប់នៅស-២១, សាកា និងវិសាកា គាត់ជាក្មេងកំព្រា ដោយសារតែបាត់បង់ឪពុក។ លោកស្រី ចាំង គ័ង ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងនាមជាពូរបស់គាត់ សុខ វិន គាត់គឺជាប្រធានអភិបាលក្រុង ហើយគាត់ត្រូវបានគេសម្លាប់ចោល។ លោក ឡាយ ចាន់ បានមកផ្តល់សក្ខីកម្មចំពោះការឈឺចាប់ដែលគាត់ទទួលរង ដែលជនរងគ្រោះទាក់ទងនឹងគាត់ជាប់នៅស-២១។ លោកស្រី នួន គីមអន បាត់បង់សមាជិកគ្រួសារបីរូប ប្អូនបងប្រុសរបស់លោកស្រីបានបង់ពីរនាក់ ហើយក៏បានបាត់បង់បង ឬប្អូនស្រីថ្លៃផងដែរ។ គឺ ឌឿន ហំ លោកមួយនេះគាត់ចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែមិត្តរបស់គាត់ស្លាប់ គឺលោក ជឿន ដែលអ្នកទាំងអស់នោះត្រូវបានគេឃុំ និងសម្លាប់ចោលនៅស-២១។ លោក ឆាត គីមសុន គាត់បានដាក់ពាក្យចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែការសម្លាប់ឪពុករបស់គាត់។ លោក អន ផាត ហើយនិងតារបស់គាត់ អាន់ សាប៊ិន។ នៅក្នុងរឿងក្តីនេះ ករណីនេះគាត់ក៏បានរកឃើញឯកសារទាក់ទងពូរបស់គាត់ ផាត់ ង៉ុយ ដែលត្រូវបានគេសម្លាប់ចោលនៅស-២១ ផងដែរ។ លោកស្រី សេក សៀក ដែលគាត់រៀបការជាមួយលោក ម៉ុក ចាន់ ការរៀបអាពាហ៍ពិពាហ៍មិនបានទទួលជោគជ័យនោះទេ ដោយសារគូដណ្តឹងរបស់គាត់ត្រូវបានគេសម្លាប់ចោល។

[១៤:១៩:៥៣]

លោកស្រី សូ សួង ចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែការសម្លាប់បង ឬប្អូនថ្លៃប្រុសរបស់គាត់ លោក តុង ស៊ុន ដែលជាអ្នកចិញ្ចឹមរូបលោកស្រី។ លោកស្រី មាស ស៊ុន ចូលរួម

ជាដើមបណ្តឹងរដ្ឋប្បវេណីដោយសារតែប្អូន ឬបងប្រុសថ្លៃរបស់គាត់ អ៊ុង ថោង ត្រូវបានគេសម្លាប់។ លោកស្រី ជិន ម៉េត មកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គសវនាការ ទាក់ទងនឹងលក្ខខណ្ឌឃុំខ្លួនគាត់នៅព្រៃស គាត់នៅមានស្លាកស្នាមនៅលើរូបរាងកាយនៅឡើយនាពេលសព្វថ្ងៃ។ លោកស្រី ស្មៀន ភូ គាត់ចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែការសម្លាប់ប្អូន ឬបងប្រុសរបស់គាត់។ លោក អេក សុខ ចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែពូរបស់គាត់ស្លាប់ ហើយគេបានចោទពូរបស់គាត់ថា បានផ្សព្វផ្សាយព័ត៌មានទាក់ទងទៅនឹងពួកចារកម្ម។ លោកស្រី អាន ស៊ុន ចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែបង ឬប្អូនប្រុសរបស់គាត់ជាទាហាននៅក្នុងរណសេរ្សនៅភូមិកុង។ លោក ម៉ន សុទ្ធា ចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះការសម្លាប់ម្តាយរបស់គាត់ គឺ សែម ឡុកស៊ីម ដែលគាត់ជាអតីតជាលេខាទូតនៅហ្វីលីពីន។ គាត់បានបង្ហាញអំពីការមិនពេញចិត្តរបបខ្មែរក្រហម ហើយបន្ទាប់មកត្រូវបានគេចាប់ខ្លួន ហើយសម្លាប់ចោលនៅស-២១។ លោក ពូ កាន់ ចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ចំពោះការស្លាប់ប្រពន្ធរបស់គាត់ និងបងប្អូនជីដូនមួយរបស់គាត់ ហើយនិងរូបស្លាកស្នាមនៅលើរូបកាយរបស់គាត់ក្រោយពីការជាប់ឃុំខ្លួន។ លោកស្រី សួន សុខុម៉ាលី ចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីបានចូលរួមតំណាងលោក កាសេត ដែលគាត់ជាសមាជិកនៃរដ្ឋសភានៅក្នុងរបប លន់ នល់ ហើយគាត់ក៏តំណាងឲ្យលោក អ៊ឹង ឈិន ដែលជាសមាជិកនៅសភាលន់ នល់ផងដែរ។ ហើយគាត់មិនបានឃើញឪពុកមិត្តរបស់គាត់នោះទេ ក្រោយពីគេចាប់ខ្លួន។ លោកស្រី លើហ្វីវ និង អ៊ុក នារី បានចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី ចំពោះការសម្លាប់ស្វាមី និងឪពុករបស់គាត់ អ៊ុក កេត ដែលគាត់នៅបារាំង ហើយត្រឡប់មកប្រទេសកម្ពុជាតាមសំណើរបស់រដ្ឋាភិបាល ហើយនិងការស្រឡាញ់ប្រទេសជាតិរបស់គាត់ ក្រោយមកគេចាប់ខ្លួនគាត់ ហើយគេសម្លាប់ចោលនៅស-២១។ លោក ម៉ាទីន លើហ្វីវ ហើយនិង អ៊ុក នារី មិនដែលបានភ្លេចនូវស្វាមី និងឪពុករបស់ពួកគេនោះទេ ហើយនៅតែទទួលការឈឺចាប់ដោយសារតែការស្លាប់នោះ។ លោកស្រី មាស សារុន ចូលខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះការស្លាប់ឪពុករបស់ខ្លួន ឈ្មោះ អ៊ុក គឿន ដែលជាទាហាន ហើយគាត់នៅក្នុងស្រុកលេខ៨ ហើយត្រូវបានគេចាប់ ហើយសម្លាប់ចោលនៅស-២១។ នៅចំណុចចុងក្រោយយើងមានលោកស្រី ប៉ាន់ ប៉េស ដែលឃុំខ្លួនប្អូនប្រុសរបស់គាត់ឈ្មោះ លន់ ហ៊ន នៅស-២១។

[១៤:២២:៥៧]

លោកប្រធានទាំងអស់នេះ គឺជាដើមបណ្តឹងរដ្ឋប្បវេណី២៨រូប ដែលយើងជាមេធាវីតំណាង

ហើយខ្ញុំសូមលើកឡើងថា ពួកគេមានសេចក្តីក្លាហានណាស់។ ពួកគេបានចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងប្រទេសកម្ពុជា។ អ្នកដែលជាអ្នកសរសេរនៅអឺរ៉ុប ដែលគាត់ជួបប្រទះទៅលើការសម្លាប់នៅរបបនៃការឃោរឃៅមួយនោះ គឺគាត់បានលើកឡើង និងសរសេរសៀវភៅមួយ ហើយវាមានការពិបាកក្នុងការយល់ទៅលើបទពិសោធ ឬក៏ការឆ្លងកាត់របស់អ្នកជាប់ឃុំ។ លោក អេចឈីមេន គាត់ត្រូវបានគេឃុំខ្លួន ហើយគេបានដកហូតនូវរបស់របរទាំងឡាយពីគាត់។ គេបានធ្វើការឲ្យគាត់ឈឺចាប់ ហើយគេមិនបានយកគាត់មកជំនុំជម្រះតាមផ្លូវតុលាការ គេដកនូវកិត្តិយសរបស់គាត់ ដោយសារតែគាត់គឺជាបុរសម្នាក់ត្រូវបានគេដកហូតនូវរបស់របរ ឬក៏សិទ្ធិរបស់គាត់ទាំងអស់ ហើយគាត់ត្រូវបានគេយកមកធ្វើបានដោយមិនមានការពិចារណាទៅលើលក្ខខណ្ឌផ្សេងៗ។ ការឈឺចាប់នេះ គឺវាអាស្រ័យទៅលើបុគ្គលទាំងឡាយដែលគាត់យល់ទៅលើចំណុចទាំងអស់នេះ។ ដូច្នេះហើយយើងអាចកំណត់ថា អំពើអមនុស្សធម៌អាចកើតឡើងចំពោះបុគ្គលដែលបានឆ្លងកាត់នៅពេលដែលគេបានដកហូតមនុស្សធម៌។ នៅក្នុងភ្នែករបស់អ្នកទាំងឡាយ បិសាចវាបានកើតឡើង សភាវៈអាក្រក់ វាកើតឡើងនៅពេលនោះ។ អ្នកទាំងអស់នោះ ជាប្រជាជនសាមញ្ញ ហើយពួកគេជាប្រជាជនធម្មតា ដែលពួកគេចង់រស់នៅយ៉ាងពិតប្រាកដ។ លោក ឌុច ប្រហែលជាលោក គឺជាបុគ្គលមួយរូបដែលមានលក្ខណៈសាមញ្ញ លោកគឺជាជនម៉ាក្សស៊ីស ហើយគាត់ជាគ្រូម្នាក់ លោកគោរពបញ្ញា ហើយលោកមានភាពហ្មត់ចត់។ លោកបានបំភ្លេចចោលទៅលើភាពមនុស្សធម៌របស់បុរសស្ត្រី ឬក៏មនុស្សទាំងឡាយដែលជាប់ឃុំនៅស-២១។ នៅក្នុងការព្យាយាម ទៅលើយោគយល់របស់លោក ពេទ្យចិត្តវិទ្យា បូរីស្ទីច បានសរសេរនៅក្នុងឆ្នាំ២០០៩ ខែ៩ថា ស្ត្រីទាំងឡាយ បុរសទាំងឡាយ ដែលត្រូវបានគេសម្លាប់ គឺគេបានដកនូវសុភមង្គលរបស់ពួកគេ ហើយពួកគេបានក្លាយទៅជាបុគ្គលទាំងឡាយស្ថិតនៅក្រោមអំពើទារុណកម្ម ហើយពួកគេត្រូវបានដកហូតសង្គម និងភាពថ្លៃថ្នូររបស់ពួកគេនៅក្នុងសង្គម ហើយពួកគេមិនស្ថិតនៅក្នុងស្ថានភាពដូចអ្នកដទៃដែលគេទទួលបាន។ ពួកគេទទួលរងនូវការឈឺចាប់ ហើយពួកគេមិនត្រូវបានគេយល់អារម្មណ៍របស់ពួកគេ។ ដូច្នេះហើយយើងឃើញថា អ្នកទាំងអស់នោះ ដែលទទួលរងនូវអំពើទាំងអស់ត្រូវបានគេសម្លាប់ចោល។ វាមិនមែនជាការឈឺចាប់ផ្លូវអារម្មណ៍ប៉ុណ្ណោះនោះទេ។ យើងអាចយល់តាមរយៈអំពើឃាតកម្មធ្ងន់ធ្ងរនិងធំធេងដូចនេះ។ ហើយចំណុចនេះ វាជាចំណុចមួយគួរឲ្យភ័យខ្លាច ចំណុចចុងក្រោយខ្ញុំលើកឡើងសម្តីលោក ហ្វ្រង់ស្វ័រ ប៊ីហ្ស ដែលគាត់ជាសាក្សីមួយដ៏សំខាន់នៅក្នុងតុលាការនេះ។ គាត់បានលើកឡើងថា គាត់បានបិតទ្វារបេះដូងរបស់គាត់ គាត់បានបំភ្លេចចូលនូវអ្វីទាំងឡាយ។ ដូច្នេះ គឺគាត់

បានបិទនៅទ្វាររបស់គាត់ គាត់មិនចង់ដឹងឮទៅលើចំណុចទាំងអស់នេះ ហើយគឺគាត់ជួបប្រទេះទៅលើអំពើទាំងអស់នោះនៅជំរំឃុំឃាំង។ ចំពោះខ្ញុំ ខ្ញុំជួបប្រទេះទៅលើភាពដ៏ស្អុតទាំងអស់នេះ។

[១៤:២៦:៤៩]

លោក ឌុច ថាតើលោកចង់លើកឡើងយ៉ាងម៉េច? ថាតើអង្គការគេបានសរសើរលោកចំពោះការងាររបស់លោកដែរឬទេ? នៅថ្ងៃនេះលោកប្រឈមនឹងដើមបណ្តឹងរដ្ឋប្បវេណី។ អ្នកទាំងអស់នោះដែលលោកបានដកនូវការសម្តែងមតិរបស់ពួកគេ ហើយសាមសិបឆ្នាំក្រោយមក លោកបានដឹង និងទទួលស្គាល់ ហើយលោកយល់ទៅលើចំណុចនេះ។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីនៅទីនេះ គ្រាន់តែចង់ផ្តល់សក្ខីកម្មថា មនុស្សធម៌ទាំងឡាយ គឺត្រូវតែទទួលស្គាល់ ដើម្បីធ្វើយ៉ាងណាឲ្យយើងយល់ ហើយឲ្យគេទទួលស្គាល់ថា ពួកគេជាសំឡេងមួយ និងមានភាពក្លាហានក្នុងការចូលរួមនៅក្នុងសវនាការរូបនេះ។ អ្នកដែលរស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ ក៏បានរៀបរាប់នៃការឆ្លងកាត់របស់គាត់នៅក្នុងព្រៃ គឺជាឧទាហរណ៍មួយដែលយើងត្រូវពិចារណា។ គាត់បានលើកឡើងអំពីរបបមួយដែលធ្វើការកាប់សម្លាប់ទៅមនុស្សស្ត្រីរាប់លាននាក់ និងបុរសនៅក្នុងនោះផងដែរ។

ដូច្នេះ នេះគឺជាដាន យើងឃើញថាវាមានដានមួយបានបន្សល់ដោយខ្មែរក្រហមនៅក្នុងប្រទេសនេះ ហើយដូច្នេះយើងស្នើសុំឲ្យមានភាពយុត្តិធម៌។ ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណីនៅទីនេះ គឺមានតួនាទី និងចង់ចូលរួមចែករំលែកនូវអ្វីដែលបានតាមលងគេជារៀងរាល់ថ្ងៃ ហើយគាត់ចង់ឲ្យយើងទាំងអស់គ្នាយល់។ យើងមិនអាចថានៅពេលដែលយើងមិនមានសាលក្រមនោះ យើងនឹងទទួលបានយុត្តិធម៌នោះទេ យើងត្រូវតែមានសាលក្រម។ ខ្ញុំអនុគ្រោះចំពោះបុគ្គលទាំងឡាយ ឬនរណាម្នាក់ដែលគាត់បង្ហាញថាគាត់បានដឹងស្មោះត្រង់ទៅលើអតីតកាលរបស់គាត់ ហើយគាត់សម្តែងចេញពីមនសិការរបស់គាត់ដោយផ្ទាល់ តាមរយៈការយល់អំពីមនសិការរបស់គេ។ តើលោកនឹងនិយាយយ៉ាងម៉េចដែរលោក ឌុច? លោកបានទទួលស្គាល់នៅក្នុងសវនាការនេះនៅចំណុចជាច្រើន ប៉ុន្តែជារឿយៗ លោកបានតវ៉ាទៅលើអង្គហេតុទាំងឡាយ។ លោកបានតវ៉ាទៅលើអង្គហេតុទាំងអស់នោះ ដោយភាពអយុត្តិធម៌ លោកបានលើកឡើងផងដែរថា លោកជំទាស់ទៅលើអង្គហេតុទាំងអស់នោះ ដោយសារតែលោកគិតថាវាមិនកើតមានឡើងមាននោះទេ។ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណី គាត់ត្រូវតែទទួលស្គាល់ ហើយការអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួមនៅក្នុងនេះ គឺជាការអនុញ្ញាតឲ្យគាត់សម្តែងមតិរបស់គាត់ ហើយនិងអារម្មណ៍របស់គាត់។ ដូច្នេះ ខ្ញុំសូមសន្និដ្ឋានបញ្ចប់នៅក្នុងពេលនេះ។

ការគោរពមនុស្សធម៌ និងមនុស្សធម៌ គឺវាមិនអាស្រ័យទៅលើកិត្តិយសតែប៉ុណ្ណោះនោះទេ គឺមនុស្សធម៌វាកើតមានឡើងដោយសារតែមនុស្សធម៌វាអាចសម្រេចថាពួកគេទទួលបាននូវកិត្តិយសថ្លៃថ្នូរ ហើយពួកគេទទួលបានសេចក្ដីថ្លៃថ្នូរទាំងអស់នេះ។ ដូច្នេះហើយដើមបណ្ដឹងរដ្ឋប្បវេណីត្រូវទទួលបាននូវសិទ្ធិរស់រានមានជីវិតទាំងអស់នេះ ប្រសិនបើយើងមិនធ្វើ មិនបំពេញទៅតាមនេះទេ យើងនឹងមិនគោរពទៅលើជីវិត ឬក៏ដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។

[១៤:៣០:០០]

ដូច្នេះក្នុងនាមជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រម និងភាគី យើងត្រូវចាំទៅលើចំណុចទាំងអស់នេះ។ យើងមិនអាចចាត់ទុកថាអំពើដែលមនុស្សម្នាក់ គាត់គ្រប់គ្រងទៅលើមនុស្សម្នាក់ទៀតជាការល្អនោះទេ។

**កញ្ញា ម៉ុច សុវណ្ណារី៖**

នៅក្នុងនាមជាជនជាតិខ្មែរជំនាន់ក្រោយម្នាក់ និងក្នុងនាមដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបីទាំងមូល។ ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដោយមានការសហការជាមួយនឹងអង្គការសហប្រជាជាតិ។ ដោយសារតែអន្តរាគមន៍ដ៏មានតម្លៃនេះ ទើបធ្វើឱ្យមានតុលាការនៅថ្ងៃនេះនៅទីនេះ។ ដោយសារតែអន្តរាគមន៍ដ៏សំខាន់នេះ ទើបធ្វើឱ្យសំឡេងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងឡាយត្រូវបានស្ដាប់ ហើយឱ្យគាត់មានសិទ្ធិដើម្បីនឹងទាមទារសំណង ជួសជុលការខូចខាតរបស់ពួកគាត់។ នៅពេលនេះ នាងខ្ញុំនឹងនិយាយតែបញ្ហាសំណង ដែលពួកគាត់ត្រូវទទួល។

យោងតាមសវនាការកន្លងមក គ្រប់គ្នាសុទ្ធតែបានទទួលស្គាល់ ដោយបដិសេធមិនបាននូវការឈឺចាប់ទាំងផ្លូវកាយនិងផ្លូវចិត្តរបស់ជនរងគ្រោះ។ ការឈឺចាប់ដែលមិនអាចជួសជុលបាន។ ជនជាប់ចោទរូបគាត់ផ្ទាល់ក៏បានទទួលស្គាល់ការទាំងអស់នេះដែរ ហើយគ្រប់គ្នាសុទ្ធតែទទួលស្គាល់ថាការឈឺចាប់ទាំងអស់នេះ វាបានកើតឡើងអំពីអំពើឧក្រិដ្ឋកម្មដែលត្រូវបានធ្វើនៅមន្ទីរស-២១ ក្រោមការគ្រប់គ្រងនិងបង្គាប់បញ្ជាដោយជនជាប់ចោទ។ ហើយនាងខ្ញុំសូមជម្រាបជូនអង្គសវនាការថា ការឈឺចាប់ទាំងអស់នេះ វានៅតែមានបន្តនិរន្តរភាពរបស់វា។ វានៅតែមានបន្តរហូតមកទល់ពេលបច្ចុប្បន្ននេះ។ ទោះបីជាពេលវេលាសាមសិបឆ្នាំ ក្រោយការដួលរំលំរបបនេះបានកន្លងផុតទៅ តែពេលវេលាទាំងអស់នោះមិនអាចលប់បំបាត់ចោល ហើយវាមិនអាចព្យាបាលនូវការឈឺចាប់ទាំងអស់នេះបានឡើយ។ ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបីសូមប្រកាសថា ខ្លួនគាំទ្រនូវគ្រប់អំណះអំណាងផ្លូវច្បាប់ទាំងឡាយដែល

ត្រូវបានលើកឡើងនៅក្នុងសារណារួមរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងជាមួយនឹងសំណង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ ដែលមានឯកសារយោងលេខ E159/3។ ពួកគាត់ក៏គាំទ្រផងដែរ ជាមួយនឹងសារណាបន្ថែមទាក់ទងនឹងសំណងចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ ដែលមានឯកសារ យោងលេខ E159/3/1។ ហើយពួកគាត់ក៏គាំទ្រផងដែរ នូវការគាំទ្រទាំងឡាយណាទាក់ទងនឹងសំណង របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមផ្សេងទៀតដែលគាត់បានលើកឡើងនៅក្នុងពេលដែលគាត់ សន្និដ្ឋានបញ្ចប់ផ្ទាល់មាត់នេះ។

[១៤:៣២:៤២]

នាងខ្ញុំសូមកត់សម្គាល់បន្ថែមទៀតថា ប្រទេសជាតិនេះ ប្រជាជននេះ កំពុងតែត្រូវការការស្តារ ឡើងវិញ។ ពួកគេត្រូវការការព្យាបាលប្រកបដោយប្រសិទ្ធភាព និងសុក្រិតភាពមួយសម្រាប់ជនរងគ្រោះ។ ការផ្សះផ្សាជាតិ ការស្តារឡើងវិញ និងការព្យាបាលប្រកបដោយប្រសិទ្ធភាពមួយ មិនអាចកាត់ផ្តាច់ ចេញពីអាទិភាពនៃតុលាការនេះ រួមបញ្ចូលទាំងការប្រកាសសំណងស្របច្បាប់ដល់ដើមបណ្តឹងរដ្ឋប្បវេ- ណី ដែលជាភាគីមួយដ៏សំខាន់នៅក្នុងដំណើរការក្តីនេះ។

នាងខ្ញុំក៏សូមជម្រាបជូនផងដែរថា អ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីក្រុមបីត្រូវការ គឺយុត្តិធម៌។ ពួកគាត់មិនត្រូវការអ្វីផ្សេង តែពួកគាត់ត្រូវការយុត្តិធម៌ ដែលប្រកាសផ្តល់សំណងដល់ពួកគាត់ គឺជា ភ័ស្តុតាងមួយដែលបង្ហាញថា យុត្តិធម៌ពិតជាត្រូវបានផ្តល់ជូនពួកគាត់ពិតប្រាកដមែន។ សំណងនេះមិន មែនជាសម្បទានដែលត្រូវផ្តល់ឲ្យពួកគាត់ដោយសារការយោគយល់ ឬការអាណិតអាសូរនោះឡើយ ក៏ ប៉ុន្តែវាគឺជាការព្យាបាល វាគឺជាការជួសជុល វាគឺការសង វាជាអ្វីដែលពួកគាត់សាកសមនឹងទទួល វាជា សិទ្ធិរបស់ពួកគាត់ វាជារបស់ពួកគាត់។

មុននឹងនាងខ្ញុំសុំដាក់ជូនអង្គជំនុំជម្រះសាលាដំបូងពិចារណាពីប្រសិទ្ធភាពនៃការអនុវត្តសំណង ដែលត្រូវប្រកាសនៅក្នុងសាលក្រមស្ថាពររបស់តុលាការនេះ នាងខ្ញុំគោរពអញ្ជើញអង្គជំនុំចម្រះទាំងមូល ពិចារណាជាដំបូងទៅលើទម្រង់មួយចំនួននៃសំណងដែលពួកគាត់បានស្នើឡើង។ ជាដំបូង ដើមបណ្តឹង រដ្ឋប្បវេណីក្រុមបីសូមប្រកាសថា ខ្លួនគាំទ្រនូវគ្រប់ទាំងទម្រង់នៃសំណងដែលមានកំណត់នៅក្នុងសារណា ទាំងឡាយទាក់ទងនឹងសំណង ដូចដែលបានរៀបរាប់ខាងលើ។ ដូច្នេះ នៅទីនេះក្នុងផលប្រយោជន៍ របស់ពួកគាត់ នាងខ្ញុំសូមគោរពអញ្ជើញអង្គជំនុំជម្រះពិចារណានូវទម្រង់បន្ថែមមួយចំនួនទៀតទាក់ទង នឹងសំណង។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុមបីយល់ឃើញថា ការបង្កើតមូលនិធិស្ម័គ្រចិត្តនិងឯករាជ្យមួយ

គឺមានសារសំខាន់ណាស់សម្រាប់ពួកគាត់។ ពួកគាត់ត្រូវការខ្លាំងបំផុត តែមុននឹងនាងខ្ញុំធ្វើការបញ្ចាក់បង្ហាញបន្ថែមទាក់ទងនឹងអាទិភាពនឹងដំណើរការនៃមូលនិធិនេះ នាងខ្ញុំសូមស្នើសុំអង្គជំនុំជម្រះសាលាដំបូងប្រកាស៖

ទី១) រក្សាការពារទីកន្លែងនៃឧក្រិដ្ឋកម្ម។

ទី២) រក្សាការចងចាំនៃទីកន្លែងទាំងនោះ។ ដោយមូលហេតុថា ទីកន្លែងនោះបានឆក់យកជីវិតមនុស្សជាទីស្រឡាញ់របស់ពួកគាត់។

[១៤:៣៥:១៨]

ដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំតុលាការប្រកាសចាត់វិធានការទាំងឡាយណាដើម្បីការពារថែរក្សាទីកន្លែងនោះ ដើម្បីប្រកាសឲ្យមនុស្សជំនាន់ក្រោយទូទាំងពិភពលោក គាត់បានដឹង ហើយគាត់បានស្គាល់នូវសោកនាដកម្មនៃប្រទេសជាតិមួយ។ លើសពីនេះទៅទៀត គាត់បានស្នើសុំបែបនេះ ពីព្រោះគាត់គិតថា វាជាការរក្សានូវភ័ស្តុតាងដ៏ចាំបាច់មួយដើម្បីរំឭកដល់យុវជនខ្មែរជំនាន់ក្រោយទាំងអស់ឲ្យពួកគេបានស្គាល់ ពួកគេបានចងចាំនូវប្រវត្តិសាស្ត្រសោកនាដកម្មនៃប្រទេសជាតិរបស់ពួកគេ ប្រជាជនរបស់ពួកគេ។ អាចឲ្យពួកគេបាន អាចនឹងមានឱកាសក្នុងការទៅឈរនៅទីកន្លែងនោះ។ ពួកគេអាចយំពួកគេអាចសម្រក់ទឹកភ្នែក ពួកគេអាចស្រែកឡើងពោពេញដោយមនសិការ និងសតិសម្បជញ្ញៈសម្រាប់អនាគតនៃប្រទេសជាតិ និងប្រជាជនរបស់ពួកគេ ហើយទីបំផុតកន្លែងនោះហើយ វានឹងក្លាយទៅជាការលើកទឹកចិត្តដ៏សំខាន់មួយសម្រាប់ពួកគេ ក្នុងការដែលពួកគេប្តាជ្ញាចិត្តថា ពួកគេម្នាក់ៗគឺមានសារសំខាន់ និងមានតម្លៃណាស់សម្រាប់ប្រទេសជាតិ សម្រាប់ការរីកចម្រើនរបស់ប្រទេសជាតិរបស់ពួកគេ។ ពួកគេមិនមែនជាឃាតក ហើយពួកគេហ្នឹងមិនក្លាយជាឃាតកសម្លាប់ប្រជាជនឯងនោះឡើយ ហើយពួកគេគឺជាមនុស្សតែម្នាក់គត់ ដែលអាចហាមឃាត់មិនឲ្យកង់ប្រវត្តិសាស្ត្រដ៏ឈឺចាប់នេះ វាត្រឡប់មកបំផ្លាញប្រទេសជាតិរបស់ពួកគេ និងប្រជាជនរបស់ពួកគេវិញ។

ហេតុដូច្នេះ ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងប្រកាស៖

ទី១) រក្សាការពារទីតាំង និងសភាពអគារ គ្រប់ទាំងបន្ទប់ឃុំឃាំងទាំងអស់នៃមន្ទីរស-២១ មជ្ឈមណ្ឌលភ្នំពេញ និងព្រៃស។

ទី២) ថែរក្សាសម្ភារៈធ្វើទារុណកម្មទាំងអស់ដែលនៅសេសសល់ ហើយតម្កល់សម្ភារៈនោះ ទុកនៅកន្លែងដែលពួកវាធ្លាប់នៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម។

ទី៣) រក្សាឯកសារទាំងឡាយណាដែរនៅសេសសល់នៅមន្ទីរស-២១ ទោះបីជាឯកសារទាំងអស់នោះត្រូវបានដាក់តាំងជាសាធារណៈ ឬមិនត្រូវបានដាក់តាំងជាសាធារណៈ។

ទី៤) អភិរក្សនូវរាល់ឯកសារទាំងឡាយណាដែលវាជាគំនូរ ជាស្នាដៃរបស់លោក វ៉ាន់ ណាត អ្នករស់រានមានជីវិតដ៏កម្រនៃមន្ទីរស-២១ ហើយដាក់តាំងឯកសារនោះនៅអតីតមន្ទីរស-២១។

បន្ទាប់មកទៀត ស្នើសុំឲ្យអង្គជំនុំជម្រះបង្គាប់ឲ្យផ្ទាំងមួយនៅមន្ទីរព្រៃស ដែលមានរៀបរាប់អំពីលក្ខខណ្ឌអមនុស្សធម៌នៃការបង្ខំឲ្យធ្វើការជាទម្ងន់ នៃការធ្វើទុក្ខបុកម្នេញ នៃការបំបិទសិទ្ធិសេរីភាព នៃការបន្ថោកជីវិតជនរងគ្រោះទាំងឡាយថាជាក្រុមសមាសភាពជនដែលបង្កដល់គ្រោះថ្នាក់បក្សកុម្មុយនីស្តកម្ពុជា។

[១៤:៣៧:៥៦]

លើសពីនេះទៅទៀតស្នើសុំឲ្យអង្គជំនុំជម្រះប្រកាសរក្សារណ្ដៅកប់សពទាំងឡាយណាដែលមាននៅជើងឯក កុំឲ្យរណ្ដៅទាំងអស់នោះរលប់ឡើយ។ ហើយនៅទីនោះស្នើសុំឲ្យបង្គាប់សង់នូវផ្ទាំងមួយដែលមានរៀបរាប់អំពីរបៀបនៃការប្រហារជីវិតជនរងគ្រោះក្រោមការបង្គាប់បញ្ជារបស់ជនជាប់ចោទ។

ទាក់ទងជាមួយនឹងការរក្សាការចងចាំ ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី ស្នើសុំអង្គជំនុំជម្រះមេត្តាបង្គាប់ចារឹកលើជញ្ជាំងដែលជារបងក្រវាត់ជុំវិញស-២១ នូវឈ្មោះរបស់ជនរងគ្រោះទាំងអស់ ដែលបានស្លាប់នៅទីនោះ។ ចាប់ចេញពីឈ្មោះដែលមាននៅក្នុងបញ្ជីអ្នកទោសរួមដែលធ្វើឡើងដោយការិយាល័យសហព្រះរាជអាជ្ញា នៅក្នុងបណ្ដុំឯកសារដែលមានលេខ E68។

ស្នើសុំឲ្យសង់ផ្ទះនិមិត្តរូបមួយទៀតសម្រាប់ជនរងគ្រោះដែលពួកយើងមិនអាចកំណត់អត្ត-សញ្ញាណរបស់ពួកគាត់បាន។ នៅក្បែររបងនោះ ពួកគាត់ស្នើសុំបន្ថែមទៀត សុំឲ្យបង្គាប់ឲ្យមានការសង់នូវចន្លោះផ្លូវដើរមួយសម្រាប់ឲ្យក្រុមគ្រួសារនៃជនរងគ្រោះទាំងអស់បានដើររំឭកនូវការចងចាំដែលពួកគេមានសម្រាប់ក្រុមគ្រួសាររបស់ពួកគេ។ ពីព្រោះទីនោះហើយ វាជាកន្លែងចុងក្រោយនៃដំណើរជីវិតមនុស្សជាទីស្រឡាញ់របស់ពួកគេ។

ស្នើសុំឲ្យមានការសង់ស្តូករំឭកវិញ្ញាណក្ខន្ធមួយក្នុងនាមជាជនរងគ្រោះទាំងអស់នៅក្នុងមន្ទីរព្រៃស និងនៅជើងឯក។

ជាបន្តទៅទៀតនេះ ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី ស្នើសុំឲ្យអង្គជំនុំជម្រះបង្គាប់ឲ្យមានការបង្កើតនូវមូលនិធិស្ម័គ្រចិត្ត និងឯកវាជ្យមួយសម្រាប់ជាប្រយោជន៍របស់ជនរងគ្រោះ។ ហេតុអ្វី? នាងខ្ញុំ

សូមពញ្ញាក់ស្មារតីអង្គសវនាការទាំងមូលថា នៅពេលដែលសំណុំរឿងនេះបានបញ្ចប់ទៅ គ្រប់គ្នានឹងទៅបាត់ តើអ្នកណាដែលនៅ? ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ គាត់ត្រូវនៅ គាត់នៅត្រូវបន្តការតស៊ូបន្តជីវិតរបស់ពួកគាត់ត្រូវរស់នៅក្នុងអនាគតកាលតទៅទៀត។ យើងដឹងថាការឈឺចាប់ទាំងអស់បានបំផ្លាញជិវិតគាត់ និងកូនចៅរបស់ពួកគាត់ ហើយពេលនេះពួកគាត់កំពុងតែប្រឈមមុខជាមួយនឹងបញ្ហាសុខភាពផ្លូវចិត្តជាខ្លាំង ហើយជាពិសេសជាមួយនឹងភាពក្រីក្រ។

[១៤:៤០:១២]

នាងខ្ញុំសូមធ្វើការកត់សម្គាល់បន្ថែមទៀតថា បីឆ្នាំប្រាំបីខែម្ភៃថ្ងៃនៃរបបខ្មែរក្រហមបានព្យាបាលជីវិតពួកគាត់ម្តងរួចទៅហើយ។ រយៈពេលជិតសាមសិបឆ្នាំក្រោយការដួលរំលំ ក៏មិនបានផ្តល់នូវការព្យាបាលជាក់លាក់ណាមួយដល់ពួកគាត់ដែរ ពីព្រោះជនដែលប្រព្រឹត្តបទល្មើស គាត់បានរស់នៅក្នុងជីវភាពមួយដែលមិនទាន់ត្រូវបានអ្នកណាម្នាក់ផ្តន្ទាទោសជាថ្នូរនឹងឧក្រិដ្ឋកម្មដែលគាត់បានប្រព្រឹត្តនៅឡើយ។ ហេតុដូច្នេះហើយ ការបង្កើតមូលនិធិស្ម័គ្រចិត្ត និងឯករាជ្យមួយ សម្រាប់ជាប្រយោជន៍ដល់ជនរងគ្រោះ ពិតជាមានសារសំខាន់ណាស់ក្នុងការជួយជ្រោមជ្រែង និងជួយគាំទ្រការរស់នៅរបស់ពួកគាត់តទៅពេលអនាគតតទៅទៀត។ ពីព្រោះថាការព្យាបាលវាគឺជាដំណើរការមួយ ហើយវាត្រូវការពេលវេលាដើម្បីព្យាបាលពួកគាត់ដែលបានជាសះស្បើយពីការឈឺចាប់របស់ពួកគាត់។

នាងខ្ញុំស្នើសុំថា មូលនិធិនេះគួរត្រូវបង្កើតឡើងជាមួយនឹងរចនាសម្ព័ន្ធគ្រប់គ្រងដ៏ច្បាស់លាស់មួយប្រកបដោយតម្លាភាព ប្រសិទ្ធភាព ទន់ភ្លន់ និងឯករាជ្យ នៅក្នុងការបំពេញបេសកកម្មរបស់ខ្លួន។

ជាបន្តទៅទៀតនេះ នាងខ្ញុំសូមលើកជូនអង្គសវនាការពីបញ្ហាមួយចំនួនដែលអាចកើតឡើងជាយថាហេតុនៅក្នុងការអនុវត្តសំណង។ បញ្ហានេះអាចកើងឡើងនៅក្នុងលក្ខណៈដូចជា ថាតើអ្នកណាជាអ្នកអនុវត្តសំណង អ្នកណាអនុវត្តសម្រាប់ពួកគាត់ តើសំណងនេះគួរត្រូវចាប់ផ្តើមនៅពេលណា? ហើយថាតើមូលនិធិស្ម័គ្រចិត្ត និងឯករាជ្យសម្រាប់ជាប្រយោជន៍របស់ជនរងគ្រោះនេះ តើត្រូវបានបង្កើតពេលណា ដោយរបៀបណា ហើយដំណើរការយ៉ាងដូចម្តេច? ហើយអាចមានបញ្ហាមួយទៀតចោទសួរឡើងថា តើត្រូវអនុវត្តសំណងដោយរបៀបណានៅក្នុងករណីដែលជនជាប់ចោទគាត់បានប្រកាសថាគាត់ជាទុរគតជន គាត់អត់មានលទ្ធភាពនៅក្នុងការសង ហើយបើសិនជាក្នុងករណីដែលសំណងប្រកាសនៅក្នុងសាលក្រមស្ថាពរហើយ ហើយមិនត្រូវបានអនុវត្ត ឬក៏អនុវត្តដោយគ្មានប្រសិទ្ធភាព តើដោះស្រាយយ៉ាងណា តើពួកគាត់មានមធ្យោបាយយ៉ាងណា?

ដើម្បីឆ្លើយតបនឹងបញ្ហាទាំងអស់នេះ ដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើសុំថា នៅក្នុងសាលក្រមស្ថាពររបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងសំណង ពួកគាត់ស្នើសុំថា អង្គជំនុំជម្រះត្រូវចង្អុលបង្ហាញរួចជាស្រេចថាតើអ្នកត្រូវទទួលបន្ទុកអនុវត្តសំណងនេះដល់ជនរងគ្រោះ។ ប្រសិនបើយើងក្រឡេកមើលទៅវិធាន១១៣ ចំណុចទី៣ បានចែងថា សហព្រះរាជអាជ្ញា គាត់អាចសុំជំនួយពីអាជ្ញាធរមូលដ្ឋានដើម្បីអនុវត្តទោស។

[១៤:៤២:៤៤]

នាងខ្ញុំសូមរំឭកផងដែរថា នៅក្នុងអំឡុងពេលនេះ យើងមានអង្គភាពជនរងគ្រោះ គាត់ជាអ្នកកណ្តាលរវាងជនរងគ្រោះនិងតុលាការ។ អង្គភាពនេះមានទម្លាប់ និងមានសមត្ថកិច្ចនៅក្នុងការធ្វើការនៅក្នុងប្រយោជន៍របស់ជនរងគ្រោះ។ ដូច្នេះ គាត់មានគុណសម្បត្តិនៅក្នុងការធ្វើជាអ្នកអនុវត្តសំណងដោយសុំជំនួយពីអាជ្ញាធរមូលដ្ឋាន ក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលកម្ពុជា។

មួយទៀត ពួកគាត់ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបញ្ជាក់រួចជាស្រេចនៅក្នុងសាលក្រមស្ថាពរប្រកាសពីសំណងរបស់ខ្លួននៅពេលវេលាកំណត់ណាមួយដើម្បីអនុវត្តសំណងនេះ។ ពួកគាត់ស្នើសុំថាប្រសិនបើអាចអនុវត្តកាន់តែឆាប់កាន់តែល្អ យ៉ាងយូរបំផុតសាមសិបថ្ងៃ ក្រោយពេលដែលសាលក្រមនេះចូលជាស្ថាពរ។

មួយទៀត គាត់ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសនៅក្នុងសាលក្រមនេះថា មូលនិធិស្ម័គ្រចិត្ត និងឯករាជ្យមួយសម្រាប់ជាប្រយោជន៍ដល់ជនរងគ្រោះទាំងអស់ និងត្រូវបង្កើតឡើងដោយត្រូវកំណត់នូវចំណុចសំខាន់ៗមួយចំនួនដូចជា៖

បង្កើតគណៈកម្មាធិការទទួលបន្ទុករៀបចំបង្កើតមូលនិធិនេះ ដែលត្រង់ចំណុចនេះ ដើមបណ្តឹងរដ្ឋប្បវេណីក្រុមបីស្នើសុំបេក្ខភាពអង្គភាពជនរងគ្រោះ ហើយនៅក្នុងករណីដែលតុលាការយល់ឃើញថាវាជាការគួរ សូមស្នើសុំតុលាការប្រកាសបន្តនិរន្តរភាព បន្តអាទិភាពនៃអង្គភាពនេះដើម្បីបំពេញបេសកកម្មមួយនេះ។ ហើយនៅក្នុងសាលក្រមស្ថាពរនេះផងដែរ ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងកំណត់ជាស្រេចនូវខ្លឹមសារសំខាន់ៗនៃលក្ខន្តិកៈរបស់មូលនិធិ រួមបញ្ចូលទាំងរបៀបនៃការជ្រើសរើសអភិបាលគ្រប់គ្រងមូលនិធិ ដែលសមត្ថកិច្ចរបស់មូលនិធិនៅក្នុងការជួយគាំទ្រដល់ជនរងគ្រោះ និងប្រភពថវិកានៃមូលនិធិ។

នៅក្នុងករណីដែលជនជាប់ចោទ គាត់ជាទុរគតជន ដោយគាំទ្រនឹងអ្វីដែលលោកមេធាវី គង់

ពិសី ក្រុមពីរ គាត់បានលើកឡើង នាងខ្ញុំស្នើសុំបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងអាចប្រើនូវអំណាចឆន្ទានុសិទ្ធិរបស់ខ្លួននៅក្នុងការរកដំណោះស្រាយតាមមធ្យោបាយផ្សេងទៀត ដើម្បីធានាថាសំណងដែលខ្លួនប្រកាសត្រូវបានអនុវត្តដោយមានប្រសិទ្ធភាព។ ហើយតុលាការអាចប្រកាសអំពីលទ្ធភាពនៃការទទួលយកប្រភពថវិកាពីប្រភពផ្សេងៗទៀតជាច្រើនកន្លែង។ ហើយនៅក្នុងករណីដែលយើងអាចរកឃើញមកក្រោយមកទៀថា ជនជាប់ចោទគាត់មានទ្រព្យសម្បត្តិ ឬក៏កម្មសិទ្ធិណាមួយដែលគាត់លាក់ទុកនៅខាងក្រៅ អ៊ីចឹងតុលាការអាចប្រកាសជាស្រេចថា កម្មសិទ្ធិនៃវត្ថុនោះ នឹងត្រូវផ្ទេរចូលមូលនិធិនេះជាស្វ័យប្រវត្តិ។

[១៤:៤៥:១៨]

ជាចុងក្រោយ ពួកគាត់ស្នើសុំថា នៅក្នុងសាលក្រមស្ថាពរ តុលាការគួរចែងពីបញ្ញត្តិមួយដើម្បីឱ្យគាត់មានផ្លូវតវ៉ានៅក្នុងករណីដែលសំណងប្រកាសជាស្ថាពរ ហើយមិនត្រូវបានអនុវត្ត ឬក៏អនុវត្តដោយគ្មានប្រសិទ្ធភាព។ ហើយនៅក្នុងនាមផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុមបីដែលនេះ នាងខ្ញុំសូមស្វាគមន៍នូវគ្រប់ដំណោះស្រាយណាមួយដែលអង្គជំនុំជម្រះអាចនឹងពិចារណាឃើញហើយយល់ថាវាមានប្រយោជន៍ វាមានលក្ខណៈប្រសើរដើម្បីជួសជុលសំណង និងអនុវត្តសំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី។

ដូច្នេះ នាងខ្ញុំសូមដាក់ជូននូវសំណើដូចបានរៀបរាប់ខាងលើនេះ នៅក្នុងការពិចារណាប្រកបដោយគតិបណ្ឌិតរបស់អង្គជំនុំជម្រះសាលាដំបូង។ ហើយនៅក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី នាងខ្ញុំសូមគោរពថ្លែងអំណរគុណជាមុនដល់អង្គជំនុំជម្រះនៅក្នុងការផ្តល់សំណងដល់ពួកគាត់ និងសម្រេចឱ្យការអនុវត្តសំណងនេះប្រកបដោយប្រសិទ្ធភាព ហើយនៅក្នុងនាមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី យើងខ្ញុំសូមថ្លែងអំណរគុណដល់អង្គជំនុំជម្រះដែលអនុញ្ញាតឱ្យពួកយើងឡើងមកធ្វើសេចក្តីថ្លែងការណ៍សន្និដ្ឋានបញ្ចប់ ដើម្បីតំណាងឱ្យផលប្រយោជនដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលយើងខ្ញុំកំពុងតែតំណាងឱ្យ។ នាងខ្ញុំសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីក្រុមបីបានឡើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ហើយបានគោរពបានល្អនូវពេលវេលាដែលបានកំណត់។

ឥឡូវនេះ ដល់ម៉ោងត្រូវសម្រាក។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ

រហូតដល់ម៉ោងបី និងប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការនិតិវិធីសវនាការ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីនៅម៉ោង១៤:៤៧នាទី ដល់ម៉ោង ១៥:៩ នាទី)*

[១៥:០៨:១៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាកិច្ចបន្តនេះអង្គជំនុំជម្រះប្រគល់វេទិការទៅមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួនដើម្បីឡើងធ្វើសេចក្តីថ្លែងការណ៍នូវសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួនគឺមានពេលវេលាដូចគ្នានឹងមេធាវីតំណាងបីក្រុមមុនដែរ គឺមួយម៉ោងដប់ប្រាំនាទី។ សូមអញ្ជើញ!

**លោក ហុង គឹមសួន៖**

ខ្ញុំបាទសូមអរគុណនិងសូមគោរពលោកប្រធានអង្គជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ព្រមទាំងលោកស្រី លោកចៅក្រម និងសវនាការជាទីគោរព។ ខ្ញុំបាទ ហុង គឹមសួន និងសហមេធាវីអន្តរជាតិ លោក ព្យែរ អូលីវីយេ សួរ នៅក្នុងក្រុមដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីបួន សូមធ្វើការសន្និដ្ឋានទាក់ទងជាមួយហ្នឹងការទាមទារសំណង ដែលបញ្ចប់ការដេញដោលនៅថ្ងៃនេះ។ ខ្ញុំបាទមិនលើកឡើងអំពីការចោទប្រកាន់ ឬបង្ហាញភាពផ្សំនៃបទល្មើសនោះទេ ដោយខាងយើងខ្ញុំយល់យ៉ាងច្បាស់ថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណី តំណាងឲ្យជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីនឹងនិយាយអ្វីដែលទាក់ទិន និងភាពឈឺចាប់ដែលបន្សល់ទុកពីរបបកម្ពុជាប្រជាធិបតេយ្យ ទាក់ទិនជាមួយនឹងមន្ទីរស-២១ ឬគុកទួលស្លែង តំបន់វាលពិឃាដជើងឯក និងព្រៃស ឬមន្ទីរស-២៤នេះ។

ជាការពិតណាស់ ក្នុងរយៈពេលសាមសិបឆ្នាំកន្លងមកនេះ បើនិយាយអំពីជនជាតិកម្ពុជា ឬអាស៊ីភាគច្រើនដែលកាន់ព្រះពុទ្ធសាសនា ឬគោរពសាសនាព្រះពុទ្ធ គឺតែងតែចងចាំច្បាស់ថា ពៀរតែងតែរម្ងាប់ដោយការមិនចង់ពៀរ ព្រោះថាបើផ្លូវសាសនានិយាយថា អ្នកណាធ្វើអំពើល្អ អ្នកនោះនឹងទទួលផលល្អ ហើយជនណាធ្វើអំពើអាក្រក់នឹងទទួលមកវិញនូវផលអាក្រក់ដូចគ្នា។ ដូច្នេះ ក៏មិនខុសអំពី

ផ្លូវលោក ឬក៏យើងនិយាយថា ផ្លូវច្បាប់សព្វថ្ងៃនេះ រដ្ឋាភិបាលមួយគឺត្រូវមានអំណាចបីជាធំ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ អ៊ីចឹង ប្រជាពលរដ្ឋខ្មែរ ឬក៏ជនបរទេសទាំងឡាយដែលបានទទួលរងទុក្ខ ទទួលទោសកំហុសដែលមិនមែនជាទោសដែលឆ្លងកាត់ការទោសពីរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសគឺនៅក្នុងគុកទួលស្លែង ឬមន្ទីរស-២១នៃរបបកម្ពុជាប្រជាធិបតេយ្យ។

ថ្ងៃនេះខ្ញុំបាទជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមបួន សូមប្រកាសជាឱឡារិកដល់ប្រជាពលរដ្ឋលើពិភពលោកថា ថ្ងៃនេះគឺជាថ្ងៃប្រវត្តិសាស្ត្រដែលអស់លោក លោកស្រីដែលជាជនជាតិនៅលើពិភពលោក ជាពិសេសគឺជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយដែលកំពុងតែរង់ចាំតុលាការមួយនេះដែលមាននិន្នាការទាក់ទងជាមួយអន្តរជាតិ និងជាតិរួមគ្នា ធ្វើការកាត់ទោស ឬក៏ធ្វើការស្វែងរកយុត្តិធម៌ជូនដល់ជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតទៅផង និងអ្នកដែលរស់នៅសព្វថ្ងៃនេះផង។

ក្នុងនេះដែរជនរងគ្រោះទាំងឡាយនៅក្នុងសំណុំរឿង០០១ ហេតុដែលមានតែជាងកៅសិបនាក់នេះ មិនមែនគេទាំងអស់នោះបំភ្លេចរឿងដែលឈឺចាប់ ឬក៏ជូរចត់នោះទេ ប៉ុន្តែអ្វីដែលពួកគេបានដាក់ពាក្យមកបានគ្នាតិចនេះក៏ព្រោះតែការមិនទាន់យល់ ហើយក៏មិនដែលឃើញថា របៀបការរកយុត្តិធម៌តាមបែបខ្នាតអន្តរជាតិនិងជាតិរួមគ្នាមួយនេះមានប្រសិទ្ធភាពប៉ុនណានោះ។ ដូច្នេះហើយទើបខ្ញុំបាទតំណាងនៅក្នុងទីពីរផង និងក្រុមទីបួនផងនេះ មានកូនក្តីមិនច្រើនលើសលប់ណាស់ណាទេ ប៉ុន្តែថិតនៅក្នុងចង្កោមនៃជាងកៅសិបនាក់នេះដែរ។ ដូច្នេះ ដោយយោងទៅតាមវិធាន ឬក៏ច្បាប់ដែលមានចែងពិសេសគឺវិធានទី២៣នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុមនេះ បានធ្វើសារណារួមគ្នាមួយរួចហើយបានដាក់ជូនទៅអង្គជំនុំជម្រះដែលថ្លែងអំពីការទាមទារសំណងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១នេះ។ នៅថ្ងៃនេះសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីបួន នឹងមានការបន្ថែមផ្ទាល់មាត់អំពីសន្និដ្ឋានទាក់ទិននឹងការទាមទារសំណងនេះ ហើយដែលក្នុងនេះក្នុងចំនួនកូនក្តីដែលជាជនរងគ្រោះផ្ទាល់ និងដោយប្រយោលដប់នាក់៖

១) គឺលោក អ៊ូ សាវរិត ដែលមានលេខសម្គាល់នៅក្នុងសំណុំរឿង E2/26

២) អ្នកស្រី ញ៉ឹក អ៊ូដារី លេខសម្គាល់ E2/31

៣) កញ្ញា អ៊ូ កាម៉េឡា មានលេខសម្គាល់ E2/27

៤) អ្នកស្រី ជុំ នៅ មានលេខសម្គាល់ D25/16

៥) លោក តូច មុនិន្ទ មានលេខសម្គាល់ D25/14

៦) អ្នកស្រី កាន់ សុន្ទរ៉ា មានលេខសម្គាល់ D25/17

៧) អ្នកស្រី ជួ ស៊ីអ៊ី លេខសម្គាល់ E2/28

៨) អ្នកស្រី រស់ មេន ឬ រស់ សាមេន លេខសម្គាល់ D25/9

៩) អ្នកស្រី គង់ ទេស លេខសម្គាល់ 25/19

១០) លោក ជ្រាំង សំអ៊ាន មានលេខសម្គាល់ D25/12

អ្នកទាំងដប់នាក់នេះ គឺជាជនរងគ្រោះដោយប្រយោលផងនិងដោយផ្ទាល់ផង។ តួយ៉ាងដូចជា លោក អ៊ូ សាវរិត ដែលមានលេខរៀង-- សំទោស ដែលមានលេខសម្គាល់ E2/26។ អ្នកស្រី ញ៉ឹក អ៊ូ ដារី និងកញ្ញា អ៊ូ កាម៉េឡា ដែលមានញាតិសន្តានរបស់គាត់ គឺជាជនរងគ្រោះមួយដែលបានបាត់បង់ជីវិតយ៉ាងអាណោចអាធ័មនៅក្នុងមន្ទីរស-២១នៃរបបកម្ពុជាប្រជាធិបតេយ្យ ឬដែលយើងសព្វថ្ងៃនេះហៅថា "មន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង" គាត់ក៏មានមុខនៅទីនេះដែរ ដែលគាត់ធ្វើដំណើរពីប្រទេសបារាំង ដោយលោក អ៊ូ សាវរិត ជាជនរងគ្រោះ និងជាញាតិសន្តានផ្ទាល់អាយុ៥៤ឆ្នាំ គាត់គឺជាប្អូនបង្កើតរបស់ជនរងគ្រោះដែលបានបាត់បង់ជីវិតនៅក្នុងមន្ទីរស-២១ ឬទួលស្លែងដែលមានឈ្មោះថា អ៊ូ វិនឌី ហើយដែលបានត្រូវក្រុម ឬបក្សពួកក្រោមបញ្ជាដែលលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច បានទទួលស្គាល់ថា ទោះគាត់ដឹង ឬមិនដឹងក៏ដោយ គាត់ជឿជាក់ថា អ្នកដែលមានឈ្មោះនៅក្នុងបញ្ជីអ្នកទោសនៃមន្ទីរស-២១ទាំងអស់នោះ គឺគាត់ទទួលស្គាល់ថាពិតជាបានទទួលរងទុក្ខវងទោស ការធ្វើទុក្ខទារុណកម្ម មុននឹងយកទៅកម្ទេចចោល ឬប្រហារជីវិតចោលនោះ។

[១៥:១៧:២៦]

ដូច្នេះ អ៊ូ វិនឌី ដែលត្រូវជាបងបង្កើតរបស់លោក អ៊ូ សាវរិត ហើយដែលត្រូវជាស្វាមីរបស់អ្នកស្រី ញ៉ឹក អ៊ូដារី និងជាឪពុកដ៏ល្អរបស់កញ្ញា អ៊ូ កាម៉េឡា ត្រូវបានយកទៅកម្ទេច សម្លាប់ចោលនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦។ ហើយដែលមានលោក អ៊ូ សាវរិត ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងនេះដែលមានលេខ ERN00364092 រហូតទៅដល់លេខ 00364093 និងមានលេខសម្គាល់លិខិតកំណើតរបស់គាត់ ERN00364089 ដល់លេខ 00364091 បញ្ជាក់នៅក្នុងសំណុំរឿងស្រាប់។ លោក អ៊ូ វិនឌី បានរៀបការជាមួយនឹងអ្នកស្រី អ៊ូ កាម៉េឡា នៅទីក្រុងភ្នំពេញតាំងតែពីថ្ងៃទី១ ខែសីហា ឆ្នាំ១៩៦៩ ដូចដែលមានការបញ្ជាក់ដាក់ទៅក្នុងសំណុំរឿង លេខ ERN00274209 ទៅដល់លេខ 00274

213 និងអត្តសញ្ញាណបណ្ណជាតិរបស់អ្នកស្រី ញ៉ឹក អ៊ូដារី នៅក្នុងសំណុំរឿងផងដែរ លេខ ERN 00274208 ហើយក៏មានកូនស្រីបង្កើតរបស់លោក អ៊ូ វិនឌី ឈ្មោះកញ្ញា អ៊ូ កាម៉េឡា សព្វថ្ងៃគាត់អាយុ ៣៨ឆ្នាំ គឺជាកូនបង្កើតរបស់អ្នកស្រី ញ៉ឹក អ៊ូដារី ហើយក៏ជាក្មួយរបស់លោក អ៊ូ សាវរិត ផងដែរ ដែលបានដាក់ឯកសារបញ្ចូលមកក្នុងសំណុំរឿងជាសាលកប័ត្រអត្រានុកូលដ្ឋានគ្រួសារលេខERN00274213 ហើយអត្តសញ្ញាណបណ្ណជាតិរបស់កញ្ញា អ៊ូ កាម៉េឡា នៅក្នុងសំណុំរឿងលេខERN00273257 ដល់លេខ 00273258។ អត្តសញ្ញាណទាំងអស់នេះ គឺសម្គាល់អំពីភាពស្របច្បាប់ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬហៅកាត់ថា អ.វ.ត.ក ដែលបានទទួលស្គាល់រួចហើយ អ៊ីចឹងខ្ញុំបាទលើកឧទាហរណ៍តែចំណុចទីមួយ ដើម្បីសម្គាល់ថា កូនក្តី ឬក៏ជនរងគ្រោះជាដើមបណ្តឹងចំនួនដប់នាក់នេះ មិនត្រូវបានអង្គជំនុំជម្រះធ្វើការបដិសេធ ឬខាងភាគីមេធាវីការពារក្តី ក៏ដូចជនជាប់ចោទបដិសេធនោះទេ។ អ៊ីចឹងនៅក្នុងនេះ ខ្ញុំបាទគ្រាន់តែរំឭកអំពីភាពស្របច្បាប់របស់កូនក្តីខ្ញុំបាទជូនអង្គសវនាការឲ្យបានដឹងខ្លះៗនិងបន្តទៅទៀតដើម្បីកុំឲ្យខាតពេលវេលា។ ខ្ញុំបាទសូមជម្រាបជូនថា លោក អ៊ូ វិនឌី មុននឹងគាត់ទទួលមរណភាពដោយអំពើធ្វើទារុណកម្មយ៉ាងសាហាវ ឬក៏ឃោរឃៅយង់ឃ្នងនៅក្នុងមន្ទីរស-២១នោះ គាត់ជាមនុស្សម្នាក់នៅក្នុងជួររដ្ឋាភិបាលតាំងពីសម័យសង្គមរាស្ត្រនិយមលើកទីមួយ រហូតមកដល់សម័យសាធារណរដ្ឋខ្មែរ ឬរបបលោក លន់ នល់នោះ គាត់ជាមន្ត្រីរាជការនៅក្រសួងការបរទេស ហើយក៏ត្រូវបានចាត់បញ្ជូនឲ្យទៅធ្វើការជានៅខុទ្ទកាល័យនាយករដ្ឋមន្ត្រី។

[១៥:២១:២១]

គាត់ជាឪពុកដ៏ល្អ គាត់បានបង្កើតកូនជាមួយនឹងភរិយារបស់គាត់អ្នកស្រី ញ៉ឹក អ៊ូដារី មានកូនបីនាក់។ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ ត្រូវបានអង្គការដ៏មានកេរ្តិ៍ឈ្មោះអាសោចនេះក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ខ្លួនគាត់បញ្ជូនទៅមន្ទីរស-២១ ហើយត្រូវបានសម្លាប់ ឬកម្ទេចខ្លួនគាត់ចោលនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦ ដែលមានឈ្មោះគាត់នៅក្នុងបញ្ជីអ្នកទោសមន្ទីរស-២១ ពីឆ្នាំ១៩៧៥ ដល់១៩៧៨ ក្នុងលំដាប់លេខរៀងទី៧០៥៩ ដែលមានលេខ ERN00171639។ ហើយបើពិនិត្យទៅលើចម្លើយសារភាពរបស់គាត់នៅក្នុងនោះគឺមានលេខ ERN00274217 ទៅដល់លេខ 00274264 ហើយក៏មានរូបថតឈ្មោះ អ៊ូ វិនឌី នេះនៅតម្កល់សព្វថ្ងៃក្នុងមន្ទីរស-២១ផងដែរ។ តាមការធ្វើទារុណកម្មដែលយើងជឿជាក់ថា ប្រាកដជាទទួលបាននៅក្នុងពេលសួរចម្លើយនៅក្នុងមន្ទីរស-២១ពេលនោះ គឺពួក ឬក៏បក្ខពួករបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច នេះ ឬក៏ក្នុងចង្កោមនៃជនជាប់ចោទនេះបានធ្វើ

ទារុណកម្មដែលយើងជឿជាក់ថា គាត់ឆ្លើយសារភាពទម្លាក់កំហុសមកលើខ្លួនគាត់ថាជា សេ.អ៊ី.អា ដែល មិនយល់ថា អ្វីទៅអត្ថន័យ សេ.អ៊ី.អា នោះ។ នេះជនជាប់ចោទចោទធ្លាប់បានជម្រាបអង្គសវនាការហើយថា ពាក្យ សេ.អ៊ី.អា ពាក្យ កា.ហ្សេ.បេ ឬក៏ខ្មាំងគ្រាន់តែជាពាក្យមួយចោទប្រកាន់ដើម្បីយកជនរងគ្រោះទៅសាកសួរចម្លើយដើម្បីប្រហារជីវិតប៉ុណ្ណោះ ឬក៏ដើម្បីចាប់ខ្លួនប៉ុណ្ណោះ។

លោក អ៊ូ វិនឌី បានស្លាប់ចោលកូនរបស់គាត់នៅពេលអាយុ១១ឆ្នាំ-- (សុំទោស) ស្លាប់ចោលបងប្អូនរបស់គាត់មានលោក អ៊ូ សាវរិត ដែលកាលនោះលោក អ៊ូ សាវរិត គាត់ទើបតែមានអាយុ១១ឆ្នាំ ហើយបានបន្តការសិក្សានៅឯប្រទេសបារាំងឯណោះ ចំណែកភរិយារបស់គាត់និងកូនៗរបស់គាត់បានស្ថិតនៅប្រទេសកម្ពុជានៃរបបកម្ពុជាប្រជាធិបតេយ្យជាមួយគ្នា។ ហើយនៅពេលដែលគាត់បានដឹងថា បងរបស់គាត់ អ៊ូ វិនឌី ឬក៏ស្វាមីរបស់អ្នកស្រី ញ៉ឹក ដាវី ឬក៏ជាឪពុករបស់កញ្ញា អ៊ូ កាម៉េឡា បានត្រូវពួកខ្មែរក្រហម ឬពួករបបកម្ពុជាប្រជាធិបតេយ្យដែលគ្រប់គ្រងនៅមន្ទីរស-២១ ឬទួលស្លែងនេះដែលមានឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាប្រធាន បានយកទៅសម្លាប់បណ្តាលឲ្យជីវិតរបស់ពួកគាត់រស់នៅសព្វថ្ងៃនេះមិនដែលភ្លេចមួយនាទីណាទេ។ ថាតើពេលដែលលោក អ៊ូ វិនឌី មុននឹងត្រូវបានយកទៅសម្លាប់នោះ គាត់ជួបប្រទះនូវផលវិបាកអ្វីដល់ខ្លួនគាត់ខ្លះ? អ៊ីចឹងខាងនេះ ក្នុងនេះ ខ្ញុំបាទនឹងសូមជម្រាបជូនអង្គសវនាការថា តាមរយៈការធ្វើសក្ខីកម្មឆ្លងតាមរយៈវីដេអូកាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ លោក អ៊ូ សាវរិត បានថ្លែងជូនអង្គសវនាការជាច្រើនមកហើយទាក់ទិនជាមួយនឹងភាពឈឺចាប់ ជាមួយនឹងការមិនអាចបំភ្លេចបាននូវទុក្ខវេទនា ក្នុងការនឹករឭកដល់ក្រុមញាតិ ក្រុមគ្រួសារ ហើយជាពិសេសទៅទៀតនោះ ទាំងប្រពន្ធរបស់គាត់ ទាំងកូនរបស់គាត់ គឺបានថ្លែងថា អ្វីដែលគាត់ចង់បាននាពេលសវនាការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការនេះ គឺការស្វែងរកការពិតដើម្បីស្វែងរកយុត្តិធម៌ជូនដល់បងរបស់លោក អ៊ូ សាវរិត គឺលោក អ៊ូ វិនឌី នេះ ឬរកយុត្តិធម៌ឲ្យប្តីរបស់អ្នកស្រី ញ៉ឹក អ៊ូដាវី និងជាឪពុករបស់កញ្ញា អ៊ូ កាម៉េឡា។ ទាក់ទងនឹងចម្លើយសារភាពទាំង៥០ទំព័រ ដែលមានតម្កល់ទុកនៅមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ឬអតីតស-២១ នេះ តើវាកើតឡើងដោយវិធីណា? ហើយតើក្នុងរយៈពេលនៃការឃុំខ្លួនគាត់ ៨៧ថ្ងៃនៅក្នុងមន្ទីរស-២១ ឬក៏យើងហៅឲ្យងាយស្តាប់ថា គុកស្លែងនោះ តើភាពវេទនា ឬក៏ភាពជូរចត់ ឬក៏ឃោរឃៅដែលជួបប្រទះមកលើខ្លួនគាត់នោះយ៉ាងម៉េចខ្លះ?

ដូច្នេះ បើមិនមានការកាត់ទោស ឬក៏ការសួរ ការស្វែងភស្តុតាង ឬក៏សាក្សីមកឆ្លើយបំភ្លឺនាពេលនេះទេ គឺពួកគាត់មិនអាចបំភ្លេច ឬមិនអាចគិតថា ជីវិតរបស់ញាតិសន្តានរបស់គាត់ដែលបានស្លាប់ទៅ

នោះបានសេចក្ដីសុខ ឬយើងនិយាយថា ទៅកាន់សុគតិភពនោះទេ។

ដូច្នេះនៅចុងក្រោយ ខ្ញុំបាទនឹងសរុបអំពីភាពឈឺចាប់ និងភាពវេទនាទាំងឡាយរបស់កូនក្ដី ដែលជាជនរងគ្រោះ ហើយជាដើមបណ្ដឹងរដ្ឋប្បវេណីនៅពេលនេះ។

បន្តទៅនេះ អ្នកស្រី ជុំ នៅ។ អ្នកស្រី ជុំ នៅ គឺជាជនរងគ្រោះដោយផ្ទាល់ ជាប្រយោលនៅក្នុងមន្ទីរស-២១ ឬអតីត-- អំ សូមទោស អតីតមន្ទីរស-២១ ឬគុកទួលស្លែង ដែលគ្រប់ដណ្ដប់ទៅលើតំបន់ព្រៃស ឬមន្ទីរស-២៤។ អ្នកស្រី ជុំ នៅ គឺជាជនរងគ្រោះផ្ទាល់ ដែលត្រូវបានចាញ់បោកពួករបបកម្ពុជាប្រជាធិបតេយ្យតាំងពីមុនរំដោះប្រទេសកម្ពុជា ១៧ មេសា ១៩៧៥ ទៅទៀត។ ដោយគាត់ជឿនោះជាមួយនឹងការឃោសនាបោកប្រាស់របស់ពួកខ្មែរក្រហមនេះហើយ ធ្វើឱ្យគាត់ចុងបំផុតមកធ្លាក់ខ្លួនជាជនមានទោស ឬជាជនមានទោសនៅក្នុងមន្ទីរស-២៤។ ឯប្ដីរបស់គាត់ ឬស្វាមីរបស់គាត់ឈ្មោះ នូ សាមឿន ដែលជាជនស្មោះត្រង់ ឬក៏ស្មោះស្ម័គ្រជាមួយរបបកម្ពុជាប្រជាធិបតេយ្យដែរនោះ ក៏ជាជនរងគ្រោះដែលបានបាត់បង់ជីវិតនៅមន្ទីរស-២១ ឬគុកទួលស្លែងផងដែរ។ ភាពខ្លោចផ្សារបស់អ្នកស្រី ជុំ នៅ ដែលគាត់មិនអាចបំភ្លេចបាន គឺការតស៊ូមួយជីវិតរបស់គាត់បានត្រលប់មកវិញត្រឹមភាពសោកសៅ និងមិនត្រឹមតែបាត់បង់ជីវិតប្ដីរបស់គាត់ កូនសម្លាញ់របស់គាត់ គឺត្រឡប់ទៅដល់ភូមិកំណើតវិញ ឪពុកម្ដាយ បងប្អូនបង្កើត ត្រូវបានពួកខ្មែរក្រហមសម្លាប់អស់ទៅទៀត។

[១៥:២៨:៣០]

មិនតែប៉ុណ្ណោះទៀត កេរ្តិ៍ឈ្មោះរបស់គាត់ត្រូវបានអ្នកភូមិបានត្មះតិះដៀលមុននឹងជួយឧបត្ថម្ភ ឬផ្ដល់កម្លាំងចិត្តដល់គាត់ថា "ពួកនាងឯង ពួកអស់ឯងនេះឯង ដែលធ្វើឱ្យពួកយើងទទួលរងទុក្ខវេទនា គឺពួកអ្នកឯងគាំទ្រពួកខ្មែរក្រហម"។ នេះជាសម្ដីមើលងាយមើលថោក ឬបង្អាប់កិត្តិយសគាត់នៅក្នុងភូមិរបស់គាត់។

ដូច្នេះ ប្រវត្តិនៃការជួរចត់របស់អ្នកស្រី ជុំ នៅ ក្នុងមន្ទីរស-២៤ ឬសព្វថ្ងៃនេះយើងហៅថា តំបន់ព្រៃស គឺជាផ្នែកមួយនៃមន្ទីរស-២១ ផងដែរ។ អ្នកស្រី ជុំ នៅ ត្រូវបានអង្គការរបបខ្មែរក្រហមចាប់ខ្លួនស្វាមីរបស់គាត់យកទៅដាក់នៅមន្ទីរស-២១ នៅក្នុងចុងឆ្នាំ១៩៧៦ ដែលចោទប្រកាន់ថាខ្មាំង ហើយដែលមុននឹងចាប់នោះ ទាំងគាត់ ទាំងគាត់ គឺជាមនុស្សម្នាក់ដែលស្មោះត្រង់នឹងអង្គការបដិវត្តន៍របស់របបកម្ពុជាប្រជាធិបតេយ្យនោះ។ នៅឆ្នាំ១៩៧៧ បន្ទាប់ពេលដែល គឺជាបន្ទាប់ពីការចាប់ស្វាមីរបស់គាត់នៅចុងឆ្នាំ១៩៧៦នោះ ដូច្នេះនៅដើមឆ្នាំ១៩៧៧ រាប់ទើបបានរយៈប្រាំខែ គឺគាត់មានទម្ងន់ មានន័យថា គាត់

មានផ្ទៃពោះប្រាំខែ ហើយគាត់បានចាកចេញ ឬក៏បែកពីស្វាមីរបស់គាត់តាំងពីពេលនោះ ទៅរងទុក្ខនៅឯងមន្ទីរស-២៤។ ហើយដែលកាលពីការធ្វើសក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ ថ្ងៃទី២០ និងថ្ងៃ២៤ ខែសីហា ២០០៩ អ្នកស្រីបានរៀបរាប់ជូនអង្គសវនាការថា គាត់បានឃើញជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច នេះ គាត់មិនបាននិយាយថា គាត់ជិតស្និទ្ធ ឬគាត់បានស្គាល់ បានជួបជាមួយទេ គឺអំឡុងពេលដែលគាត់ទទួលរងការដាក់ពិន័យ ដែលជាជនសមាសភាព ដូចជនជាប់ចោទធ្លាប់បានលើកឡើងនៅក្នុងមន្ទីរស-២៤ នេះ។ គាត់កំពុងធ្វើការនៅក្នុងវាលស្រែ ដកស្ទូងស្រែ គឺគាត់បានឃើញ ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច នេះ ដើរលើទំនប់ ហើយការស្គាល់របស់គាត់នេះ គឺត្រូវបានជនជាប់ចោទបដិសេធដែរ។

ក្រោយមកទៀត គាត់មិនចាំថាមានរយៈពេលប៉ុន្មានទេ តែនៅពេលដែលគាត់កំពុងធ្វើការនៅក្នុងនាមជាអ្នកទោសនោះនៅក្នុងមន្ទីរស-២១នោះ ភាពវេទនាលំបាករបស់គាត់ គឺការចាញ់កូននេះឯង។ ស្ត្រីនៅក្នុងលោកនេះ ដែលកំពុងមានផ្ទៃពោះប្រាំប្រាំមួយខែ ទៅរស់នៅជាអ្នកទោស ដែលគាត់ទទួលបន្ទុកផ្តល់ជីវភាពទៅដល់កូននៅក្នុងផ្ទៃផង ចិញ្ចឹមខ្លួនគាត់ផង ហើយដែលគាត់ទទួលម្ហូបអាហារបន្តិចបន្តួច។ តើពិបាក ឬក៏វេទនាយ៉ាងណា? គាត់ឃ្លានប៉ុនណា?

[១៥:៣១:៥៤]

ភាពដែលគាត់បានថ្លែងនៅពេលសវនាការនោះគឺនៅពេលដែលគាត់សម្រាលកូន។ នៅក្នុងបន្ទប់ជាកន្លែងឃុំឃាំង ព្រោះពេលយប់គេដាក់នៅក្នុងបន្ទប់គេចាក់សោ ពេលថ្ងៃគេឲ្យទៅធ្វើការ។ គាត់បានសម្រាលកូនទាំងគ្មានឆ្មប ទាំងគ្មានថ្នាំសង្កូវ មានអ្នកជាប់ឃុំដូចគ្នាបានជួយ ដោយមិនមែនជាអ្នកជំនាញខាងបង្កើតកូន។ អ្វីដែលជាភាពសោកសៅបំផុត គឺកើតកូនមកហើយ គ្មានក្រណាត់កន្ទបរុំ ឬជូតដួសលាង គ្មានទឹកក្តៅ។ មានសំពត់ ហែកមួយសម្រាប់ធ្វើកន្ទប ឱបរុំកូនខ្ចី។ សួរថានេះហើយឬដែលជាការឆ្លើយថាមិនដឹង ឬមិនបានយល់ ឬមិនចេះច្បាប់ទម្លាប់ ដែលលោក ឌុច ឬ កាំង ហ្កេកអ៊ាវ ហៅ ឌុច បានឆ្លើយដូចលោកមេធាវី គង់ ពិសី បានលើកឡើងថា គាត់មិនយល់អំពីច្បាប់ ឬមិនបានរៀនច្បាប់ព្រហ្មទណ្ឌ។

នេះគឺជាការបង្ហាញភាពឈឺចាប់ខ្លះៗ ដែលអ្នកស្រី ជុំ នៅ បានជួបប្រទះ។ អ្នកស្រីខំធ្វើការងារដើម្បីឲ្យជីវិតរស់ នៅពេលដែលសម្រាលកូនហើយមិនបានចិញ្ចឹម មិនបានបីបាច់ថែរក្សាកូន ត្រូវបានខ្មែរក្រហម ឬក៏ពួកកម្មាភិបាល ឬក៏ក្រោមបង្គាប់របស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច នៅមន្ទីរស-២៤

បង្ខំឲ្យគាត់ទៅធ្វើការទៀត ដោយទុកកូនចោល។ មួយរយៈដែលគាត់មិនបានថែទាំផ្ទាល់ដៃចំពោះកូនខ្ចីរបស់គាត់ គ្មានទឹកដោះឲ្យកូនបៅទៀត រហូតកូនរបស់គាត់បានឈឺ ហើយបើពិនិត្យមើលទៅតាមចម្លើយរបស់គាត់ គឺឈឺដោយជំងឺបាក់ទឹកដោះ។ ហើយតើកុមារយ៉ាងតូចល្អិត ដែលខំបើកភ្នែកឡើងមើលពិភពលោកស្ថិតនៅក្នុងអំឡុងពេលខ្មៅចផ្សា ពេលទារុណកម្មបំផុតទូទាំងប្រទេសនេះ និងអ្នកដទៃទៀត ឈឺចាប់ប៉ុនណានោះ គឺមិនមានអ្នកដឹងក្រៅអំពីសាមីខ្លួនទេ។

នៅចុងឆ្នាំ១៩៧៨ កូនតូច កូនង៉ាររបស់គាត់បានទទួលមរណភាព ហើយនៅពេលនោះដែលពេលពួកអង្គការ ឬក៏ពួកក្រោមបង្គាប់ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានអនុញ្ញាតឲ្យអ្នកស្រី ជុំ នៅ ទៅមើល កូនចុងក្រោយ។ គាត់មិនទាន់ដង្ហើម ទៅដល់កូនគាត់លែងដឹងខ្លួនហើយ រហូតដល់ស្លាប់ ហើយត្រូវបានពួកអ្នកដែលមាននិន្នាការពួកសមាសភាពនឹកឃើញថា គាត់ត្រូវបានអង្គការយកទៅទៀតហើយ។ ប៉ុន្តែជាសំណាងល្អរបស់គាត់ណាស់ ដែលគាត់បានត្រឡប់មកវិញ ហើយត្រូវបានរស់រានមានជីវិតរហូតសព្វថ្ងៃ ហើយម្យ៉ាងទៀតគាត់បានថ្លែងជូនអង្គសវនាការកាលពីនៅពេលថ្ងៃ២០, ២៤ ថា គាត់ត្រូវបានក្រុមយោធាក្រោមបង្គាប់ កាំង ហ្គេកអ៊ាវ នេះបង្ខំឲ្យរត់លូនជាមួយនឹងពួកយោធាចូលទៅក្នុងព្រៃភ្នំអស់រយៈរាប់ខែទៅទៀត។ ថ្ងៃមួយនោះ គាត់បានថ្លែងប្រាប់ថា គាត់ព្យាយាមរត់គេច ប៉ុន្តែត្រូវបានពួកកម្មាភិបាលឈ្មោះត្រង់ជាមួយ កាំង ហ្គេកអ៊ាវ ហៅ ឌុច នេះ ចាប់គាត់ទៅប្រគល់ឲ្យ កាំង ហ្គេកអ៊ាវ ហៅ ឌុច នៅជួរភ្នំ នៅជួរព្រៃភ្នំ ហើយត្រូវឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ជនជាប់ចោទនេះដកកាំភ្លើងខ្លីភ្ជង់ក្បាលគាត់ទៅទៀត។ ប៉ុន្តែត្រង់ចំណុចនេះត្រូវបាន កាំង ហ្គេកអ៊ាវ ហៅ ឌុច បដិសេធចោលទៅហើយ។

[១៥:៣៥:៣៥]

ខ្ញុំបាទសូមជម្រាបថា នៅពេលដែលគាត់ត្រឡប់មកស្រុកទេស គឺគាត់បានបាត់បង់ទាំងអស់អម្បាញ់មិញ។ បន្តិចទៀត ខ្ញុំបាទ សូមជ្រាបខ្លីៗបានហើយ ដោយសារបន្ទាប់ពីខ្ញុំទៅ គឺលោក ព្យែរ អូលីវៀរ ស្នួរ គាត់និងធ្វើការថ្លែងបន្តទៀត។

ខ្ញុំបាទសូមជម្រាបខ្លីៗ ទាក់ទងជាមួយនឹងលោក តូច មុនិន្ទ។ លោក តូច មុនិន្ទ គឺជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានបងបង្កើត អ៎! សូមទោសបងជីដូនមួយគាត់ឈ្មោះ ជា ខន ហៅ ជិន ដែលនៅក្នុងពេលសវនាការលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច នេះបានទទួលស្គាល់យ៉ាងច្បាស់ដោយមិនសង្ស័យអ្វីបន្តិចណាទេ ហើយដែលជាមិត្តជិតស្និទ្ធរបស់ជនជាប់ចោទនេះទៀត ដែលត្រូវបានស្លាប់នៅកណ្តាប់

ដែរបស់ការគ្រប់គ្រងរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច នេះដែរ។

អ្នកស្រី កាន់ សុន្ទរ៉ា មានបងប្រុសឈ្មោះ ជឹម ឡាង ក៏បានស្លាប់នៅមន្ទីរស-២១ នេះដែរ ទាំងបងរបស់គាត់ ជឹម ឡាង និងប្រពន្ធរបស់គាត់ យិន តូនី កូនបង្កើត និងក្មួយៗរបស់គាត់ពីរនាក់ទៅទៀត។

អ្នកស្រី រស់ ជួស៊ីអ៊ី គឺជាជនរងគ្រោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដដែល ហើយដែលគាត់--។ ខ្ញុំបាទនឹងជូនការថ្លែងអំពីអ្នកស្រី ជួស៊ីអ៊ី ទៅលោកលោក ព្យែរ អូលីវីយេ សួរ ទៅតាមក្រោយ ហើយខ្ញុំបាទនិយាយតែអំពីអ្នកដែលរស់នៅក្នុងប្រទេសកម្ពុជា ដោយអ្នកស្រី ជួស៊ីអ៊ី គាត់រស់នៅប្រទេសបារាំង។

ហើយខ្ញុំបាទក៏សូមបន្តទៅឈ្មោះ រស់ សាម៉េន ឈ្មោះ គង់ ទេស និងឈ្មោះ ជ្រាំង សំអ៊ាន។ ខ្ញុំបាទសូមនិយាយសរុប ដោយសារលោកទាំងបីនេះ គឺជាញាតិសន្តានផ្ទាល់របស់ជនរងគ្រោះដែលបានបាត់បង់ជីវិតនៅក្នុងទួលស្លែង មន្ទីរ ស-២១ ដែលមានឈ្មោះ ជ្រាំង សំអ៊ុន ជាប្អូនរបស់ ជ្រាំង សំអ៊ាន ហើយ រស់ ម៉េន មានស្វាមីរបស់គាត់ និងបងប្អូនរបស់គាត់ឈ្មោះ រស់ ធឹម ស្វាមីឈ្មោះ សេក ឆៀក, គង់ ទេស ស្វាមីឈ្មោះ សេក ឆៀក ក៏បានរកឃើញថាបានត្រូវសម្លាប់នៅមន្ទីរស-២១ ឬទួលស្លែងនេះផងដែរ។

[១៥:៣៨:០៣]

ក្នុងនោះដែរ ខ្ញុំបាទសូមជម្រាបចុងក្រោយថា ឈ្មោះអ្នកដប់នេះ គឺខ្ញុំបាទសូមជម្រាបលោកប្រធានថា គាត់ចូលខ្លួនមកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅពេលនេះ គឺសូមឲ្យលោកប្រធាន និងលោក លោកស្រីចៅក្រមពិចារណាអំពីភាពឈឺចាប់របស់គាត់ទាំងអស់ ដែលក្រុមញាតិក្រុមគ្រួសាររបស់គាត់បានទទួលមរណភាពនៅក្នុងមន្ទីរស-២១ ឬទួលស្លែងនេះយ៉ាងវេទនាបំផុត ហើយដែល កាំង ហ្គេកអ៊ាវ ហៅ ឌុច តែងតែបដិសេធនូវអ្វីដែលកូនក្តី ឬក៏ជនរងគ្រោះជាដើមបណ្តឹងបានលើកឡើងប៉ះពាល់ទៅដល់គាត់។ អ៊ីចឹង អ្វីដែលខ្ញុំបាទចង់និយាយនោះ គឺថាមាននៅក្នុងសារណារួមគ្នារបស់មេធាវីទាំងក្រុមដែលបានលើកឡើងជាបន្តបន្ទាប់មកហើយ ប៉ុន្តែខ្ញុំបាទសូមបន្ថែមតែពីរចំណុចទេ គឺថាទាក់ទងជាមួយនឹងការទាមទារសំណងនេះ គឺសូមឲ្យអង្គសវនាការមេត្តាយកចិត្តទុកដាក់ថា ជនរងគ្រោះសព្វថ្ងៃនេះមិនសង្ឃឹមថា នឹងបានសំណងផ្ទាល់អំពីជនជាប់ចោទរូបនេះទេ ដោយសារជនជាប់ចោទរូបនេះ គឺតុលាការបានទទួលស្គាល់ថា ជាជនក្រីក្ររួចទៅហើយ។ ដូច្នេះ ខ្ញុំបាទសូមឲ្យថា យ៉ាងណាក៏ដោយ គឺ

ជនរងគ្រោះជាដើមបណ្តឹងសូមឲ្យមានការធ្វើឡើងវិញ ឬបង្កាប់នៅក្នុងសាលក្រមឲ្យមានជាផ្លាក ឬផ្ទាំងឆ្លាក់ឈ្មោះជនរងគ្រោះជាដើមបណ្តឹងទាំងអស់នៅមន្ទីរទួលស្លែងសព្វថ្ងៃនេះ ទុកជាអនុស្សាវរីយ៍ដែលនៅក្នុងសំណុំរឿង០០១ មានតែជាកៅសិបនាក់ទេ និងធ្វើនៅបឹងជើងឯក ឬកន្លែងវាលពិឃាដ ព្រមទាំងនៅព្រៃស ឲ្យមានជាកន្លែងទីរំឭកនៅពេលអនាគត និងសម្រាប់អ្នកចុងក្រោយតទៅទៀត។ ហើយទីពីរទៅទៀតសូមឲ្យមានបង្កើត ឬក៏ការកាត់យកប្រាក់ចំណូលនៃការចូលទស្សនានៅមន្ទីរ ទួលស្លែងឬនៅជើងឯក ដើម្បីយកមកដាក់ចូលនៅក្នុងមូលនិធិរបស់សមាគមជនរងគ្រោះសម្រាប់ធ្វើការសាងសង់ឬអភិវឌ្ឍន៍ផ្សេងពីរទៀតទាក់ទងជាមួយនឹងមន្ទីរឧក្រិដ្ឋកម្មនេះ។ ដូច្នេះ បន្តទៅទៀត ខ្ញុំបាទសូមអញ្ជើញលោក ព្យែរ អូលីវីយេ សួរ បន្តពីខ្ញុំបាទលម្អិតបន្តតទៅទៀត។ សូមអរគុណ។

**លោក ព្យែរ អូលីវីយេ សួរ៖**

លោកប្រធាន លោក លោកស្រី ចៅក្រម ជាទីគោរព, ខ្ញុំដឹងអំពីកិត្តិយសនៅទីនេះ ហើយខ្ញុំនៅទីនេះដើម្បីចូលរួមនៅក្នុងការដាក់សារណាបញ្ចប់ក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះនៅ ស-២១។

ដូចដែលសហសេវិក សហមេធាវីជាតិ និងអន្តរជាតិនីមួយៗបានសម្តែង និងថ្លែងជូនសវនាការរួចមកហើយ ហើយគាត់បានលើកឡើងអំពីអង្គហេតុ និងអង្គច្បាប់រួមជាមួយគ្នា រួមទាំងប្រវត្តិសាស្ត្រនៃតុលាការនេះផងដែរ។ ខ្ញុំនឹងកម្រិតនូវសេចក្តីសន្និដ្ឋានរបស់ខ្ញុំត្រឹមតែចំណុចសង្ខេប និងលាតត្រដាងខ្លីៗតែប៉ុណ្ណោះ។ ថាតើយើងយល់យ៉ាងម៉េចនាពេលនេះ? ទាក់ទងទៅនឹងម្ចាស់បណ្តឹងដែលជាដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមគ្រួសារទាំងឡាយដែលមានជនរងគ្រោះស្លាប់នៅមន្ទីរស-២១។

ការចាប់អារម្មណ៍ជាបឋមរបស់ខ្ញុំ អស់លោក លោកស្រី ចៅក្រមជាទីគោរព គឺខ្ញុំទាក់ទងទៅនឹង បរានុម័ត ខ្ញុំសូមលើកឡើងអំពី បរានុម័ត។ យើងបានកត់សម្គាល់ឃើញថា ប្រសិនបើឌុច គាត់មកទីនេះដោយមិនមានភាពលំបាកលំបិនទេនោះ ជនរងគ្រោះគាត់មានភាពពិបាក និងភាពលំបាកលំបិនទាំងឡាយដែលយើងដឹង។ ជាពិសេសទាក់ទងទៅនឹងការសុំឲ្យទទួលស្គាល់ពួកគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី។ ដោយសារតែនៅក្នុងការវិភាគចុងក្រោយ គឺមានប្រហែលជិតពីររយនាក់ ដែលពួកគេគឺនៅមាននៅមិនទាន់បានទទួលស្គាល់។ ដូច្នេះ បរានុម័តនេះគឺវាទាក់ទងទៅនឹងការបន្ថយទ្រឹស្តីនេះ។ ឌុចគឺអ្នកដែលត្រូវធ្វើការទទួលស្គាល់ និងបញ្ជាក់នៅលើចំណុចនេះ។

ជនរងគ្រោះជាយូរមកហើយ គឺមានការភ្ញាក់ផ្អើលនឹងនីតិវិធីនៅទីនេះផងដែរ។ វាមានផ្លូវមួយ

វែងដើម្បីឲ្យជនរងគ្រោះធ្វើដំណើរ ហើយវាជាផ្លូវមួយដ៏ពិបាកសម្រាប់ពួកគាត់។ វាមានរយៈពេលសាមសិបឆ្នាំ រួចមកហើយ ក្រោយពីរយៈពេលសាមសិបឆ្នាំ នៅតាមភូមិដែលពួកគេរស់នៅ នៅតាមវាលស្រែដែលពួកគេធ្វើការងារ ពួកគេស្វែងរកវិធី ដើម្បីធ្វើយ៉ាងណារស់នៅជាមួយអ្នកដទៃ ថាតើអ្នកដទៃនោះជានរណាទៅ?

[១៥:៤៤:០៥]

នៅក្នុងគ្រួសារមួយ អ្នកដទៃនោះគឺជាអតីតខ្មែរក្រហមមួយរូប។ ហើយក្រៅពីនេះ ពួកគេនៅក្នុងចំណោមកូនក្តីរបស់ខ្ញុំ ដែលពួកគេធ្លាប់ជាជនរងគ្រោះផងដែរ។ ហើយពួកគេក៏ធ្លាប់ជាទាហានរបស់ខ្មែរក្រហមផងដែរ។

លោកប្រធាន លោក លោកស្រី ចៅក្រមជាទីគោរព, យើងឃើញមានបញ្ហាកើតឡើងនៅទីនេះដែលវាអាចធ្វើឲ្យបញ្ហាដែលយើងពិចារណានៅទីនេះមានភាពពិបាក។ សហសេវិករបស់ខ្ញុំដែលជាមេធាវីជាតិនិងអន្តរជាតិបានលើកឡើងរួចមកហើយ។ ហើយខ្ញុំសូមលើកឡើងសាជាថ្មី គឺវាមានករណីនៃសាសនាព្រះពុទ្ធដែលភ្ជាប់មកជាមួយនៅក្នុងចំណុចនេះ។ សាសនានេះ គឺវាទាក់ទងទៅនឹងសញ្ញាណនៃកម្ម បាននន័យថា ការជឿទៅលើការចាប់កំណើតសាជាថ្មី និងគោលគំនិតក្នុងការបំភ្លេចរឿងចោល។

នាពេលបច្ចុប្បន្ននេះ ប្រទេសមួយនេះដែលមានការដឹកនាំដោយអតីតខ្មែរក្រហមផងដែរនោះមានភាពលំបាកលំបិននៅក្នុងការគ្រប់គ្រង ហើយយើងត្រូវយល់ទៅលើចំណុចទាំងអស់នេះ។ វាពិបាកក្នុងការធ្វើឲ្យសង្គមនេះ វាភ្ជាប់គ្នាឡើងវិញ ហើយនិងពិចារណាទៅពេលអនាគត ហើយត្រូវរក្សាការចងចាំទាំងឡាយឲ្យវាឋិតថេរ។

ដូច្នេះ យើងឃើញថាវាមានរយៈពេលជាច្រើនខែតែប៉ុណ្ណោះដែលការអប់រំត្រូវបានយកប្រវត្តិ-សាស្ត្រខ្មែរក្រហមមកបញ្ចូល។ នៅក្នុងការប៉ះទង្គិចផ្នែកវប្បធម៌នេះ យើងឃើញវាមានពាក់ព័ន្ធទៅនឹងការមកចូលរួមនៅក្នុងសវនាការនេះ មកសម្តែងនិងបញ្ចេញមតិជូន អស់លោក លោកស្រីចៅក្រម។ ហើយយើងមានវប្បធម៌មួយដែលវាប្រព័ន្ធនីតិវិធីដឹកនាំដោយចៅក្រម ហើយនីតិវិធី និងវិធានច្បាប់មានចែងនៅក្នុងច្បាប់ ដូច្នេះកិច្ចដំណើរការនីតិវិធីគឺត្រូវគោរពតាមច្បាប់។ ដូច្នេះ នៅទីនេះគឺជាសវនាការមួយដែលយើងបានយល់ស្របគ្នា ហើយមានសិទ្ធិនៅក្នុងការសម្តែងមតិ ហើយនិងអាចធ្វើការបញ្ចេញឬក៏បង្ហូរទឹកភ្នែករបស់ដើមបណ្តឹងរដ្ឋប្បវេណីបាននៅទីនេះ នៅចំពោះសាធារណជន។

[១៥:៤៧:១១]

ដើម្បីឱ្យភាពលំបាកលំបិននេះ ដូចដែលសហសេវិករបស់ខ្ញុំបានលើកឡើង ឬក៏ការលាងនូវអ្វីដែលវាមានការជាប់ពាក់ព័ន្ធទៅនឹងការឃឺចាប់របស់គេបានរំសាយទៅតាមទស្សនទាន ឬក៏សាសនាព្រះពុទ្ធ។

ឌុច គឺជាបុគ្គលម្នាក់ដែល ស៊ីរ៉ូនី បានលើកឡើងអំពីផ្នែកចិត្តសាស្ត្រ ហើយបានលើកឡើងអំពីអាការៈចំនួនពីររបស់ជនជាប់ចោទ។ អាការៈទីមួយ គឺជនរូបនេះ គឺគាត់ជ្រើសរើសយកច្បាប់នៃការធ្វើឱ្យបរាជ័យដែលវាទាក់ទងទៅនឹងវប្បធម៌នៃប្រទេសបារាំង នៅពេលដែលគាត់បានសិក្សា ហើយនិងអាការៈដែលគាត់ស្រលាញ់នឹងការងាររបស់គាត់ ដូចដែលអ្នកជំនាញគាត់បានលើកឡើង។

ជនរូបនេះ គឺមានការបម្រើការងារនៅក្នុងប្រព័ន្ធ ឬក្នុងរបបនោះ ហើយនៅថ្ងៃនេះ គឺជនជាប់ចោទរូបនេះ គឺគាត់អាចធ្វើការរំឭកឡើងវិញនូវការងារ ឬបទពិសោធន៍របស់គាត់ ដោយមិនចាំបាច់ទៅមើលកំណត់ត្រារបស់គាត់។ ហើយគាត់អាចលើកឡើងអំពីការស្លាប់នៃចចករបស់លោក អាល្ប្រែត ដឺវីញី ផងដែរ។

នៅពេលដែលខ្មែរក្រហមចាប់ផ្ដើមកាន់អំណាចនៅក្នុងប្រទេសនេះ គាត់បានជ្រើសរើសយកផ្លូវចូលបម្រើក្រុមខ្មែរក្រហម ហើយគាត់ចូលរួមបម្រើនោះ ដោយយើងអាចមើលឃើញតាមរយៈការបំពេញការងាររបស់គាត់យ៉ាងល្អ។ យើងសួរថា តើគាត់បំពេញការងារនោះត្រឹមកម្រិតណា? ត្រឹមរយៈពេលណា? ហើយយើងអាចពិចារណាទៅលើដំណើរការ ដំណាក់កាលទីបីនៅក្នុងជីវិតរបស់គាត់ក្រោយពីការដួលរលំនៃរបបខ្មែរក្រហមខ្លួនគាត់បានចូលរួម ឬក៏បានប្ដូរសាសនាជាសាសនាគ្រិស្ត។ ដូច្នេះ គឺគាត់បានប្ដូរខ្លួនឯង ក្លាយទៅជាជនដែលស្រលាញ់វប្បធម៌អឺរ៉ុប ដូចដែលបណ្ឌិត ស៊ីរ៉ូនី ដែលជាអ្នកជំនាញខាងផ្នែកចិត្តសាស្ត្របានលើកឡើង។ ទោះបីជាការប្ដូរសាសនារបស់គាត់មានភាពស្មោះត្រង់ក៏ដោយនោះ ការប្ដូរសាសនានោះ គឺគ្រាន់តែចង់បំពេញទៅតាមបំណងរបស់គាត់ ដែលចង់បានតែប៉ុណ្ណោះ។ គាត់ធ្វើការបំពេញបំណងរបស់គាត់សាជាថ្មី ដើម្បីដើរតាមច្បាប់ ដើម្បីរស់រានមានជីវិតនិងដើម្បីការបរាជ័យ។

[១៥:៥០:២៦]

ដូច្នេះ នៅទីនេះគាត់បានចូលរួម ឬបង្ហាញខ្លួននៅក្នុងសវនាការនេះ ហើយគាត់ត្រូវបំពេញបន្ថែមទៅលើចំណុចនេះ ហើយគាត់ជាកម្មវត្ថុនៃការជំនុំជម្រះ។ ហើយពេលខ្លះអង្គសវនាការបានកំណត់ទៅលើចំណុចល្អ និងចំណុចមិនល្អ ជាច្រើននៅក្នុងសវនាការយើង។ ហើយជបជាប់ចោទរូបនេះ គាត់បាន

ធ្វើការជំទាស់ទៅលើចំណុចមួយចំនួន ទៅលើសមាជិកជនរងគ្រោះ ឬក៏គ្រួសារដែលជាកូនក្តីរបស់ខ្ញុំ។

ចំណុចនេះ វាមិនពិបាកទេសម្រាប់រូបគាត់។ អាការៈ ឬក៏បុគ្គលិកលក្ខណៈរបស់គាត់ទីពីរ យោងតាមបណ្ឌិត ស៊ីរ៉ូនី ហ្កៀលបូ គឺជនរូបនេះមានកង្វះផ្នែកចិត្តសាស្រ្តទាក់ទងទៅនឹងការមិនចេះយល់អារម្មណ៍របស់គេ។ បុគ្គលរូបគាត់មានការពិបាកក្នុងការយល់នូវអារម្មណ៍របស់គេ ហើយនិងស្វែងយល់នូវអារម្មណ៍ទាំងអស់នោះ ហើយនិងពិបាកក្នុងការយល់ដឹងអំពីការឈឺចាប់របស់អ្នកដទៃ។ ដូច្នេះគឺគាត់អាចជាជនមួយរូបដែលទទួលជោគជ័យនៅក្នុងទីនេះ។

លោក លោកស្រី ចៅក្រមជាទីគោរព, ខ្ញុំសូមទាញការចាប់អារម្មណ៍ពីអង្គសវនាការទាក់ទងទៅនឹងការលំបាកលំបិនទាំងឡាយដែលកូនក្តីយើងខ្ញុំមាន។ ក្នុងចំណោមជនរងគ្រោះទាំងឡាយ យើងឃើញមានភាពពិបាកក្នុងផ្លូវអារម្មណ៍របស់ពួកគាត់។

ចំណុចទីពីរដែលខ្ញុំចង់លើកឡើង និងចូលរួមចំណែកបញ្ជាក់ជូនអង្គសវនាការនៅទីនេះ គឺទាក់ទងទៅនឹងរបៀប ឬក៏ទម្រង់នៃការឆ្លើយតបពីកូនក្តីរបស់ខ្ញុំចំពោះការសម្តែងវិប្បដិសារីរបស់ជនជាប់ចោទ។ ខ្ញុំបានលើកឡើងពីមុនហើយ គឺវាទាក់ទងទៅនឹងវប្បធម៌ប៉ះទង្គិចគ្នា ដែលវាទាក់ទងទៅនឹងចំណុចទាំងអស់នេះ។ ប៉ុន្តែ ប្រសិនបើយើងព្យាយាមបំពេញការងារ ហើយព្យាយាមគិតពិចារណាទៅលើចំណុចនេះ យើងអាចយល់ឃើញថា-- យើងអាចឆ្លើយតបទៅនឹងប្រតិកម្មរបស់ ឌុច ឬការសម្តែងឡើងវិញរបស់ក្នុងពីររបៀប៖

របៀបទីមួយ ជនរងគ្រោះបានទទួលស្គាល់នូវជំហរដែលពួកគេទទួលយកនៅទីនេះ ខ្ញុំជាមេធាវីតំណាងនូវស្រ្តីមួយរូបដែលគាត់ទទួលរងការឈឺចាប់រយៈពេលជាច្រើនឆ្នាំ ដោយអំពើសាហាវមួយដែលខ្ញុំលើកឡើងអំពី បាឌិនគួ *(Betancourt)* ដែលគាត់ជាជនអកុសលមួយរូប គាត់បានលើកឡើងថា “អ្នកធ្វើទារុណកម្មជាការពិត មិនដែលលើកឡើងអំពីការអត់ឱននោះទេ" ហើយស្រ្តីទាំងនោះ ឬក៏ស្រ្តីនីមួយៗនៅក្នុងរឿងក្តីនេះ គឺគាត់មិនទទួលបានសេរីភាពរបស់គាត់បានវិញនោះទេ។ នៅពេលដែលពួកគេអង្គុយជិះឧទ្ធម្ភាគចក្រ ហើយពួកគេមិនទទួលបាននូវការថែទាំសុខភាពរបស់ពួកគេ។ ពួកគេទទួលបានសេរីភាពរបស់ពួកគេក្រោយមកតែប៉ុណ្ណោះ។ នៅពេលដែលពួកគេចាប់ផ្តើមទទួលយកនូវការសូមទោស។ នេះជាអារម្មណ៍ដែលវាទាក់ទងទៅនឹងជនរងគ្រោះនីមួយៗ។

លោក លោកស្រីចៅក្រមជាទីគោរព, ដូច្នេះបញ្ហាទាំងអស់នេះវាទាក់ទងទៅលើជនរងគ្រោះ។ ដោយសារតែចំពោះករណីជនជាប់ចោទរូបនេះដែលវាឲ្យខ្ញុំនឹកឃើញអំពីការអត់អោនទៅលើជនរូបនេះ

គឺវាទាក់ទងទៅនឹងស្ថានភាពមួយ ប៉ុន្តែស្ថានភាពនោះ វាខុសពីនោះ។

ដូច្នេះ ការអត់ឱនអាចធ្វើទៅបាន ដរាបណាវាមានការសារភាពដោយស្មោះត្រង់ និងការសម្តែងការសារភាពឲ្យអស់ចេញពីដួងចិត្ត ប៉ុន្តែយើងមិនយល់ឃើញថាចម្លើយសារភាពរបស់ជនរូបនេះបានរៀបរាប់ពេញលេញ ហើយមានភាពស្មោះត្រង់នោះទេ។ យើងចាំហើយដែលលោក ការីម ខាន បានលើកឡើងអំពីរឿងរ៉ាវនៃការធ្វើទារុណកម្ម យកម្ជុលចាក់ក្រចក ហើយខ្ញុំក៏ចាំអំពីរឿងរ៉ាវ ដែលគេយកស៊ីម៉ង់ដ៍ប៉ាតមុខផងដែរ។ ព្រឹត្តិហេតុនិងហេតុការណ៍ទាំងអស់នេះ គឺវាទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលអ្នកទោសបរិភោគលាមកខ្លួនឯងផងដែរ តាមរយៈរឿងរ៉ាវទាំងឡាយដែលយើងទទួលបាន ខ្ញុំបានឮសហសេវិកមេធាវីជាតិនិងអន្តរជាតិ បានជម្រាបខ្ញុំទៅលើចំណុចទាំងអស់នេះ ហើយរាល់ពេលក្នុងពេលសវនាការយើងឮអំពីករណីអតីតគ្រូរបស់គាត់ ដែលគេបានលើកឡើងយកមកនិយាយដែលបង្ហាញថាជនជាប់ចោទរូបនេះមានភាពកំរោល។ សហសេវិករបស់ខ្ញុំ ហុង គឹមសួន បានលើកឡើងនៅចុងបញ្ចប់សេចក្តីសន្និដ្ឋានរបស់គាត់ ហើយខ្ញុំសូមលើកពីករណី សួស នៅ។ គឺទាក់ទងទៅនឹងករណីលោក ជុំ នៅ ហើយខ្ញុំដឹងថាវាមិនទាក់ទងទៅនឹងយុត្តាធិការនៃតុលាការនេះទេ ប៉ុន្តែយ៉ាងណាក៏ដោយ យើងត្រូវចងចាំអំពីការចងចាំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលថាគេបានយកកាំភ្លើងមកភ្ជង់ក្បាលគាត់ ហើយជនជាប់ចោទបដិសេធមិនទទួលស្គាល់អង្គហេតុនៃការភ្ជង់កាំភ្លើងលើក្បាលគាត់នេះ។ ហើយទាក់ទងទៅនឹងការសុំអភ័យទោសដែលគាត់បានលើកឡើង គឺមិនមែនជាការសុំអភ័យទោសដោយសុទ្ធចិត្តនោះទេ នៅពេលដែលគាត់មិនបានបញ្ជាក់ឲ្យច្បាស់ ពីព្រោះថាវាត្រូវមានកត្តាដោះដូរក្នុងករណីនោះដែរ ហើយនៅក្នុងការអះអាងមេធាវីការពារនោះ យើងបានបញ្ជាក់សួរទៅលោកទាក់ទងទៅនឹងខ្លឹមសារនៃការសុំអភ័យទោស ហើយដោយសារគាត់លើកឡើងដើម្បីចរចារអំពីស្ថានសម្រាលក្នុងការកាត់ទោសរបស់គាត់។

[១៥:៥៩:០២]

លោក លោកប្រធាន លោកស្រីចៅក្រមជាទីគោរព, មានចំណុចទីបីមួយទៀត គឺជាអារម្មណ៍ដែលបង្ហាញច្បាស់លាស់នៅក្នុងសវនាការរបស់អង្គជំនុំជម្រះ ពេលដែលយើងនិយាយជាមួយគ្នាក្នុងក្រុមមេធាវី ហើយទទ្បីករណ៍របស់ ឌុច បានបញ្ជាក់ប្រាប់យើងថា គាត់គឺធ្វើឡើងដោយស្របទៅតាមគ្រឿងម៉ាស៊ីនរបស់ខ្មែរក្រហម។ ប្រសិនបើជនណាម្នាក់ក្លាយទៅជាប្រធានស-២១នោះ អ្នកនោះនឹងធ្វើស្រដៀងគ្នា ឬដូចទៅនឹងលោក អៃស្មិន ដូចដែលលោកជននោះសារភាពនៅក្នុងសាលាក្តី ជេរ៉ូសាឡឹមនោះដែរ។ នៅក្នុងទទ្បីករណ៍របស់គាត់នេះ គឺមិនអាចទទួលយកបានទេ។ ជាបឋម យើងដឹងច្បាស់

ហើយថា គាត់បានចាកចេញពីមន្ទីរម-១៣ ដើម្បីមកកាន់តំណែងនៅស-២១ ដោយសារតែគាត់មានបទពិសោធន៍ក្នុងការធ្វើទារុណកម្ម ដោយសារនៅមន្ទីរម-១៣នោះ គាត់បានសម្ពិតសម្ពាង មានបទពិសោធន៍ គាត់បានចងក្រងនូវវិធីសាស្ត្រ។ អាស្រ័យដោយហេតុនោះហើយ គាត់ស្រឡាញ់ការងារដែលទទួលជោគជ័យនៅម-១៣ ហើយគាត់បានធ្វើការងារល្អនៅទីនោះ ហើយគាត់ចង់ធ្វើការងារឲ្យល្អជាងម-១៣នោះទេ។ នោះមានន័យថា ជាចំណុចមួយដែលអង្គការជ្រើសរើសគាត់ឲ្យធ្វើជាប្រធាននៃស-២១ ដែលគាត់បញ្ជាក់ដោយខ្លួនគាត់ដូច្នេះ។

បុគ្គលម្នាក់ដែលជាអ្នកចងក្រងទ្រឹស្តី ហើយជាអ្នកកែលម្អនូវរចនាសម្ព័ន្ធ ហើយក៏ជាអ្នកបញ្ជាទីកន្លែងមួយនោះ មន្ទីរសន្តិសុខមួយនោះ មិនមែនជាករណីសាមញ្ញធម្មតានោះទេ។ ជាពិសេសទៅទៀតយើងក៏បានដឹងច្បាស់ផងដែរ យើងបានស្តាប់មតិយោបល់របស់សាក្សី ហើយគាត់ក៏បានរក្សាទុកជីវិតពេទ្យធ្មេញ ជាងគំនូរ ហើយនឹងជាងមួយចំនួននៅស-២១ បានផងដែរ។

នៅក្នុងបទសម្ភាសន៍ជាមួយអ្នកថតរូប នៅពេលដែលអ្នកថតរូបនៅស-២១នោះ ចួនកាលគាត់ទៅផ្ទះរបស់ ឌុច ហើយយករូបថតរាប់ពាន់ ឬក៏ជាច្រើនថតឲ្យ ឌុច នោះផងដែរ គឺរាប់ពាន់ជារូបថតរបស់ ឌុច នៅក្នុងជីវិតឯកជនរបស់គាត់នៅកាលនោះ បុរសម្នាក់នេះ។ ហើយជាអ្នកដែលបានរស់បានដោយសារ ដូចជាអ្នកបានជួយគាត់នោះឯង។ លោកបណ្ឌិត ឆេនដ៏ល័រ បានផ្តល់សក្ខីកម្ម ហើយគាត់បានបញ្ជាក់ថា តាមពិត ឌុច មិនអាចត្រឹមតែសង្គ្រោះជីវិតអ្នកទាំងឡាយនៅស-២១ទេ ប៉ុន្តែគាត់អាចទប់ស្កាត់ការចាប់ខ្លួនបានដែរ ប្រសិនបើគាត់ចង់។ ប៉ុន្តែប្រសិនបើគាត់មានលទ្ធភាពសង្គ្រោះ ឬក៏រក្សាទុកអ្នកណាម្នាក់ គាត់ក៏មានលទ្ធភាពដើម្បីកម្ទេចអ្នកណាម្នាក់នោះដែរ ដោយសារថាការកម្ទេចនេះគាត់ធ្វើឡើងក្នុងន័យមួយដែលប្រាស់ចាកពីគំនិតដើមថាគាត់ជាគ្រូបង្រៀន។ ក្នុងឋានៈជាគ្រូបង្រៀនយើងទាំងអស់គ្នាចងចាំច្បាស់ហើយថា ជាគ្រូច្បាប់។ ឧទាហរណ៍យើងតែងតែចងចាំនូវទីបំផុត គឺអតីតមេរបស់គាត់ សុន សេន នោះឯង ត្រង់ចំណុចនេះហើយដែលគាត់មិនគប្បីថា ជាអ្នកតែងតែគោរពបញ្ជានោះទេ ប៉ុន្តែជាស្ថានភាពផ្ទុយទៅទេ គឺគាត់ជាអ្នកបង្កនូវអំពើភ័យខ្លាច គឺបង្កនូវភាពភ័យខ្លាចដល់ថ្នាក់លើរបស់គាត់ទៀតផង។

[១៦:០៣:៥៥]

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព, ឌុច នៅទីបំផុតគាត់បានព្យាយាមនិយាយជាមួយមេធាវីរបស់គាត់ ហើយក៏ប្រើនូវស្ថានភាពដើម្បីបំបាត់នូវលក្ខណៈមនុស្សធម៌ទៅដល់ដើមបណ្តឹង

រដ្ឋប្បវេណី ហើយកត្តាសំខាន់បំផុត អង្គជំនុំជម្រះបានចាត់ទុករូបគាត់ថា គាត់គឺជាជនម្នាក់នៅក្នុងការជំនុំជម្រះនេះ ដោយមានការគោរពទៅតាមគោលការណ៍ច្បាប់ ដោយមានមេធាវីការពារផងដែរ។ ហើយប្រសិនបើគាត់អាចនឹងមានមនុស្សធម៌មកវិញបាននោះ ថាតើធ្វើដូចម្ដេច? តើយើងអាចនាំគាត់ត្រឡប់ថយក្រោយវិញ អាចនឹងចូលទៅសហគមន៍នៃមនុស្សធម៌ មនុស្សជាតិវិញបានដែរឬទេ? បើដូច្នេះយើងត្រូវតែពិចារណាប្រសិនបើផ្នែកណាមួយនៃក្រុមសង្គមដែលជាសមាគមនៃសង្គម ដែលថាយើងទាំងអស់គ្នានៅក្នុងនោះដែរ ហើយដែលជាក្រុមដែលបង្កើតនៅសង្គមទាំងមូលនោះ។

ដូច្នេះគាត់ត្រូវតែទទួលនូវការវិនិច្ឆ័យមួយតាមតួនាទីរបស់គាត់ ជាតួនាទីនៃឧក្រិដ្ឋជន ជាឧក្រិដ្ឋជនប្រឆាំងមនុស្សជាតិ ប្រសិនបើ ឌុច ព្យាយាមពន្យល់យើងក្នុងពេលដំបូងដែលគាត់មកកាន់ក្រចកសេះនោះ ហើយគាត់និយាយថា ក្នុងខណៈពេលមួយគាត់មិនអាចដើរថយក្រោយវិញបានទេ ហើយគាត់អំពីកូនរបស់គាត់ ហើយគាត់មិនអាចធ្វើអ្វីបានទេ កាលណោះគាត់ជាមនុស្សកំសាកម្នាក់។ ខ្ញុំអនុញ្ញាតរំឭកឡើងវិញថា បុរសម្នាក់នេះក៏ជាមនុស្សម្នាក់នៅក្នុងដំណាក់កាលមួយ ដែលគាត់បានបង្កើតឲ្យកំណើតដល់កូន ហើយគាត់បានរៀបចំផ្លូវចិត្តសាស្ត្ររបស់គាត់ ដើម្បីឲ្យស្របទៅតាមហ្នឹង ក៏ប៉ុន្តែគាត់ក៏បានធ្វើផ្ទុយពីមាគ៌ា បំផ្លាញអ្នកដទៃ ប៉ុន្តែគាត់អភិវឌ្ឍខ្លួនឯង ក្រុមគ្រួសារខ្លួនឯងដែលផ្ទុយពីការប្រព្រឹត្តិរបស់គាត់ទៅលើអ្នកដទៃក្នុងកាលនោះ។

នៅក្នុងទីនេះ ដើម្បីសន្និដ្ឋាននូវអ្វីដែលខ្ញុំបញ្ជាក់ ខ្ញុំចង់បញ្ជាក់ពាក្យមួយចំនួនតូចចំពោះមនុស្សដែលខ្ញុំបានជួប ហើយខ្ញុំមិនដែលអាចបំភ្លេចបាន។ ខ្ញុំសូមជម្រាបអ្នកដែលថា លោក វស់ ម៉ែន ពីម្សិលមិញនោះ គឺស្ថិតនៅក្នុងស្ថានភាពមួយដែលងងឹតសុង គាត់មិនអាចធ្វើឲ្យយើងរស់រានមានជីវិតវិញបានទេ មិនអាចនាំជីវិតបងប្រុសរបស់គាត់មកវិញទេ ពីព្រោះគាត់បានបាត់បង់ជីវិតនៅស-២១នោះទៅហើយ មិនអាចធ្វើឲ្យអ្នកស្លាប់នោះរស់វិញបានទេ នៅក្នុងអារម្មណ៍ដែលគាត់ចងចាំនោះ គឺយើងមិនអាចឈានទៅដល់កម្រិតនេះបានទេ គឺអ្វីៗវាហាក់បីដូចជាត្រូវបានបិទទ្វារចាក់សោរួចទៅហើយ ហើយខ្ញុំអាចនឹងនិយាយអំពី-- ជាថ្មីម្តងទៀតនោះ គឺពេលដែលគាត់និយាយតែងតែស្រក់ភ្នែក ទឹកភ្នែកទាំងនេះបានធ្វើឲ្យខ្ញុំរន្ធត់ចិត្ត ដែលថានេះគឺជាអំពើមួយដែលបង្ហាញអំពីការប្រឈមមុខទៅនឹងអារម្មណ៍ដែលគេត្រូវតែទទួលស្គាល់នៅក្នុងការជំនុំជម្រះ ហើយកូនស្រីរបស់គាត់បានប្រាប់ខ្ញុំថា យើងមិនអាចស្រម៉ៃដល់ទេ អ្វីៗដែលកើតនៅក្នុងរបបខ្មែរក្រហមនោះ គឺកាលណានិយាយពីអ្វីយើងតែងតែស្រក់ទឹកភ្នែកពីរឿងនោះ។

គោលការណ៍ទីប្រាំមួយនៃវិន័យស-២១ ដែលគេបានសរសេរនោះ នៅពេលដែលគេវៃអ្នកឯង នៅពេលដែលទទួលការឆក់ខ្សែភ្លើងមិនត្រូវស្រែកបានទេ។ ដូច្នេះហើយ ខ្ញុំចង់ជម្រាបជូនលោក លោកស្រីចៅក្រមរបស់លោកស្រី ជុំ នៅ ដែលជាអ្នកបានទទួលការភ្ជង់អាវុធខ្លីទៅលើក្បាលរបស់គាត់ ហើយលោក កាន់ សុន្ទរ៉ា ហើយមេធាវីរបស់ខ្ញុំបានបង្ហាញជូននូវរូបថតមួយចំនួន។ ខ្ញុំសូមអនុញ្ញាតដើម្បីដោយសេចក្តីគោរពចំពោះគាត់ ដើម្បីរំឭកឡើងវិញអ្វីដែលបាននិយាយនៅក្នុងកំណត់ត្រាលាយលក្ខណ៍អក្សរទាក់ទងទៅនឹងបងប្រុសរបស់គាត់។ ដើម្បីធ្វើឱ្យគាត់អាចនឹងយល់បាន គាត់មានកម្ពស់មួយម៉ែត្រហុកសិបប្រាំ។ គាត់ជាមនុស្សសង្ហា ដូចជាបុរសកាត់ចិនដូច្នោះដែរ ហើយគាត់សម្បុរសណ្តែកបាយ។

ហើយខ្ញុំនឹងអានអ្វីដែលបានបញ្ជាក់នៅក្នុងខែសីហា នោះ អ្វីដែលលោក អ៊ូ សាវរិត បានវត្តមានកាលនោះ គាត់បានផ្តល់សក្ខីកម្មតាមរយៈវីដេអូពីចម្ងាយ ហើយគាត់បានអានលិខិតមួយ គឺជាលិខិតពីក្មួយស្រីរបស់គាត់ ដែលជាកូនស្រីរបស់បងគាត់ ដែលបានបាត់បង់ជីវិតនៅស-២១។ ក្មួយស្រីរបស់គាត់ជាក្មេងស្រីម្នាក់ដែលជាអ្នកទទួលជោគជ័យ ហើយនាងមានរូបស្អាត។ គាត់ទទួលសញ្ញាបត្រអំពីការសិក្សាដ៏លំបាកគឺជាគណនេយ្យកម្មួយរូប ហើយខ្ញុំនឹងជម្រាបជូនខ្លឹមសារ។ នេះជាសំបុត្រទាំងប្រាំដែលបានសរសេរ ដែលនិយាយអំពីអវត្តមានរបស់ឪពុករបស់គាត់ ធ្វើឱ្យគាត់មានការលំបាកជីវិត ហើយជីវិតរបស់គាត់មានការឈឺចាប់ ហើយខ្ញុំសូមឱ្យគាត់មកនៅជាមួយខ្ញុំ ការពារខ្ញុំនៅពេលដែលខ្ញុំត្រូវការសេចក្តីត្រូវការ ខ្ញុំបានទទួលអ្វីៗជាសេចក្តីស្រឡាញ់ ហើយនិងមោទនភាពរបស់គាត់ជាឪពុក ហើយខ្ញុំនៅពេលដែលខ្ញុំជាប់បាក់ឌុប ឬក៏ប្រលងជាប់នោះ ហើយនៅពេលទទួលការងារជាដំបូង។

[១៦:១២:៤២]

ខ្ញុំនឹងអរគុណគាត់ក្នុងឋានៈជាស្ត្រីដែលគាត់បានធ្វើជាម្តាយ ហើយគាត់បានរក្សាទុកការចងចាំនឹងដប់ឆ្នាំ ហើយមិនទាន់មានកូនទៀតនោះទេ។ ហើយគាត់ក៏នៅរង់ចាំថានឹងបានបង្កើតជាក្រុមគ្រួសារដែលនឹងកំណត់នោះ។ ហើយសូមអរគុណចំពោះអង្គជំនុំជម្រះ ការលាតត្រដាងនូវអ្វីៗ ពីមធ្យោបាយអ្វីដែលយើងអាចមើលឃើញ សម្លឹងឃើញទៅអនាគត ហើយអាចបន្តរស់ ហើយបំភ្លេចពីអតីតកាលមួយចំនួន ហើយផ្សារភ្ជាប់អតីតភាពរបស់ឪពុករបស់គាត់ដែលមិនចាំមុខ ហើយគាត់នោះបានស្លាប់នៅក្នុងស-២១ បន្ទាប់ពីបានទទួលរងនូវអំពើឃោរឃៅ ការបង្ខំឱ្យឆ្លើយសារភាពដោយទារុណកម្ម ដោយសារអំពើទាំងនេះ ហើយគាត់ត្រូវបានទទួលរងនូវអំពើញុះញង់ដោយរបបខ្មែរក្រហម ហើយគាត់បានទទួលសញ្ញាបត្រសាលារដ្ឋបាលមួយនៅបារាំង ហើយគេបង្ខំឱ្យគាត់ឆ្លើយសារភាពឆ្លើយដាក់មិត្តភក្តិផ្សេងៗ

ទៀតដើម្បីឲ្យមានការចាប់ខ្លួនជាច្រើន ហើយទទួលទារុណកម្ម ហើយទីបំផុតត្រូវគេសម្លាប់។

លោកប្រធានជាទីគោរព, លោក លោកស្រីចៅក្រម ឥឡូវនេះ ខ្ញុំនឹងនិយាយលឿនបន្តិចអំពីរឿងក្តីមួយ ដើម្បីរំឭកអង្គជំនុំជម្រះ។ លោក វស់ ម៉េន គឺជាមិត្តរបស់ ឌុច ក៏បានត្រឡត់មកកម្ពុជានៅពេលដែលគាត់នៅប្រទេសចិន ដើម្បីមកបម្រើការងាររដ្ឋក្នុងរបបនោះ។ នៅពេលដែល ឌុច *ខល(called)* គាត់មកក្នុងកាលនោះ គេបានបញ្ជូនគាត់មកស-២១ ហើយបានជួបប្រទះដូចលោក ចៅ សេង ដែលជាអតីត ជាប្រធានអាកាសយាននៅប្រទេស ហើយគាត់បានត្រឡប់ប្រទេសដើម្បីបម្រើជាតិ។ ពេលដែលគាត់ត្រឡប់មកវិញនោះ ក្រោយពីខ្មែរក្រហមទទួលអំណាចឆ្នាំ១៩៧៥ គេបានបញ្ជូនអ្នកនោះមក ស-២១។

[១៦:១៦:៥១]

ឥឡូវនេះ ខ្ញុំបានបញ្ចប់ ខ្ញុំសូមជម្រាបអង្គជំនុំជម្រះថា មនុស្សក្នុងជំនាន់ខ្ញុំនេះកើតម្ភៃឆ្នាំក្រោយពីសង្គ្រាមស៊ីវិល បានស្តាប់ជីដូនជីតានិយាយម្តងហើយម្តងទៀត គឺថាជំរំមរណៈត្រូវបានបញ្ចប់ហើយ ហើយមិនអាចនឹងកើតឡើងទៀតទេនៅក្នុងអនាគតនោះ។ ជំរំមរណៈ រណ្តៅសពរួម នៅតែមានជាបន្តមក។ មធ្យោបាយតែមួយគត់ ហើយជនជំនាន់ខ្ញុំជឿបាននោះ គឺជាមធ្យោបាយតែមួយដើម្បីជម្នះលើបញ្ហានេះបាន គឺដើម្បីផ្តល់សេចក្តីទុកចិត្តដល់យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិដែលយើងបានរៀបចំទីនេះ ដែលជាបេសកកម្មមួយដ៏ឧត្តុងឧត្តម ដែលអាចនិយាយបានថាគឺជាការវិនិច្ឆ័យទៅលើបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដែលមិនត្រូវស្ថិតនៅគ្មានការជំនុំជម្រះ និងទណ្ឌកម្មនោះទេ។

**ប្រធានអង្គជំនុំ៖**

បាទឥឡូវនេះ សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន បានធ្វើសេចក្តីថ្លែងនៅចំពោះមុខអង្គជម្រះបានចប់តាមពេលវេលាដែលបានកំណត់ជូនគាត់។ ហើយឥឡូវនេះម៉ោងបួន ដប់ប្រាំពីរនាទីហើយ ដូច្នេះគឺត្រូវដល់ពេលត្រូវឈប់សម្រាកនៅពេលល្ងាចនេះហើយ។ អង្គជំនុំជម្រះសាលាដំបូងប្រកាសផ្អាកដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តនៅថ្ងៃស្អែក ថ្ងៃអង្គារ ទីម្ភៃបួន ខែវិច្ឆិកា ឆ្នាំពីរពាន់ប្រាំបួន ចាប់ពីម៉ោងប្រាំបួនព្រឹកទៅ។

ហើយអង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគី និងសាធារណជនបានជ្រាបផងដែរថា នៅថ្ងៃស្អែកនេះពេញមួយថ្ងៃ អង្គជំនុំជម្រះនឹងប្រគល់វេទិកាទៅសហព្រះរាជអាជ្ញាដើម្បីមានឱកាសឡើងធ្វើ

សេចក្ដីថ្លែងការណ៍នូវសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។ ហេតុដូច្នេះ សូមភាគី និងសាធារណជនជ្រាប និងសូមអញ្ជើញចូលរួមឲ្យបានមុខម៉ោងបានកំណត់។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយនិងឲ្យនាំគាត់មកកាន់សាលសវនាការនេះនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនជាកំហិត៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង១៦:១៩នាទី)*

ចម្លង